ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក
# ការពិត



- គម្លៃនៃបណ្ណសារ
- ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្នុងសម័យខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨៧ ខែមីនា ឆ្នាំ២០០៧

ស្វែងរកការពិត

លេខ៨៧ ខែមីនា ឆ្នាំ២០០៧

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ តម្លៃនៃបណ្ណសារ ........................................................១

**ផ្នែកឯកសារ**

◆ ចាកចេញពីស្រុកកំណើតដើម្បីបំភ្លេចអតីតកាល ...................................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ..........................................................................៨

◆ ជីវិតជាកងទ័ពទទួលបានអ្វីខ្លះ? ..................................................១៣

◆ និរសារតំបន់២៥ ......................................................................១៥

◆ នៅកៀនជញ្ជាំងស-២១ ៖ រឿងរ៉ាវពីគុកទួលស្លែង .........................១៨

◆ ការបាត់ខ្លួនរបស់កងពិសេសតំបន់១០៦ ......................................១៩

◆ ទោជាផេះផង់ធូលី ...................................................................២១

◆ ក្រោយមរណភាពរបស់ឪពុកទើបដឹងការពិត ..................................២៣

◆ ក្រុមយុវជនចាមមូស្លីមនិងយុវនិស្សិតច្បាប់ ...................................២៦

◆ តើគួរសាងសង់ស្តូបតម្កល់អដ្ឋិធាតុនៅជើងភ្នំវល្លិ៍ដែរទេ? ..............៣៣

**ផ្នែកច្បាប់**

◆ យន្តការសាលាក្តីខ្មែរក្រហម ........................................................៣៦

◆ វិធានការចាំបាច់បន្ទាន់ទៅលើវិធានផ្ទៃ...........................................៣៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្នុងសម័យខ្មែរក្រហម ...................៤៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្រវត្តិដ៏កម្សត់របស់ខ្ញុំ .............................................................៥៥



ការរៀបចំឯកសារដាក់តាមប្រភេទក្នុងប្រទេសហ្គាតេម៉ាឡា



លលាដ៍ក្បាលបុរសម្នាក់គាស់ចេញពីដីក្នុងប្រទេសហ្គាតេម៉ាឡា

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរខក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, នង ឧត្តតារា, អែម សុខឃីម, ឆាយ ណារឿន, ប៉ាង ពីរីន, លឿង សូភ័ក្ត, កែវ ដាស៊ីល, ខេតទ្រីណា អេនឌីសុន, លីម ស្រីដល្លា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោរ

Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# តម្លៃនៃបណ្ណសារ ឧទាហរណ៍ពីប្រទេសហ្គាតេម៉ាឡា

ប្រទេសហ្គាតេម៉ាឡាស្ថិតនៅក្នុងទ្វីបអាមេរិកកណ្តាល ជាប្រទេសដែលមានទំហំផ្ទៃដីនិងចំនួនប្រជាជនប្រហាក់ប្រហែលនឹងប្រទេសកម្ពុជាដែរ ។ មិនខុសពីប្រទេសកម្ពុជាទេ ដែលថ្មីៗនេះហ្គាតេម៉ាឡាទើបនឹងចេញផុតពីសោកនាកម្មដ៏គួរឲ្យរន្ធត់បំផុតនៅក្នុងទំព័រប្រវត្តិសាស្ត្ររបស់ខ្លួនគឺប្រទេសជាតិទាំងមូលបានឆ្លងកាត់នូវជម្លោះសព្វាវុធផ្ទៃក្នុងប្រទេស បណ្តាលឲ្យប្រជាជនប្រមាណ ១៥ម៉ឺន នាក់ស្លាប់បាត់បង់ជីវិតក្នុងរវាងឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៩៦ ។ ប្រជាជនហ្គាតេម៉ាឡាជាង៤៥ពាន់នាក់បានបាត់ខ្លួននិងប្រហែល២លាននាក់បានផ្លាស់ទីជម្រក ឬសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួននៅប្រទេសឯទៀត ។ ផ្ទះសម្បែងរាប់ពាន់ខ្នងត្រូវបានកម្ទេច ។ ភូមិដ្ឋានជាង៦០០ត្រូវបំផ្លាញចោលទាំងស្រុង ។

ជនរងគ្រោះភាគច្រើនជាប្រជាជនក្រីក្រក្នុងស្រុកដែលរស់នៅតាមតំបន់ជនបទនិងជាសមាជិកសហព័ន្ធឬកសិករធ្វើការឲ្យម្ចាស់ដី ។ ក្រៅពីនោះ ប្រជាជនដែលប្រឆាំងជំទាស់នឹងការគ្រប់គ្រងជិះជាន់នៅក្នុងប្រទេសហ្គាតេម៉ាឡា ក៏ត្រូវបានដៅសម្គាល់ជាមុខសញ្ញា ។ អ្នកទាំងនោះរួមមាន សិស្ស ចៅក្រម មេធាវី សាក្សី និងអ្នកសារព័ត៌មានដែលសុទ្ធសឹងជាអ្នករស់នៅរដ្ឋធានីនៃប្រទេសហ្គាតេម៉ាឡា ។ បុរស ស្ត្រី និងកុមារត្រូវបានបង្ខំឲ្យទទួលរងនូវការរំលោភសិទ្ធិមនុស្សជាច្រើនសណ្ឋានរាប់មិនអស់ ដូចជាការសម្លាប់ដោយគ្មានការកាត់ក្តីតាមផ្លូវច្បាប់ ទារុណកម្ម ការគំរាមកំហែងដល់អាយុជីវិតនិងការបង្ខូចកិត្តិយស ។

បុគ្គលជាជនដៃដល់នៃជម្លោះនេះគឺក្រុមនគរបាលជាតិដែលអ្នកទាំងនោះកាន់តែពិបាកសម្គាល់អត្តសញ្ញាណ ដូចគ្នានឹង“អង្គការ” នៅកម្ពុជាដែលរក្សាការសម្ងាត់ខ្ពស់បំផុត ។ ក្រុមនគរបាលជាតិបែកចេញជាពីរផ្នែក ។ ផ្នែកទីមួយជាប៉ូលិសក្នុងឯកសណ្ឋានដែលយើងអាចសម្គាល់បាន ។ ប៉ូលិសទាំងនេះខ្លាច ដោយមូលហេតុថាខ្លួនធ្លាប់បានធ្វើទារុណកម្ម ចាប់ និងសម្លាប់បាតុករ ឬជនណាដែល ប្រឆាំងនឹងរដ្ឋាភិបាលដោយខស្ម័នពុល ។ អំពើភេរវកម្មភាគច្រើនធ្វើឡើងដោយក្រុមប៉ូលិសសម្ងាត់ដែលស្ថិតក្នុងសម្លៀកបំពាក់ដូចប្រជាជនធម្មតា ។ ប៉ូលិសសម្ងាត់បង្កើតឲ្យមានក្រុមឃាតករសម្លាប់មនុស្ស ជាពិសេសចលនាកម្លាំងប្រឆាំងប្រមូលផ្តុំនៅតាមជនបទ ។ មិនត្រឹមតែប៉ុណ្ណោះប៉ូលិសសម្ងាត់ ថែមទាំងចាប់បង្ខាំងប្រជាជនយកទៅធ្វើទារុណកម្មនិងសម្លាប់ទៀតផង ។

**“ការរកឃើញ” បណ្ណសារ**


គំនរឯកសាររបស់ប្រទេសហ្គាតេម៉ាឡា

ដូចគ្នានឹងសកម្មភាពរបស់ខ្មែរក្រហម ក្រុមប៉ូលិសជាតិហ្គាតេម៉ាឡាបានរក្សានូវកំណត់ត្រាជាច្រើនរបស់ប្រជាជនដែលខ្លួនចាត់ទុកថាជាខ្មាំង ។ ចំណុចខុសគ្នានឹងខ្មែរក្រហមត្រង់ថា ពេលដែលកងទ័ពរណសិរ្សជាតិ និងវៀតណាមវាយចូលប្រទេសកម្ពុជាខ្មែរក្រហមព្យាយាមដុតបំផ្លាញឯកសារតាមដែលអាចធ្វើទៅបាន រីឯក្រុមប៉ូលិសជាតិហ្គាតេម៉ាឡា បែរជារក្សានូវរាល់ឯក-សារដោយទំនងជាមិនខ្លាចពីការចោទ

ប្រកាន់ចាប់ខ្លួននាពេលខាងមុខណាមួយឡើយ ។

មុនថ្ងៃ៥ ខែឧសភា ឆ្នាំ២០០៥ មានមនុស្សតិចតួចបំផុតដែលដឹងពីកំណត់ត្រាឯកសារនេះ ។ នៅថ្ងៃនោះ របាយការណ៍ព័ត៌មានបានរំឭកប៉ូលិសថា អាចនឹងមានការផ្ទុះដ៏ធំមួយបង្កឡើងដោយសម្ភារសព្វាវុធដែលរក្សាទុកតាំងពីឆ្នាំ១៩៩៧នៅបណ្ណិតសភានគរបាលជាតិឯទីក្រុងហ្គាតេម៉ាឡា ។

អ្នកទទួលពាក្យបណ្តឹងសិទ្ធិមនុស្សប្រចាំនៅប្រទេសហ្គាតេ-ម៉ាឡាមានការព្រួយបារម្ភនៅពេលដឹងថា ការផ្ទុះអាវុធនេះអាចបំផ្លាញតំបន់មួយគឺឡូម៉ែត្រជុំវិញនោះដែលមានផ្ទះសាលារៀន អគារពាណិជ្ជកម្មនិងមន្ទីរពេទ្យ ។

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ប្រជាជននៅទីក្រុងភ្ញាក់ពីដំណេកដោយឮសំឡេងផ្ទុះចេញពីតំបន់មួយនៃទីក្រុង ។ គ្រាប់មិនទាន់ប្រើប្រាស់ជាង១តោនដែលនៅសេសសល់ពីជម្លោះសព្វាវុធផ្ទុកក្នុងបានក្លាយជាផ្សែងអណ្តែតឡើងនិងក្លាយជាពពកពណ៌សដែលប្រជាជនជាច្រើនយល់ថាជាជាតិពុលធ្វើឲ្យមានការបារម្ភរីករាលដាលគ្រប់ទីកន្លែង ។ ព្រឹត្តិការណ៍នេះផ្តល់ឱកាសឲ្យអ្នកទទួលពាក្យបណ្តឹងដើម្បីរៀបចំឯកសារ ស្នើចុះត្រួតពិនិត្យបណ្ណិតសភានគរបាលជាតិ ហើយនៅថ្ងៃ៥ ខែកក្កដា ក្រុមការងារនេះបានទៅដល់ទីនោះ ។

ខណៈពេលដែលកំពុងត្រួតពិនិត្យអគារជាប់បន្ទប់ផ្ទុកជាតិផ្ទុះ ក្រុមការងារទទួលពាក្យបណ្តឹងបានរកឃើញឯកសារខ្លះដែលទាក់ទាញចំណាប់អារម្មណ៍ខ្លួន ។ ពេលដែលក្រុមការងារធ្វើការត្រួតពិនិត្យបន្ទប់មួយទៅបន្ទប់មួយ នៅក្នុងអគារដ៏ខ្វាត់ខ្វែង ក្រុមការងារបានរកឃើញឯកសារកាន់តែច្រើន ។ សមាជិកក្រុមទាំងអស់ភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយស្ទើរតែមិនជឿថាបញ្ជីឯកសារទាំងនេះពិតជាមានប្រាកដមែន (ក្រុមប៉ូលិសបានអះអាងថាមិនដែលមានបញ្ជីឯកសារដូច្នោះឡើយ ឬថាបញ្ជីឯកសារទាំងនោះត្រូវបានកម្ទេចចោល) ។ ក្រុមការងារស្មានមិនដល់ថាឯកសារទាំងនេះត្រូវបានរក្សាទុកជាង២០ឆ្នាំនៅកន្លែងដែលងាយស្រួលនឹងរកឃើញបំផុត ។ ទន្ទឹមនឹងនោះក្រុមការងារបានរកឃើញបន្ថែមនូវឧបករណ៍ជាតិផ្ទុះជាង៣៥០០ទៀតដូចជា រំសេវ គ្រាប់បែក គ្រាប់បែកដៃ កាំភ្លើងត្បាល់ និងសារធាតុគីមីប៉ូតាស្យូមក្លរីត ។



សកម្មភាពសម្អាតឯកសារនៅបណ្ណាសារដ្ឋា[illegible]ទៅហ្គាតេម៉ាឡា

## ដំណោះស្រាយចំពោះបណ្ណសារ

ក្រុមការងារទទួលពាក្យបណ្តឹងត្រូវប្រឈមមុខនឹងការសម្រេចចិត្តមួយថាតើគួរធ្វេចភ្នែកមិនរវល់នឹងឯកសារដែលរកឃើញ ឬក៏ត្រូវស្វែងរកដំណោះស្រាយបន្ត ។ ក្រុមការងារសម្រេចយកជម្រើសទី២ ហើយធ្វើសំណើសុំដីកាពីតុលាការដើម្បីធ្វើការសិក្សាស្រាវជ្រាវលើឯកសារ និងស៊ើបអង្កេតពីបញ្ហារំលោភសិទ្ធិមនុស្សដែលមានកត់ត្រានៅក្នុងបញ្ជីឯកសារនោះ ។ សំណើនេះបានទទួលការអនុញ្ញាតមួយសប្តាហ៍បន្ទាប់ ។

ក្នុងពេលជាមួយគ្នានោះដែរ ស្ថាប័នដទៃទៀតព្យាយាមរកដំណោះស្រាយការពារបញ្ជូនឯកសារទៅកន្លែងផ្សេងទៀតដោយគិតទាំងឯកសារដែលបានរកឃើញនៅប៉ុស្តិ៍ប៉ូលិសជាតិតាមតំបន់ជនបទ ។ អ្នកទទួលពាក្យបណ្តឹងសាធារណៈរកដំណោះស្រាយ ភ្លាមដោយធ្វើសំណើទៅក្រសួងមហាផ្ទៃសុំឲ្យបញ្ជូនឯកសារទាំងអស់មកតម្កល់ទុកនៅបណ្ណិតសភាប៉ូលិសជាតិដើម្បីងាយស្រួលការពារសុវត្ថិភាព ។

លោករដ្ឋមន្ត្រីបានយល់ស្របហើយស្នងការនគរបាលជាតិ

បានបញ្ជូននាយនគរបាលដើម្បីយាមការពារបណ្ណសារដ្ឋាននេះ ។

## ស្ថានភាពនិងសមាសភាពក្នុងនៃបណ្ណសារ

នៅពេលដែលខ្ញុំទៅបំពេញការងារឯកសារនៅប្រទេសហ្គាតេម៉ាឡាកាលពីខែវិច្ឆិកា ឆ្នាំ២០០៦ ខ្ញុំបានទៅមើលបណ្ណា-សារនេះផ្ទាល់ភ្នែក ។ ឯកសារប្រមាណជាង៨០លានច្បាប់ (ប្រសិនបើដាក់តម្រៀបបន្តគ្នា ឯកសារនោះមានប្រវែងជាង ៨,៥គីឡូម៉ែត្រ) ដែលតម្កល់ទុកនៅទីនោះស្ថិតក្នុងស្ថានភាពគួរឲ្យអស់សង្ឃឹម ។ ឯកសារត្រូវបានចងជាដុំៗគរលើគ្នាតាំងពីកម្រាលឥដ្ឋមកទល់នឹងជញ្ជាំងពិតានអគារ ។ បន្ទប់ផ្ទុកឯកសារជាច្រើនលិចទឹកបណ្តាលឲ្យឯកសារមួយចំនួនខូច ជាពិសេសសំណើមឥតឈប់ឈរបានបំផ្លាញឯកសារមួយចំនួនធំ ។ មិនត្រឹមតែប៉ុណ្ណោះ ឯកសារខ្លះត្រូវសត្វល្អិតស៊ី និងខ្លះទៀតខូចដោយសារពន្លកវុក្ខជាតិដុះប៉ះ ។ សត្វកណ្តុររត់ខ្វែងខ្វាត់ពាសពេញបន្ទប់ ហើយពេលយប់មានសត្វប្រចៀវនិងចាបហើរចូលតាមបង្អួចបាក់បែក ។ ម្យ៉ាងទៀត ដោយសារប្រព័ន្ធខ្សែអគ្គិសនីរៀបចំមិនបានល្អអាចបង្កឲ្យមានគ្រោះថ្នាក់ដុះខ្សែភ្លើងបង្កជាអគ្គិភ័យ ។ ទោះបីជាស្ថិតក្នុងម៉ោងបុគ្គលិកកំពុងធ្វើការក៏ដោយក៏គ្មានដំណោះស្រាយលើបញ្ហាសន្តិសុខដែរ ។

អ្នកទទួលពាក្យបណ្តឹងសាធារណៈប្រញាប់អនុវត្តជំហានដើម្បីការពារឯកសារក្នុងស្ថានភាពដ៏យ៉ាប់នេះ ។ បុគ្គលិកស្ត្រី ៩នាក់និងបុរស២នាក់ ដែលជាក្រុមថែរក្សាបណ្ណសារនេះទុកជាកេរមរតកជាតិនៃប្រទេសហ្គាតេម៉ាឡា ដោយមានជំនួយឧបត្ថម្ភពីអ្នកស្ម័គ្រចិត្តចំនួនជិត២០០នាក់ ។

ឯកសារប្រមាណពី១៥ ទៅ២០ភាគរយនៃឯកសារក្នុងបណ្ណសារដ្ឋានសុទ្ធតែជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ។ ឯកសាររបស់បណ្ណសារមានខ្លឹមសារផ្សេងៗរួមមានពាក្យស្នើសុំសំបុត្រស្នាម ឬរបាយការណ៍លើអត្តសញ្ញាណប័ណ្ណ ពាក្យស្នើសុំប័ណ្ណបើកបរកំណត់ត្រាចាប់ខ្លួនចំពោះឧក្រិដ្ឋកម្មគ្រប់ប្រភេទ បញ្ជីឯកសារឧក្រិដ្ឋកម្មនយោបាយ (តួយ៉ាងដូចជា កំណត់ត្រាចាប់ខ្លួនជនជាប់ចោទថាជាកុម្មុយនិស្ត) និងឯកសារមានស្នាមផ្តិតម្រាមដៃ ។

ឯកសារមួយចំនួនតូចត្រូវបានរៀបចំរួចពេលក្រុមការងាររកឃើញ ។ ក្រុមការងារបានរកឃើញទូឯកសារមានបិទស្លាកថា "ឃាតកម្ម" "បាត់ខ្លួន" និង "មនុស្សឃាត" និងសំណុំរឿងជនរងគ្រោះពីឃាតកម្មនយោបាយ ។ នៅទីនោះក៏មានរូបថត ជាច្រើនដុំ មានរូបថតសាកសព បញ្ជីឈ្មោះអ្នកយកការណ៍ឲ្យប៉ូលិសកាសែ្សតវីដេអូ និងស៊ីឌីកុំព្យូទ័រ ។

បច្ចុប្បន្ន ឯកសារទាំងនេះត្រូវបានរៀបចំទៅតាមថ្ងៃខែឆ្នាំប្រភេទ និងភ្នាក់ងារដែលចេញឯកសារនោះ ។ ឯកសារទាំងឡាយត្រូវបានរក្សាទុកមិនកំណត់ថាឯកសារនោះទាក់ទងនឹងជម្លោះប្រដាប់អាវុធ ឬអត់នោះឡើយ ។

ការងាររបស់ក្រុមឯកសាររួមមាន ស្វែងរកប្រភពនិងរៀបចំកំណត់ត្រាជាប់ទាក់ទិន (ឯកសារដ៏ចំណាស់បំផុតនៅបណ្ណសារដ្ឋានមាននិយាយពីដីកាចាប់ខ្លួនពីឆ្នាំ១៨៨៥) សម្អាតឯកសារ (បោស សម្អាត ផ្សិត និងប្រេះលើដែកកិប) សិក្សាស្រាវជ្រាវលើឯកសារ ស្កេនឯកសារ និងបញ្ចូលទិន្នន័យពីខ្លឹមសារឯកសារក្នុងប្រព័ន្ធកុំព្យូទ័រ ។

នៅក្នុងរយៈពេលមិនដល់២ឆ្នាំផង ក្រុមការងារសម្រេចបានជាង២,៧លានសន្លឹក ហើយបានសម្អាត រៀបចំ និងបញ្ចូលក្នុងប្រព័ន្ធឌីជីថលជិត៣លានឯកសារ ។ ដោយមានថវិកាពីអង្គការសហប្រជាជាតិ រដ្ឋាភិបាលស៊ុតដេន (ស៊ុយអែត) និងនេតឌីឡែន (ហូឡង់) រៀបចំឯកសារធ្វើទៅតាមរូបមន្ត "៣-២-១" ដោយដាក់ឯកសារជា៣ប្រភេទ (ឯកសារក្រដាស ឯកសារស្កេន និងឯកសារជាប្រព័ន្ធឌីជីថល) រួចយកទៅតម្កល់ទុកនៅកន្លែង២ (នៅប្រទេសហ្គាតេម៉ាឡានិងបណ្ណសារដ្ឋានជាតិនៅប្រទេសស៊ីស) ហើយឯកសារទាំងអស់ចម្លងជា២ច្បាប់ ។ នេះជាទម្រង់ការងារតែមួយដូចគ្នានឹងការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ។ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតក្នុងទម្រង់ជាម៉ៃ-ក្រូហ្វីម ម៉ៃក្រូហ្វីស និងឯកសារស្កេន (យើងក៏មានគម្រោងនឹងធ្វើឯកសារឌីជីថលដែរ) និងមានតម្កល់ទុកនៅប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ដោយមានការចម្លងជាស៊ីឌី និងអ៊ីនធឺណែត ។

## សារសំខាន់នៃបណ្ណសារដ្ឋាន

កាលពី១៨ឆ្នាំកន្លងទៅនេះ ការិយាល័យសិទ្ធិមនុស្សនៅប្រទេសហ្គាតេម៉ាឡាបានទទួលនូវរបាយការណ៍រាប់ពាន់ទាក់ទិននឹងបញ្ហារំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយកងកម្លាំងសន្តិសុខ

រដ្ឋ ។ ទន្ទឹមនឹងនោះ ជនរងគ្រោះមួយចំនួនបានស្ម័គ្រចិត្តចេញមុខរៀបរាប់រឿងរ៉ាវរបស់ខ្លួន ។ ការរកឃើញគួបផ្សំនឹងការចងក្រងឯកសារនៅបណ្ណសារដ្ឋាន នេះជាលើកទីមួយហើយដែលប្រទេសហ្គាតេម៉ាឡាចាប់ផ្ដើមលាតត្រដាងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួន និងថែរក្សាប្រវត្តិសាស្ត្រនេះដែលសរសេរចងក្រងដោយជនដែលឆ្លងកាត់ផ្ទាល់ ។ បន្ទាប់ពីដំណើរការនេះ ប្រទេសហ្គាតេម៉ាឡា អាចឈានទៅរកការទទួលខុសត្រូវលើផ្លូវច្បាប់ចំពោះមុខតុលាការនិងទំនួលខុសត្រូវជាប្រវត្តិសាស្ត្រមួយ ។

យ៉ាងតិចណាស់១០ឆ្នាំទៅមុខ ក្រុមការងារនឹងបន្តកិច្ចការជំនាញ និងការខិតខំប្រឹងប្រែងក្នុងការថែរក្សាឯកសារទាំងនេះ ។ បច្ចុប្បន្នក្រុមការងារកំពុងបោះជំហានសុំការអនុញ្ញាតតាមផ្លូវច្បាប់ចំពោះបណ្ណសារដ្ឋាននេះ ។ ពេលកិច្ចការនេះចប់សព្វគ្រប់ប្រទេសហ្គាតេម៉ាឡាអាចចាប់ផ្ដើមប្រឈមមុខនឹងអតីតកាលរបស់ខ្លួននឹងស្ដាបនាឡើងវិញនូវប្រវត្តិសាស្ត្របច្ចុប្បន្ន ។ កិច្ចការនេះអាចជួយឲ្យប្រទេសជាតិផ្ដើមចេញពីការបង្កើតសង្គមប្រកបដោយសមភាពមួយ និងធ្វើឲ្យប្រព័ន្ធតុលាការរីកចម្រើនជឿនលឿន ។

នៅប្រទេសហ្គាតេម៉ាឡា មានពាក្យមួយពិពណ៌នាពីប្រជាជនបាត់ខ្លួនក្នុងជម្លោះផ្ទៃក្នុងប្រទេស "មិនត្រឹមតែជីវិតប្រជាជនទាំងអស់គ្នាត្រូវបានបដិសេធទេ សូម្បីតែការស្លាប់របស់ប្រជាជនទាំងអស់ក៏ត្រូវបានបដិសេធដែរ" ប៉ុន្តែរឿងនេះនឹងឈានទៅរកការផ្លាស់ប្ដូរពេលដែលបណ្ណសារដ្ឋាននេះត្រូវបើកជាសាធារណៈ ប្រជាជនជាច្រើនគ្រួសារកើតក្ដីសង្ឃឹមថ្មីថានឹងអាចរកឃើញពីវាសនាសាច់ញាតិរបស់ខ្លួនធ្វើឲ្យការសម្ងាត់ត្រូវបានទម្លាយចេញ ។ ដូចគ្នា នឹងនៅប្រទេសកម្ពុជាដែរ ប្រជាជនសាមញ្ញ អាចស្វែងរកមនុស្សជាទីស្រឡាញ់របស់ខ្លួនតាមរយៈបណ្ណសារដ្ឋាន ។ មេធាវីអាចប្រើប្រាស់បណ្ណសារដ្ឋាននេះដើម្បីជំរុញប្រព័ន្ធតុលាការ ។ អ្នកប្រាជ្ញនានាអាចធ្វើការស្រាវជ្រាវនៅទីនោះផងដែរ ហើយក្មេងជំនាន់ក្រោយក៏អាចទាញរកហេតុផលផ្សេងៗចេញពីបណ្ណសារនេះដើម្បីធ្វើកិច្ចការមួយជួយអភិវឌ្ឍសង្គមជាតិទាំងមូល ។

**ឆាំង យុ**

# ចាកចេញពីស្រុកកំណើតដើម្បីបំភ្លេចអតីតកាល

ធ្វើដំណើរចេញពីរួមខេត្តពោធិ៍សាត់តាមផ្លូវជាតិលេខ៥ ប្រមាណពីរគីឡូម៉ែត្រ និងបន្តឆ្ពោះទៅកាន់ឃុំរលាបតាមផ្លូវក្រួសក្រហមដ៏វែងមួយ ដែលអមសងខាងផ្លូវដោយវាលស្រែដែលមានទឹកពេញព្រៀបចម្ងាយប្រហែល៦គីឡូម៉ែត្រ យើងនឹងទៅដល់ភូមិមួយនៅក្នុងឃុំរលាប ស្រុកសំពៅមាស ក្នុងខេត្តពោធិ៍សាត់ ជាកន្លែងដែលអ៊ីស្រី ចិន ស៊ីម កំពុងរស់នៅ ។ ចិន ស៊ីម មានអាយុ៦៣ឆ្នាំ ជាអ្នកភូមិម្នាក់ដែលបានទទួលឯកសារស្ដីអំពីដំណើរការរបស់សាលាក្ដីកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមពីក្រុមការងារចែកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាមួយគ្នានេះអ៊ីស្រីក៏បានផ្ដល់បទសម្ភាសន៍អំពីជីវិតរបស់អ៊ីស្រីនៅក្នុងរបបខ្មែរក្រហមនិងផលប៉ះពាល់នៃរបបនេះមកលើជីវិតគ្រួសាររបស់អ៊ីស្រី ។

**ចូលបម្រើបដិវត្តន៍**

ស៊ីម មានបងប្អូនបួននាក់ (ប្រុសមួយ ស្រីបី) មានស្រុកកំណើតនៅខេត្តកំពង់ចាម ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ស៊ីមកំពុងសិក្សានៅឡើយ ។ ឪពុកម្ដាយរបស់ ស៊ីម មិនចង់ឲ្យកូនចូលរៀនទេ ព្រោះខ្លាចកូនលួចទៅមានសង្សារឬសរសេរសំបុត្រស្នេហា ។ ទោះបីជាយ៉ាងនេះក្ដី ដោយទឹកចិត្តចង់រៀនសូត្រ ស៊ីមបានជម្នះចិត្តឲ្យឪពុកម្ដាយចុះឈ្មោះចូលរៀន ដែលកាលណោះមានការជួយជ្រោមជ្រែងពីគ្រូបង្រៀនផង ។ នៅពេលនោះដែរ ស៊ីម បានចូលរួមធ្វើបាតុកម្មជាមួយសិស្សនៅក្នុងខេត្តកំពង់ចាមប្រឆាំងនឹងរបបថ្មី"របបសាធារណរដ្ឋខ្មែរ" ដែលគ្រប់គ្រងដោយលោកសេនាប្រមុខ លន់ នល់ ។ ពេលត្រឡប់មកផ្ទះវិញ សិស្សមួយចំនួនរួមទាំង ស៊ីម ផង ត្រូវប្រធានភូមិចុះឈ្មោះក្នុងបញ្ជីអ្នកចូលរួមក្នុងជួរបដិវត្តន៍ ដើម្បីធ្វើការតស៊ូទាមទារសម្ដេចព្រះនរោត្តម សីហនុ មកគ្រប់គ្រងប្រទេសវិញ ។ ស៊ីម មិនបានជំទាស់ទៅនឹងការជ្រើសរើសនេះទេ ពីព្រោះគាត់ពេញចិត្តនឹងចូលរួមក្នុងចលនានេះដើម្បីសម្ដេចឪដែរ ។

នៅក្នុងភូមិមានយុវជនអាយុស្រករ ស៊ីម ជាច្រើនត្រូវបានចាត់បញ្ចូលក្នុងជួរបដិវត្តន៍ ដែលរួមមានឈ្មោះ ហ៊ឹម ទី និង វ៉ុន ។ យុវជនដែលមិនទាន់មានគូស្រករត្រូវបានចាត់តាំងឲ្យធ្វើជាកងឈ្លបការពារភូមិ ។ ក្រោយមកនៅក្នុងព្រៃម៉ាគី ស៊ីម ត្រូវបានបញ្ជូនឲ្យទៅលត់ដំហាត់ក្បួន ទ័ពដូចជាហាត់បាញ់កាំភ្លើង លូនក្រាបក្រោមបន្ទាលួស របៀបគេចគ្រាប់ និងរបៀបដោះនិងបញ្ចូលគ្រាប់ ដែលមានគ្រូបង្ហាត់ឈ្មោះមិត្តហឿន និងមិត្តលៀន ដែលជាគណៈតំបន់ ។ ក្នុងរយៈហ្វឹកហ្វឺននេះ ស៊ីម និងកងទ័ពទាំងអស់ទទួលបានរបបអាហារបីពេលក្នុងមួយថ្ងៃ ដែលក្នុងមួយពេលទទួលបានបាយមួយចានចង្កឹះ ។ ក្នុងមួយវគ្គៗមានកងទ័ពហ្វឹកហ្វឺនពី៦០ទៅ១០០នាក់ ។ ក្នុងការហាត់នេះគឺមានប្រើប្រាស់អាវុធកាំភ្លើងនិងគ្រាប់បែកមែនទែន ដែលជួនកាលបានធ្វើឲ្យកងទ័ពរងរបួសក៏មាន ។ ដៃជើងរបស់ ស៊ីម ក្រិនដោយសារតែការហាត់រៀននេះ ។

ទោះបីជាការហាត់ក្បួនទ័ពមានសភាពលំបាកជាខ្លាំងយ៉ាងណាក៏ដោយ ក៏ ស៊ីម នៅតែបន្តនៅទីនោះដែរ ព្រោះ ស៊ីម មិនស្គាល់ភូមិសាស្ត្រ ហើយមិនទាំងដឹងថាខ្លួនកំពុងនៅទីណាផង ។ ក្រោយពីបញ្ចប់ការហាត់រៀន ស៊ីម ត្រូវបានបញ្ចូលជាកងទ័ពស្រួចដែលជាកងទ័ពជំនួយរបស់កងទ័ពមជ្ឈិម ។ នៅក្នុងអំឡុងឆ្នាំ១៩៧៣-១៩៧៤ ស៊ីម បានដឹកនាំទ័ពឡើងសមរភូមិជាច្រើនកន្លែង ដូចជានៅខេត្តកំពង់ធំនិងស្រុកមួយចំនួនក្នុងខេត្តកំពង់ចាម ។ កងទ័ពរបស់ ស៊ីម ចាប់បានឈ្លើយសឹកជាទាហានលន់នល់ជាច្រើន ហើយបានបញ្ជូនឈ្លើយសឹកទាំងនោះទៅបន្ទាយរបស់ខ្មែរក្រហម ដែលនៅទីនោះទាហានទាំងនេះនឹងត្រូវបានសម្លាប់ចោលទាំងអស់ ។ ដោយបានដឹងពីហេតុការណ៍ឃោរឃៅនេះ ក្រុមកងទ័ពរបស់ ស៊ីម បានជួយលាក់កំបាំង ហើយបានលួចបញ្ជូនឈ្លើយសឹកទាំងនោះទៅកាន់ភូមិកំណើតរៀងៗខ្លួនវិញ ។

ជីវិតរស់នៅជាកងទ័ពរំដោះជួបការលំបាកច្រើន ព្រោះពេលខ្លះកងទ័ពមិនបានទទួលអាហារគ្រប់គ្រាន់ ដោយសារតែស្បៀងបញ្ជូនមកមិនទាន់ពេលវេលា ។ ពេលខ្លះទៀត ស៊ីម ត្រូវរត់គេចពីទាហានលន់នល់ និងការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់មកលើតំបន់រស់នៅរបស់កងទ័ពរំដោះ ។ ស៊ីម បានរំឭកថា មានកងទ័ពជាច្រើនបានស្លាប់បាត់បង់ជីវិតនៅក្នុងការប្រយុទ្ធគ្នា ជាពិសេសនៅក្នុងប្រតិបត្តការសឹកចេនឡាទី១ និងចេនឡាទី២ ។ កងទ័ពរបស់គាត់ដែលមានសមាជិកចំនួន៥០០នាក់ បានស្លាប់របួសបាត់ខ្លួនជាបន្តបន្ទាប់ ហើយកងទ័ពថ្មី ដែលហាត់រៀនចេះក្បួនទ័ពបន្តិចបន្តួចត្រូវបានដាក់បញ្ចូលជំនួសមកវិញដើម្បីរក្សាចំនួនទ័ពឲ្យនៅដដែល ។ មានពេលមួយប្រហែលក្នុងឆ្នាំ១៩៧៣ ស៊ីម ត្រូវរបួសជាទម្ងន់ ដោយគ្រាប់កាំភ្លើងចាក់ធ្លាយពីពោះចេញមកចង្កេះ ។ ស៊ីម ត្រូវបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យកងទ័ពអស់រយៈពេលជិតមួយឆ្នាំ ។

ក្នុងរយៈពេលនៃការរស់នៅជាកងទ័ពរបស់មជ្ឈិម ស៊ីម ទទួលបានការអប់រំពីថ្នាក់លើថា ក្រោយពីរំដោះប្រទេសបានហើយ កងទ័ពទាំងអស់នឹងអាចទៅជួបជុំឪពុកម្តាយបងប្អូន ហើយរស់នៅជាមួយគ្នាយ៉ាងសុខសប្បាយ ។ ប៉ុន្តែ ស៊ីម មិនបានជួបជុំសាច់ញាតិដូចការឃោសនារបស់ខ្មែរក្រហមឡើយ ។ ស៊ីម បានជួបតែការវិនាសព្រាត់ប្រាស ការបង្ខំឲ្យធ្វើការហួសកម្លាំង និងការកាប់សម្លាប់ប៉ុណ្ណោះ ។ រំឭកដល់ត្រង់ចំណុចនេះ ស៊ីម មានទឹកភ្នែករលីងរលោងនិងអួលដើមក ហើយបាននិយាយបន្តថា ឪពុកម្តាយរបស់មិត្តភក្តិគាត់ម្នាក់ឈ្មោះ មិត្តហាន ត្រូវបានសម្លាប់នៅចំពោះមុខ មិត្តហាន ដោយសារអ្នកទាំងពីរបានលួចស្ករត្នោតមួយស្លាបព្រាយកមកឲ្យកូនហូប ។

## ទៅរៀននៅប្រទេសចិន

ពីរខែក្រោយជ័យជម្នះឆ្នាំ១៩៧៥ ស៊ីម ដែលនៅពេលនោះមានឋានៈជាប្រធានកងវរសេនាធំត្រូវបានបញ្ជូនឲ្យទៅរៀនផ្នែកបច្ចេកទេសយោធានៅប្រទេសចិនរយៈពេល៦ខែ ។ ស៊ីម ទៅជាមួយមិត្តភក្តិចំនួន១២នាក់ ។ កម្មាភិបាលដែលត្រូវសិក្សាផ្នែកនយោបាយត្រូវបានបញ្ជូនឲ្យទៅមុនកម្មាភិបាលដែលសិក្សាផ្នែកយោធា ។ ក្នុងចំណោមនោះមានម្នាក់ឈ្មោះ មិត្តមិ បានឈឺនៅប្រទេសចិន ហើយបានស្លាប់បន្ទាប់ពីធ្វើដំណើរមកដល់កម្ពុជាវិញនៅដើមឆ្នាំ១៩៧៦ ។ ស៊ីម បានធ្វើដំណើរត្រឡប់មកកាន់មាតុប្រទេសវិញតាមជើងយន្តហោះចិនដែលហោះហើរពីក្រុងប៉េកាំងមកព្រលានយន្តហោះវាលវែងខេត្តកំពង់ចាម ។ ក្រោយមកអ្នកទាំងនោះត្រូវអង្គការចាត់តាំងទៅកាន់កន្លែងរៀងៗខ្លួន

ប៉ុន្តែត្រូវបានសម្លាប់ចោលទាំងអស់នៅពេលក្រោយមកទៀត ។ ស៊ឹម រំឭកថា ក្នុងចំណោមមិត្តភក្តិដែលទៅរៀនជាមួយគ្នានៅប្រទេសចិនស្ទើរតែទាំងអស់ត្រូវបានអង្គការសម្លាប់ ដោយសារតែមនុស្សម្នាក់ត្រូវបានចោទថាក្បត់ ហើយបានឆ្លើយសារភាពដាក់មិត្តភក្តិផ្សេងទៀតដែលធ្លាប់ទៅសិក្សារៀនសូត្រនៅប្រទេសចិនជាមួយគ្នា ។ ស៊ឹម ងឿងឆ្ងល់រហូតដល់សព្វថ្ងៃថា “យើងទៅរៀនសូត្រដល់ត្រឡប់មកវិញគេថាយើងក្បត់ ។ គេថាយើងមានយកគ្រណាត់ខោអាវទៅឲ្យបងប្អូន” ។

ស៊ឹម រៀបការនៅឆ្នាំ១៩៧១ ហើយមានកូនប្រុសម្នាក់ ។ មកពីប្រទេសចិនបានពីរថ្ងៃ ប្តីរបស់ ស៊ឹម ត្រូវអង្គការយកទៅសម្លាប់នៅបន្ទាយស៊ុប ក្នុងខេត្តកំពង់ចាម ដោយចោទថាក្បត់អង្គការ ។ ស៊ឹម និយាយថា ប្តីរបស់គាត់ដឹងខ្លួនជាមុនអំពីវាសនារបស់ខ្លួន ហើយបានផ្តែផ្តាំគាត់ថា “ឲ្យតែឮផ្ទុះអាវុធស្លាប់ហើយ” ។

## ត្រឡប់មកនៅក្នុងជួរកងទ័ព

ក្រោយមក ស៊ឹម ត្រូវបានចាត់តាំងឲ្យទៅនៅផ្នែកយោធាក្នុងភូមិភាគឧត្តរ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ កែ ពក ។ យូរៗម្តង ស៊ឹម បានឃើញថ្នាក់ដឹកនាំចុះមកពិនិត្យមើលការងាររបស់ថ្នាក់ក្រោមនិងមានបើកអង្គប្រជុំ ។ ស៊ឹម មានការធុញទ្រាន់នឹងអង្គប្រជុំទាំងនោះយ៉ាងខ្លាំង ព្រោះក្រៅពីការងារផ្នែកយោធា កងទ័ពទាំងអស់ត្រូវបានចាត់តាំងឲ្យចុះភ្ជួរដីធ្វើស្រែដូចប្រជាជននៅតាមសហករណ៍ដែរ ។ ស៊ឹម និយាយថា “ប្រជុំម្តងៗមិនមានអ្វីក្រៅពីវាយសម្រុកធ្វើស្រូវឲ្យបានបីតោនក្នុងមួយហិកតាទេ” ។ ស៊ឹម និងមិត្តភក្តិនៅក្នុងកងជាមួយគ្នាត្រូវផ្លាស់ប្តូរគ្នាធ្វើគោអូសនង្គ័លភ្ជួរដី ។ ចំណែកដីស្រែដែលស្ថិតនៅក្បែរបន្ទាយទាហាន ដែលពោរពេញទៅដោយគ្រាប់មីន យុទ្ធជនទាំងអស់ត្រូវចាប់ឆ្នោតដើម្បីទៅភ្ជួររាស់ដាំស្រូវនៅទីនោះ ។ សន្លឹកឆ្នោតមានលេខរៀងពីលេខ១ដល់លេខ៣ អ្នកដែលចាប់បានលេខ៣អាចធ្វើការនៅឆ្ងាយពីដីស្រែដ៏គ្រោះថ្នាក់នោះបន្តិច ។ មនុស្សមួយចំនួនដែលចាប់បានលេខ១ត្រូវមីនស្លាប់ ឬរងរបួសដាច់ដៃដាច់ជើង ។ ក្នុងឋានៈជាប្រធានកងវរសេនាធំ ស៊ឹម ធ្លាប់បានមកប្រជុំនៅទីក្រុងភ្នំពេញពីរ-បីដងដែរ ។ ការប្រជុំភាគច្រើនគឺពិភាក្សាគ្នាពីការចាប់ខ្លួនកម្លាំងបង្កប់ស៊ីរូងផ្ទៃក្នុងនៅតាមតំបន់និងភូមិភាគ ។

ធ្វើការនៅទីនោះ ស៊ឹម បានឈ្លោះប្រកែកជាមួយ កែ ពក ទាក់ទងនឹងបញ្ហាធ្វើសង្គ្រាមជាមួយវៀតណាម ។ កែ ពក បានបញ្ជាឲ្យ ស៊ឹម រៀបចំកម្លាំងទ័ពដើម្បីធ្វើការវាយប្រហារចូលទៅក្នុងទឹកដីវៀតណាម ប៉ុន្តែ ស៊ឹម បានជំទាស់ថា “ទៅវ៉ៃគេយ៉ាងម៉េចបើគេនៅក្នុងទឹកដីគេ ហើយយើងនៅក្នុងទឹកដីយើង” ។ ជាពិសេសទៅទៀតនោះ ស៊ឹម មិនចង់ឲ្យកងទ័ពចំនួន៥០០នាក់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនរងគ្រោះថ្នាក់ទេ “ខ្ញុំកាន់ទ័ព៥០០នាក់ ហើយឲ្យខ្ញុំយក៥០០នាក់ហ្នឹងទៅគ្រវែងចោលយ៉ាងម៉េច” ។ ជម្លោះរវាងអ្នកទាំងពីរមានសភាពខ្លាំងក្លារហូតដល់មានការបាញ់គ្នារវាងក្រុមរបស់ ស៊ឹម និងក្រុមរបស់ កែ ពក ។ ប៉ុន្តែការបាញ់គ្នានេះមិនបានបណ្តាលឲ្យភាគីណាមួយរងរបួសធ្ងន់ទេ ។ ស៊ឹម ត្រូវរបួសស្រាលត្រង់ជើង ។

## ផ្លាស់មកនៅក្នុងសហករណ៍

ដោយមានការជំទាស់យ៉ាងខ្លាំងបែបនេះ កែ ពក បានបញ្ជាឲ្យ មិត្តម៉ែន ដែលជាប្រធានកងធំ ដឹកនាំទ័ពវាយចូលទឹកដីវៀត-ណាមវិញ ។ ចំណែក ស៊ឹម ត្រូវបានដកហូតតំណែងចេញពីកងទ័ព ហើយបញ្ជូនឲ្យមកធ្វើការខាងនេសាទតំបន់៤១ ស្រុកកំពង់សៀម ដែលនៅទីនោះ ស៊ឹម ទទួលបន្ទុកធ្វើត្រីប្រហុកសម្រាប់ផ្គត់ផ្គង់កម្មាភិបាលដែលធ្វើការនៅតាមការដ្ឋានលើកទំនប់ ។

ដោយលែងទទួលបានការទុកចិត្តនិងមានការសង្ស័យពីអង្គការ ស៊ឹម ក្រោយមកទៀតត្រូវបានដកចេញពីផ្នែកនេសាទឲ្យទៅរស់នៅក្នុងសហករណ៍កាប់ដីដំបូកយកមកលាយជាមួយលាមកមនុស្សធ្វើជីលេខ១និងស្ទូងស្រូវ ។

ស៊ឹម សប្បាយចិត្តយ៉ាងខ្លាំង ដែលត្រូវបញ្ជូនមកសហ-ករណ៍ព្រោះអ្នកធ្វើការនៅផ្នែកនេសាទបានបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ “យ៉ាងហោចណាស់ ក៏មួយថ្ងៃបាត់ខ្លួនម្នាក់ឬពីរនាក់ដែរ” ។ ទោះជាយ៉ាងនេះក្តី ជីវិតរស់នៅក្នុងសហករណ៍គឺជាបទពិសោធន៍ឈឺចាប់មួយទៀតរបស់ ស៊ឹម ។ ស៊ឹម រៀបរាប់ថា គាត់មិនអាចបេះបន្លែបង្ការឬដឹកដំឡូងដែលគាត់ដាំនៅក្បែរផ្ទះយកមកហូបបានទេ ។ ប្រសិនបើគាត់ចង់ហូប គាត់ត្រូវយកទៅសហករណ៍ហូបរួម បើមិនអីចឹងច្បាស់ជាត្រូវចោទថាជាខ្មាំងហើយអាចត្រូវបានយកទៅវាយចោលទៀតផង ។ ជាពិសេស

ទៅទៀតនោះ គាត់មិនមានពេលវេលាច្រើននៅក្បែរនិងថ្នាក់ថ្នមកូនប្រុសតូចជាទីស្រឡាញ់ដែលមានអាយុទើបតែបានបីឆ្នាំប៉ុណ្ណោះ ។ មុន ចេញទៅធ្វើការ ស៊ីម ត្រូវទុកកូនឲ្យនៅជាមួយយាយចាស់ៗដែលជាអ្នកមើលថែក្មេងៗនៅក្នុងសហករណ៍ ។

រឿងដែលកាន់តែធ្វើឲ្យ ស៊ីម ឈឺចាប់បំផុតនិងមិនអាចទប់ទឹកភ្នែកបានគឺ គាត់គ្មានលទ្ធភាពជួយសង្គ្រោះម្តាយមីងដែលត្រូវឈ្លបខ្មែរក្រហមសម្លាប់យ៉ាងឃោរឃៅ ។ ស៊ីម បានត្រឹមតែឈរមើលម្តាយមីងដែលត្រូវកងឈ្លបវាយនឹងត្បូងចបប្រកាប់ធ្លាក់ទៅក្នុងរណ្តៅពោរពេញដោយឈាម ។ ម្តាយមីងរបស់ ស៊ីម ត្រូវបានចោទប្រកាន់ថាបាននិយាយបរិហារអង្គការ ។

បងស្រីនិងបងថ្លៃរបស់ ស៊ីម ដែលមាននាទីជាប្រធានកងនៅក្នុងភូមិបានតាមដាន ស៊ីម ហើយចង់យក ស៊ីម ទៅសម្លាប់ទៀតផង ។ ចំណែកឪពុកម្តាយរបស់ ស៊ីម ក៏មិនហ៊ានមកសម្រុះសម្រួលដែរ ព្រោះគាត់ទាំងពីរក៏ស្ថិតនៅក្នុងសមាសភាពសង្ស័យដែរ ។ ស៊ីម និយាយថា “*នៅសម័យ ប៉ុល ពត សក់អ្នកណាក្បាលអ្នកហ្នឹង កូនក៏ជួយឪមិនរួច ហើយឪក៏ជួយកូនមិនរួចដែរ*» ។ ក្នុងចំណោមអ្នកធ្វើការនៅក្នុងសហករណ៍ជាមួយគ្នា មិត្តថា ត្រូវបានអង្គការហៅទៅរៀនសូត្រ ហើយក៏បាត់ខ្លួនរហូតមក ។ ដោយឆ្ងល់អំពីការបាត់ខ្លួនរបស់ មិត្តថា ស៊ីម និងមិត្តភក្តិបានសួរប្រធានសហករណ៍ ហើយប្រធានសហករណ៍ឆ្លើយថា មិត្តថា គឺជាខ្មាំងបង្កប់សេ.អ៊ី.អា ដែលបានបំផុសផ្ទៃក្នុងឲ្យបះបោរ ។ ក្រោយពីឮដំណឹងនេះភ្លាម ស៊ីម មានការបារម្ភយ៉ាងខ្លាំង ដោយសារខ្លួនក៏ស្ថិតនៅក្រោមការតាមដានរបស់អង្គការជាប្រចាំ ។

**រួចផុតពីសេចក្តីស្លាប់**

ជីវិតរស់នៅឆ្លងកាត់របបដែលពោរពេញទៅដោយសង្គ្រាមនិងការកាប់សម្លាប់ ។ ទាំងនេះ គឺជាកត្តាចម្បងមួយដែលធ្វើឲ្យជីវិតរបស់ ស៊ីម ជួបប្រទះនូវការលំបាក ព្រាត់ប្រាសប្តី និងបងប្អូន ហើយថែមទាំងធ្វើឲ្យមានរបួសផ្លូវកាយនិងផ្លូវចិត្តរហូតដល់សព្វថ្ងៃ ។ អំបែងគ្រាប់នៅក្នុងសម័យសង្គ្រាមបានធ្វើឲ្យ ស៊ីម កើតជំងឺតេតាណូសហើយខស្សរាហ៍គ្រុនជាញឹកញាប់ ។ រៀងរាល់ពេលដែល ស៊ីម ទៅធ្វើបុណ្យនៅវត្តម្តងៗ ស៊ីម តែងតែប្រាថ្នាសុំកុំឲ្យកើតមកជួបនឹងសង្គ្រាមទៀត ។

រឿងរ៉ាវក្នុងរបបខ្មែរក្រហមហាក់នៅថ្មីៗនៅឡើយសម្រាប់ ស៊ីម ។ ការតស៊ូរបស់ ស៊ីម នៅក្នុងព្រៃលំបាកវេទនា គឺក្នុងគោលបំណងរបស់គាត់ដើម្បីឲ្យស្រុកបានសុខសប្បាយនិងបានរួមរស់ជួបជុំគ្រួសារប្រកបដោយសុភមង្គល ។ ប៉ុន្តែក្តីសង្ឃឹមទាំងនេះបានរលាយបាត់អស់ ។ ទោះបីជា ស៊ីម មិនមានបងប្អូនបង្កើតស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្តី ក៏ប៉ុន្តែបងប្អូនជីដូនមួយនិងសាច់ញាតិមួយចំនួនផ្សេងទៀតបានស្លាប់និងបាត់ខ្លួនដែរ ។

ទឹកដីកំណើតបានបន្សល់ទុកនូវរឿងរ៉ាវឈឺចាប់យ៉ាងច្រើនដែលមិនអាចឲ្យគាត់បំភ្លេចបាន ដោយមូលហេតុនេះ ស៊ីម បានសម្រេចចិត្តចាកចេញពីស្រុកកំណើត ឆ្ងាយពីញាតិសន្តានមករស់នៅទីក្រុងភ្នំពេញប្រកបមុខរបរធ្វើចំណីត្រីលក់ឲ្យបងប្អូនចាមនៅគីឡូម៉ែត្រលេខ៩ ។ រស់នៅភ្នំពេញប្រហែល១០ឆ្នាំ ស៊ីម បានផ្លាស់មករស់នៅខេត្តតាកែវ ហើយរៀបការជាមួយប្តីទីពីរ បង្កើតបានកូនស្រីម្នាក់ ។ នៅខេត្តតាកែវ ស៊ីម ប្រកបមុខរបរធ្វើស្រែចម្ការ ។ នៅឆ្នាំ២០០២ ស៊ីម បានផ្លាស់ទៅរស់នៅខេត្តពោធិ៍សាត់ដោយមានការជួយជ្រោមជ្រែងផ្នែកជីវភាពពីក្មួយខាងប្តីមុនដែលបានចែកដីស្រែឲ្យ ស៊ីម ដើម្បីរកស៊ីចិញ្ចឹមគ្រួសារ ។

**ឌី ខាំបូលី**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# គុកខ្មែរក្រហម

*(តពីលេខមុន)*

## ស្រុកមុខកំពូល

### ១៤) មន្ទីរសន្តិសុខវត្តរកាកោង

មន្ទីរសន្តិសុខវត្តរកាកោងស្ថិតនៅភូមិរកាកោង ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ។ មន្ទីរសន្តិសុខនេះ ហៅវត្តកែវមុនីជោតិ ជាកន្លែងឃុំឃាំងអ្នកទោសដែលចាប់មកពីស្រុកមុខកំពូល ខេត្តកណ្តាល ។ ព្រះវិហាររបស់វត្តនេះគឺជាមន្ទីរឃុំឃាំងនិងសួរចម្លើយអ្នកទោស ។ នៅលើកោះមរណៈ ហៅថាកោះស្នេហា គឺជាទីតាំងសម្លាប់អ្នកទោសដែលនាំមកពីមន្ទីរសន្តិសុខវត្តរកាកោង ។ ចំណែកទីតាំងខាងត្បូងព្រះវិហារវត្តរកាកោងក៏ជាទីតាំងសម្លាប់ដែរ ។

### ១៥) មន្ទីរសន្តិសុខសាលារៀនសិរីមង្គល


មន្ទីរសន្តិសុខសាលារៀនសិរីមង្គល ភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល

បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះទូទាំងប្រទេស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សាលារៀនសិរីមង្គល ត្រូវបានអង្គការកំណត់យកធ្វើជាមន្ទីរសន្តិសុខ ដើម្បីឃុំឃាំងអ្នកទោស ។ មន្ទីរសន្តិសុខមានទីតាំងនៅសាលាសិរីមង្គលស្ថិតក្នុងភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល ។

ទុយ ប៉ុន អាយុ៥៩ឆ្នាំ ជាអនុប្រធានភូមិរកាកោង ឃុំរកាកោង១ ស្រុកមុខកំពូល ធ្លាប់ជាអ្នកទោសនៅមន្ទីរសន្តិសុខសាលាសិរីមង្គលតាំងពីខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីកងសន្តិសុខស៊ើបដឹងថាគាត់ក្បត់នឹងអង្គការ ។ មិនយូរប៉ុន្មានដោយសារគាត់ជាអ្នកទោសប្រភេទធ្ងន់ ប៉ុន ត្រូវកងឈ្លបបញ្ជូនបន្តទៅកាន់មន្ទីរសន្តិសុខមួយរបស់តំបន់ផ្សេងដែលមានទីតាំងនៅក្នុងវិទ្យាល័យព្រែកពោធិ៍ (បច្ចុប្បន្នវិទ្យាល័យស្រីសន្ធរ) ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ប៉ុន និយាយថា ខ្មែរក្រហមបានចាប់អ្នកទោសមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខសាលារៀនសិរីមង្គលច្រើនណាស់ ក្នុងនោះមានតាំងពីប្រជាជនដែលកងឈ្លបធ្លាប់មានគំនុំគុំកួនពីមុនមកដែរ ។ បន្ទប់រៀននីមួយៗត្រូវកងឈ្លបដាក់អ្នកទោសពេញទាំងអស់ ។ ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ អ្នកទោសភាគច្រើនជាប្រជាជនដែលអង្គការជម្លៀសមកពីទីក្រុងភ្នំពេញ ។ ពីឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨ អ្នកទោសច្រើនជាអ្នកខុសសីលធម៌ និងកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ា ។ កម្មាភិបាលខាងភូមិភាគនិរតីបានផ្តើមសម្លាប់មនុស្សយ៉ាងប្រញឹកដៃ ។ អ្នកទោសត្រូវកងឈ្លបនាំយកទៅសម្លាប់នៅលើកោះមរណៈ ឬកោះស្នេហា និងនៅក្នុងនិងក្រៅបរិវេណវត្តរកាកោង ។ ប៉ុន បានឃើញស្នាមឈាមប្រឡាក់ពេញជញ្ជាំងព្រះវិហារ និងរណ្តៅសាកសពជាច្រើន ។ ជន ជុន អាយុ៤០ឆ្នាំ ជាប្រធានកងសេនាជនឃុំរកាកោង១ បានឲ្យដឹងថាមានរណ្តៅសាកសពជាង១០០នៅលើកោះមរណៈហៅកោះស្នេហា ។ ជុន និយាយប្រាប់ថា បច្ចុប្បន្ននេះ រណ្តៅមួយចំនួនត្រូវប្រជាជនគាស់ឡើងដើម្បីយកអដ្ឋិធាតុទៅតម្កល់ទុក ហើយរណ្តៅមួយចំនួនទៀតបានបាក់ធ្លាក់ទៅក្នុងទន្លេជារៀងរាល់ឆ្នាំ ។ ប្រជាជនដែលមកនេសាទ តាមដងទន្លេនិង

ជាយកោះ បានត្អូញត្អែរថា មងនិងអូនរបស់គាត់ ជាប់ឆ្អឹងខ្មោច ច្រើនជាងគេ ។

## ស្រុកភ្នំពេញ (អង្គស្នួល)

### ១៦) មន្ទីរសន្តិសុខព្រៃស្រែកាច់

ព្រៃស្រែកាច់ ជាព្រៃអាថ៌កំបាំងមួយស្ថិតនៅក្នុងទឹកដីភូមិស្រែអំព្រំ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ។ សព្វថ្ងៃ ទីតាំងនេះបានក្លាយទៅជាទីរហោឋានមួយដែលមានតែដើមរុក្ខជាតិតូចធំប៉ុណ្ណោះ ។ កាលពីជំនាន់ខ្មែរក្រហម មន្ទីរសន្តិសុខមួយត្រូវបានបង្កើតឡើងនៅក្នុងបរិវេណព្រៃនេះ បច្ចុប្បន្នពុំសូវមាននរណាដឹងច្បាស់អំពីប្រវត្តិនៃការកកើតរបស់មន្ទីរសន្តិសុខនេះឡើយ ។ នៅឆ្នាំ១៩៨០ ពេលដែល សែ សឿន ដើររកខសនៅក្នុងព្រៃនេះ គាត់បានប្រទះឃើញរណ្តៅសាកសពមួយចំនួន និងរោងឈើមួយដែលសង់នៅចំកណ្តាលត្រពាំងដីស្ងាត់ជ្រងំ ។ សឿន និយាយថា គាត់មិនហ៊ានចូលទៅជិតទេ ព្រោះខ្លាចខ្មោចលង ។ សឿន ដឹងថាកន្លែងនោះជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ព្រោះជីតារបស់គាត់ធ្លាប់និយាយរឿងនេះប្រាប់គាត់ ។ សឿង ឌុក អាយុ៥៧ឆ្នាំ រស់នៅភូមិស្រែអំព្រំ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល បានឮចាស់ៗដែលធ្លាប់ធ្វើការក្បែរមន្ទីរនេះនិយាយប្រាប់ថា ជារឿយៗកងសន្តិ-សុខដែលធ្វើការក្នុងមន្ទីរនោះបានបណ្តើរមនុស្សម្តងពី៣ទៅ៥នាក់ យកទៅសម្លាប់ ។ បងថ្លៃរបស់ សឿន ម្នាក់ឈ្មោះ ពៅ ធ្លាប់ជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខព្រៃស្រែកាច់ដែរ បច្ចុប្បន្នគាត់រស់នៅភូមិធ្លក ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។


មន្ទីរសន្តិសុខព្រៃស្រែកាច់ ភូមិស្រែអំព្រំ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល

អ្នកទោសមួយចំនួនត្រូវបញ្ជូនពីមន្ទីរសន្តិសុខព្រៃស្រែកាច់ ទៅកាន់មន្ទីរសន្តិសុខដ៏តឹងរ៉ឹងមួយទៀតនៅភ្នំប្រសិទ្ធ ។

### ១៧) មន្ទីរសន្តិសុខវត្តស្នួនពេជ្រ

ខ្មែរក្រហមបង្កើតមន្ទីរសន្តិសុខនេះនៅឆ្នាំ១៩៧៦ ដោយបានកំណត់យកកុដិព្រះសង្ឃ និងសាលារៀនធ្វើជាបន្ទប់ឃុំឃាំងអ្នកទោស ។ ព្រះវិហារធ្វើជារោងបាយ កុដិមួយនៅប៉ែកខាងត្បូងព្រះវិហារធ្វើជាកន្លែងស្នាក់នៅរបស់កម្មាភិបាលនិងយកបរិវេណជុំវិញវត្តជាទីតាំងសម្លាប់ ។ ជនរងគ្រោះជាច្រើនដែលជាប់នៅវត្តស្នួនពេជ្រនេះ ត្រូវខ្មែរក្រហមចាប់មកពីឃុំនានាទូទាំងស្រុកអង្គស្នួល ដែលមានជនជាតិ ចិន ចាម និង ខ្មែរ ។ ក្នុងចំណោមអ្នកទោសទាំងអស់ មានតែ


មន្ទីរសន្តិសុខវត្តស្នួនពេជ្រ ភូមិស្នួនពេជ្រ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល

ប្រជាជនជម្លៀសប៉ុណ្ណោះ ដែលត្រូវចោទប្រកាន់ថាជាខ្មែរ-ស ភ្នាក់ងារ កា.ហ្សេ.បេ, សេ.អ៊ី.អា និងមន្ត្រីរដ្ឋការដែលជាប់និន្នាការនយោបាយពីសង្គមចាស់ ។ ចំណែកអ្នកទោសជាប្រជាជនមូលដ្ឋានត្រូវចោទប្រកាន់ ពីបទធ្វើឲ្យខុសនឹងអង្គការវិន័យ ។ សែ និយាយថា ក្រុមកងឈ្លបរបស់គាត់ដែលមានសមាជិក៣០នាក់ ត្រូវកងសន្តិសុខចាប់ខ្លួនមកដាក់ឃុំឃាំងនិងវាយ ធ្វើបាបយ៉ាងខ្លាំង ដោយសារតែរើសបានត្នោតទុំមួយផ្លែកយកមកចែកគ្នាហូបប៉ុណ្ណោះ ។ សែ បន្តថា ដោយសារគ្មានអាហារហូប ពេលកំពុងធ្វើការអ្នកទោសខ្លះបានលួចបបូតត្រួយស្មៅដុះតាមភ្លឺស្រែហូប ។ មានអ្នកទោសខ្លះ បានស្លាប់នៅកន្លែងធ្វើការព្រោះតែគ្មានកម្លាំងកំហែង ។ ចំណែក ឯការស្តីបន្ទោស... ការសួរចម្លើយវិញ កងសន្តិសុខតែងតែចងជើងព្យួរអ្នកទោសនឹងខ្សែរ៉តមួយដែលភ្ជាប់ពីលើដំបូលព្រះវិហារ ហើយទាញឡើងទៅលើរួចទម្លាក់មកក្រោមវិញ ។

នៅចុងឆ្នាំ១៩៧៨ កងសន្តិសុខនាំអ្នកទោសជាច្រើនទៅសម្លាប់ចោលនៅជុំវិញបរិវេណវត្តក្នុងស្រះទឹកខាងមុខព្រះវិហារ នៅជុំវិញព្រះវិហារ និងនៅខាងលិចសាលារៀន ។ អ្នកទោសមួយចំនួនទៀតបានលួចរត់ចេញពីមន្ទីរឃុំឃាំង ដែលក្នុងចំណោមនោះមានអ្នកទោសខ្លះត្រូវកងឈ្លបចាប់យកមកវិញ ។

នៅក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខវត្តស្នួនពេជ្រមានបន្សល់ទុកនូវស្នាមឈាមប្រឡាក់ជិតជាមពេញនៅលើជញ្ជាំងព្រះវិហារនិងឧបករណ៍ធ្វើទារុណកម្មជាច្រើន ។ នៅឆ្នាំ១៩៨២ ឧបករណ៍ទាំងនេះត្រូវបានដឹកជញ្ជូនមកទីក្រុងភ្នំពេញ ហើយរណ្តៅមួយចំនួនត្រូវប្រជាជនគាស់ឡើងដើម្បីយកអដ្ឋិធាតុមកតម្កល់ទុកនៅក្នុងបរិវេណវត្តស្នួនពេជ្រ ។

## ទិន្នន័យសង្ខេប

**ទីតាំង** : មន្ទីរសន្តិសុខវត្តស្នួនពេជ្រ បង្កើតឡើងនៅឆ្នាំ១៩៧៦ ស្ថិតនៅភូមិស្នួនពេជ្រ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ។

**ស្ថិតិ** : អ្នកទោសនៅមន្ទីរសន្តិសុខនេះជាប្រជាជនជម្លៀសត្រូវបានចោទថាជាភ្នាក់ងារ កា.ហ្សេ.បេ, សេ.អ៊ី.អា. និងប្រជាជនមូលដ្ឋានដែលបានប្រព្រឹត្តខុសអង្គការវិន័យ ។ ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះមាននៅសេសសល់សម្ភារធ្វើទារុណ-កម្មជាច្រើនប្រភេទ ដែលក្រោយមកត្រូវបានដឹកមកកាន់ទីក្រុងភ្នំពេញ ។

## ស្រុកពញាឮ

### ១៨) មន្ទីរសន្តិសុខវត្តកាសពព្រះវិហារ

មន្ទីរសន្តិសុខវត្តកាសពព្រះវិហារ ស្ថិតនៅក្នុងបរិវេណវត្តកាសពព្រះវិហារ ។ ស៊ឹម ព្រីង អាយុ៥៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងស្រុកពញាឮ ខេត្តកណ្តាល បាននិយាយថា សាលាបុណ្យនិងសាលាឆាន់នៅក្នុងបរិវេណវត្តត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។ អ្នកទោសត្រូវបានបញ្ជូនមកកាន់មន្ទីរសន្តិសុខនេះជាបន្តបន្ទាប់


មន្ទីរសន្តិសុខវត្តកាសពព្រះវិហារ ភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល

និងសួរចម្លើយជារៀងរាល់ថ្ងៃ ។ ប្រសិនជាអ្នកទោសណាម្នាក់ស្លាប់ដោយសារការសួរចម្លើយ ឬស្លាប់ដោយសារការអត់អាហារ កងឈ្លបនឹងអូសយកទៅកប់នៅខាងលិចមន្ទីរ ។ អ្នកទោសរាប់រយនាក់ត្រូវកងឈ្លបបញ្ជូនមកឃុំឃាំងជាហូរហែ ហើយក្នុងចំណោមនោះ មានមួយចំនួនត្រូវកងសន្តិសុខបញ្ជូនបន្តទៅកាន់ភ្នំត្រ័យត្រឹង្សនិងភ្នំប្រសិទ្ធិបន្ទាប់ពីបានសួរចម្លើយ ។ ស៊ីម ព្រឹង ជាអតីតអ្នកទោសរបស់មន្ទីរនេះ ហើយមានតែគាត់ម្នាក់គត់ដែលបានរួចជីវិតពីការសម្លាប់របស់ខ្មែរក្រហម ព្រោះគាត់បានចេញទៅធ្វើចម្ការចំពេលដែលអ្នកទោសទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ ។


មន្ទីរសន្តិសុខចម្ការស្វាយ ភូមិតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល

ឆ្នាំ១៩៧៩ អឿ វ៉ិក អាយុ៧៩ឆ្នាំ សព្វថ្ងៃរស់នៅឃុំផ្សារដែក ស្រុកពញាឮ បានឃើញឈាមជិតដាមជាប់នឹងជញ្ជាំងនិងលើសសរមន្ទីរឃុំឃាំង ។ វ៉ិក បានប្រាប់ថា មន្ទីរឃុំឃាំងនេះមានទទឹងប្រវែង ១៥ម៉ែត្រ និងបណ្តោយ ២៨ម៉ែត្រ ។

**ទិន្នន័យសង្ខេប**

***ទីតាំង*** ៖ វត្តកាសពព្រះវិហារស្ថិតនៅក្នុងភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល ។

***ស្ថិតិ*** ៖ សាលាឆាន់និងសាលាបុណ្យត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលកងសន្តិសុខចាប់មកពីសហករណ៍ផ្សេងៗ ។ អ្នកទោសត្រូវឆ្លងកាត់ការសួរចម្លើយសិន មុននឹងយកទៅសម្លាប់ ឬបញ្ជូនទៅកាន់ភ្នំប្រសិទ្ធិនិងភ្នំត្រ័យត្រឹង្ស ។

## ១៩) មន្ទីរសន្តិសុខចម្ការស្វាយ

ចម្ការស្វាយជាមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខពីរទៀតគឺមន្ទីរសន្តិសុខនៅវត្តប្រសិទ្ធិក្រោម និងមន្ទីរសន្តិសុខនៅខាងត្បូងវត្តត្រ័យត្រឹង្ស ។ ឈ្មោក មាស អាយុ៦៣ឆ្នាំ បច្ចុប្បន្នជាប្រធានភូមិ បានហៅមន្ទីរសន្តិសុខទាំងបីនេះថាជា "គុកអស់ជីវិត" ។ មាស ជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខទាំងបីនេះ ។ ចំណែកមិត្តភក្តិរបស់គាត់ម្នាក់ទៀតឈ្មោះ ខាន់ ក៏ធ្លាប់ជាប់គុកដែរ ហើយបច្ចុប្បន្នប្រកបរបរជាជាងជួសជុលម៉ូតូ ។ មាស បន្តថា ចម្ការស្វាយមិនត្រឹមតែជាមន្ទីរសន្តិសុខប៉ុណ្ណោះទេ ថែមទាំងជាទីតាំងសម្លាប់មនុស្សទៀតផង ។ មាស បានរៀបរាប់ពីទិដ្ឋភាពដែលគាត់ធ្លាប់ជួបប្រទះថា ថ្ងៃមួយពេលគាត់កំពុងដើរគាស់ឬសឈើនៅលើភ្នំយកមកធ្វើថ្នាំសម្លាប់សត្វល្អិត ស្រាប់តែគាត់ឮសម្រែករបស់អ្នកទោសស្រែកឲ្យជួយ ។ មាស ក៏ប្រញាប់ស្ទុះទៅរកមើល ប៉ុន្តែត្រូវកងឈ្លបប្រចាំមន្ទីរភ្ជង់កាំភ្លើង ហើយថែមទាំងចាប់បញ្ជូនទៅឲ្យអ្នកគ្រប់គ្រងរបស់គាត់ព្រមានទៀតផង ។ ចាប់តាំងពីថ្ងៃនោះមក ខ្មែរក្រហមលែងអនុញ្ញាតឲ្យ មាស ទៅរកថ្នាំទៀតហើយ ។ មាស បន្តថា ជនរងគ្រោះមិនកំណត់ថាខុសអ្វីទេ គឺកំណត់ត្រឹមតែថាប្រជាជនទាំងនោះធ្លាប់ទទួលការស្អប់ខ្ពើមពីខ្មែរក្រហម ។ អ្នកទោសភាគច្រើនសុទ្ធតែត្រូវចោទប្រកាន់ថាជាខ្មាំង អ្នកខ្ជិលច្រអូស និងអ្នកខុសសីលធម៌ ។ អ្នកទោសត្រូវកងឈ្លបបញ្ជូនពីឃុំនានាមកកាន់មន្ទីរសន្តិសុខទាំងបីកន្លែងដើម្បីអប់រំនិងបង្ខំឲ្យធ្វើពលកម្មហួសប្រមាណ ។ អ្នកទោសទាំងអស់ត្រូវបានចាត់តាំងឲ្យជីកស្រះមួយនៅជើងភ្នំត្រ័យត្រឹង្សដែលមានសុទ្ធតែថ្មភ្នំទំហំធំៗ ហើយឧបករណ៍សម្រាប់ជីកមានតែញញួរប៉ុណ្ណោះ ។ ពេលសួរចម្លើយម្តងៗអ្នកទោសត្រូវកងសន្តិសុខចងជើងចងដៃភ្ជាប់នឹងខ្សែមួយ ហើយទាញចុះទាញឡើងទម្លាក់ក្នុងអាងទឹក ។ ជួនកាលអ្នកទោសត្រូវសន្លប់បាត់ស្មារតីដោយសារឈ្លក់ទឹកនិងជួនកាល

ត្រូវស្លាប់តែម្តង ។ ចំណែកការធ្វើទារុណកម្មមួយបែបទៀតគឺ កងឈ្លបបញ្ជាឲ្យឆ្កែដែលចិញ្ចឹមខាំហែកសាច់អ្នកទោស បណ្តាល ឲ្យអ្នកទោសជាច្រើននាក់ត្រូវស្លាប់ក្រោមការធ្វើទណ្ឌកម្មបែប នេះ ។ ខាន់ បានឲ្យដឹងថា មានអ្នកទោសប្រហែល៧០០០នាក់ បានស្លាប់នៅក្នុងបរិវេណចម្ការស្វាយនេះ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : ចម្ការស្វាយ ស្ថិតនៅភូមិតាពេជ្រ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ។

**ស្ថិតិ** : មន្ទីរសន្តិសុខចម្ការស្វាយជាសាខារបស់មន្ទីរសន្តិ-សុខវត្តប្រសិទ្ធិក្រោមនិងមន្ទីរសន្តិសុខ នៅខាងត្បូងវត្តត្រ័យ ត្រិង្ស ។ អ្នកទោសជាច្រើននាក់ត្រូវកងឈ្លបបញ្ជូនមកកាន់មន្ទីរ នេះដើម្បីសួរចម្លើយ សម្លាប់ និងបញ្ជូនបន្តទៅកាន់មន្ទីរសន្តិសុខ ទាំងពីរ ។ ជនរងគ្រោះប្រមាណ ៧០០០នាក់ត្រូវបានសម្លាប់ និងស្លាប់នៅលើទីតាំងចម្ការស្វាយនេះ ។ ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខចម្ការស្វាយមានបន្សល់ទុកខ្មោះឃ្មោងមួយចំនួនធំ ។

## ខេត្តកោះកុង

## ស្រុកស្មាច់មានជ័យ

### ២០) វត្តជោតញ្ញាណ

វត្តជោតញ្ញាណស្ថិតនៅភូមិបឹងយុនឆាង ឃុំស្មាច់មានជ័យ ស្រុកស្មាច់មានជ័យ ។ ជោតញ្ញាណ គឺជាឈ្មោះដែលសម្តេច សង្ឃរាជ ជួន ណាត សព្វព្រះទ័យដាក់ឈ្មោះឲ្យ ។ វត្តនេះកសាង ឡើងដោយសេនាប្រមុខ លន់ នល់ និងពលទាហានរបស់គាត់នៅ ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ កុដិធំៗចំនួនបីនិងសាលារៀនមួយ ខ្នងត្រូវខ្មែរក្រហមយកធ្វើជាកន្លែងសម្រាប់ឃុំឃាំងអ្នកទោស ។

ព្រះតេជគុណ លីន ជីន ជាព្រះសង្ឃមកពីកម្ពុជាក្រោម ដែលបច្ចុប្បន្នជាចៅអធិការគ្រៀមនៅវត្តជោតញ្ញាណ បានមាន ពុទ្ធដីកាថា ក្រោយឆ្នាំ១៩៧៩ វត្តនេះត្រូវកងទ័ពវៀតណាម



វត្តជោតញ្ញាណ ភូមិបឹងយុនឆាង ឃុំស្មាច់មានជ័យ ស្រុកស្មាច់មានជ័យ

យកធ្វើជាមូលដ្ឋានទ័ពនិងមន្ទីរពេទ្យ ។ ព្រះសង្ឃនិងពុទ្ធបរិស័ទ នៅក្នុងវត្តភាគច្រើន និមន្តមកពីតំបន់ផ្សេងៗ ដូចជាខេត្តកំពតនិង ខេត្តតាកែវជាដើម ។ អ៊ឹ ខ្មែកហ៊ាន អាយុ៥៦ឆ្នាំ បច្ចុប្បន្នរស់នៅ ស្រុកស្មាច់មានជ័យបាននិយាយថា នៅឆ្នាំ១៩៨៨ គាត់បាន ប្រទះឃើញមានស្នាមឈាមប្រឡាក់នៅតាមជញ្ជាំងព្រះវិហារ និងកម្រាលឥដ្ឋប៉ែកខាងក្រោយបល្ល័ង្កព្រះនៅឡើយ ។ ក្រោយ មកទើបប្រជាជនដុសលាងសម្អាតចេញអស់ ។

**ផេង ពង្សរ៉ាស៊ី**

# ជីវិតជាកងទ័ពទទួលបានអ្វីខ្លះ?

ម៉ម សារ៉ន រស់នៅភូមិត្រពាំងក្តី ឃុំតាកែន ស្រុកឈូក ខេត្តកំពត ។ ក្រឡេកមើលអតីតកាលរបស់ខ្លួន ម៉ម សារ៉ន មានការសោកស្តាយជាខ្លាំង ដែលគាត់បានចូលបដិវត្តន៍អស់រយៈពេលជាច្រើនឆ្នាំ ដោយមិនគិតដល់ពីសុខទុក្ខរបស់ឪពុកម្តាយសាច់ញាតិបងប្អូនដែលនៅសមរភូមិក្រោយ ហើយនៅទីបំផុតគាត់គ្មានទទួលបានប្រយោជន៍អ្វីបន្តិចពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ខាងក្រោមនេះគឺជាការរៀបរាប់ពីជីវិតរបស់ ម៉ម សារ៉ន ៖


ម៉ម សារ៉ន

ខ្ញុំមិនដែលនឹកនាចង់ចូលបម្រើបដិវត្តន៍ខ្មែរក្រហមឡើយ ហើយក៏មិនដែលនឹកនាចង់រស់នៅបែកពីឪពុកម្តាយរបស់ខ្ញុំដែរ ប៉ុន្តែដោយសារតែការចាត់តាំងពីអង្គការ ខ្ញុំត្រូវបង្ខំចិត្តចូលធ្វើជាកងទ័ពខ្មែរក្រហមទាំងវ័យក្មេង ។ មេឃុំលាយបូរ ឈ្មោះ ហួល ជាអ្នកបញ្ជូនខ្ញុំទៅដាក់នៅ“កងតា១៥” ឬហៅថា “កងតាម៉ុក” ។ នៅក្នុងឆ្នាំ១៩៧១ ខ្ញុំចាប់ផ្តើមធ្វើជាកុមារឈានមុខនៅក្នុងមន្ទីរ១៦០ ដែលមន្ទីរនេះមិនស្ថិតនៅក្នុងភូមិទេ គឺនៅម្តុំភ្នំម៉ងមានទីតាំងជាប់នឹងព្រៃក្តួច ស្ថិតនៅជាប់ព្រំប្រទល់ខេត្តតាកែវ និង កំពត ជាទីតាំងធំមួយរបស់ខ្មែរក្រហមដែលមាន ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ជាមេដឹកនាំ ។ ទីតាំងនេះ មនុស្សទូទៅមិនអាចចូលក្នុងបានទេប្រសិនបើគ្មានការអនុញ្ញាត ។ ខ្ញុំមានតួនាទីត្រឹមតែជាអ្នកយាមនៅក្នុងបរិវេណមន្ទីរនោះប៉ុណ្ណោះ ។

បីខែក្រោយមក ខ្ញុំនិងកុមារចំនួន១២នាក់ ត្រូវអង្គការចាត់ឲ្យទៅរៀនផ្នែកនយោបាយខ្មែរក្រហម ។ ខ្ញុំនៅក្នុងកងកុមារសិល្បៈតំបន់១៣ ក្រោមការគ្រប់គ្រងរបស់លោកគ្រូ វ៉ាន់ ហន នៅក្នុងទំនប់ពិសេសរបស់តាអ៊ី ។ ខ្ញុំដើរសម្តែងសិល្បៈកម្សាន្តតាមតំបន់រំដោះនានា ដូចជាភូមិអន្លង់ថ្ម ភូមិត្រពាំងថ្ម និងភូមិកោះក្អែក ។ ខ្ញុំនៅចាំបានថា ខ្ញុំជាតួអង្គនៅក្នុងរឿងដែលភាគច្រើនសុទ្ធតែនិយាយពាក់ព័ន្ធពីរឿងនយោបាយ និងទាក់ទងនឹងការវាយប្រយុទ្ធគ្នារវាងទាហានលន់នល់និងទាហានខ្មែរក្រហម ។ នៅក្នុងសាច់រឿងតម្រូវឲ្យមានការដេរប្រមាថមើលងាយ មើលថោកទាហានលន់នល់ ។

ក្រោយមក អង្គការបានបញ្ជូនពួកខ្ញុំទៅវែកបាយស្ទុកទៅឲ្យកងទ័ពខ្មែរនៅសមរភូមិមុខ ។

នៅក្នុងអំឡុងឆ្នាំ១៩៧៣និងឆ្នាំ១៩៧៤ ខ្ញុំមមាញឹកក្នុងការវែកបាយស្ទុកជូនកងទ័ពខ្មែរក្រហម ។ បន្ទាប់មកទៀត ខ្ញុំត្រូវផ្លាស់ទីកន្លែងទៅឈរយាមនៅថ្នល់បំបែកគុស ដើម្បីឆែកឆេរប្រជាជន“១៧មេសា”ក្នុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ ។ អ៊ំឃួន ជាប្រធានឈ្លបនៅឃុំរំចង់ គាត់ទទួលបន្ទុកមើលការខុសត្រូវឆែកឆេរសម្ភារផ្សេងៗរបស់ប្រជាជននិងឃាត់ទុករថយន្តនៅថ្នល់បំបែកគុសនេះ ។ ខ្ញុំត្រូវត្រួតពិនិត្យមើលប្រជាជនដើម្បីតម្រង់ទិសពួកគេឲ្យដើរទៅតាមផ្លូវជនបទ ។ ប្រសិនបើប្រជាជនមានយានជំនិះផ្ទាល់ខ្លួន ខ្ញុំត្រូវដកហូតយកទៅឲ្យ អ៊ំឃួន ។ លើសពីនេះទៀត ខ្ញុំក៏ត្រូវត្រួតពិនិត្យអាវុធជាតិផ្ទុះ និងឆែកឆេរអីវ៉ាន់នៅក្នុងកាបូបរបស់ប្រជាជនទៀត ។

នៅក្នុងឆ្នាំ១៩៧៦ កុមារខ្លះដោយនឹកឪពុកម្តាយពេកក៏នាំគ្នារំសាយកងរត់ទៅផ្ទះសម្ងំទៅតាមភូមិឃុំរៀងៗខ្លួន ម្យ៉ាងទៀត គិតថាអង្គការវាយរំដោះប្រទេសបានជោគជ័យហើយ ។ ផ្ទុយទៅវិញ កុមារទាំងនោះរួមទាំងខ្ញុំផង ត្រូវអង្គការចាប់ត្រឡប់មកវិញ ហើយបញ្ជូនទៅធ្វើការនៅផ្ទះតាម៉ុក ឃុំលាយបូរ ខេត្តតាកែវ ដែលផ្ទះនោះសង់អំពីថ្ម មានទីតាំងនៅកណ្តាលបឹងមួយនៅក្នុងខេត្តតាកែវ ។ ខ្ញុំចាំថា តាម៉ុក មានប្រពន្ធនិងកូនជាច្រើននាក់ ។ កូនស្រីគាត់ម្នាក់មានឈ្មោះ ភាញ ។

នៅទីនោះខ្ញុំគឺជាអ្នកបើកគោយន្តបម្រើការងារក្នុងឃុំទាំងអស់ ។ នៅពេលឃុំនីមួយៗត្រូវភ្ជួររាស់សហករណ៍ទាំងនោះត្រូវយកកម្លាំងកុមារឈានមុខទៅជួយចុះភ្ជួរបន្ថែម ។ ជាទូទៅកងកម្លាំងរបស់យើងចុះជួយតាមសហករណ៍ផ្សេងៗ ។ តាម៉ុក

ហៅតា១៥ យកចិត្តទុកដាក់ខ្លាំងក្នុងការកសាងតំបន់ប៉ែកនិរតី ដោយយកភូមិធ្នង់រលើងក្នុងឃុំលាយបូរ ធ្វើជាឃុំគំរូដល់ឃុំដទៃទៀត ។ កម្លាំងនៅក្នុងឃុំទាំងពីរនេះត្រូវ តាម៉ុក យកទៅអប់រំនយោបាយខ្មែរក្រហម ហើយថែមទាំងផ្តល់ម្ហូបម្ហាបរិបូណ៌ទៀតផង ដោយក្នុងមួយថ្ងៃទទួលទានបាយបីពេល និងអាហារបំប៉នដូចជាសាច់ជ្រូកសាច់គោប្រចាំសប្តាហ៍ថែមទៀត ។ នៅក្នុងអំឡុងពេលនេះ ខ្ញុំមិនដែលឃើញមានការអត់ឃ្លាន ឬក៏ការកាប់សម្លាប់មនុស្សអ្វីឡើយ ។

នៅចុងឆ្នាំ១៩៧៧ អង្គការបញ្ជូនកងកុមារទាំងកង ធ្វើដំណើរតាមរថភ្លើង ដើម្បីទៅធ្វើការនៅភូមិភាគពាយ័ព្យនៅក្នុងអគ្គភាពរបស់ បងស៊ឹម ជាមេឃុំ និង បងឈួន ជាចៅហ្វាយស្រុកនៅទីនោះ ។

ចំណែកឯអតីតប្រធានភូមិភាគ មានឈ្មោះថា ញឹម ត្រូវអង្គការចោទថា ក្បត់ទៅចុះចូលជាមួយកងទ័ពវៀត-ណាម ។ ដំបូងខ្ញុំធ្វើជានិរសារខ្មែរក្រហមនៅក្នុងឃុំ ។ បន្ទាប់មក ខ្ញុំបន្តការងាររបស់ខ្ញុំនៅក្នុងស្រុក ហើយចេញពីស្រុកទៅធ្វើការនៅទន្លេសាប ។ ខ្ញុំវាយប្រយុទ្ធនៅទន្លេសាបអស់រយៈពេលបីខែ រហូតដល់ចុងឆ្នាំ១៩៧៨ ទើបកងទ័ពវៀត-ណាមវាយចូលរំដោះនៅតំបន់នោះ ។ ខ្ញុំដកខ្លួនថយមកវាយនៅជុំវិញខេត្តបាត់ដំបងវិញដូចជា ស្ទឹង, ស្តៅ, លាជ, ផ្ដុ, កោះចន្ទោ និង មោង ជាដើម ។



កងទ័ពខ្មែរក្រហមក្រោយឆ្នាំ១៩៧៩

នៅពេលដែលកងទ័ពវៀតណាមវាយសម្រុកចូលក្នុងប្រទេស ខ្ញុំកំពុងធ្វើជាកងទ័ពនៅស្រុកសង្កែស្ថិតនៅខាងជើងផ្សារបាត់ដំបង ។ កងទ័ពខាងខ្មែរក្រហមបានបាក់ទ័ពរត់មកនៅម្តុំផ្លូវជាតិលេខ១០ ម្តុំភ្នំវាយចាប ម្តុំស្ទឹងស្ពានដងទង់ និងនៅទីបញ្ចប់ ដកទ័ពមកបោះទីតាំងនៅខាងកោះចន្ទោវិញ ។ ទៅដល់ទីនោះ ទើបខ្ញុំឃើញផ្លូវខ្មោចទាំងរណ្តៅៗ ។ ខ្ញុំគ្រាន់តែដឹងថា វិន័យកងទ័ពមានភាពតឹងរ៉ឹងណាស់ ព្រោះខ្ញុំមិនដែលបានត្រឡប់មកលេងឪពុកម្តាយបងប្អូនទេ ។ មកទល់សព្វថ្ងៃទើបខ្ញុំយល់ឃើញថា នេះជាល្បិចកលរបស់ខ្មែរក្រហមដើម្បីគ្រប់គ្រងកងទ័ព ។ ប្រសិនបើកងទ័ពដែលនៅសមរភូមិមុខ បានមកលេងស្រុកភូមិនោះ ពួកនេះពិតជាបានដឹងពីគោលនយោបាយដ៏សាហាវឃោរឃៅរបស់អង្គការ តាមរយៈស្ថានភាពរស់នៅដ៏លំបាកវេទនារបស់ឪពុកម្តាយ សាច់ញាតិ បងប្អូន និងប្រជាជនទាំងអស់នៅក្នុងភូមិផ្ទាល់តែម្តង ។ នៅអំឡុងពេលខ្ញុំធ្វើទ័ព ខ្ញុំមិនដែលស្គាល់រសជាតិហូបបបរឡើយ ប៉ុន្តែបែរជាប្រជាជននៅក្នុងភូមិព្រមទាំងឪពុកម្តាយ បងប្អូនរបស់ខ្ញុំ ហូបតែបបររាវកក្លូក ។

ខ្ញុំជាកងទ័ពខ្មែរក្រហមមួយរូបមានតួនាទីបម្រើជាតិការពារជាតិ ប៉ុន្តែបែរជាអ្នកគ្រប់គ្រងនៅសម័យនោះនាំគ្នាបង្វិនបង្ហោចជាតិឯងទៅវិញ ។

ក្រោយរបបខ្មែរក្រហមបញ្ចប់ទៅ ខ្ញុំមិនបានវិលត្រឡប់មកភូមិកំណើតរបស់ខ្ញុំវិញភ្លាមឡើយ ។ ខ្ញុំនៅតែតស៊ូជាមួយកងទ័ពខ្មែរក្រហមទៀត ពីព្រោះខ្ញុំមិនដាច់អាល័យពីមិត្តភក្តិរបស់ខ្ញុំ ។ ម្យ៉ាងទៀត ដោយសារខ្ញុំបែកចេញពីឪពុកម្តាយ បងប្អូនរបស់ខ្ញុំជាយូរខែឆ្នាំ ដូច្នេះខ្ញុំមិនសូវនឹកនាឡើយ ។ ពេលទាហានខ្មែរក្រហមបាក់ទ័ព កូនទាហានដែលនៅសេសសល់គ្រាន់តែទៅតាមគេឯងតែប៉ុណ្ណោះ ។ ពេលនោះខ្ញុំមិនចង់ត្រឡប់មកនៅក្នុងភូមិកំណើតវិញឡើយ ពីព្រោះអង្គការប្រាប់ថា ប្រសិនបើយើងត្រឡប់ទៅវិញ យើងនឹងជាប់ខ្នោះច្រវាក់ ឬនឹងត្រូវគេសម្លាប់ជាមិនខាន ។ ខ្ញុំយល់ឃើញថា ប្រសិនបើខ្ញុំទៅក៏ស្លាប់ ខ្ញុំនៅក៏ស្លាប់

ព្រោះជីវិតកងទ័ពមិនទៀងទាត់ ។

នៅពេលរាជរដ្ឋាភិបាលកម្ពុជាចាប់ផ្ដើមធ្វើសមាហរណកម្មជាមួយកងទ័ពខ្មែរក្រហម ខ្ញុំក៏ត្រឡប់មករស់នៅស្រុកភូមិរបស់ខ្ញុំវិញ ។ ពេលឃើញដំបូង ម្ដាយរបស់ខ្ញុំស្ទើរតែចំណាំមិនបានថា ខ្ញុំគឺជាកូនប្រុសរបស់គាត់ ពីព្រោះខ្ញុំបែកពីគាត់ច្រើនឆ្នាំពេក ។ ខ្ញុំខំពលីកម្មអស់ពីកម្លាំងកាយចិត្តជូនអង្គការ ប៉ុន្តែទីបញ្ចប់ ខ្ញុំគ្មានទទួលបានផលអ្វីទាំងអស់ ទម្រាំតែខ្ញុំភ្ញាក់ខ្លួនវាហួសពេលទៅហើយ ។

ប្រសិនបើប្រជាជនដឹងជាមុនថា ការដើរតាមគន្លងនយោបាយខ្មែរក្រហមទាំងនេះជាផ្លូវមិនល្អនោះ គ្មាននរណាម្នាក់ចង់ចូលបម្រើបដិវត្តន៍ខ្មែរក្រហមឡើយ ។

ខ្ញុំមិនដែលនិយាយរឿងរ៉ាវពីសម័យខ្មែរក្រហមប្រាប់កូនចៅរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំខំស្វាហ៍ផ្ដាំកូន ថាជំនាន់ណាក៏ដូចជំនាន់ណាដែរ ជីវិតទាហានមិនស្រួលឡើយ ។ តាមបទពិសោធន៍របស់ខ្ញុំផ្ទាល់ ខ្ញុំបម្រើការងារជាកងទ័ពទាំងខាងខ្មែរក្រហម និងខាងរាជរដ្ឋាភិបាលកម្ពុជាអស់ប្រមាណជាង៣០ឆ្នាំហើយ ទីបញ្ចប់ខ្ញុំគ្មានបានផលប្រយោជន៍អ្វីទាំងអស់ ។

ទោះជាយ៉ាងណា ខ្ញុំយល់ថារាជរដ្ឋាភិបាលកម្ពុជាត្រូវមានតួនាទីចងក្រងប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យឲ្យក្មេងជំនាន់ក្រោយបានដឹង ហើយប្រទេសខ្មែរគួរតែមានប្រព័ន្ធតុលាការសុក្រឹតមួយក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីជាគំរូនិងពង្រឹងប្រព័ន្ធច្បាប់នៅក្នុងប្រទេសឲ្យកាន់តែមានប្រសិទ្ធភាព ។

**នន ឧត្តតារា**

# និរសារតំបន់២៥

សេក សារ៉ុន ជាកូនកសិករថ្នាក់កណ្ដាលម្នាក់រៀនត្រឹមថ្នាក់ទី១០(ទី៣បច្ចុប្បន្ន) ។ សារ៉ុន ត្រឹមតែចេះអាននិងសរសេរអក្សរតិចតួចប៉ុណ្ណោះ ។ ក្រោយមកបានក្លាយនិរសាររបស់ សេក សាត ហៅប្រាក់ នៅតំបន់២៥ក្នុងភូមិភាគនិរតីចាប់តាំងពីឆ្នាំ១៩៧៥រហូតដល់អង្គការចាប់ខ្លួននិងបញ្ជូនទៅដាក់គុកជ្រៃអូរញ្ញៅក្នុងឆ្នាំ១៩៧៨ ។

សារ៉ុន មានស្រុកកំណើតភូមិតាដោល ឃុំសំព័រ ស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង ។ ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ខេត្តនេះទទួលរងនូវការទម្លាក់គ្រាប់យ៉ាងខ្លាំងពីសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិក ធ្វើឲ្យប្រជាជនកម្ពុជាបាត់បង់ជីវិតអស់រាប់ម៉ឺននាក់ ។ កុមារដែលពេញវ័យសិក្សាបានបាត់បង់ឱកាសរៀនសូត្រត្រូវរត់គេចពីកន្លែងមួយទៅកន្លែងមួយ ។ សារ៉ុន អស់សង្ឃឹមយ៉ាងខ្លាំងចំពោះស្ថានភាពស្រុកទេសបែបនេះ ។

ក្នុងឆ្នាំដដែលសភាពការណ៍ប្រទេសកម្ពុជាកាន់តែធ្លាក់ដុនដាបទៅៗ ។ វត្តមានកងទ័ពវៀតកុងរាប់ពាន់នាក់រស់នៅលើទឹកដីកម្ពុជា ។ កងទ័ពទាំងនោះ មានឯកសណ្ឋានពណ៌ខៀវកាន់អាវុធគ្រប់ដៃដើរជាជួរៗពី៤០០ទៅ៥០០នាក់ក្នុងមួយយប់ៗ ។ តាមផ្ទះរបស់អ្នកភូមិគ្រប់គ្នាត្រូវបានដាក់ពង្រាយដោយកងទ័ពវៀតកុងក្រោមលេសថា ជួយការពារសុវត្ថិភាពប្រជាជន ។ ផ្ទះអ៊ំមាមីងរបស់ សារ៉ុន ក៏ត្រូវកងទ័ពវៀតកុងស្នាក់នៅជាមួយ ប៉ុន្តែកងទ័ពទាំងនោះពុំបានធ្វើទុក្ខបុកម្នេញដល់អ្នកភូមិដោយប្រការណាមួយឡើយ ។ ផ្ទុយទៅវិញ ធ្វើឲ្យអ្នកភូមិស្រឡាញ់រាប់អានគាំទ្រ ថែមទាំងជួយទំនុកបម្រុងដល់កងទ័ពទាំងនោះដើម្បីធ្វើការវាយបកលើទាហានលន់នល់វិញ ។ ចាប់តាំងពីពេលនោះមកភូមិរបស់ សារ៉ុន ក្លាយជាតំបន់រំដោះរបស់ខ្មែរក្រហមដោយស្វ័យប្រវត្តិ ។ ដោយសារមូលហេតុនេះ ទើបស្រុកកំពង់ពោធិ៍និងស្រុកចន្ទ្រាទទួលរងនូវការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងពីសំណាក់កងទ័ពអាកាសរបស់លន់នល់ ។

ឆ្នាំ១៩៧៣-៧៤ សារ៉ុន លែងឃើញវត្តមានកងទ័ពវៀតកុងនៅក្នុងភូមិរបស់គាត់ហើយ ប៉ុន្តែបែរជាឃើញកងទ័ពខ្មែរក្រហមរាប់ពាន់នាក់ធ្វើដំណើរឆ្លងកាត់ភូមិរបស់គាត់ទៅវិញ ។ យុវជនយុវនារីក្មេងៗជាច្រើនត្រូវបានលើកទឹកចិត្តឲ្យចូលបម្រើបដិវត្តន៍ដើម្បីវាយចក្រពត្តិអាមេរិក រំដោះមាតុភូមិ និងរំដោះវណ្ណៈកម្មករកសិករចេញពីរបបមូលធន ។

រយៈពេលបីបួនខែបន្ទាប់ពីទទួលជ័យជម្នះថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ សារ៉ុន ត្រូវឪពុកមាខាងម្ដាយឈ្មោះ តាប្រាក់ យក

គាត់ពីស្រុកកំពង់រោទ៍ទៅរស់ជាមួយគាត់នៅតំបន់២៥ ដែលមានទីតាំងនៅទីរួមស្រុកកោះធំ ខេត្តកណ្តាល ។

សារ៉ុន គឺជាក្មេងដែលមានសំណាងជាងគេក្នុងចំណោមក្មេងជាច្រើននាក់នៅក្នុងភូមិ គាត់បានក្លាយជានិរសារម្នាក់ដោយពុំបានឆ្លងកាត់ជីវិតតស៊ូបដិវត្តន៍លំបាកលំបិនដូចក្មេងៗឯទៀតឡើយ ។ ភារកិច្ចដំបូងរបស់គាត់នៅមន្ទីរតំបន់២៥ គឺធ្វើជាកងការពារ និងជាអ្នកបើករថយន្តឲ្យ តាប្រាក់ ។ នៅមន្ទីរតំបន់២៥ សារ៉ុន ឃើញមានតែបុគ្គលិកជាង១០នាក់ជាអ្នកធ្វើបញ្ជីឯកសារផ្សេងៗ ។ ក្នុងនោះមានប្រធានមន្ទីរឈ្មោះ ខេម៉ារា មានស្រុកកំណើតនៅស្រុកព្រះស្តេច ខេត្តព្រៃវែង ។ ជាអកុសល ក្នុងឆ្នាំ១៩៧៨ គាត់ត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅគុកទួលស្លែង ។

ចុងឆ្នាំ១៩៧៥ សារ៉ុន ត្រូវបានបញ្ជូនឲ្យទៅហាត់ក្បួនយុទ្ធសាស្ត្ររយៈពេលបីខែជាមួយយុវជនជាង១០០នាក់នៅស្រុកកោះធំដើម្បីត្រៀមប្រយុទ្ធនៅព្រំដែនវៀតណាម ។ បន្ទាប់ពីចប់វគ្គហ្វឹកហ្វឺន សារ៉ុន ពុំត្រូវបានបញ្ជូនទៅព្រំដែនដូចយុវជនឯទៀតទេ គាត់ត្រូវបានចាត់តាំងជាកងការពារនិងជានិរសាររបស់ តាប្រាក់ ដដែល ។ តាប្រាក់ បានប្រគល់ម៉ូតូម៉ាកសេអ៊ិលមួយគ្រឿងឲ្យគាត់សម្រាប់ជិះរត់សំបុត្រពីស្រុកមួយទៅស្រុកមួយ នៅក្នុងភូមិភាគនិរតី ។ មានពេលខ្លះ សារ៉ុន ត្រូវចុះតាមការដ្ឋានជាមួយ តាប្រាក់ ដើម្បីពិនិត្យមើលប្រជាជនធ្វើស្រែ លើកទំនប់ជីកប្រឡាយ និងអមដំណើរ តាប្រាក់ ទៅចូលរួមប្រជុំនៅមន្ទីរភូមិភាគនិរតី និងទៅព្រំដែនវៀតណាមដើម្បីលើកទឹកចិត្តកងទ័ពឲ្យមានជំហររឹងប៉ឹងក្នុងការប្រយុទ្ធជាមួយកងទ័ពវៀតណាម ។

ភារកិច្ចរបស់ សារ៉ុន គឺគ្រាន់តែយកសំបុត្រទៅឲ្យលេខាស្រុកដោយផ្ទាល់ដៃនិងវិលត្រឡប់មកវិញដោយពុំមានការបង្អែបង្អង់តាមផ្លូវឡើយ ។ នៅថ្ងៃមួយ សារ៉ុន បានជិះម៉ូតូយកសំបុត្រទៅឲ្យ គណៈតំបន់១៣ក្នុងស្រុកត្រាំកក់ ។ សារ៉ុន បានជួបតាម៉ុកនៅតាមផ្លូវ ។ ដោយឃើញគាត់ជិះម៉ូតូបែបសង្ហាហើយមិនគោរពគាត់ តាម៉ុក បានបញ្ជាឲ្យកងការពាររបស់ខ្លួនចាប់ សារ៉ុន មកសួរចម្លើយ ហើយដុតម៉ូតូ សារ៉ុន ចោលនៅចំពោះមុខ ។ សារ៉ុន ភ័យញ័រខ្លួនចំពោះការព្រមានរបស់ តាម៉ុក មកលើរូបគាត់ ។ តាម៉ុក សម្លុតគាត់ថា «អាណាឲ្យជិះម៉ូតូដោយគ្មានការអនុញ្ញាតយ៉ាងដូច្នេះ» ហើយ សារ៉ុន បានប្រាប់ តាម៉ុក ថាជានិរសាររបស់ តាប្រាក់ នៅតំបន់២៥ មានភារកិច្ចយកសំបុត្រទៅឲ្យគណៈស្រុកតំបន់១៣ ។ ទោះយ៉ាងណាក៏ដោយ តាម៉ុក នៅតែមិនស្តាប់ហេតុផលនេះ ហើយដុតម៉ូតូរបស់គាត់ចោលថែមទាំងគំរាមមុននឹងដោះលែងថា «ថ្ងៃក្រោយត្រូវជិះសេះរត់សំបុត្រ បើមិនដូច្នេះទេគាត់នឹងចាប់សម្លាប់ចោល» ។ សារ៉ុន ត្រឡប់មកតំបន់២៥វិញដោយថ្មើរជើង ហើយប្រាប់អំពីហេតុការណ៍នេះដល់ តាប្រាក់ ប៉ុន្តែគាត់ពុំមានមាត់ក ឬនិយាយថាម៉េចឡើយ គឺគ្រាន់តែស្តាប់ហើយនៅស្ងៀមប៉ុណ្ណោះ ។ តាប្រាក់ និង តាម៉ុក ធ្លាប់ថ្នាំងថ្នាក់ចិត្តនឹងគ្នាម្តង ។ តាប្រាក់ មិនពេញចិត្តចំពោះគំនិត តាម៉ុក ដែលគាំទ្រឲ្យប្រជាជនហូបបាយរួមទេ ហើយគាត់ថែមទាំងបានពិភាក្សាបញ្ហានេះជាមួយ ឌុច នៅខណៈពេលដែល ឌុច ធ្វើជាប្រធានគុកនៅខេត្តកំពង់ស្ពឺ ក៏ប៉ុន្តែ ឌុច ក៏គ្មានប្រតិកម្មអ្វីដែរ គ្រាន់តែស្តាប់ចោលប៉ុណ្ណោះ ។

ក្នុងឆ្នាំ១៩៧៦ សារ៉ុន បានអមដំណើរ តាប្រាក់ ទៅទទួលគណៈប្រតិភូចិនដែលមកធ្វើទស្សនកិច្ចប្រទេសកម្ពុជា ។ គណៈប្រតិភូនេះ បានដើរទស្សនារោងចក្រ និងការដ្ឋានជីកប្រឡាយមួយចំនួននៅក្នុងតំបន់២៥ ។

ឆ្នាំ១៩៧៧ សារ៉ុន ក៏ត្រូវផ្លាស់ទៅធ្វើការជាមួយ តាប្រាក់ នៅតំបន់១៣ក្នុងខេត្តតាកែវ ។ ជាញឹកញាប់ សារ៉ុន ត្រូវបើកឡានជូន តាប្រាក់ ទៅចូលរួមប្រជុំជាមួយ តាម៉ុក នៅមន្ទីរភូមិភាគនិរតីនិងទៅសមរភូមិមុខភ្នំដិន ដើម្បីស្ទាបស្ទង់សភាពការណ៍នៅតាមព្រំដែនវៀតណាម និងដើម្បីលើកទឹកចិត្តយុទ្ធជនទាំងអស់ឲ្យខិតខំប្រឹងប្រែងការពារមាតុភូមិ ។ ក្នុងពេលនោះដែរ តាប្រាក់ បានក្លាយជាអនុប្រធាន តាម៉ុក ផង និងលេខាតំបន់១៣ផង ។

ធ្វើការនៅតំបន់១៣មិនបានមួយឆ្នាំផង តាម៉ុក ដក តាប្រាក់ ឲ្យទៅប្រចាំការនៅតំបន់៣៣ក្នុងខេត្តកំពង់ស្ពឺ ដែលមានទីតាំងនៅស្រុកត្រាំខ្នារ ។ នៅទីនោះ សារ៉ុន មានតួនាទីមួយទៀតគឺដឹកស្បៀងនិងសម្ភារសឹកទៅសមរភូមិមុខតាមបណ្តោយព្រំដែនវៀតណាម ។

សារ៉ុន បានឲ្យដឹងថា ក្នុងឆ្នាំ១៩៧៧សភាពការណ៍ផ្ទៃក្នុងបក្សបានឈានដល់ការបែកបាក់គ្នាយ៉ាងខ្លាំង អង្គការបានចាប់កម្មាភិបាលធំៗ ស្ទើរតែគ្រប់ភូមិភាគដែលសង្ស័យថាក្បត់ និងផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយដោយសម្ងាត់ ធ្វើឲ្យ តាប្រាក់ ព្រួយបារម្ភអំពីសុវត្ថិភាពរបស់គាត់ជាខ្លាំង ។ តាប្រាក់ បានលួច

ទំនាក់ទំនងជាមួយ សោភឹម ប្រធានភូមិភាគបូព៌ាតាំងពីឆ្នាំ១៩៧៦ ម៉្លេះ ដើម្បីត្រៀមខ្លួនរត់ទៅប្រទេសវៀតណាម ។

ចុងឆ្នាំ១៩៧៧ សារ៉ុន ទទួលបញ្ជាពី តាប្រាក់ យកសំបុត្រទៅឲ្យគណៈស្រុកកំពង់រោទិ៍ ដើម្បីប្រជុំពីផែនការសម្ងាត់ត្រៀមរត់ទៅវៀតណាម ពីព្រោះ តាប្រាក់ ដឹងថាមិត្តភក្តិនិងអ្នកធ្លាប់រួមអាវុធជាមួយគាត់ជាច្រើននាក់កាលពីសម័យតស៊ូក្នុងទសវត្សរ៍ឆ្នាំ១៩៦០និង៧០ត្រូវអង្គការចាប់ខ្លួន ដែលធ្វើឲ្យគាត់គិតថាថ្ងៃណាមួយនឹងដល់វេនគាត់ជាមិនខាន ។ ម្យ៉ាងទៀតអង្គការពុំមានទំនុកចិត្តចំពោះកម្មាភិបាលដែលមានសាច់ញាតិនិងដើមកំណើតនៅភូមិភាគបូព៌ាឡើយ ។ នៅចុងឆ្នាំ១៩៧៧ សារ៉ុន បានផ្លាស់មកធ្វើការនៅស្រុកតាខ្មៅក្នុងតំបន់២៥ ជាមួយ តាប្រាក់ វិញ ។



ចាន់ គីមស្រ៊ុន និងកូនតូច

ដើមឆ្នាំ១៩៧៨ តាប្រាក់, សារ៉ុន និងមនុស្ស៥នាក់ទៀត បានធ្វើដំណើរទៅខេត្តស្វាយរៀងឆ្ពោះទៅប្រទេសវៀត-ណាម ។ នៅសល់ចម្ងាយតែប្រមាណ៧គីឡូម៉ែត្រប៉ុណ្ណោះ នឹងចូលដល់ទឹកដីវៀតណាម ក៏ប៉ុន្តែ តាម៉ុក ហៅតាមគេអូឲ្យ តាប្រាក់ វិលត្រឡប់ទៅប្រជុំនៅភូមិភាគនិរតីវិញ ។ មកដល់តំបន់២៥ សារ៉ុន និងកងការពារទាំងអស់ត្រូវបានដកហូតអាវុធ តាប្រាក់ និងប្រពន្ធឈ្មោះ ចាន់គីមស្រ៊ុន ហៅ សាង ព្រមទាំងកូនតូចម្នាក់ត្រូវអង្គការចាប់បញ្ជូនទៅគុកទួលស្លែង (ស-២១) ។ ក្រោយពីការចាប់ខ្លួន តាប្រាក់ បានមួយថ្ងៃ សារ៉ុន ទទួលដំណឹងថា គាផុន គណៈស្រុកកំពង់រោទិ៍ ក៏ត្រូវចាប់ខ្លួនដែរ ហើយ សោភឹម បាញ់សម្លាប់ខ្លួននៅភូមិភាគបូព៌ា ។ ខេម៉ារា និង បុគ្គលិកតំបន់២៥មួយចំនួនត្រូវចាប់ខ្លួន ។ សារ៉ុន កូនស្រីពីរនាក់ ឪពុកម្តាយបងប្អូន និងសាច់ញាតិរបស់ តាប្រាក់ ៤គ្រួសារទៀត ដែលមានសមាជិកជាង២០នាក់រស់នៅខេត្តស្វាយរៀង ត្រូវបានចាប់បញ្ជូនទៅគុកអូរជ្រៅតំបន់៣៣ ក្នុងខេត្តកំពង់ស្ពឺ ដែលមាន តាខុន (កំបុតដៃ) ជាប្រធានគុក ។ តាខុន ជាអតីត កងទ័ពរបស់អង្គការតាំងពីសម័យតស៊ូមកពីខេត្តតាកែវ គាត់មានចរិតកាចសាហាវពុំមានការយោគយល់ចំពោះអ្នកទោសណាម្នាក់ឡើយ ។ មានពេលខ្លះ តាខុន បានវាយអ្នកទោសឲ្យស្លាប់នៅនឹងកន្លែង ដើម្បីជាការព្រមានដល់អ្នកទោសផ្សេងទៀត ។

ក្នុងចំណោមនោះមានបងប្រុសរបស់ តាប្រាក់ ម្នាក់ត្រូវចាប់ខ្លួនបញ្ជូនទៅគុកវត្តចំពុះក្អែក ស្ថិតនៅក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល ។

សារ៉ុន និងឪពុកម្តាយបងប្អូនរបស់ តាប្រាក់ ត្រូវអង្គការបញ្ជូនទៅរស់នៅមន្ទីរអប់រំកែប្រែជាមួយមនុស្សរាប់ពាន់នាក់ដែលត្រូវចោទថា ជាប់និន្នាការ ឬសាច់ញាតិកម្មាភិបាលដែលត្រូវអង្គការចាប់ខ្លួន ។ សារ៉ុន បានរំឭករឿងឈឺចាប់និងការបាត់បង់សាច់ញាតិនៅក្នុងគុកអូរព្រៃព្នៅឲ្យដឹងថា គុកជ្រៃអូរព្នៅមានទំហំ៤គីឡូម៉ែត្រ បួនជ្រុង ហ៊ុមព័ទ្ធដោយបន្ទាលួស ដែលមានផ្ទុកអ្នកទោសគ្រប់វ័យប្រមាណ៥០០០នាក់ ។ នៅទីនោះមាន ដីស្រែ, ការដ្ឋាន, មន្ទីរពេទ្យ និងរោងសហករណ៍ហូបបាយរួម ។ អង្គការបានចែកអ្នកទោសជាបីប្រភេទ ៖ ប្រភេទទី១ អ្នកទោសកម្រិតធ្ងន់ ជាទោសក្បត់ជាតិ ក្បត់ប្រជាជន ឬជាគិញសម្ងាត់របស់វៀតណាម ។ អ្នកទោសប្រភេទនេះ ត្រូវដាក់ខ្នោះជើងទាំងយប់ទាំងថ្ងៃ នៅលើកំពូលភ្នំដើម្បីសួរចម្លើយនិងត្រៀមយកទៅសម្លាប់ចោល ។ ប្រភេទទី២ ជាអ្នកទោសដែលដាក់ខ្នោះជើងតែពេលយប់ នៅពេលថ្ងៃសន្តិសុខគុកបណ្តើរចេញឲ្យទៅធ្វើការនៅខាងក្រៅដូចជាវាយថ្មភ្នំ និងដាំបន្លែ ។ ប្រភេទទី៣ ជាអ្នកទោសស្រាលត្រូវបែងចែកតាមវ័យនិងតាមអាយុ ដើម្បីងាយស្រួលធ្វើពលកម្ម ។ អ្នកទោសប្រភេទនេះ អង្គការអនុញ្ញាតឲ្យរៀបការដូចប្រជាជននៅខាងក្រៅដែរ ប៉ុន្តែត្រូវស្ថិតក្នុងការតាមដានអំពីសកម្មភាពការងារនិងកំណត់បរិវេណឲ្យដើរមិនឲ្យចេញពីបរិវេណគុកឡើយ ។

ទោះបីជា សារ៉ុន ជាអ្នកទោសប្រភេទទី៣ក៏ដោយ ក៏គាត់រស់នៅក្នុងសេចក្តីភ័យខ្លាចជានិច្ច គាត់ឃើញសន្តិសុខចាប់អ្នកដែលនៅក្នុងក្រុមជាមួយយកទៅសម្លាប់ជារៀងរាល់ថ្ងៃ ។ ក្រោ

ពីស្លាប់ដោយការសម្លាប់ អ្នកទោសជាច្រើននាក់ទៀតត្រូវបានស្លាប់ដោយការបង្អត់អាហារនិងជំងឺផ្សេងៗ ។ ប្អូនប្រុសរបស់ តាប្រាក់ ពីរនាក់ត្រូវស្លាប់ដោយដាច់ពោះ ។ ចំណែកកូនស្រីរបស់ តាប្រាក់ ឈ្មោះ សេក សុធី ដែលមានអាយុមិនដល់ ១០ឆ្នាំផងត្រូវបាត់ដំណឹងរហូតដល់សព្វថ្ងៃ ។

សារ៉ុន នៅតែមិនអាចបំភ្លេចបាននូវកាយវិការរបស់ តាម៉ុក និង តាខុន ដែលមានចរិតសាហាវឃោរឃៅមកលើរូបគាត់និងអ្នកទោសទាំងអស់នៅក្នុងគុកជ្រៃអូរញ្ញោ ។ សារ៉ុន បញ្ជាក់ថា គាត់ គឺជាសាក្សីផ្ទាល់ភ្នែកចំពោះហេតុការណ៍ទាំងឡាយដែល តាម៉ុក បញ្ជាឲ្យចាប់គណៈតំបន់២៥ និងយុវជនយុវនារីរាប់រយនាក់ដែលគ្មានកំហុសយកទៅដាក់គុកទួលស្លែងនិងគុកផ្សេងទៀត ។ សារ៉ុន បន្ថែមថា អ្នកដែលហ៊ាននិយាយថា តាម៉ុក គឺជាមនុស្សស្លូតបូតសូម្បីតែសម្លាប់ត្រីមួយមិនហ៊ានសម្លាប់ផងនោះគឺជាការបំផ្លើសទាំងស្រុង ។ តាម៉ុក ជាឃាតករឈាមស្រស់ដែលសម្លាប់ជីវិតប្រជាជនរាប់ម៉ឺននាក់នៅភូមិភាគនិរតី ។ ទោះបីជា តាម៉ុក ស្លាប់ដោយរួចផុតពីការកាត់ទោសក៏ដោយ តាម៉ុក ក៏មិនអាចរួចផុតពីកម្មពៀរតាមជំនឿព្រះពុទ្ធសាសនាដែរ ។

**វ៉ែម សុខឃីម**

# នៅកៀនជញ្ជាំងស-២១ : រឿងរ៉ាវពីគុកទួលស្លែង

«នៅកៀនជញ្ជាំងស-២១»គឺជាភាពយន្តឯកសារទីពីរផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ខ្សែភាពយន្តរឿង«វាលស្រែខ្មែរក្រហម» ដែលត្រូវបានផលិតឡើងនៅឆ្នាំ ២០០៤ ។ ខ្សែភាពយន្តនេះមានរយៈពេល៣០នាទី ហើយបង្ហាញពីរឿងរ៉ាវដែលបានកើតឡើងនៅមន្ទីរស-២១ តាមរយៈការរៀបរាប់របស់អតីតអ្នកទោសគុកទួលស្លែងពីររូប ប៊ូ ម៉េង និង ជុំ ម៉ី និង អតីតអ្នកយាមគុកម្នាក់ឈ្មោះ ហ៊ឹម ហ៊ុយ ។

នៅក្នុងខ្សែភាពយន្ត ប៊ូ ម៉េង និង ជុំ ម៉ី បានរៀបរាប់ពីជីវិតរបស់អ្នកទាំងពីរតាំងពីក្មេងរហូតដល់ពេលត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ និងទារុណកម្មដែលអ្នកទាំងពីរបានទទួលរងយ៉ាងឈឺចាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែក ហ៊ឹម ហ៊ុយ ក៏បានរៀបរាប់ពីជីវិតរបស់ខ្លួនតាំងពីក្មេងរហូតត្រូវបានបញ្ជូនឲ្យមកធ្វើជាអ្នកយាមមន្ទីរស-២១ដោយបង្ខំ ។ អ្នកទាំងបីទោះជាជនរងគ្រោះក្តីឬជនដៃដល់ក្តី ក៏ត្រូវជាប់នៅក្នុងមន្ទីរស-២១ ដោយភាពភ័យខ្លាចរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជា-ធិបតេយ្យ ។




ប៊ូ ម៉េង និង ជុំ ម៉ី សុទ្ធតែជាកូនកសិករ ហើយធ្លាប់បានបួសរៀនជាសង្ឃ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអ្នកទាំងពីរត្រូវអង្គការចាប់បញ្ជូនមកមន្ទីរស-២១ ក្រោមបទចោទប្រកាន់ថា ជាភ្នាក់ងារ សេ.អ៊ី.អា របស់អាមេរិក ។ អ្នកទាំងពីរត្រូវទទួលរងទារុណកម្មយ៉ាងព្រៃផ្សៃ នៅក្នុងមន្ទីរស-២១ ។ ទោះជាយ៉ាងនេះក្តី អ្នកទាំងពីរអាចរស់រានមានជីវិតបានដោយសារតែជំនាញគូររូបគំនូរ និងបច្ចេកទេសជួសជុលគ្រឿងម៉ាស៊ីនដែលមានប្រយោជន៍សម្រាប់មន្ទីរស-២១ ។ ហ៊ឹម ហ៊ុយ ក៏កូនកសិករម្នាក់ដែរ ។ ហ៊ុយ បានជាប់ក្នុងកំណែនកងទ័ពរបស់ខ្មែរក្រហមក្រោយរដ្ឋប្រហារ

ឆ្នាំ១៩៧០ ។ ចុងបញ្ចប់ ហ៊ីុយ ត្រូវខ្មែរក្រហមបញ្ជូនឲ្យមកធ្វើជាអ្នកយាមគុកនៅមន្ទីរស-២១ នៅចុងឆ្នាំ១៩៧៦ ។

នៅក្នុងខ្សែភាពយន្តនេះ ប៊ូ ម៉េង បានចោទប្រកាន់ ហ៊ីម ហ៊ីុយ ថាជាអ្នកធ្វើ ទារុណកម្មមកលើរូបគាត់ផ្ទាល់រហូតធ្វើឲ្យគាត់សន្លប់ជាច្រើនដង និងធ្វើឲ្យមានស្នាមរបួសជាប់ខ្លួនរហូតដល់សព្វថ្ងៃ ។ ហ៊ីុយ បានរៀបរាប់ថា គាត់ត្រូវអង្គការខ្មែរក្រហមបង្ខំឲ្យមកបម្រើការនៅក្នុងមន្ទីរស-២១ ។ ហ៊ីុយ ក៏បានសារភាពដែរថា គាត់ពិតជាបានសម្លាប់អ្នកទោសមួយចំនួនក្រោមបញ្ជារបស់ថ្នាក់លើនិងក្នុងកាលៈទេសៈបង្ខំចិត្ត ។ ហ៊ីុយ បានអះអាងថា ការជំទាស់នឹងបញ្ជារបស់អង្គការឬការរារែកចិត្តមិនហ៊ានធ្វើនឹងបណ្តាលឲ្យមានគ្រោះថ្នាក់ដល់ជីវិត ដោយសារតែជំហរមិនដាច់ខាតចំពោះខ្មាំងសត្រូវ ។

គោលបំណងនៃការផលិតខ្សែភាពយន្តនេះ គឺដើម្បីបង្ហាញនូវអ្វីដែលបានកើតឡើងនៅក្នុងគុកសម្ងាត់ដ៏សំខាន់របស់ខ្មែរក្រហម ដែលបានឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់អ្នកទោសប្រហែលមួយម៉ឺនបួនពាន់នាក់ដោយគ្មានធ្វើការកាត់ក្តីអ្វីទាំងអស់ ។ ក្នុងចំណោមនោះ មានតែអ្នកទោសប្រហែល១២នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។ ជាងនេះទៅទៀត ខ្សែភាពយន្តនេះមានរយៈពេលខ្លីនិងមានភាពងាយស្រួលយល់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា តាមរយៈ ការទស្សនាខ្សែភាពយន្តនេះ ប្រជាពលរដ្ឋខ្មែរនឹងធ្វើការស្វែងយល់នូវអ្វីដែលបានកើតឡើងពិតប្រាកដនៅមន្ទីរស-២១ និងធ្វើការពិភាក្សាគ្នាជុំវិញប្រធានបទនេះ ដែលជាជំហានឆ្ពោះទៅការផ្សះផ្សាគ្នារវាងជនរងគ្រោះនិងជនដៃដល់ ។

គម្រោងនេះ ទទួលបានជំនួយផ្នែកហិរញ្ញវត្ថុដ៏សប្បុរសពីមូលនិធិ សូរ៉ុស នៃវិទ្យាស្ថានសង្គមសេរីក្រោមគម្រោងប្រមូលឯកសារ និងការប្រឈមមុខនឹងអតីតកាល ។ ជំនួយសម្រាប់ប្រតិបត្តិការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ឲ្យដោយទីភ្នាក់ងាររសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ ស៊ុយអែត (Sida) ។ **ឌី ខាំបូលី**

# ការបាត់ខ្លួនរបស់កងពិសេសតំបន់១០៦

នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិលឆ្នាំ១៩៧០-១៩៧៥ ទូទាំងប្រទេសកម្ពុជាខ្មែរក្រហមបានបែងចែកជាភូមិភាគ តំបន់ និងស្រុក ដែលការបែងចែកភូមិភាគតំបន់ទាំងនោះតែងតែមានការផ្លាស់ប្តូរជារឿយៗ ។ ឧទាហរណ៍ដូចជា ខេត្តសៀមរាបដំបូងឡើយស្ថិតនៅក្នុងតំបន់៣៥ ភូមិភាគ៣០៤ បន្ទាប់ពីថ្ងៃជ័យជម្នះរបស់កងទ័ពរណសិរ្សរួបរួមជាតិកម្ពុជាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខេត្តសៀមរាបក្លាយជាតំបន់ស្វយ័ត១០៦ ដែលមាន ប៉ា ផល ហៅ សុទ្ធ ជាលេខាតំបន់ ។ ប៉ុន្មានឆ្នាំក្រោយមក បន្ទាប់ពីការចាប់ខ្លួន សុទ្ធ នៅដើមឆ្នាំ១៩៧៧ ខេត្តសៀមរាបស្ថិតនៅក្នុងភូមិភាគឧត្តរថ្មី ដែលរួមបញ្ចូលខេត្តទាំងបីគឺ ខេត្តសៀមរាប ឧត្តរមានជ័យ និងខេត្តព្រះវិហារ ។ ការផ្លាស់ប្តូរនេះប្រហែលជានៅក្រោយពេលដែលអង្គការចាប់ខ្លួន សុទ្ធ និង សៀន ។ ក្រោយពីការចាប់ខ្លួន សុទ្ធ អង្គការបានតែងតាំង កុត ហៅ ជាតិ ដែលជាអតីតគណៈស្រុកជីក្រែងឲ្យមកគ្រប់គ្រងខេត្តសៀមរាបជាបណ្តោះអាសន្ន ។ ជាតិ និងគ្រួសារ ត្រូវអង្គការចាប់ខ្លួនប្រហែលជា១ខែមុនពេលអង្គការតែងតាំង កង ចាប ហៅ សែ ឲ្យមកគ្រប់គ្រងភូមិភាគឧត្តរថ្មី ។

## ការលាក់ខ្លួនរបស់កងពិសេសតំបន់១០៦

នៅដើមឆ្នាំ១៩៧៧ អង្គការបានហៅលេខាតំបន់១០៦ ទៅរៀនសូត្រនៅទីក្រុងភ្នំពេញ ។ ហៃ សៀប ហៅ ជាត ដែលជានិរសាររបស់ សុទ្ធ គឺជាអ្នកបើករថយន្តជូន សុទ្ធ មកភ្នំពេញ ។ ប៉ុន្មានថ្ងៃក្រោយមក ដោយយល់ឃើញថាសភាពការណ៍មិនស្រួល តាម៉ៃ ដែលជាប្រធានកងពិសេសតំបន់១០៦ បានបញ្ជាឲ្យអនុប្រធានរបស់គាត់ឈ្មោះ ង៉ួន រ៉ុំ ដែលត្រូវជាបងជីដូនមួយរបស់ ជាត ដឹកនាំកងពិសេសរបស់តំបន់ទៅលាក់ខ្លួននៅក្នុងព្រៃស្អកជាប់ព្រំដែនថៃ ។ រ៉ុំ និយាយថា គាត់មិនបានដឹងពីផែនការរបស់ តាម៉ៃ នៅពេលនោះទេ គាត់ធ្វើតែតាមបញ្ជាតែប៉ុណ្ណោះ ។ មុនពេលចេញដំណើរ តាម៉ៃ បានផ្តាំផ្តាច់ខាតមិនឲ្យបាញ់ ឬ

បន្តការផ្ទុះគ្រាប់នៅក្នុងព្រៃដែលបោះទីតាំងនោះទេ ។ ការធ្វើដំណើរនេះ មានការរៀបចំទុកជាមុនយ៉ាងប្រុងប្រយ័ត្ន ។ ស្បៀងនិងសម្ភារសឹកត្រូវបានរៀបចំដាក់ក្នុងរថយន្តចំនួនប្រាំគ្រឿង ក្នុងនោះមានរថយន្តពីរគ្រឿងដឹកអង្ករ និងរថយន្តមួយគ្រឿងដឹកត្រីប្រឡាក់ ។ ស្បៀងទាំងអស់នេះអាចផ្គត់ផ្គង់កងទ័ពបានរយៈពេលជាងមួយឆ្នាំ ។ អាវុធនិងគ្រាប់រំសេវថ្មីៗដែលប្រើសម្រាប់កងពិសេសក៏ដឹកទៅជាមួយដែរ ។ តាម៉ៃ មិនបានធ្វើដំណើរទៅជាមួយកងទ័ពទេ ព្រោះ តាម៉ៃ ត្រូវមើលការខុសត្រូវពេលដែលលេខាតំបន់មិននៅ ។ រុំ ដឹកនាំកងពិសេសតំបន់១០៦ ដែលមានទ័ពចំនួន៣០០នាក់ ស្មើមួយវរសេនាតូច ទៅកាន់ព្រៃស្អាក ។ រុំ និង តាម៉ៃ បន្តទាក់ទងគ្នាតាមវិទ្យុទាក់ទងជានិច្ច ប៉ុន្តែមិនយូរប៉ុន្មាន ការទាក់ទងរវាង តាម៉ៃ និង រុំ ត្រូវកាត់ផ្តាច់ ។ ចាប់តាំងពីពេលនោះមក រុំ មិនដឹងថាមានរឿងអ្វីកើតឡើងនៅឯខេត្តសៀមរាបនោះទេ ហើយក៏មិននឹកស្មានថាមានការចាប់ខ្លួនកម្មាភិបាលធំៗនៅក្នុងតំបន់១០៦ដែរ ។


មួន អ៊ី ហៅ រុំ

## ការចាប់ខ្លួនកងពិសេសតំបន់១០៦

រយៈពេលប្រហែលជា៦ខែក្រោយ លីន ដែលទើបតែមកពីភូមិភាគនិរតីបានហៅ រុំ តាមវិទ្យុទាក់ទងឲ្យនាំទ័ពត្រឡប់មកសៀមរាបវិញដើម្បីចូលរួមប្រជុំ ។ កងពិសេសនេះបានមកដល់ខេត្តសៀមរាបនៅម៉ោង១២យប់ ស្នាក់នៅម្តុំចុងស្ពានសៀម-រាប ។ ដោយសារកងពិសេសនេះជាកងខ្លាំងជាងគេប្រចាំតំបន់១០៦ កម្មាភិបាលខាងនិរតីមិនទាន់ធ្វើសកម្មភាពចាប់ភ្លាមៗទេ ។ កម្មាភិបាលភូមិភាគនិរតីប្រើមធ្យោបាយមួយ ដោយហៅកម្មា-ភិបាលធំៗរបស់កងពិសេស និងកងទ័ពថ្មើជើងរបស់តំបន់ទៅប្រជុំដើម្បីជាលេសចាប់ខ្លួន ។ ស្អែកឡើង រុំ និងប្រធាន"គ"ផ្សេងទៀតបានទៅចូលរួមប្រជុំ ។ សមាជិកដែលចូលរួមប្រជុំទាំងអស់មានគ្នាប្រហែល២០នាក់ សុទ្ធសឹងតែជាប្រធានគនិងអនុវរសេនាតូច ។ ដោយឡែក តាពែង ប្រធានវរសេនាតូចលេខ១១៣ ត្រូវអង្គការចាប់ខ្លួនតាំងពីមុនពេលដែល រុំ នាំទ័ពពិសេសពីព្រៃត្រឡប់មកសៀមរាបម្ល៉េះ ។ រុំ ត្រូវបានសួរចម្លើយថា គាត់នាំកងទ័ពទៅក្នុងព្រៃធ្វើអ្វីខ្លះ? រុំ ប្រាប់ថាមិនបានធ្វើអ្វីទេ ហើយក៏មិនបានទៅវាយខ្មាំងឯណាដែរ ។ រុំ ត្រូវបានសួរចម្លើយទៀតថា "មានដឹងថាពួកអាសុទ្ធ អាពែង អាម៉ៃ ក្បត់ដែរទេ?" រុំ បានបដិសេធថាមិនបានដឹងរឿងឡើយព្រោះគាត់នៅដាច់ឆ្ងាយពីអ្នកទាំងនោះ ។

បន្ទាប់ពីនោះ កម្មាភិបាលភូមិភាគនិរតីប្រកាសថា សុទ្ធ, ម៉ៃ និង ពែង ជាជនក្បត់ជាតិត្រូវអង្គការចាប់ខ្លួនអស់ហើយ ។ ភ្លាមៗនោះកម្មាភិបាលដែលចូលរួមប្រជុំប្រមាណ២០នាក់ត្រូវបានចាប់ចងដាក់ឡានទាំងអស់ នៅសល់តែ រុំ ម្នាក់ឯងប៉ុណ្ណោះ ហើយគាត់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ ។ រុំ មិនដែលនឹកគិតថារឿងរ៉ាវធ្ងន់ធ្ងរដល់ថ្នាក់នេះទេ នៅពេលដែលមានការចាប់ខ្លួននៅក្នុងអង្គប្រជុំគ្មាននរណាម្នាក់អាចតដៃបានទេ ព្រោះថាមុនពេលប្រជុំអង្គការប្រមូលកាំភ្លើងដាក់ដោយឡែកនៅលើតុមួយ ។ រុំ រំឭកថា បើទោះជាគាត់ធ្លាប់ធ្វើសង្គ្រាមច្រើនឆ្នាំយ៉ាងណាក៏ដោយ ក៏ក្នុងព្រឹត្តិការណ៍បែបនោះគាត់តក់ស្លុតយ៉ាងខ្លាំង ។

រុំ មិនហ៊ានប្រាប់ពីហេតុការណ៍នេះដល់យុទ្ធជននៅក្នុងកងទេ គាត់សុខចិត្តដេកអត់បាយអត់ទឹកតែម្នាក់ឯង ដោយសារភ័យខ្លាំងពេក ។ នៅម៉ោងប្រហែល៣រសៀលថ្ងៃដដែល អង្គការបានហៅ រុំ ទៅប្រជុំម្តងទៀតដើម្បីបញ្ជាក់ប្រាប់ថា ពួកក្បត់ត្រូវអង្គការចាប់អស់ហើយ ។ នៅព្រឹកថ្ងៃបន្ទាប់ អង្គការបានប្រមូលកងទ័ពទាំងអស់ទៅប្រជុំនៅវាលឫស្សីបីដើមដើម្បីប្រកាសប្រាប់ពីអំពើក្បត់របស់កម្មាភិបាលចាស់ៗនៅក្នុងតំបន់ ។ ក្រោយពីប្រជុំចប់ អង្គការប្រកាសដកអាវុធពីកងពិសេសទាំងអស់ដោយលើកហេតុផលថា អាវុធទាំងនោះជារបស់ពួកក្បត់ "កាំភ្លើងនេះកាំភ្លើងចាស់សម័យអាក្បត់ យើងទុកមិនបានទេ យើងត្រូវតែផ្លាស់ប្តូរយកកាំភ្លើងថ្មី" ។ ក្រោយពីដកកាំភ្លើង អង្គការបញ្ជូនកងទ័ពទាំងអស់ទៅធ្វើស្រែ ។ ដោយឡែកកាំភ្លើងខ្លីរបស់ រុំ មិនត្រូវបានដកឡើយ ហើយថែមទាំងបញ្ចូលគាត់ជាសមាជិកសំខាន់បន្ទាប់ពី លីន និង ណាត់ ។ រុំ បញ្ជាក់ថា លីន និង ណាត់ បញ្ចូលគាត់ជាសមាជិក ពីព្រោះគាត់ស្គាល់ទ័ពច្បាស់ និងចង់ប្រើគាត់ដើម្បីរៀបចំទ័ពឲ្យបានរៀបរយ ។

កន្លះខែក្រោយមកអង្គការបានដក រុំ ឲ្យទៅគ្រប់គ្រងកងទ័ពរំសាយនៅខេត្តបាត់ដំបង ដោយអនុញ្ញាតឲ្យ រុំ យកនិរសារពីរនាក់ កាំភ្លើងខ្លីផ្ទាល់ខ្លួនមួយដើម និងកាំភ្លើងវែងពីរដើមសម្រាប់និរសាររបស់គាត់ ។ នៅបាត់ដំបងអង្គការចាត់តាំង រុំ ឲ្យមើលការខុសត្រូវកងទ័ពធ្វើស្រែ ។ តាំងពីពេលនោះមក រុំ មិនបានដឹងថា មានរឿងអ្វីកើតឡើងចំពោះកងពិសេសទាំង៣០០នាក់របស់គាត់ទេ សព្វថ្ងៃនេះគាត់ក៏មិនដែលបានជួបយុទ្ធជនកងពិសេសរបស់គាត់ដែរ ។ មានតែនិរសាររបស់គាត់ម្នាក់គត់ដែលនៅរស់រានមានជីវិតមកទល់សព្វថ្ងៃនេះ ។

**គេចខ្លួនដើម្បីរស់**

ក្នុងរយៈពេលដែល រុំ គ្រប់គ្រងកងទ័ពរំសាយនៅស្ទឹងធំក្នុងខេត្តបាត់ដំបង អង្គការថ្នាក់លើបានមកស្នើយកមនុស្សបីបួននាក់ជារៀងរាល់ថ្ងៃ ប៉ុន្តែ រុំ មិនដឹងថាទ័ពទាំងអស់នោះត្រូវអង្គការស្នើយកទៅកន្លែងណាឡើយ ។ រុំ រំឭកថា "មួយយប់មានបីបួននាក់ ដល់ល្ងាចឡើងឃើញសំបុត្រមក មានឈ្មោះ ក ឈ្មោះ ខ អីចឹងទៅសុំដកយកទៅរៀនសូត្រ... ។ ទាហានរាប់ពាន់នាក់ នៅធ្វើស្រែនៅស្ទឹងធំ» ។ ថ្ងៃមួយ រុំ ត្រូវអង្គការចោទប្រកាន់ថាគាត់នៅប្រកាន់យកសង្គមពុករលួយ បន្ទាប់ពីគាត់ស្លៀកខោខ្មៅដែលនៅសេសសល់ពីសង្គមទៅចូលរួមក្នុងមីទ្ទីង ។ រុំ មិនបានដឹងថាអង្គការមានគម្រោងសម្លាប់ខ្លួននោះទេ ប៉ុន្តែសំណាងល្អអាយុមិនអស់ មិត្តនារីម្នាក់ដែលស្តាប់ពុកម្នាភិបាលខ្មែរក្រហមពិភាក្សាគ្នាពីរឿងនេះ បានមកខ្សឹបប្រាប់គាត់ឲ្យរត់ ។ បានដំណឹងនេះភ្លាម រុំ គិតរកវិធីរត់គេចខ្លួន ។ ព្រឹកឡើង រុំ ប្រាប់និរសារទាំងពីរនាក់របស់គាត់ឲ្យដើរប្រមូលទ័ពទាំងអស់ទាំងឈើទាំងដាមកជុំគ្នាដើម្បីចែកបាយម្នាក់មួយតឹកបួនជ្រុង(បាយដាក់ស្លុកបន្លាប់ឲ្យណែនរួចកាត់ជាបួនជ្រុង) ។ ក្រោយពីបរិភោគបាយរួច រុំ និងនិរសារបានស្រុះស្រួលគ្នារត់ចេញពីអង្គភាពស្ទឹងធំ ។ ដើម្បីការពារខ្លួន រុំ បានប្រមូលបញ្ជីប្រវត្តិរូបឈ្មោះយុទ្ធជនដែលរត់ចោលជួរដាក់ក្នុង បាឡូពីរ និងកាំភ្លើងខ្លីមួយដើមព្រមទាំងសំបុត្រខុទ្ទេសនាមចុះប្រមូលយុទ្ធជនរត់ចោលជួរមួយច្បាប់ ។ រុំ ធ្វើដំណើរពីសហ-ករណ៍មួយទៅសហករណ៍មួយ ដោយប្រើប្រាស់សំបុត្រខុទ្ទេស-នាមនោះថា គាត់និងនិរសារចុះមកប្រមូលកងទ័ពឲ្យត្រឡប់ទៅអង្គភាពវិញ ។ "*ទៅដល់សហករណ៍គេសួរថាមកធ្វើអី? ខ្ញុំថាមកតាមទ័ព រួចបង្ហាញលិខិតខុទ្ទេសនាមឲ្យគេមើល*" ។

បញ្ជីឈ្មោះនិងលិខិតខុទ្ទេសនាមអាចជួយឲ្យ រុំ និងនិរសារបន្តដំណើររហូតដល់ផ្ទះនៅខេត្តសៀមរាប ។ រុំ សម្រាកនៅផ្ទះសុំបាយសហករណ៍ហូបបានប្រហែលជាពីរខែ ត្រូវអង្គការហៅមកសៀមរាបវិញ ។ រុំ រំឭកថា អង្គការបានស៊ើបពីប្រវត្តិរូបរបស់គាត់ ហើយតែងតាំងគាត់ឲ្យគ្រប់គ្រងក្រុមកុមារទូទាំងខេត្តសៀមរាបរហូតដល់កងទ័ពវៀតណាមចូលរំដោះប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ។ សព្វថ្ងៃ រុំ រស់នៅជាមួយប្រពន្ធនិងកូនបួននាក់នៅក្នុងខេត្តសៀមរាប ។

**ឆាយ ណារឿន**

# ទៅជាផេះផង់ធូលី

"ទៅជាផេះផង់ធូលី" ជាចំណងជើងនៃសៀវភៅរូបថតដែលបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ "ទៅជាផេះផង់ធូលី"មានចំណងជើងជាភាសាអង់គ្លេសថា "Vanished: Stories from Cambodia's New People under Democratic Kampuchea" នេះ គឺជាសៀវភៅទី១១ហើយដែលបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏ជាសៀវភៅរូបថតទី២បន្ទាប់ពីការបោះ ពុម្ពផ្សាយសៀវភៅទី១ ដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ជាភាសាអង់គ្លេសថា "Stilled Lives: Photographs from Cambodia Genocide" រៀបរាប់ពីប្រវត្តិរឿងរ៉ាវរបស់ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ ។

"ទៅជាផេះផង់ធូលី" ត្រូវបានបោះពុម្ពឡើងក្នុងគោលបំណងដើម្បី ÷ ១)ឲ្យមានការទទួលស្គាល់ភាពជាមនុស្ស ២)ឲ្យមានការគោរពសិទ្ធិមនុស្ស ៣)អប់រំសិស្សនិងសាធារណជនអំពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រយោជន៍ក្នុងការជួយប្រជាជនឲ្យមើលឃើញនូវភាពជាមនុស្សនិងសិទ្ធិរបស់ជនរងគ្រោះ

និងជនដៃដល់ ៤)ជាភ័ស្តុតាងនៅពេលមានតុលាការខ្មែរក្រហម ៥)ប្រើប្រាស់ជាប្រភពព័ត៌មានសម្រាប់អ្នក ច្បាប់និងអ្នកសិក្សាស្រាវជ្រាវក្នុងការសរសេរប្រវត្តិសាស្ត្រប្រជាជនកម្ពុជា ៦) ជួយដាស់អារម្មណ៍ប្រជាជនក្នុងការរក្សានូវលទ្ធិប្រជាធិបតេយ្យឲ្យស្ថិតស្ថេរនិងមានការចម្រើន និង ៧)ជាជំនួយដល់អ្នកដែលមានបំណងចង់ស្វែងរកគ្រួសារនិងសាច់ញាតិ ។

«ទៅជាផេះផង់ធូលី»រៀបរាប់អំពីប្រវត្តិរឿងរ៉ាវរបស់អតីតប្រជាជន១៧មេសា ឬហៅថាប្រជាជនថ្មី ចំនួន៥២គ្រួសារដែលរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅរស់នៅតាមទីជនបទដាច់ស្រយាល បង្ខំឲ្យបោះបង់ចោលផ្ទះសម្បែង ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងចាត់តាំងឲ្យធ្វើស្រែចម្ការ ។ ខ្មែរក្រហមបានដាក់ឈ្មោះអ្នកទាំងនោះថាជា «ប្រជាជនថ្មី» ឬ «ប្រជាជន១៧មេសា» ។ ប្រជាជនថ្មី គឺជាអ្នកដែលរស់នៅក្នុងទីក្រុង ឬអ្នកដែលមកពីបណ្តាខេត្តផ្សេងៗមកប្រកបរបររកស៊ីនៅក្នុងទីក្រុង ដែលអ្នកទាំងនោះជាសិស្ស និងនិស្សិតក្នុងស្រុកនិងមកពីបរទេស ជាព្រះសង្ឃ អ្នករដ្ឋការនៅសង្គមចាស់ (ទាហាន សាស្ត្រាចារ្យ គ្រូពេទ្យ វិស្វករ កម្មករ រោងចក្រ...) ជាអ្នកជំនួញនិងប្រជាជនទូទៅដែលត្រូវជម្លៀសពីទីក្រុងទៅទីជនបទ ។

ប្រជាជនថ្មី គ្មានសិទ្ធិសេរីភាពដូច «ប្រជាជនចាស់» ឬ «ប្រជាជនមូលដ្ឋាន»ឡើយ ទាំងការហូបចុក និងការធ្វើស្រែចម្ការ ។ លើសពីនេះទៅទៀត អ្នកទាំងនោះត្រូវខ្មែរក្រហមចាត់ទុកថា ខ្មាំងរបស់អង្គការ ហើយត្រូវសម្រិតសម្រាំងយកទៅសម្លាប់ចោល ។ ចំពោះអ្នកដែលជាប់ពាក់ព័ន្ធ ឬធ្វើការនៅក្នុងរដ្ឋការលន់នល់ ត្រូវអង្គការស្វែងរកនិងតាមចាប់យកទៅសម្លាប់ចោល ។ តាមរយៈបទសម្ភាសន៍ជាមួយអតីតប្រជាជនថ្មីចំនួន៥២នាក់ អ្នកនិពន្ធបានរកឃើញថា ប្រជាជនថ្មីខ្លះត្រូវស្លាប់ដោយសារការសម្លាប់ ខ្លះស្លាប់ដោយសារជំងឺគ្មានថ្នាំសង្កូវព្យាបាល ខ្លះស្លាប់ដោយសារគ្មានអាហារហូបគ្រប់គ្រាន់ និងខ្លះទៀតស្លាប់ដោយសារធ្វើការងារហួសកម្លាំង ។

តាមរយៈសមិទ្ធផលរបស់សៀវភៅនេះ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយក្នុងការប្រមូលរូបថតនិងធ្វើការសិក្សាស្រាវជ្រាវសៀវភៅនេះ និងដោយការគាំទ្រយ៉ាងអស់ពីចិត្តរបស់លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក៏សូមថ្លែងអំណរគុណដល់ម្ចាស់រូបថត ដែលបានផ្តល់រូបថតនិងបទសម្ភាសន៍ក្នុងការសរសេរសៀវភៅនេះ ។ លើសពីនេះទៅទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ជំនួយសប្បុរសធម៌ពីទេយ្យទានជាតិសម្រាប់ប្រជាធិបតេយ្យ ក្នុងការស្រាវជ្រាវនិងបោះពុម្ពសៀវភៅនេះ ។ យើងក៏សូមកោតសសើរផងដែរចំពោះរដ្ឋាភិបាលប្រទេសស៊ុយអែត រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ដែលនៅតែបន្តការគាំទ្រមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**ប៊ាង ពីវ័ន**



# ក្រោយមរណភាពរបស់ឪពុកទើបដឹងការពិត

របបកម្ពុជាប្រជាធិបតេយ្យបានកើតឡើងនៅលើទឹកដីកម្ពុជាអស់រយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ដែលនៅក្នុងអំឡុងពេលនោះបានធ្វើឲ្យប្រជាជនកម្ពុជាស្លាប់អស់ជាងមួយលាននាក់ ដោយសារជំងឺ ការធ្វើការហួសកម្លាំង ការអត់អាហារ និងការសម្លាប់ ។ នៅក្នុងចំណោមនោះមានប្រជាជនមន្ត្រីរដ្ឋការ ទាហានលន់នល់ បញ្ញវន្ត និងអ្នកចេះដឹងជ្រៅជ្រះដែលបានសិក្សានៅក្រៅប្រទេស ។

ប្រជាជនខ្មែរភាគច្រើនរស់នៅដោយភាពភ័យខ្លាច និងហូបមិនគ្រប់គ្រាន់ ក៏ប៉ុន្តែមានមនុស្សមួយក្រុមយល់ថា របបកម្ពុជាប្រ-ជាធិបតេយ្យជារបបល្អដោយសារតែខ្លួនទទួលរបបអាហារបរិបូណ៌នៅក្នុងសម័យខ្មែរក្រហម ហើយរស់នៅខិតខំបម្រើការងារជូនអង្គការយ៉ាងប្តូរផ្តាច់ ដោយមិនបានដឹងពីភាពព្រៃផ្សៃនៃរបបនេះ តួយ៉ាងដូចជាមីង កាន់ ឡុប ដែលជាអតីតសមាជិកនៅក្នុងក្រុមផ្នែកបោះពុម្ពកាសែត និងទស្សនាវដ្តី នៅទីក្រុងភ្នំពេញនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឡុប មួយថ្ងៃៗរវល់តែការងារខាងបោះពុម្ពមិនបានដឹងអំពីហេតុការណ៍ពិតដែលកើតឡើងនៅតាមភូមិ ឃុំ ស្រុក ខេត្ត ទូទាំងប្រទេសឡើយ ។ ឡុប រស់នៅឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប មានប្រសាសន៍ថា "ខ្ញុំទើបតែដឹងការពិតក្រោយពេលដែលឪពុកខ្ញុំស្លាប់និងពេលត្រឡប់មកស្រុកកំណើតវិញគឺ ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ" ។ ឡុប បានរំឭកទាំងទឹកមុខស្រងូតស្រងាត់ថា ៖


កាន់ ឡុប

"នៅឆ្នាំ១៩៧០ គឺជាឆ្នាំដែលមានសភាពច្របូកច្របល់ដោយសារមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ខ្ញុំត្រូវបង្ខំចិត្តឈប់រៀនត្រឹមថ្នាក់ទី៩ ។ កាលនោះខ្ញុំរៀននៅសាលារៀនចារឈូក ខេត្តសៀមរាប ហើយអាចអានអក្សរបានខ្លះៗ ។ ក្រោយពេលឈប់រៀនភ្លាម ខ្ញុំត្រូវមេឃុំជ្រើសឲ្យចូលបម្រើបដិវត្តន៍ ។ កាលនោះខ្ញុំអាយុទើបតែ១៧ឆ្នាំប៉ុណ្ណោះ ហើយត្រូវបញ្ជូនឲ្យទៅរែកដីនៅការដ្ឋានកុមារនៅឯស្រុកពួកដោយកំណត់ការងារឲ្យខ្ញុំរែកដីចាប់តាំងពីព្រលឹមដល់ព្រលប់ ហើយពេលខ្លះខ្ញុំត្រូវធ្វើការរហូតដល់យប់ទៀតផង ។ រហូតមកដល់ឆ្នាំ១៩៧៣ ខ្ញុំត្រូវបាន តាអុល ជាមេឃុំចាត់តាំងឲ្យធ្វើជាប្រធានក្រុមក្តាប់សមាជិក ១០នាក់នៅការដ្ឋានស្រុកពួក ។ នៅក្នុងក្រុមរបស់ខ្ញុំ គឺតម្រូវឲ្យធ្វើការដូចជា លើកដី និងជីកដី ហើយដល់រដូវវស្សាធ្វើស្រែ ដល់ផុតពីខែធ្វើស្រែ គឺត្រូវលើកដីវិញ ។ ចំពោះរបបអាហារគឺហូបនៅតាមក្រុម ដោយពេលខ្លះហូបឆ្អែត ហើយមានពេលខ្លះហូបមិនឆ្អែតអាស្រ័យទៅលើភោគផលសម្បូរនៅតាមភូមិ ។

ឆ្នាំ១៩៧៥ គឺជាឆ្នាំដែលខ្មែរក្រហមទទួលបានជ័យជម្នះលើរបបលន់នល់និងកាន់កាប់ទូទាំងប្រទេស ។ នៅក្នុងឆ្នាំនោះ ខ្ញុំត្រូវមេឃុំកត់ឈ្មោះជ្រើសយកទៅភ្នំពេញ ។ នៅពេលនោះ ខ្ញុំមិនបានដឹងខ្លួនថាត្រូវបានជ្រើសរើសឲ្យទៅភ្នំពេញទេ ព្រោះគ្មាននរណាមកប្រាប់ថាតើត្រូវបញ្ជូនទៅណាឡើយ ។ មុនពេលចេញ

ដំណើរ ខ្ញុំបានសុំអ្នកគ្រប់គ្រងទៅផ្ទះដើម្បីប្រាប់ដំណឹងពុកនិងម៉ែសិន ។ ក៏ប៉ុន្តែការសុំទទួចរបស់ខ្ញុំត្រូវបានបដិសេធ ។ អ្នកដែលធ្វើដំណើរទៅភ្នំពេញជាមួយខ្ញុំមានច្រើនតែខ្ញុំស្គាល់មិនអស់ ។ នៅក្នុងការដ្ឋានរបស់ខ្ញុំអង្គការជ្រើសរើសយក៥នាក់សុទ្ធតែស្រីៗ ដែលរួមមានខ្ញុំ បងឃីម បងទ្រេន បងកឹក ដែលរស់នៅក្នុងភូមិជាមួយគ្នា ចំណែកម្នាក់ទៀតខ្ញុំមិនស្គាល់ឈ្មោះ ។ ដំបូងពួកខ្ញុំត្រូវបានបញ្ជូនទៅទីរួមខេត្តសៀមរាបចំនួន៣ថ្ងៃ ។ នៅថ្ងៃនោះប្រហែលជាម៉ោង៦ល្ងាចមានរថយន្តចំនួន៤គ្រឿងបានមកដឹកពួកខ្ញុំចេញពីខេត្តសៀមរាប ។ ខ្ញុំជិះរថយន្តដល់កន្លែងមួយ រថយន្តក៏ឈប់ហើយដាក់មនុស្ស២ក្រុមចុះដើម្បីឆ្លងស្រឡាងទៅភ្នំពេញ ។ អ្នកដែលត្រូវធ្វើដំណើរទៅភ្នំពេញមានគ្នាចំនួនប្រហែល៣០នាក់ដែលមានលាយមនុស្សប្រុសមកពីខាងស្រុកពួកផង ។ ពេលទៅដល់ភ្នំពេញភ្លាម ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុងក្រុងភ្លាមទេ ខ្ញុំត្រូវនៅស្នាក់នៅមុំប្រាំងចំរេះមួយរយៈ ។ នៅទីនោះខ្ញុំត្រូវបានចាត់តាំងឲ្យដាំដំណាំ និងធ្វើចម្ការតាមមាត់ទន្លេរយៈពេល១៥ថ្ងៃ ទើបមានរថយន្តមកដឹកមនុស្សយកទៅ មានអ្នកខ្លះក៏ត្រូវនៅបន្តនៅទីនោះទៀត ពួកខ្ញុំបីនាក់គឺ ខ្ញុំ បងឃីម និង បងទ្រេន ត្រូវបានហៅឲ្យឡើងឡានចូលទីក្រុងភ្នំពេញ ។ មកដល់ភ្នំពេញ ខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើការនៅរោងពុម្ព ចំណែក បងឃីម និង បងទ្រេន ត្រូវបានចាត់តាំងឲ្យទៅយាមម៉ាស៊ីនខាងប៉ុស្តិ៍វិទ្យុនៅឯស្ទឹងមានជ័យ និងដាំបាយនៅខាងកងទ័ពជើងគោកផ្នែកដឹកជញ្ជូន ។

ខ្ញុំបានធ្វើការនៅរោងពុម្ពកាសែតក-២៦ខាងលិចស្ពានអូរឡាំពិក ។ ពេលទៅដំបូងគេបង្ហាត់ឲ្យខ្ញុំចេះការងារផ្នែករោងពុម្ពដូចជា រាប់លេខ យប់ឡើងរៀនរាប់អក្សរតាមលំដាប់តួអក្សរ ។ គេ បង្ហាត់យើងដូចកុមារទើបតែរៀនស្រះអ ស្រះអា ស្រះអិ ដើងក ដើងខ អីចឹង ។ ខ្ញុំរៀនអស់រយៈ៣ថ្ងៃ លុះត្រាតែចេះស្រៈនិងតួអក្សរទាំងអស់ ទើបគេឲ្យយកកាឡេទៅភ្ជាប់ជាអក្សរ ។ នៅក្នុងរោងពុម្ពក-២៦ មានមនុស្សធ្វើការទាំងអស់៦០នាក់ ដែលភាគច្រើនជានារី ។ បុរសកាន់គ្រឿងម៉ាស៊ីននិងបោះពុម្ព ចំណែកនារីជាអ្នកចាប់ក្រដាសរាប់សន្លឹក ។ រោងពុម្ពក-២៦ បោះពុម្ពកាសែតប្រចាំថ្ងៃចំនួនជាង១ម៉ឺនច្បាប់ រួចបញ្ជូនទៅតាមឃុំ ស្រុក ខេត្ត នៅទូទាំងប្រទេស ។ ប្រសិនបើហ៊ុលត្រូវចេញបន្ទាន់ ក្នុងមួយព្រឹកយើងបោះពុម្ពបាន៣ហ៊ុល ហើយព័ត៌មានដែលចុះផ្សាយនៅក្នុងកាសែត គឺនិយាយតែអំពីការបង្កបង្កើនផលនៅតាមស្រុក ភូមិ និងខេត្តនានានៅទូទាំងប្រទេស ។ កាសែតនេះមាននិមិត្តសញ្ញាកំពូលប្រាសាទអង្គរវត្ត បោះពុម្ពអក្សរពណ៌សខ្មៅនិងក្រដាសស្តើង ។ នៅក្នុងរោងពុម្ពមានការយាមកាមយ៉ាងតឹងរ៉ឹង និងមិនអនុញ្ញាតឲ្យចេញចូលដោយសេរីឡើយ ។ រោងពុម្ពនេះស្ថិតក្រោមការគ្រប់គ្រងនិងពិនិត្យមើលពីសំណាក់កូនប្រុសរបស់ យាយអាត ឬ យាយយ៉ាត ប្រធានគ្រប់គ្រងរោងពុម្ពក-៣០ ។ ខ្ញុំធ្វើការនៅរោងពុម្ពកាសែតក-២៦ បានរយៈពេល១ឆ្នាំត្រូវអង្គការផ្លាស់ទៅធ្វើការនៅរោងពុម្ពក-៣០ ដោយសារតែខ្ញុំមិនសូវចេះការងារខាងកាសែត ជាពិសេស ខ្ញុំមិនចេះគុណនិងបូកលេខ ។

រោងពុម្ពក-៣០ស្ថិតនៅក្បែរវត្តកោះជាប់ផ្លូវមុនីវង្ស មានតួនាទីបោះពុម្ពទស្សនាវដ្តី ។ រោងពុម្ពនេះមានម៉ាស៊ីនចំនួន៣គ្រឿង គឺម៉ាស៊ីនកិប ម៉ាស៊ីនកាត់ និងម៉ាស៊ីនបោះពុម្ព ។ ខ្ញុំធ្វើការខាងផ្នែកចាប់ក្រដាសនិងចាប់អក្សរសម្រាប់បោះពុម្ព ។ ខ្ញុំចាប់អក្សរដាក់កាឡេ និងយកទឹកថ្នាំពណ៌ខ្មៅមកអូសនិងកៀរ ។ នៅពេលអូសហើយ មានអ្នកត្រួតពិនិត្យមើលម្តងទៀត បើអក្សរណាខុសត្រូវដកចេញហើយដាក់អក្សរត្រូវមកជំនួសវិញ ។ ខ្ញុំមានពេលដេកតិចតួចណាស់ ពីព្រោះទស្សនាវដ្តីចេញផ្សាយរាល់ថ្ងៃ ដូច្នេះត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ជួនពេលពេលខ្លះខកខានបោះ៣-៤ថ្ងៃ ពេលចាប់ផ្តើមបោះពុម្ពវិញគឺ ធ្វើការទល់ភ្លឺ ។ ប្រសិនបើនៅតាមខេត្តបញ្ជូនព័ត៌មានមកដល់ពេលយប់ ព្រឹកឡើងត្រូវតែចាប់ផ្តើមបោះពុម្ពភ្លាម ។ កម្មករនៅរោងពុម្ពក-៣០មានគ្នាទាំងអស់៣០នាក់ នារី២០នាក់និងបុរស១០នាក់ ។ ខ្លឹមសារនៅក្នុងទស្សនាវដ្តីគឺនិយាយតែព័ត៌មាននៅក្នុងស្រុក ដូចជាការបង្កបង្កើនផល មាគ៌ាបក្សនិងពាក្យស្លោកខ្មែរក្រហម ។ ទស្សនាវដ្តីត្រូវបានចែកចាយនៅតាមស្រុកនិងខេត្តទូទាំងប្រទេស ។ ទស្សនាវដ្តីមាននិមិត្តសញ្ញាទូលក្អម ក្របធ្វើអំពីក្រដាសរលោងព៌ណសនិងពណ៌ក្រហម ។ ពេលខ្លះខ្ញុំត្រូវបញ្ជូនទៅជួយបត់ក្រដាសកាសែតនៅរោងពុម្ពក-៣១មុំព្រះបរមរាជវាំង ហើយពេលខ្លះទៀតខ្ញុំទៅជួយបោះក្រដាសនិងចាប់ក្រដាសនៅ

រោងពុម្ពក-២៩ នៅក្បែរសាកលវិទ្យាល័យភូមិន្ទភ្នំពេញថែមទៀត ។ ក្រៅពីនោះមានរោងពុម្ពក-២៧ នៅជិតផ្សារថ្មី បោះពុម្ពសៀវភៅសិក្សាសម្រាប់ក្មេង ។ យាយយ៉ាត ឬយាយអាត គឺជាអ្នកក្តាប់រួមនិងមើលការខុសត្រូវរោងពុម្ពទាំងអស់នៅក្នុងទីក្រុងភ្នំពេញ មាន ជាអាទិ៍រោងពុម្ពក-២៦, ក-២៧, ក-២៩, ក-៣០ និងក-៣១ ។

ក្រៅពីការងារនៅរោងពុម្ព ខ្ញុំមានពេលសម្រាកតែ៣ថ្ងៃប៉ុណ្ណោះនៅរដូវចូលឆ្នាំខ្មែរនិងរដូវភ្ជុំបិណ្ឌក្នុង១ឆ្នាំ នៅពេលមានការសម្តែងសិល្បៈ ឬល្ខោនម្តងៗខ្ញុំមិនដែលហ៊ានទៅមើលតាមចិត្តទេ លុះត្រាតែអង្គការចាត់តាំងទើបខ្ញុំហ៊ានទៅ ។ ខ្ញុំធ្លាប់ទៅមើលសិល្បៈបាន២ដងនៅមហោស្រពជាតិបេនឡានិងមហោស្រពជាតិមាត់ទន្លេ(មហោស្រពឆេះសព្វថ្ងៃនេះ) ។ ល្ខោនកាលពីសម័យនោះសម្តែងតែពីភាពកម្សត់ ធ្វើបាបកម្មករ កម្មករត្រូវគេវាយទាត់ធាក់និងការងារពលកម្មផ្សេងៗ ។

នៅក្នុង១៩៧៨ ខ្ញុំធ្លាប់ចូលរួមប្រជុំពីរដងនៅបូរីកីឡាខណៈពេលខ្ញុំបម្រើការនៅរោងពុម្ពក-៣០ ។ ការប្រជុំនោះនិយាយតែអំពីរឿងប្រទេសជាតិនិងការវាយប្រយុទ្ធជាមួយខ្មាំងសត្រូវ និងនិយាយពីអ្នកចាញ់និងអ្នកឈ្នះ ។ ខ្ញុំឃើញ ប៉ុល ពត និង នួន ជា ឡើងនិយាយក្នុងអង្គប្រជុំ ចំណែក ខៀវ សំផន គ្រាន់តែអង្គុយអមប៉ុណ្ណោះ ។

៣ខែមុនពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅទទួលគណៈប្រតិភូនៅព្រលានយន្តហោះពោចិនតុងចំនួន២ដងជាមួយថ្នាក់ដឹកនាំធំៗ ។ លើកទី១ខ្ញុំទៅទទួលគណៈប្រតិភូចិននិងលើកទី២ខ្ញុំទៅទទួលគណៈប្រតិភូកូរ៉េ ។

ចុងឆ្នាំ១៩៧៨ នៅរោងពុម្ពក-៣០ មានការបញ្ចូលបុគ្គលិកថ្មី ហើយបុគ្គលិកចាស់ត្រូវបានដកចេញឲ្យទៅធ្វើការនៅជនបទ ។ ដោយឡែកអ្នកដែលខុសសីលធម៌ ដូចជានិយាយពាក្យសម្តីខុស ឬនិយាយលេងទល់មុខគ្នារវាងប្រុសនិងស្រី ឬសរសេរសំបុត្រស្នេហា ត្រូវបានចាត់ទុកថាខុសសីលធម៌ ហើយត្រូវបញ្ជូនទៅកាន់ទីជនបទ ប៉ុន្តែធាតុពិតអ្នកទាំងនោះត្រូវបានយកទៅសម្លាប់ចោល ។ ដំបូងខ្ញុំមិនសូវជាចាប់អារម្មណ៍នឹងពាក្យ «បញ្ជូនទៅជនបទ» នោះទេ ប៉ុន្តែនៅយូរៗទៅខ្ញុំចេះតែស៊ើបសួរទើបដឹងថា អ្នកទាំងនោះត្រូវបញ្ជូនយកទៅសម្លាប់ ។ ខ្ញុំធ្លាប់តែធ្វើការនៅភ្នំពេញទទួលរបបអាហារហូបគ្រាប់គ្រាន់ មិនដែលឃើញព្រឹត្តិការណ៍ធ្វើទារុណកម្ម ឬកាប់សម្លាប់មនុស្សពីសំណាក់ខ្មែរក្រហមផ្ទាល់ភ្នែកឡើយ ។ ខ្ញុំមិនដឹងថា ខ្មែរក្រហមធ្វើបាបប្រជាជនយ៉ាងណានោះទេ ហើយក៏មិនដឹងថា នៅតាមសហករណ៍ប្រជាជនហូបបបរចានចង្កឹះនិងធ្វើការធ្ងន់ហួសកម្លាំងរហូតក្បាលជង្គង់ធំជាងក្បាលនោះដែរ ។ ខ្ញុំទើបតែដឹងច្បាស់បណ្តើរៗ ពេលដែលខ្ញុំរត់គេចខ្លួនទៅកាន់ខេត្តពោធិ៍សាត់មុនពេលដែលកងទ័ពវៀតណាមចូលដល់ទីក្រុងភ្នំពេញនៅដើមឆ្នាំ១៩៧៩ ។ ពេលនោះ ខ្ញុំធ្វើដំណើរដោយថ្មើរជើងរហូតទៅដល់អមលាំង ខេត្តកំពង់ស្ពឺ រួចបន្តដំណើរទៅដល់ខេត្តពោធិ៍សាត់ ។ ខ្ញុំឡើងភ្នំអស់រយៈ២០ថ្ងៃជាមួយប្រជាជនរាប់ម៉ឺននាក់ អ្នកខ្លះស្លាប់ដោយអត់អាហារ ដោយផ្ទុះមីន និងរបួសនៅជើងភ្នំ ទើបមកដល់ស្រុកកំណើតវិញ ។

ខ្ញុំបម្រើការងារជូនអង្គការយ៉ាងប្តូរផ្តាច់នៅរោងពុម្ព ហើយខ្ញុំតែងតែគិតថារបបខ្មែរក្រហមជារបបល្អសម្រាប់ខ្លួនខ្ញុំ ។ នៅពេលដែលខ្ញុំត្រឡប់មកដល់ផ្ទះកំណើតនៅជនបទទើបដឹងថា ឪពុកនិងឪពុកមាស្លាប់អស់ ។ ឪពុកខ្ញុំស្លាប់ដោយសារតែធ្វើការធ្ងន់ហួសកម្លាំងនៅឆ្នាំ១៩៧៧ ។ ខ្ញុំភ្ញាក់ខ្លួនលាយឡំនឹងទឹកភ្នែកនឹកស្តាយពីការខំប្រឹងរបស់ខ្ញុំដែលខំធ្វើការទាំងយប់ទាំងថ្ងៃ អត់ងងុយដើម្បីអង្គការ ។ ប៉ុន្តែខ្ញុំមិនបានទទួលផលប្រយោជន៍អ្វីទេ បានត្រឹមតែរស់នៅក្នុងភាពងងឹត មិនដឹងធាតុពិតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងនាមខ្ញុំដែលធ្លាប់ឆ្លងកាត់របបនេះ ខ្ញុំបាននិយាយប្រាប់ពីការលំបាកនៅក្នុងសម័យនោះប្រាប់កូនចៅជំនាន់ក្រោយឲ្យដឹង ប៉ុន្តែវាបែរជាមិនជឿ បើទោះបីជាមើលកុនឯកសារពីរបបកម្ពុជាប្រជាធិបតេយ្យឃើញការកាប់សម្លាប់យ៉ាងណាក៏ពួកវាមិនជឿ ហើយថែមទាំងពោលពាក្យថា «មិនជឿទេ! ចុះបើពិបាកម៉េចរស់» ។ ហេតុដូច្នេះខ្ញុំចង់ឲ្យមានការបង្រៀនអំពីប្រវត្តិសាស្ត្រនៅតាមសាលារៀននិងឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រព្រឹត្តទៅដោយជោគជ័យនិងផ្តល់យុត្តិធម៌ជូនខ្ញុំក៏ដូចជាជនរងគ្រោះដទៃទៀត» ។

**លឿង សុភ័ក្ត**

# ក្រុមយុវជនចាមមូស្លីមនិងយុវនិស្សិតច្បាប់ ស្វែងយល់ពីអំពើប្រល័យពូជសាសន៍និងសាលាក្ដីខ្មែរក្រហម

កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៧ យុវជនចាមមូស្លីមចំនួន១០០នាក់(សិស្សនិងនិស្សិត) បានចូលរួមទស្សនកិច្ចសិក្សាទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជើងឯក ហើយនៅថ្ងៃបន្ទាប់មានយុវនិស្សិតច្បាប់មួយក្រុមទៀតចំនួន៣៥០នាក់មកសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក៏បានចូលរួមជាមួយក្រុមយុវជនចាមមូស្លីមក្នុងកម្មវិធីទៅទស្សនាអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ឬសាលាក្ដីខ្មែរក្រហម)ដែរ ។ ដំណើរទស្សនកិច្ចលើកនេះខុសគ្នាបន្តិចពីលើកមុនៗ លើកនេះ ផ្ដោតសំខាន់លើយុវវ័យដែលស្ថិតក្នុងវ័យចន្លោះពី១៧-២៥ឆ្នាំ ដែលកើតក្រោយរបបប្រល័យពូជសាសន៍ ។ ក៏ប៉ុន្តែគោលបំណងនៃដំណើរទស្សនកិច្ចនៅដដែល គឺសង្កត់ធ្ងន់ទៅលើការអប់រំប្រជាជនកម្ពុជាពីអំពើប្រល័យពូជសាសន៍ និងផ្ដល់តួនាទីដល់ប្រជាជននៅក្នុងដំណើរការសាលាក្ដីខ្មែរក្រហម ។

អស់រយៈកាលជិត៣០ឆ្នាំបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានៅតែមិនទាន់ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិនៅឡើយ ។ អ្វីដែលក្មេងជំនាន់ក្រោយបានដឹងទាក់ទងនឹងអំពើប្រល័យពូជសាសន៍គឺដឹងតាមតែរយៈការនិយាយប្រាប់របស់ឪពុកម្ដាយប៉ុណ្ណោះ ។ បញ្ហាតុលាការ ជាប្រធានបទមួយដែលធ្វើឲ្យមានការនឿយណាយសម្រាប់អ្នកតាមដានដំណើរការចរចាដ៏គ្មានគីងវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជានៅក្នុងរយៈកាល៩ឆ្នាំកន្លងមកនេះ ។ អ្នកខ្លះបានបោះបង់ចោលក្ដីសង្ឃឹមក្នុងការតាមដានព្រឹត្តិការណ៍នេះ ។ យ៉ាងណាមិញរដូវក្ដៅនៃឆ្នាំ២០០៦ បាននាំមកនូវក្ដីសង្ឃឹមថ្មីក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមមកកាត់ទោសជាមួយនឹងការចាប់ផ្ដើមដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញនៅពេលនេះបានក្លាយទៅជាប្រធានបទដ៏ចម្បងនៅក្នុងទំព័រសារព័ត៌មានក្នុងស្រុក ។

ថ្ងៃទី១នៃដំណើរទស្សនកិច្ចនេះត្រូវបានរៀបចំដោយកញ្ញា សូ ហ្វារីណា ជាប្រធានកម្មវិធីប្រវត្តិសាស្ត្រផ្ទាល់មាត់របស់ជនជាតិចាមមូស្លីមនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ យុវជនចាមមូស្លីមទាំងនេះមកពីខេត្តក្រុងចំនួន១១ ដែលរួមមាន ខេត្តកណ្ដាល ខេត្តកំពង់ចាម ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកំពត ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ ខេត្តក្រចេះ ខេត្តពោធិ៍សាត់ ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ ។ នេះជាលើកទីមួយសម្រាប់យុវជនចាមមូស្លីមក្នុង


និស្សិតច្បាប់ទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ការមកទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងបូជនីយដ្ឋានប្រល័យពូជសាសន៍ជើងឯក ។

កម្មវិធីចាប់ផ្ដើមនៅម៉ោង១និង៣០នាទីរសៀល គឺនៅពេលដែលនិស្សិតធ្វើដំណើរមកដល់សារមន្ទីរគុកទួលស្លែង ។ យុវ-និស្សិតស្រីខ្លះស្លៀកសម្លៀកបំពាក់ប្រពៃណីជនជាតិចាម ។ ជាមួយកន្សែងរុំក្បាលពណ៌ខ្មៅ កញ្ញា ហ្វារីណា បាននាំក្រុមនិស្សិតទៅកាន់អគារ“ក”និងពន្យល់ប្រាប់ពីប្រវត្តិនៃសារមន្ទីរ ។

នៅក្នុងសម័យសង្គមរាស្ត្រនិយមចន្លោះទសវត្សរ៍ឆ្នាំ ១៩៥០ និង១៩៦០ សារមន្ទីរគុកទួលស្លែងជាអតីតវិទ្យាល័យមួយឈ្មោះវិទ្យាល័យពញាយ៉ាត ។ បន្ទាប់ពីរដ្ឋប្រហារនាដើមឆ្នាំ១៩៧០ វិទ្យាល័យនេះត្រូវបានប្តូរឈ្មោះទៅជាវិទ្យាល័យទួលស្វាយព្រៃ ។ រយៈពេលខ្លីបន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច និងជម្លៀសប្រជាជនឲ្យទៅតាំងលំនៅតាមជនបទ វិទ្យាល័យនេះត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំងនិងសួរចម្លើយវិញ ។ កម្មាភិបាលថ្នាក់ដឹកនាំរបស់ខ្មែរក្រហម បានដាក់ឈ្មោះថ្មីឲ្យវិទ្យាល័យនេះថា "មន្ទីរស-២១" ដែលជាមន្ទីរសន្តិសុខកម្រិតខ្ពស់ក្នុងចំណោមមន្ទីរសន្តិសុខខ្មែរក្រហមទាំង១៩៨កន្លែងដែលមាននៅទូទាំងប្រទេសនៅចន្លោះឆ្នាំ១៩៧៥និង១៩៧៩ ។ អ្នកទោសប្រមាណ២ម៉ឺននាក់បានឆ្លងកាត់ខ្លោងទ្វារគុកនេះ ។ អ្នកទោសទាំងនោះត្រូវបាននាំចូលមកជាក្រុមដោយបិទមុខ ដោយការបំភ័ន្ត និងការបំភិតបំភ័យ ។ អ្នកទោសត្រូវបានថតរូបដោយអ្នកថតរូបម្នាក់ក្នុងចំណោមអ្នកថតរូប៦នាក់ មុនពេលដែលអ្នកទោសទាំងនោះត្រូវនាំទៅសួរចម្លើយពី"បទល្មើស"របស់ខ្លួន ។ អំពើដែលចាត់ទុកថាជាបទល្មើសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានលួចអង្ករនិងមិនព្រមរៀបការជាមួយមនុស្សចម្លែក (មនុស្សដែលមិនធ្លាប់ស្គាល់) ។ មានអ្នកទោសតិចតួចណាស់ ដែលបានរួចផុតពីមន្ទីរនេះ ។ សារមន្ទីរនេះជាកន្លែងគួរឲ្យភ័យខ្លាច សាហាវឃោរឃៅ និងកន្លែងសម្លាប់ដែលវិលវល់ពេញប្រទេស ក្នុងអំឡុងពេល៣ឆ្នាំ៨ខែនិង២០ថ្ងៃនៃរបបដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ។



យុវជនចាមមូស្លីមដើរទស្សនាអគារទាំងបួននៃសារមន្ទីរដែលមានរូបថតទស្សន៍ ពិព័រណ៍រូបថត បន្ទប់គុកធ្វើពីថ្មនិងឈើ និងលលាដ៏ក្បាលតម្កល់នៅក្នុងអតីតបន្ទប់រៀនទាំងនោះ ។ យុវសិស្សខ្លះ មានការរំជួលចិត្តចំពោះអ្វីដែលពួកគេបានឃើញ ហើយយុវនិស្សិតខ្លះទៀតមើលទិដ្ឋភាពទាំងនោះក្នុងភាពភ្ញាក់ផ្អើលតាមរបៀបកូនក្មេងដែលចង់ដឹងចង់ឮនូវអ្វីមួយ ។

តាមកាំជណ្តើរខាងក្រៅអគារ"គ" ខាងក្រោមលួសបន្លាដែលព័ទ្ធស្ទើរតែពេញផ្នែកខាងមុខអគារ ហ្វារីណា សម្មាសនិស្សិតម្នាក់ឈ្មោះ លី ម៉ី អាយុ២០ឆ្នាំ និងជាកូនច្បងក្នុងចំណោមបងប្អូន៨នាក់ ។ ទោះបីជានាងទើបតែរៀនបានត្រឹមថ្នាក់ទី១២ ម៉ីនិយាយពីអំពើប្រល័យពូជសាសន៍និងសាលាក្តីប្រកបដោយការយល់ដឹងភាពស្មោះត្រង់និងប៉ិនប្រសប់ ។

មុនពេលមកដល់សារមន្ទីរ ម៉ី មិនបានឲ្យតម្លៃខ្ពស់លើដំណើរទស្សនកិច្ចនេះទេ ។ ម៉ី គិតទុកថា ខ្លួននឹងបានឃើញរូបថតដែលនៅសល់ពីរបបខ្មែរក្រហម និងទទួលបានចំណេះដឹងបន្តិចបន្តួចប៉ុណ្ណោះ ។ នៅពេលដើរកាត់ជួររូបថតអ្នកទោសមន្ទីរស-២១ ម៉ីរំជួលចិត្តយ៉ាងខ្លាំង ។ ម៉ី ប្រាប់ថា "ខ្ញុំស្ទើរតែស្រក់ទឹកភ្នែកទៅហើយ ហើយមិនដែលនឹកស្រម៉ៃថាទិដ្ឋភាពនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩មានសភាពសាហាវយ៉ាងដូច្នេះទេ" ។ ការមកទស្សនាសារមន្ទីរនេះពិតជាបានបង្ហាញឲ្យ ម៉ី ដឹងថា ប្រជាជនឈឺចាប់ដល់កម្រិតណា ។ ថ្វីបើមុនពេលចូលរួមដំណើរទស្សនកិច្ចនេះ ម៉ីជឿថាពិតជាមានអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏ការឃើញនឹងភ្នែកនូវវត្ថុតាងនៅសារមន្ទីរបានផ្សារភ្ជាប់ទៅនឹងរឿងរ៉ាវដែលឪពុកម្តាយបានប្រាប់មែន ។ ម៉ី បន្តថា កាលពីក្មេងឪពុកម្តាយនិងគ្រូបង្រៀនរបស់ខ្លួនក៏ធ្លាប់និយាយប្រាប់ពីប្រវត្តិជីវិតរបស់ពួកគាត់នៅក្នុងរបបនោះដែរ ។ ម៉ី ប្រាប់អ្នកគ្រូថា មិនជឿទេ ហើយអ្នកគ្រូបានឲ្យ ម៉ី ទៅសួរឪពុកម្តាយ ។ ឪពុកម្តាយរបស់ ម៉ី បានបញ្ជាក់បន្ថែមលើអ្វីដែលគ្រូរបស់ ម៉ី បាននិយាយទៀត ។

ឪពុករបស់ ម៉ី ឈ្មោះ ឯល ជប់ ជាអតីតអ្នកថែក្របីនៅក្នុងរបប ប៉ុល ពត ។ ការងារនេះ ក៏ដូចជាការងារផ្សេងទៀតដែរដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើនៅពេលនោះដែលអាចកំណត់ពីជោគវាសនារបស់មនុស្ស ។ កំហុសមួយគឺអាចនាំឲ្យអ្នកបាត់បង់ជីវិតបាន ។ ដូចជាករណីឪពុករបស់ ម៉ី, ការធ្វើឲ្យបាត់ក្របីមួយមានន័យថា ជាការបាត់ជីវិតរបស់គាត់ ។ ជាអកុសល ក្របីមួយក្បាលបានបាត់ចេញពីហ្វូង ។ ប្រធានក្រុមបានទុកពេលឲ្យឪពុក ម៉ី រយៈពេល៣ថ្ងៃដើម្បីរកក្របីនោះឲ្យឃើញ ។ ឯល ជប់

ដឹងថាគាត់នឹងត្រូវសម្លាប់ប្រសិនបើគាត់រកក្របីនោះមិនឃើញ ក្នុងរយៈពេល៣ថ្ងៃ ។ ជប់ រកក្របីនោះមិនឃើញសោះ គាត់បានត្រៀមខ្លួនជាស្រេចដើម្បីស្លាប់ ។ ប្រហែលជាមកពីភាពអាណិត ទើបប្រធានក្រុមសម្រេចទុកឲ្យគាត់មានជីវិតរស់បន្តទៀត ។ ជប់ ត្រូវទទួលពិន័យឲ្យទៅវែកដីនិងថ្មដោយមិនបានទទួលរបបអាហារមួយរយៈពេល ។ ជប់ អាចរស់រានជីវិតបានដោយការចាប់ក្តាមហូបនៅពេលយប់ ។ ជប់ មិនដែលជឿថាគាត់អាចរស់រានមានជីវិតនៅក្នុងរបបនោះឡើយ ។ ច្រើនទសវត្សរ៍បន្ទាប់មក ឪពុករបស់ មុី ពិតជាមានការពិបាកក្នុងការនិយាយពីអតីតកាលរបស់គាត់ប្រាប់កូនណាស់ ។

ចំណែកពូរបស់ មុី វិញ ស្លាកស្នាមរបស់គាត់ពីរបបប្រល័យពូជសាសន៍មានទាំងខាងផ្លូវចិត្តនិងផ្លូវកាយ ។ គេ រូសាត ជាកុមារនិងធ្វើការកើបអាចម៍គោដើម្បីធ្វើជី ។ នៅថ្ងៃមួយ គាត់ត្រូវបានចោទប្រកាន់ពីបទលួចទឹកត្នោត ។ មុី និយាយថាខ្មែរក្រហមបានវាយពូរបស់ខ្លួនស្ទើតែករម្រើកខ្លួនមិនរួច បន្ទាប់មកក៏ចាប់គាត់ចងព្យួរជើងឡើងលើដើម្បីបង្ហាញឲ្យប្រជាជនមើល ។ ចាប់តាំងពីពេលនោះមក ភ្នែករបស់គាត់អាចមើលឃើញព្រិលៗ ហើយអាចធ្វើតែកិច្ចការណាស្រាលៗប៉ុណ្ណោះ ។ រាល់លើកនៅពេលដែល រូសាត ព្យាយាមរំឭកពីប្រវត្តិជូរចត់របស់ខ្លួន គាត់តែងស្រក់ទឹកភ្នែកជានិច្ច ។

ហ្វារីណា សួរពីគំនិតរបស់ មុី ថាតើខ្មែរក្រហមមានគោលនយោបាយខុសគ្នាចំពោះជនជាតិភាគតិចចាម និងជនជាតិខ្មែរឬយ៉ាងណា ។ មុី និយាយថានៅខេត្តស្វាយរៀង ប្រជាជនខ្មែរត្រូវបានដាក់ឲ្យរស់នៅផ្សេងពីជនជាតិចាមនិងត្រូវបាននាំយកទៅសម្លាប់ ។ ប្រជាជន(ខ្មែរ) ទាំងនោះត្រូវបានប្រមូលផ្តុំគ្នារាប់ពាន់នាក់ដាក់តាមរថភ្លើងហើយបញ្ជូនទៅសម្លាប់នៅកន្លែងផ្សេង ។ មុី ជឿថា នៅទីនោះជនជាតិខ្មែរស្លាប់ច្រើនជាងជនជាតិចាម ។ ជនជាតិចាមត្រូវបានសម្លាប់ ដោយចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ឬបានប្រឆាំងនឹងបញ្ជារបស់ថ្នាក់លើ ចំណែកជនជាតិខ្មែរវិញត្រូវបានយកទៅសម្លាប់រាប់ពាន់នាក់តាមបញ្ជារបស់ថ្នាក់លើ ។

នៅពេលសួរពីសាលាក្តីខ្មែរក្រហម មុី បានបញ្ជាក់ពីគំនិតច្របូកច្របល់គ្នា ។ មុី ចង់ដឹងការពិតពីអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងអស់នោះ ហើយនាងសប្បាយចិត្តពីការដែលអង្គការសហប្រជាជាតិកំពុងជួយប្រទេសកម្ពុជា ព្រោះថាបន្ទាប់មកអ្វីៗនឹងប្រព្រឹត្តទៅនៅក្រោមច្បាប់ ។ នៅពេលសួរថាតើអ្នកណាខ្លះដែលត្រូវទទួលការកាត់ទោស មុី និយាយថាពិបាកឆ្លើយណាស់ មនុស្សជាច្រើនបានធ្វើតាមបញ្ជាគេនៅពេលនោះ ហើយអ្នកទាំងនោះនឹងមានគ្រោះថ្នាក់ប្រសិនបើមិនស្តាប់បញ្ជា ។ គឺមេដឹកនាំដែលជាអ្នកចេញបទបញ្ជា ឬគំនិតក្នុងការធ្វើទារុណកម្ម ឬសម្លាប់មនុស្ស ។ មុី បង្អង់បន្តិច បន្ទាប់មកនិយាយថា ខ្លួនក៏មិនច្បាស់ថាយុត្តិធម៌នឹងមានសម្រាប់ជនរងគ្រោះដែរ ដោយលើកហេតុផលថា អំពើប្រល័យពូជសាសន៍បានកើតឡើងរយៈយូរមកហើយ និងថាវាមានឧបសគ្គជាច្រើនក្នុងដំណើរការតុលាការ ។ មុី សង្ឃឹមថានឹងមិនមានការពន្យារពេលទៀតទេ និងសង្ឃឹមថាមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញនឹងប្រឹងប្រែងអស់ពីសមត្ថភាពនិងស្វែងរកការពិតជូនប្រជាជន ដែលកំពុងរង់ចាំស្តាប់នូវសវនាការដំបូង ។ ចំពោះមុីយល់ថា ប្រសិនបើតុលាការនេះដំណើរការទៅបានសម្រេច វានឹងផ្តល់នូវយុត្តិធម៌បន្តិចបន្តួចដល់ជនរងគ្រោះតែប៉ុណ្ណោះ ព្រោះថាយុត្តិធម៌នឹងមិនអាចលុបបំបាត់នូវការឈឺចាប់ដែលជនរងគ្រោះបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមបានទេ «វានឹងនៅតែដក់ជាប់ក្នុងចិត្តរបស់ជនរងគ្រោះជានិច្ច» ។

យុវនិស្សិតអាយុ២១ឆ្នាំ សុខ វាសនា ក៏មានការគិតទុកជាមុនពីសាលាក្តីខ្មែរក្រហមដែរ ។ ដូចគ្នានិង លី មុី, វាសនា ធ្លាប់ឮព័ត៌មានពីសាលាក្តីខ្មែរក្រហមដែរ ។ បន្ទាប់ពីបានស្តាប់ការផ្សាយតាមវិទ្យុនៅពេលថ្មីៗនេះ វាសនា យល់ថាបញ្ហាដែលសាលាក្តីដែលកំពុងជួបប្រទះមិនមែនបញ្ហាថវិកាទេ គឺបញ្ហាដែលភាគីទាំងសងខាង(ខ្មែរនិងបរទេស) ត្រូវសហប្រតិបត្តិការគ្នា ។ វាជាការពិបាកសម្រាប់ភាគីទាំងពីរក្នុងការធ្វើការជាមួយគ្នាដោយយោងលើហេតុផលមួយចំនួន ដែលជាហេតុធ្វើឲ្យភាគីទាំងសងខាងត្រូវចំណាយពេលច្រើនដើម្បីស្រុះស្រួលគ្នាក្នុងការបំពេញការងារ ។ ចំណែកមួយនៃបញ្ហានេះគឺការស្វែងយល់ពីអ្វីដែលបានកើតឡើងនៅក្នុងរបប ប៉ុល ពត ។ វាសនា គិតថាការមកទស្សនាសារមន្ទីរទួលស្លែងគឺជាការធម្មតាទេសម្រាប់ខ្លួនដំបូង ។ នៅពេលដើរឆ្លងកាត់ខ្លោងទ្វារ វាសនា មានអារម្មណ៍ធម្មតាដូច

សព្វថ្ងៃ ។ ប៉ុន្តែ ពេលដើរចូលដល់អគារនិងបានឃើញនូវរូបថតនៅតាមបន្ទប់នីមួយៗ វាសនា ចាប់ផ្តើមរួលដើមកខំទប់អារម្មណ៍និងទប់ទឹកភ្នែកដែលបម្រុងនឹងហូរចេញមក ។ វាសនា នឹកឃើញដល់ជីដូនជិនិងជីតារបស់ខ្លួនដែលស្លាប់នៅក្នុងរបបខ្មែរក្រហមដោយមិនធ្លាប់បានឃើញមុខ ។

វាសនា ធ្លាប់បានឮពីរបបប្រល័យពូជសាសន៍នេះតាមរយៈការរៀបរាប់ប្រាប់ពីឪពុកម្តាយកាលពីខ្លួននៅក្មេង ។ ឪពុករបស់ វាសនា ប្រាប់ថា អំឡុងពេលនោះគឺជាពេលដែលពិបាកបំផុតនៅក្នុងខ្សែជីវិតរបស់គាត់ ពីព្រោះគាត់គ្មានសិទ្ធិសេរីភាពគ្មានអាហារ ហើយសូម្បីតែអំបិលញាំុក៏គ្មានដែរ ។ ឪពុករបស់ វាសនា ត្រូវបានបង្ខំឲ្យទៅធ្វើការនៅកងកុមារ ហើយគាត់ត្រូវក្រោកពីព្រលឹមរៀងរាល់ថ្ងៃដើម្បីទៅធ្វើការ ។ នៅពេល វាសនា អាយុបាន១៨ឆ្នាំ គ្រូបង្រៀនក៏បាននិទានពីប្រវត្តិរបស់គាត់នៅក្នុងសម័យខ្មែរក្រហមប្រាប់ដែរ ហើយខ្លួនចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងជំពូកនៃប្រវត្តិសាស្ត្រកម្ពុជានេះ ។ ចំណែក ឯល យ៉ាគីន អាយុ២០ឆ្នាំ មានយោបល់ថា នាងចង់ឲ្យមានការបញ្ចូលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីអប់រំថ្នាក់ជាតិ ពីព្រោះនេះជាមធ្យោបាយមួយដើម្បីទប់ស្កាត់កុំឲ្យរបបប្រល័យពូជសាសន៍កើតមានម្តងទៀត ។

បន្ទាប់ពីបានទស្សនាសារមន្ទីរទួលស្លែងរួចហើយ យុវ-និស្សិតទាំងនោះបានបន្តដំណើរទស្សនកិច្ចទៅបូជនីយដ្ឋានតម្កល់អដ្ឋិធាតុជើងឯក ។ យុវជនចាមមូស្លីមបានដើរបែកខ្ញែកគ្នាជាក្រុមៗដើម្បីដើរមើលជុំវិញវាលពិឃាដនោះ ។ រយៈពេល៤៥នាទីក្រោយមក ហ្វារីណា បានហៅអ្នកទាំងអស់ឲ្យមកជួបជុំគ្នានៅកន្លែងសម្រាក ដើម្បីពន្យល់អំពីគម្រោងដល់អ្នកចូលរួមទាំងអស់ ។ គម្រោងនេះជាផ្នែកមួយនៃគម្រោងស្រាវជ្រាវទាំងមូលស្តីពីសហគមន៍ចាមមូស្លីមនិងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ហ្វារីណា និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបែកគាពងស្មុំមតិដែលមានសំណួរជាច្រើនទាក់ទងនឹងរបបខ្មែរក្រហម ការយល់ដឹងអំពីយុត្តិធម៌ និងយោបល់ជុំវិញអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ។ លើសពីនេះទៀត ដោយសង្ឃឹមនឹងទាក់ទាញចំណាប់អា-រម្មណ៍ នៅក្នុងរបបខ្មែរក្រហមនិងជំរុញឲ្យមានការប្រាស្រ័យទាក់ទងគ្នារវាងឪពុកនិងកូនលើប្រធានបទនេះ ហ្វារីណា បានពិភាក្សាជាមួយក្រុមយុវជនអំពីការប្រកួតប្រជែងក្នុងការចងក្រងសាច់រឿង ។ បន្ទាប់មកបានប្រគល់សៀវភៅមួយក្បាលនិងប៊ិចមួយដើមដល់យុវជនម្នាក់ៗ ។ យុវជនទាំងអស់ត្រូវបានស្នើឲ្យសរសេរសាច់រឿងស្តីពីបទពិសោធន៍របស់ឪពុកម្តាយខ្លួនក្នុងអំឡុងឆ្នាំ ១៩៧៥ - ១៩៧៩ ដោយមិនមានកំណត់ទំព័រ ។ សាច់រឿងដែលជាប់ចំណាត់ថ្នាក់នឹងចុះផ្សាយក្នុងទស្សនាវដ្តីសម្រាប់សហគមន៍ប្រចាំត្រីមាសទី២និងលេខបន្តបន្ទាប់ទៀត ។ បន្ទាប់មកយុវ-សិស្ស-និស្សិតម្នាក់ៗទទួលបានទស្សនាវដ្តីស្វែងរកការពិតមួយច្បាប់សម្រាប់អានដើម្បីឲ្យយល់ដឹងពីសាច់រឿងរបស់អ្នកដែល


ក្រុមនិស្សិតនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានៅបូជនីយដ្ឋានបឹងជើងឯក

រស់រានមានជីវិតពីរបបខ្មែរក្រហម ។

សិស្សទាំងអស់ហាក់ដូចជារំភើបចិត្តនៅពេលស្តាប់ពត៌មានគម្រោងនោះ ហើយថែមទាំងបានសួរសំណួរជាច្រើនមកកាន់អ្នកដឹកនាំគម្រោង ។ ហ្វារីណា បានបកស្រាយនូវចម្ងល់ទាំងឡាយហើយបានពន្យល់បន្ថែមដើម្បីឲ្យសិស្សទាំងអស់ងាយយល់ ។

នៅថ្ងៃទី២ និស្សិតច្បាប់និងយុវជនចាមមូស្លីមបានជួបជុំគ្នានៅបន្ទប់សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រុមនិស្សិតត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ពីមន្ត្រីព័ត៌មាន លោក រាជ សម្បត្តិ, លោកស្រី ជា លាង សហព្រះរាជអាជ្ញាខ្មែរ, និងកញ្ញា ដាមេឡា រីស្ស ជាជំនួយការជាន់ខ្ពស់នៃការិយាល័យសហព្រះរាជអាជ្ញា ។ វាគ្មិនកិត្តិយសបានបកស្រាយលើប្រធានបទផ្សេងៗគ្នាទាក់ទិននឹងសាលាក្តីខ្មែរក្រហម និងបានឆ្លើយនូវសំណួររបស់ក្រុមនិស្សិតផងដែរ ។

ការប្រជុំចាប់ផ្តើមនៅម៉ោង៩ៈ១៥នាទី ចម្រៀងចាប៉ីដងវែងប្រគំឡើងមុនពេលលោក រាជ សម្បត្តិ ស្វាគមន៍ការមកដល់របស់និស្សិត ។ លោក រាជ សម្បត្តិ, ចិន ហែមវិចិត្រ (ជំនួយការលោក រាជ សម្បត្តិ) និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកកូនសៀវភៅពណ៌ទឹកប៊ិចស្តីពីសំណួរចម្លើយជុំវិញសាលាក្តីខ្មែរក្រហមដល់និស្សិតទាំងអស់ ។ បន្ទាប់មកលោក រាជ សម្បត្តិ ចាប់ផ្តើមនិយាយអំពីរចនាសម្ព័ន្ធសវនាការផ្នែកផ្សេងៗរបស់អង្គជំនុំជម្រះវិសាមញ្ញនិងនិយាយពីការវិវត្តន៍ថ្មីរបស់អង្គជំនុំជម្រះវិសាមញ្ញ និងបានពន្យល់អំពីផ្ទាំងរូបភាពផ្សព្វផ្សាយទាំង ៤ ដែលមានលោក ភីធ័រ ហ្វុសទ័រ មន្ត្រីកិច្ចការសាធារណៈតំណាងឲ្យខាងអង្គការសហប្រជាជាតិ ជាអ្នកលើកបង្ហាញ ។ លោក រាជ សម្បត្តិ បានចោទសួរនិស្សិតបីបួនសំណួរដែលជាសំណួរកូនៗរបស់គាត់តែងតែសួរគាត់ ។ សំណួរទី១ «ប្រសិនបើប៉ុលពតហូបតែបបររាវៗរាល់ថ្ងៃ តើមានកម្លាំងឯណាដឹកប្រឡាយបានជ្រៅម្ល៉េះ?» សិស្ស-និស្សិតជាច្រើននាំគ្នាសើចនៅពេលឮសំណួរនេះ ។ សំណួរមួយទៀតសួរថា «នៅពេលដែលគេធ្វើឲ្យយើងឈឺនិងវាយដំហេតុអីបានជាយើងមិនតដៃ?» ជាថ្មីម្តងទៀត និស្សិតទាំងអស់នាំគ្នាសើចតិចៗ ។ ការណ៍នេះប្រហែលមកពីពួកគេធ្លាប់សួរសំណួរទាំងនេះដល់ឪពុកម្តាយរបស់គេក្រោយពីបានស្តាប់រឿងរ៉ាវប្រល័យពូជសាសន៍ ។ លោក សម្បត្តិ បានពន្យល់បន្ថែមទៀតអំពីការលំបាកទាក់ទិននឹងការគេចវេះឬគបគរបស់កម្មាភិបាលខ្មែរក្រហម ។

ដោយមានសំណួរត្រៀមទុកជាស្រេច និស្សិតកម្ពុជាបានដើរតម្រង់ទៅក្បាលមីក្រូហ្វូន និយាយណែនាំខ្លួន ថ្លែងអំណរគុណដល់វាគ្មិននិងចោទជាសំណួរឡើង ។ ឡាយ បុទ្ធី និស្សិតច្បាប់និងជាអ្នកដឹកនាំក្រុមនិស្សិតមកពីសាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានសួរសំណួរមុនគេបង្អស់ ។ បុទ្ធី បានចាប់



លោក រាជ សម្បត្តិ ជួបសំណេះសំណាលជាមួយក្រុមនិស្សិតនៅមុខរូបចម្លាក់

ផ្តើមសង្ខេបសេចក្តីដែលដកស្រង់ចេញពីវិទ្យុFM93.5MHz ទាក់ទងនឹងការពន្យារពេលសម្រេចវិធានផ្ទៃក្នុង ។ បុទ្ធី ចង់ដឹងថាតើការពន្យារពេលជាលទ្ធផលនៃអំពើពុករលួយនិងអសមត្ថភាពក្នុងការសហការគ្នារវាងចៅក្រមជាតិនិងអន្តរជាតិដូចដែលកម្មវិធីវិទ្យុខាងលើបានផ្សព្វផ្សាយដែរឬទេ? លោក ដូស៊័រ បានឆ្លើយតបនឹងសំណួរនេះថា ក្នុងរយៈពេលដ៏ខ្លីនេះចៅក្រមទាំងសងខាងនឹងជួបគ្នានៅការិយាល័យរដ្ឋបាលដើម្បីពិភាក្សាវិធានផ្ទៃក្នុង និងបញ្ហាជាច្រើននឹងត្រូវបានដោះស្រាយនៅចុងសប្តាហ៍នេះ ហើយនៅថ្ងៃទី១៦ ខែមីនានេះនឹងមានសន្និសីទកាសែតមួយ ដើម្បី

ពិភាក្សាពីលទ្ធផលនៃការប្រជុំ ។ សំណួរជាច្រើនទៀតបានចោទសួរអំពីនិយមន័យ"អ្នកទទួលខុសត្រូវខ្ពស់បំផុត" ហេតុអ្វីបានជាច្បាប់កម្ពុជានិងច្បាប់អន្តរជាតិចាំបាច់ប្រៀបបញ្ចូលគ្នា ដើម្បីអនុវត្តជាជាងប្រើប្រាស់ច្បាប់អន្តរជាតិសុទ្ធដូចជាករណីតុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងកាលៈទេសៈផ្សេងៗទាក់ទិននឹងការមិនយល់ស្របរវាងចៅក្រមជាតិនិងអន្តរជាតិ ។

និស្សិតម្នាក់សួរសំណួរដាច់ដោយឡែកពីសំណួរខាងលើដោយបន្លាញថា តុលាការខ្មែរក្រហម ដូចដែលមានឈ្មោះជាផ្លូវការថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" បង្កើតឡើងដើម្បីវិនិច្ឆ័យទោសអតីតមេដឹកនាំខ្មែរក្រហម ។ ហេតុដូច្នេះតើយើងគួរបង្កើតតុលាការមួយទៀតដើម្បីកាត់ក្តីរវាងប្រទេសនិងប្រទេសឬជនបរទេសដែលបានគាំទ្ររបបខ្មែរក្រហមឬទេ? ហើយតាមរយៈនេះវាអាចជួយរកយុត្តិធម៌ដល់ការស្លាប់បាត់បង់ជីវិតមនុស្សជិតពីរលាននាក់ដែរឬទេ?


ក់លោកតាដំបងដែកនៅក្នុងបរិវេណអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅវេលាម៉ោង១០ព្រឹក លោកស្រី ជា លាង និង លោកស្រី ជាម៉េឡា វីស បានមកដល់ ។ លោកស្រី ជា លាង បាននិយាយដោយសង្ខេបអំពីច្បាប់កម្ពុជានិងកំណកំណើតតុលាការខ្មែរក្រហម ។ ហើយសង្កត់ធ្ងន់ថា តុលាការនេះគឺរដ្ឋាភិបាលកម្ពុជាជាអ្នកស្នើសុំជំនួយពីអង្គការសហប្រជាជាតិ ហេតុដូច្នេះហើយវាមិនសមហេតុផលសម្រាប់ភាគីកម្ពុជាក្នុងការបង្អាក់ដំណើរតុលាការដោយចេតនាឡើយ ។ ភាគីទាំងសងខាងកំពុងធ្វើការយ៉ាងសកម្មនិងស្វែងយល់ពីគ្នាទៅវិញទៅមក ។ លោកស្រី វីស បានបញ្ជាក់ឡើងវិញថា ភាគីកម្ពុជានិងអន្តរជាតិកំពុងធ្វើសហប្រតិបត្តិការជាមួយគ្នាយ៉ាងស្អិតល្មួត ។

បន្ទាប់ពីនិយាយដោយសង្ខេប វាគ្មិនទាំងបីនាក់អនុញ្ញាតឲ្យសិស្សនិស្សិតទាំងអស់សួរសំណួរ ។

សំណួរផ្សេងៗដែលលើកឡើងគឺដូចគ្នានឹងសំណួរពីមុន និងសំណួរដែលអ្នកចូលរួមដំណើរទស្សនកិច្ចមុនៗបានសួរ ។ សំណួរទាំងនោះរួមបញ្ចូលទាំងសន្តិសុខមន្ទីរស-២១ ដំណើរការស៊ើបអង្កេត ពេលវេលាសម្រាប់ការកាត់ក្តី ច្បាប់ខ្មែរក្រហម ការដាក់ទណ្ឌកម្មនិងការកាត់ទោស តើព្រះរាជអាជ្ញាបានជួបនិយាយជាមួយមេដឹកនាំខ្មែរក្រហមហើយឬនៅ? តើអ្នកដែលជាប់ចោទនឹងត្រូវនាំទៅកាន់កន្លែងឃុំឃាំងដោយរបៀបណា? តើមានជម្រើសអ្វីខ្លះដែលត្រូវបានផ្តល់ដល់ចុងចោទប្រសិនបើចុងចោទមិនយល់ស្របនឹងសាលក្រមតុលាការ តើតុលាការនេះអាចក្លាយជាតុលាការគំរូដែរឬទេ? លោកស្រី ជា លាង និង លោកស្រី វីស មានការរីករាយក្នុងការឆ្លើយសំណួររបស់សិស្ស-និស្សិត ។

ការប្រជុំបានកំណត់ចប់នៅម៉ោង១១ព្រឹក សិស្ស-និស្សិតចង់សួរសំណួរជាច្រើនទៀត ប៉ុន្តែដោយសារវាគ្មិនទាំងបីមិនមានពេលវេលាបន្តទៅទៀតបាន លោកស្រី ជា លាង បានមានប្រសាសន៍បញ្ចប់ការប្រជុំ ។ ចុងបញ្ចប់ លោក រាជ សម្បត្តិ បានដឹកនាំក្រុមនិស្សិតទាំងអស់ទៅទស្សនារូបចម្លាក់លោកតាដំបងដែកនៅពីចំហៀងអគារសវនាការ ។

កិច្ចសម្ភាសន៍ចុងក្រោយធ្វើឡើងដោយក្រុមកុនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមុនពេលនិស្សិត ច្បាប់ឡើងរថយន្តក្រុង ។ ឡុំ ចិន្តា អាយុ២៣ឆ្នាំ ជានិស្សិតច្បាប់មកពីសាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានប្រាប់ថា គាត់ចាប់អារម្មណ៍ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាំងពីពេលដែលឪពុកម្តាយនិងសាច់ញាតិរបស់គាត់និយាយរៀបរាប់អំពី

បទពិសោធន៍នៅក្នុងរបបនោះ ។ ចិន្តា ធ្លាប់អានអត្ថបទទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយថ្មីៗនេះនាងចាប់អារម្មណ៍អំពីតុលាការខ្មែរក្រហម ។ ចិន្តា សង្ឃឹមថា សវនាការនឹងប្រព្រឹត្តទៅតាមច្បាប់ ហើយអ្នកដែលធ្វើការនៅក្នុងតុលាការនេះនឹងប្រឹងប្រែងធ្វើការដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ។ ចិន្តា បន្ថែមថា ការអប់រំពីអំពើប្រល័យពូជសាសន៍គឺចាំបាច់ខ្លាំងណាស់ ដើម្បីការពារប្រល័យពូជសាសន៍កុំឲ្យវិលមកវិញ ។ នាងចង់ដឹងយ៉ាងខ្លាំងថា ប្រសិនបើសាច់ញាតិរបស់សហព្រះរាជអជ្ញាឬមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញផ្សេងទៀតមានជាប់ពាក់ព័ន្ធនឹងរឿងក្តី តើពួកគេនៅតែបន្តកិច្ចការរបស់ខ្លួនដោយគ្មានការផ្លាស់ប្តូរឬដាក់កម្រិតផ្សេងៗឬយ៉ាងណា ។

សម្រាប់យុវជនចាមមូស្លីមប្រហែល៩០នាក់ដែលបានចូលរួមប្រជុំនៅសវនាការអង្គជំនុំជម្រះវិសាមញ្ញនេះ បានបន្តទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទៀត ។ សិស្សនិស្សិតទាំងនោះមានឱកាសជួបជាមួយនាយកមជ្ឈមណ្ឌលឯកសារកម្ពុជានិងបានទស្សនាខ្សែភាពយន្ត «នៅកៀនជញ្ជាំងមន្ទីរសន្តិសុខស-២១» ផលិតដោយលោក ឆាំង យុ, ដឹកនាំដោយ លោក ដាក កាស និងនិយាយរៀបរាប់ដោយ លោក វ៉ូឡង់ ជួហុ ។ ភាពយន្តឯកសារនេះបង្ហាញពីអតីតអ្នកទោសនៅមន្ទីរស-២១ និងអតីតសន្តិសុខជាន់ខ្ពស់ ដែលសាច់រឿងរបស់អ្នកទាំងនោះពាក់ព័ន្ធគ្នា ហើយភាគច្រើនមានទំនាស់គ្នាទៅវិញទៅមក ។ តាមរយៈខ្សែភាពយន្តឯកសារ យើងអាចដឹងអំពីរឿងរ៉ាវដែលអតីតអ្នកទោសទាំងពីរត្រូវបានចាប់ខ្លួនបញ្ជូលមកមន្ទីរស-២១ ទារុណកម្មដែលពួកគាត់ទទួលរងនិងវិធីដែលពួកគាត់អាចរស់រានពីភាពឃោរឃៅនិងការអត់ឃ្លាននៅក្នុងមន្ទីរសន្តិសុខ ។ សាច់រឿងនោះចោទសួរគ្នាអំពីឆ្មាំគុកជាន់ខ្ពស់របស់ខ្មែរក្រហមដែលអះអាងថា សកម្មភាពទាំងឡាយរបស់ខ្លួនមិនមានអ្វីលើសពីភារកិច្ចយាមកាមអ្នកទោសឡើយ ។ ខ្សែភាពយន្តនេះក៏អាចឲ្យទស្សនិកជនគិតពីបញ្ហាដែលមិនមានការបែងចែកច្បាស់លាស់រវាងជនរងគ្រោះនិងជនដៃដល់ខណៈពេលដែលសាច់រឿងសង្កត់ធ្ងន់ទៅលើការតស៊ូដែលយើងមិនសង្ឃឹមថា អ្នកទោសនឹងអាចរស់រានមានជីវិតពីមន្ទីរសន្តិសុខ ។

សរុបមក ដំណើរទស្សនកិច្ចដែលរួមមានយុវជនចាមមូស្លីមនិងនិស្សិតច្បាប់ដំណើរការទៅដោយរលូន ។ ទាំងនិស្សិត និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាសហការគ្នាធ្វើឲ្យដំណើរទស្សនកិច្ចនេះទទួលបានជោគជ័យ ។ ដំណើរទស្សនកិច្ចលើកនេះនិងលើកមុនបានផ្តល់ឱកាសឲ្យយុវជនជាច្រើនចូលរួមបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនអំពីអតីតកាលនិងតុលាការខ្មែរក្រហម ។ ដូច្នេះយុវជនគួរតែត្រូវបានផ្តល់ឲ្យនូវឱកាសដើម្បីរៀនសូត្រអំពីអតីតកាលរបស់ប្រទេស ។ ការនាំយុវជនទៅកាន់សារមន្ទីរគុកទួលស្លែង បូជនីយដ្ឋានប្រល័យពូជសាសន៍បឹងជើងឯក និងអង្គជំនុំជម្រះវិសាមញ្ញគឺជាឱកាសដ៏មានតម្លៃសម្រាប់យុវជនក្នុងការរៀនសូត្រនិងស្វែងយល់អំពីអ្វី ដែលបានកើតឡើងនៅក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ ។ លើសពីនេះទៀត ការលើកទឹកចិត្តគឺមានសារសំខាន់ណាស់ក្នុងការអប់រំពីប្រល័យពូជសាសន៍ ។ ការប្រឡងប្រជែងក្នុងការតែងនិពន្ធដែលស្ថិតនៅក្រោមគម្រោងប្រវត្តិសាស្ត្រចាមមូស្លីមអាចជំរុញឲ្យយុវជន ដែលកើតក្រោយរបបខ្មែរក្រហមមានឱកាសនិយាយជាមួយអ្នករស់រានមានជីវិតអំពីបទពិសោធន៍របស់ពួកគេដោយផ្ទាល់ ។ សៀវភៅសិក្សាដែលនឹងដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ហើយដែលនឹងចេញនៅពេលខាងមុខមានឈ្មោះថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩» ដែលរៀបរៀង ដោយ ឌី ខាំបូលី បុគ្គលិកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ការសន្ទនាជាមួយឪពុកម្តាយនិងការរៀនសូត្រពីមេរៀនក្នុងថ្នាក់នឹងជួយឲ្យយុវជនរកឃើញរឿងរ៉ាវខ្មោងងឹតនៃប្រវត្តិសាស្ត្រកម្ពុជា គឺការប្រល័យពូជសាសន៍នៅក្រោមរដ្ឋាភិបាលកម្ពុជាប្រជាធិប-តេយ្យដែលមិនអាចបំភ្លេចនិងអត់ឱនឲ្យបាន ។ **កែវ ជាស៊ីល**

## សេចក្តីកែតម្រូវ

សូមកែតម្រូវចំណងជើងផែនទី ដែលបានចុះផ្សាយនៅទំព័រមាតិការបស់ទស្សនាវដ្តីស្វែងរកការពិត លេខ៨៦ ខែកុម្ភៈ ឆ្នាំ២០០៧ ពី «ផែនទីប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ» ទៅជា «ផែនទីតំបន់រំដោះរបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៧២និង១៩៧៣» ។ សូមអរគុណ ។

# តើគួរសាងសង់ស្តូបតម្កល់អដ្ឋិធាតុនៅជើងភ្នំវល្លិ៍ដែរទេ?

គណៈកម្មការវត្ត "ខ្នាយព្រៃ" បានស្នើសុំឲ្យមានការសាងសង់ស្តូបមួយនៅក្នុងបរិវេណវត្តសង់ថ្មីនេះ ដើម្បីទុកជានិមិត្តរូបនិងរំឭកដល់ការសម្លាប់មនុស្សរបស់ខ្មែរក្រហមនិងក្រុមខ្ទាមខ្មែរក្រហមនៅក្រោយឆ្នាំ១៩៧៩ ។

ការស្នើសុំនេះ បានធ្វើឡើងនៅក្នុងពិធីបុណ្យសាសនាមួយនៅក្នុងបរិវេណវត្ត"ខ្នាយព្រៃ"ដែលទើបនឹងចាប់ផ្តើមសាងសង់ ។ សំណូមពរដ៏សមហេតុផលមួយនេះ បានទទួលការគាំទ្រពីប្រជាជនក្នុងភូមិនិងបានធ្វើឲ្យមនុស្សម្នាទាំងឡាយក្នុងភូមិនឹកឃើញរឿងរ៉ាវសម្លាប់មនុស្សក្នុងជំនាន់ខ្មែរក្រហម និងការសម្លាប់ជនជាតិបរទេស៣នាក់ដោយក្រុមខ្ទាមខ្មែរក្រហមក្នុងឆ្នាំ១៩៩៤ នៅក្បែរជើងភ្នំវល្លិ៍ ។


សំណល់ឆ្អឹងជនរងគ្រោះនៅក្បែរជើងភ្នំវល្លិ៍ ខេត្តកំពត

គួររំឭកថា ជួរភ្នំវល្លិ៍ត្រូវខ្មែរក្រហមគ្រប់គ្រងតាំងពីឆ្នាំ១៩៧១ ហើយឃុំស្រែជាទាំងមូលត្រូវបានបំបែកចេញជាឃុំមួយទៀតគឺឃុំ"រោងវែង" ដែលនៅក្នុងឃុំនោះខ្មែរ-ក្រហមបានបង្កើតមន្ទីរអប់រំកែប្រែមួយនិងទីតាំងសម្លាប់មួយ ។ គង់ ជាអតីតប្រធានឃុំរោងវែងតាំងពីឆ្នាំ១៩៧១ ហើយ ផន បានគ្រប់គ្រងឃុំនេះបន្តពី គង់ នៅដើមឆ្នាំ១៩៧៥ ។ ក្រោយឆ្នាំ១៩៧៩ គង់ និង ផន បានត្រូវសម្លាប់ ។ ទោះជាយ៉ាងនេះក៏ដោយ ជួរភ្នំវល្លិ៍ទាំងមូលនៅតែជាតំបន់ដែលគ្រប់គ្រងដោយក្រុមខ្ទាមខ្មែរក្រហមដដែល ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ រាជរដ្ឋាភិបាលកម្ពុជាបានវាយដណ្តើមយកតំបន់នេះមកគ្រប់គ្រងវិញ ហើយក្រុមខ្ទាមខ្មែរក្រហមដែលនៅសេសសល់មួយចំនួនត្រូវបានចាប់ខ្លួន និងខ្លះទៀតបានរត់ទៅកាន់តំបន់កោះស្លា ហើយក្រោយមករត់ទៅកាន់តំបន់ជាយដែនកម្ពុជា-ថៃ ។

ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់១៩៧៩ ទីតាំងសម្លាប់មនុស្សមួយ ត្រូវបានបង្កើតឡើងនៅក្នុងព្រៃអូរដីបាក់ មានទីតាំងស្ថិតនៅជាប់នឹងជើងភ្នំវល្លិ៍ ភូមិត្រពាំងប្រទៀង ឃុំស្រែជាខាងជើង ស្រុកដងទង់ ខេត្តកំពត ។ ប្រជាជនជម្លៀសរាប់រយនាក់ ត្រូវខ្មែរក្រហមសម្លាប់ចោល ហើយកប់ចោលនៅក្នុងបរិវេណព្រៃអូរដីបាក់ ដែលក្នុងរណ្តៅចំនួនប្រហែលពី៧០ទៅ៨០នាក់ ។ គល់ ម៉ាក អាយុ៥៧ឆ្នាំ ជានាយកសាលាបឋមសិក្សាស្រែជានិយាយថា ប្រជាជនជម្លៀសទាំងនោះពុំមានកំហុសឡើយ ។ ម៉ាក់ និយាយថា "ខ្ញុំកំពុងតែឆ្ងល់ ហើយឆ្ងល់មិនឈប់ ព្រោះអ្នកដែលនៅជិតខ្ញុំហ្នឹងនិយាយពីធ្វើការវិញ អ្នកមូលដ្ឋានធ្វើមិនដូចទេ មានតែធ្វើលើស ស្រាប់តែគេមកនាំទៅកាន់ភូមិថ្មី" (ភូមិថ្មីជាពាក្យដែលខ្មែរក្រហមប្រើសម្រាប់បោកបញ្ឆោតប្រជាជនជម្លៀសយកទៅសម្លាប់) ។

ប្រជាជនមូលដ្ឋានមិនបានដឹងថា "ភូមិថ្មី" ស្ថិតនៅទីណាទេ ហើយក៏មិនដឹងថាមានការសម្លាប់មនុស្សដោយសារតែពាក្យនេះដែរ ។ វ៉ែន ឃឹម អាយុ៥១ឆ្នាំ ជាភរិយារបស់ គល់ ម៉ាក បន្ថែមថា ប្រជាជនជម្លៀសទាំងនោះមិនចាំបាច់មានកំហុសទេ ព្រោះអង្គការជាអ្នកកំណត់អាយុជីវិតពួកគេ ។ នៅឆ្នាំ១៩៧៨ ប្រជាជនជម្លៀសទាំងគ្រួសារៗ បានទទួលបញ្ជាឲ្យទៅរស់នៅភូមិថ្មី ព្រោះ ជាកន្លែងដែលសម្បូរហូបចុកនិងមិនចាំបាច់ធ្វើការរួមនិងដេករួមទេ ។ ឡុង សឿន អាចារ្យវត្តខ្នាយព្រៃបានប្រាប់ថា គាត់បានឃើញរទេះគោដឹកប្រជាជនជម្លៀសចេញពីភូមិទៅកាន់ភូមិថ្មីជាច្រើនរទេះនៅដើមឆ្នាំ១៩៧៨ ។ បងថ្លៃរបស់ សឿន ឈ្មោះ រេន បានហាមប្រាម សឿន មិនឲ្យទៅជិត"ព្រៃអូរដីបាក់" ព្រោះខ្មែរក្រហមបានសម្លាប់មនុស្សនៅទីនោះ ។ រេន ជាអ្នកឃ្វាលទា

និងខ្សែរហ៍ដេញទាឲ្យទៅស៊ីចំណីនៅក្បែរកន្លែងសម្លាប់មនុស្ស នៅ“ព្រៃអូរដីបាក់” បានឃើញសាកសពជាច្រើនដែលត្រូវបានសម្លាប់ដោយវាយនឹងដំបងនិងត្បូងចបនៅក្នុងរណ្តៅដែលមិនទាន់កប់ ។ ក្រៅពី រេន មានតែកម្មាភិបាលប៉ុន្មាននាក់ប៉ុណ្ណោះ ដែលដឹងរឿងរ៉ាវសម្លាប់មនុស្សនៅព្រៃអូរដីបាក់ ព្រោះមានជាប់ពាក់ព័ន្ធនឹងការសម្លាប់ប្រជាជនទាំងនោះ ។ នាយកសាលាបឋមសិក្សាស្រែជានិយាយថា គណៈកងទាំង៤នៃឃុំរោងវែង ធ្លាប់បានទទួលសេចក្តីរាយការណ៍ពីកងឈ្លប“សកម្មប្រចាំភូមិ” ពីប្រវត្តិមនុស្សចំណូលថ្មី ហើយកងឈ្លបឃុំជាអ្នកនាំប្រជាជនទាំងនោះដែលត្រូវបានរាយការណ៍ដោយផ្ទាល់មកកាន់បរិវេណ “ខ្លាយព្រៃ” ដើម្បីឃុំឃាំងនិងក្រោយមកសម្លាប់ចោលនៅ“ព្រៃអូរដីបាក់” ដែលមានចម្ងាយជាងមួយគីឡូម៉ែត្រពីកន្លែងឃុំឃាំង ។ នៅចុងឆ្នាំ ១៩៧៨ ប្រជាជនមូលដ្ឋានភាគច្រើនបានដឹងរឿងរ៉ាវសម្លាប់មនុស្សនៅព្រៃអូរដីបាក់ ។

ក្នុង រយៈពេលប្រហែល៤ខែក្រោយថ្ងៃរំដោះខែមករា ឆ្នាំ ១៩៧៩ រណ្តៅទាំងអស់ត្រូវបានជីកកកាយដើម្បីរកមាស ។ ឆ្អឹងដែលសល់ពីការជីកពុំត្រូវបានប្រមូលទុកដាក់ត្រឹមត្រូវឡើយ ។ ម៉ែន ខុន អាយុ៦៥ឆ្នាំ ជាប្រជាជនរស់នៅភូមិត្រពាំងប្រទៀង បានប្រាប់ថា ក្នុងរដូវភ្លៀងធ្លាក់នាឆ្នាំ១៩៨៤គាត់ដើររកគោរបស់គាត់ដែលបាត់ ហើយបានមកដល់ព្រៃអូរដីបាក់នេះ ពេលនោះគាត់ប្រទះឃើញឆ្អឹងលលាដ៍ក្បាលនិងឆ្អឹងផ្សេងៗទៀត ជាច្រើននៅពាសពេញដី ។ ខុន ខ្លាចទីនោះខ្លាំងណាស់ គាត់ក៏សម្រេចចិត្តឈប់តាមរកគោរបស់គាត់តទៅទៀត ។ បន្ទាប់ពីនោះមក ទីតាំង“ព្រៃអូរដីបាក់”បានត្រូវបានបោះបង់ចោល និងគ្រប់គ្រងដោយក្រុមខ្មាំងខ្មែរក្រហម ។ នៅក្នុងទសវត្សន៍ឆ្នាំ៩០ បន្ទាប់ពីក្រុមខ្មាំងខ្មែរក្រហមសម្លាប់ជនជាតិបរទេសបីនាក់ តំបន់នេះត្រូវកងទ័ពរាជរដ្ឋាភិបាលកម្ពុជាវាយដណ្តើមយកមកគ្រប់គ្រងវិញ ហើយចាប់ខ្លួនបានមេខ្មាំងធំៗប្រចាំតំបន់ដូចជា នួន ប៉ែត និង ឈូក រិន មកផ្តន្ទាទោសពីទោសកំហុសថាបានដាក់បញ្ជាឲ្យសម្លាប់ជនជាតិបរទេសទាំងបី នាក់នោះ ។ គល់ ម៉ាក បានប្រាប់ឲ្យដឹងថា បុណ្យជាអ្នកសម្លាប់ជនជាតិបរទេសទាំងបីនាក់នោះ ប៉ុន្តែបច្ចុប្បន្ន បុណ្យបានស្លាប់បាត់ទៅហើយ ។

ខ្ញុំបានធ្វើដំណើរទៅកាន់ទីតាំង“ព្រៃអូរជ្រៃបាក់”ជាមួយនឹង សឿន, ខុន និង ម៉ាក ដើម្បីពិនិត្យផ្ទាល់ ។ ស្លាកស្នាមរណ្តៅជាច្រើននៅមិនរលុបអស់នៅឡើយ ។ រណ្តៅប្រៀបដូចជារន្ធបាយខ្ញុំនិងមានសភាពប្រហាក់ប្រហែលនឹងរណ្តៅសាកសពនៅមណ្ឌលខក្រិដ្ឋកម្មជើងឯកដែរ ។ ឆ្អឹង“ស្មងដៃ-ជើង”ពុកផុយពីរបីដុំបានលេចចេញនៅលើមាត់រណ្តៅ នៅពេលដែលក្រុមស្រាវជ្រាវយកឈើឆ្កឹះបន្តើលើដីមាត់រណ្តៅ ។

សន្ទឹកភ្លៀងមួយមេធំបានធ្លាក់នៅឯជើងភ្នំវល្លិ៍ប្រមាណពីរគីឡូម៉ែត្រពីទីតាំងរណ្តៅសាកសព ។ ក្រុមស្រាវជ្រាវនិងអ្នកផ្តល់ពត៏មានទាំងបីនាក់បានស្រូតរូតត្រឡប់ក្រោយវិញ ។ នៅតាមផ្លូវត្រឡប់មក កាន់វត្ត “ខ្លាយព្រៃ” អាចារ្យ សឿន បានត្អូញត្អែរថា គាត់នៅតែចង់ឲ្យមានការសង់ស្តូបមួយដើម្បីដាក់តម្កល់ឆ្អឹងដែលពុកផុយទាំងនោះ ទោះជាឆ្អឹងមានចំនួនតិចតួចក៏ដោយ ។ សឿន បានទាញហេតុផលពីការបូជាឆ្អឹងនិងការថែរក្សាឆ្អឹងថាពុំមានមួយណាខុសឡើយ ។ ការថែរក្សាឆ្អឹងគឺជាផលប្រយោជន៍ដើម្បីស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះដែលបានស្លាប់ដោយអំពើអយុត្តិធម៌កាលពីជំនាន់ខ្មែរក្រហម ។ ចំណែក ឯការបូជាឆ្អឹងវិញ គឺជាការស្វែងរកសេចក្តីសុខឲ្យព្រលឹងដែលវិលវល់អស់រយៈពេលជាយូរមកហើយ ។ ទោះជាយ៉ាងនេះក្តី សឿន សរុបសេចក្តីថា ទោះជាឆ្អឹងទាំងអស់ត្រូវបូជាក៏ដោយ ឲ្យតែផេះដែលនៅសល់ក្រោយការបូជា យើងយកមកទុកដាក់ត្រឹមត្រូវនៅក្នុងកោដ្ឋ ហើយដាក់តម្កល់នៅកន្លែងសុវត្ថិភាពមួយ គឺជាការប្រពៃណាស់ទៅហើយ ។ អាចារ្យ សឿន, គល់ ម៉ាក និង ខុន ព្រមទាំងប្រជាជនជាច្រើនទៀត បានផ្តួចផ្តើមធ្វើបុណ្យបង្សុកូលចំនួនពីរដងរួចមកហើយនៅកន្លែងសម្លាប់មនុស្ស“ព្រៃអូរដីបាក់” ។ អ្នកទាំងបីនឹងព្យាយាមធ្វើបុណ្យបែបនេះបន្តទៀតនៅរៀងរាល់ឆ្នាំទោះជាមានការសាងសង់ស្តូប ឬមិនមានក៏ដោយ ដើម្បីឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធអ្នកដែលបានចែកឋានទៅឲ្យបានកាន់សុគតិភព ។ សឿន បានបង្ហើបឲ្យដឹងថា ប្រសិនមានការសាងសង់ស្តូបមែន គាត់និងពុទ្ធបរិស័ទចំណុះជើងវត្តនឹងអនុញ្ញាតឲ្យសាងសង់នៅក្នុងបរិវេណវត្តដែលទើបនឹងសង់ថ្មី“ខ្លាយព្រៃ” ។

**ផេង ពង្សរ៉ាស៊ី**

# សេចក្តីប្រកាសរកបងប្រុស និងបងស្រី

បន្ទាប់ពីខ្ញុំបានអានព័ត៌មាននិងបានដឹងថាអង្គការរបស់លោកជួយស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួន នាងស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកបងប្រុសនិងបងស្រីរបស់ខ្ញុំដែលបានបែកពីខ្ញុំនៅក្នុងឆ្នាំ១៩៧៥ ។



ណាអូមិ ហាមម័រស្ទី

ខ្ញុំនិងបងស្រីភ្លោះរបស់ខ្ញុំ កើតក្នុងខែមករា ឆ្នាំ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ ។ មួយសប្តាហ៍ក្រោយ យើងទាំងពីរត្រូវបានបញ្ជូនទៅកាន់មណ្ឌលកុមារកំព្រានៅទីក្រុងភ្នំពេញដែលមានឈ្មោះថាផ្ទះកាណាដា ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៥ យើងទាំងពីរត្រូវបានគ្រួសារជនជាតិកាណាដាមួយ យកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ សព្វថ្ងៃយើងខ្ញុំទាំងពីរនាក់កំពុងតែស្វែងរកព័ត៌មានស្តីពីបងប្រុសនិងបងស្រីដែលត្រូវបានទុកចោលនៅទីក្រុងភ្នំពេញ ។

យើងខ្ញុំទាំងពីរពុំដឹងថាឪពុកម្តាយបងប្អូនរបស់ខ្ញុំមានឈ្មោះអ្វីខ្លះ និងក៏ពុំដឹងថាយើងទាំងពីរនាក់កើតនៅទីណានោះទេ ។ យើងខ្ញុំទាំងពីរនាក់គ្រាន់តែដឹងព័ត៌មានបន្តិចបន្តួចពីស្ត្រីជនជាតិកាណាដាដែលបម្រើការនៅមណ្ឌលកុមារកំព្រាតែប៉ុណ្ណោះ ។

ឪពុករបស់យើងខ្ញុំទាំងពីរនាក់ បានស្លាប់នៅមុនពេលដែលយើងទាំងពីរនាក់កើតមកម្ល៉េះ ហើយគាត់ទំនងជាទាហាន លន់ នល់ ។ បន្ទាប់ពីម្តាយរបស់ខ្ញុំបានផ្តល់កំណើតឲ្យយើងទាំងពីរនាក់នៅក្នុងឆ្នាំ១៩៧៥មក សុខភាពរបស់គាត់បានចុះទន់ខ្សោយដោយសារតែកង្វះអាហារបរិភោគ និងធ្វើឲ្យគាត់មិនអាចចិញ្ចឹមបីបាច់យើងទាំងពីរបាន ។ បន្ទាប់ពីបុគ្គលិកមណ្ឌលកុមារកំព្រាទទួលបានព័ត៌មានអំពីខ្ញុំទាំងពីរ ពួកគេបានស្វែងរកយើងរហូតបានប្រទះឃើញយើងនៅដេកលើគំនរសំរាមនៅក្នុងខ្ទមមួយ ។ បន្ទាប់មកក៏បាននាំយើងទាំងពីរទៅកាន់ផ្ទះកាណាដា និងយកម្តាយរបស់ខ្ញុំទៅសាលាសំណាក់ ។ បងស្រីខ្ញុំមានអាយុប្រហែល១៨ឆ្នាំ ធ្វើការនៅមណ្ឌលកុមារកំព្រា ហើយបងប្រុសខ្ញុំមានអាយុប្រហែល៧ឆ្នាំស្នាក់នៅជាមួយម្តាយ ។

នៅក្នុងផ្ទះកាណាដា មានកុមារកំព្រាចំនួន៤០នាក់ និងបុគ្គលិកខ្មែរប្រហែល១០នាក់ឬ១៥នាក់មើលថែរក្សាកុមារទាំងនោះ ។ ក្រោយមក កុមារទាំងនោះត្រូវបានយកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ ផ្ទះកាណាដានេះ រៀបចំឡើងដោយស្ត្រីជនជាតិកាណាដាជាច្រើននាក់ ។ លោក ស្រី ណាអូមិ ប្រុណស្តេន បានធ្វើដំណើរចុះឡើងពីកម្ពុជាទៅកាណាដាក្នុងការចាត់ចែងការទទួលយកក្មេងទៅចិញ្ចឹម ចំណែកលោកស្រី ដុល្លី ឆារ៉េត និង អាណា ឆារ៉េត ជាអ្នកមើលថែរក្សាកុមារកំព្រាទាំងនោះ ។

ទោះបីជាយើងខ្ញុំទាំងពីរនាក់ពុំមានព័ត៌មានលម្អិតច្រើនស្តីអំពីក្រុមគ្រួសាររបស់ខ្ញុំយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា សាវតាររបស់ខ្ញុំ និងផ្ទះកាណាដានេះ អាចផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់បងប្អូន ដែលបានដឹងដំណឹងអំពីបងប្រុស និងបងស្រីរបស់យើងទាំងពីរនាក់ ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការជួយជ្រោមជ្រែងស្វែងរកព័ត៌មានបន្ថែមស្តីអំពីគ្រួសាររបស់យើងខ្ញុំទាំងពីរនាក់ និងអាចជួយធ្វើឲ្យយើងទាំងពីរនាក់ជួបជុំគ្រួសារវិញ ។ **ណាអូមិ ហាមម័រស្ទី**



បងស្រីរបស់ ណាអូមិ ហាមម័រស្ទី នៅផ្ទះកាណាដា

# យន្តការសាលាក្តីខ្មែរក្រហម ៖ វិធាននីតិវិធី និង វិធានភស្តុតាង

អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួន ដោយរាប់បញ្ចូលទាំងអតីតមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មថ្នាក់ជាតិនិងអន្តរជាតិ ។ ក៏ប៉ុន្តែ ការដាក់ទោសអ្នកទាំងនេះឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនមិនមែនជាការងាយស្រួលដូចដែលគេរំពឹងទុកនោះទេ ។ ការលំបាកក្នុងការដាក់ឲ្យទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋ គឺជាការបង្ហាញអំពីដំណើរការជំនុំជម្រះឧក្រិដ្ឋកម្មដែលមានប្រសិទ្ធភាព មានយុត្តិធម៌ និងមានតម្លាភាពមួយដើម្បីការពារនូវសិទ្ធិរបស់ភាគីដែលពាក់ព័ន្ធទាំងអស់ ដោយរាប់បញ្ចូលទាំងជនជាប់ចោទផងដែរ ។ វិធានភស្តុតាងនិងវិធាននីតិវិធី បានកំណត់លើនីតិវិធីព្រហ្ម-ទណ្ឌ ហើយវិធាននេះជា «វិធាននៃល្បែង»ដើម្បីការកាត់ទោស ឬការការពារអតីតមេដឹកនាំខ្មែរក្រហម ។ ការប្រកាន់ខ្ជាប់នូវច្បាប់ដែលទទួលស្គាល់ជាអន្តរជាតិនឹងជាជោគជ័យមួយផ្នែកសម្រាប់ដំណើរការសាលាក្តីខ្មែរក្រហមនេះ ដោយមិនគិតថាការដាក់ទោសត្រូវបានធានាដែរឬយ៉ាងណានោះ ពីព្រោះការបង្ហាញពិរុទ្ធភាព ឬភាពគ្មានទោសនៃមេដឹកនាំខ្មែរក្រហម គ្រាន់តែជាគោលដៅសំខាន់មួយនៃសាលាក្តីនេះប៉ុណ្ណោះ ។ គោលដៅសំខាន់មួយទៀតនៃសាលាក្តីនេះ គឺជាការបង្ហាញនូវភាពត្រឹមត្រូវនៃនីតិវិធី និងការពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា ។ វិធានភស្តុតាងគ្រប់គ្រងលើប្រភេទនៃព័ត៌មានដែលអាចប្រើប្រាស់សម្រាប់ការបង្ហាញនូវពិរុទ្ធភាព ឬភាពគ្មានទោស ឬចុងចោទណាមួយ ។



លោក ម៉ាសែល ឡឺមុន (រូបកណ្តាល) សហចៅក្រមស៊ើបអង្កេតជនជាតិបារាំង នៅក្នុងអគារសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ចំពោះវិធាននីតិវិធី គឺការការពារសិទ្ធិរបស់ចុងចោទ និងការកំណត់ដំណាក់កាលនីមួយៗនៃដំណើរការកាត់សេចក្តី ដោយគិតចាប់ពីការចោទប្រកាន់ចុងចោទ ជាបឋមរហូតដល់ការស៊ើបអង្កេត ការបង្ហាញភស្តុតាងចំពោះមុខចៅក្រម ការវិនិច្ឆ័យ និងការផ្តន្ទាទោសរបស់ចៅក្រម និងនីតិវិធីប្តឹងឧទ្ធរណ៍និងសាលក្រមសម្រេចដាក់ទោសចុងក្រោយ ។ គ្រប់បុគ្គលដែលពាក់ព័ន្ធនៅក្នុងដំណើរការកាត់ក្តីនេះ រួមមាននគរបាលស៊ើបអង្កេត សាក្សី ព្រះរាជអាជ្ញា មេធាវីការពារក្តី ចៅក្រមស៊ើបអង្កេត និងចៅក្រមវិនិច្ឆ័យសាលាដំបូងនិងឧទ្ធរណ៍ មានកាតព្វកិច្ចអនុវត្តវិធានទាំងនេះទៅតាមផ្លូវច្បាប់ ។ ការដែលមិនឲ្យភ្ជាប់នូវវិធាននីតិវិធី និងវិធានភស្តុតាង អាចនឹងនាំឲ្យមានការច្រានចោលនូវការចោទប្រកាន់ចំពោះពាក្យបណ្តឹងឧទ្ធរណ៍ ឬការចោទប្រកាន់ថាតុលាការផ្ទាល់ មិនមានភាពស្របច្បាប់ ។

**បំណងវិធាននៃនីតិវិធី និងភស្តុតាង**

បំណងសំខាន់នៃវិធាននៃនីតិវិធីនិងភស្តុតាង បញ្ជាក់ថាតុលាការនេះនឹងឆ្លើយតបទៅនឹងខ្នាតគំរូយុត្តិធម៌និងភាពត្រឹមត្រូវជាមូលដ្ឋាន ។ វិធាននេះ ផ្តល់ភាពស្របគ្នាពីសវនាការមួយទៅសវនាការមួយ ដើម្បីធានាបាននូវការគោរពសិទ្ធិចុងចោទដូចៗគ្នា ។ ជាងនេះទៀត ការអនុវត្តដែលត្រូវបានទទួលស្គាល់នេះនឹងនាំទៅដល់លទ្ធផលល្អនៃការជំនុំជម្រះដោយការបញ្ចៀសនូវការប្តឹងផ្តល់រាល់នីតិវិធីនៅក្នុងតុលាការ ។ ម្យ៉ាងវិញទៀត

វិធាននេះនឹងធ្វើឲ្យមានតម្លាភាពតាមរយៈការបង្កើតគោលការណ៍ណែនាំ ដែលក្រុមអ្នកសង្កេតការណ៍ខាងក្រៅអាចប្រើប្រាស់ដើម្បីវាយតម្លៃពីភាពសុក្រឹតនៃដំណើរការកាត់ក្តីនេះ ។ ការគ្រប់គ្រងយុត្តិធម៌ពិតប្រាកដនិងមានតម្លាភាព បង្ហាញឲ្យឃើញថា គ្មានជនណាម្នាក់អាចនៅពីលើច្បាប់បានឡើយ សូម្បីនៅពេលដែលចុងចោទទាញផលចំណេញលើជនផ្សេងទៀតក៏ដោយ ដូចជា ឥទ្ធិពលនយោបាយ ឬធនធានផ្ទាល់ខ្លួន ។ ក្នុងមធ្យោបាយបែបនេះ ការអនុវត្តន៍វិធាននៃភ័ស្តុតាង និងនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់យ៉ាងធំធេង ដើរតួនាទីសំខាន់ក្នុងការផ្តល់យុត្តិធម៌ និងបញ្ចប់ការលើកលែងទោសនៅកម្ពុជាក៏ដូចជានៅទីកន្លែងផ្សេងៗទៀតដែរ ។

វិធានដដែលនេះ នឹងប្រើប្រាស់សម្រាប់ការកាត់សេចក្តីចុងចោទនឹងការពារសិទ្ធិរបស់ចុងចោទក្នុងនាមជាជន ដែលត្រូវជាប់ចោទ ដែលជាគំរូសម្រាប់ការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅក្នុងគ្រប់ប្រព័ន្ធច្បាប់ទំនើបទាំងអស់ ។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបង្កើតឲ្យមានសិទ្ធិរបស់ជនជាប់ចោទ ដែលជាសិទ្ធិមនុស្សជាមូលដ្ឋានដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។ ដោយអះអាងជាថ្មីនូវគោលការណ៍មូលដ្ឋាននៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ប្រទេសជាសមាជិកនៃអនុ-សញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានទទួលស្គាល់ថាចុងចោទនៅក្នុងតុលាការព្រហ្មទណ្ឌស័ក្តិសមនឹងទទួលបាននូវការការពារមួយចំនួនក្នុងលក្ខណៈជាមនុស្ស ។ សិទ្ធិមួយក្នុងចំណោមសិទ្ធិសំខាន់ៗនៃនីតិវិធីដែលស្ថិតនៅក្រោមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនោះ គឺការសន្មតទុកជាមុននូវភាពគ្មានទោសរបស់ចុងចោទ ។ គោលការណ៍នេះដកស្រង់ចេញពីបទដ្ឋានអន្តរជាតិដែលទទួលស្គាល់សេចក្តីថ្លៃថ្នូរ និងបុគ្គលិកលក្ខណៈរបស់ជនគ្រប់រូប ព្រមទាំងដកស្រង់ចេញពីការស្វែងយល់ជាសកលដែលចៅក្រមទទួលបានអត្ថប្រយោជន៍មួយចំនួននៅក្នុងប្រព័ន្ធប្រតិប័ក្ស(ប្រព័ន្ធនៃនីតិវិធីតុលាការដឹកនាំដោយភាគី) ។ ដោយមូលហេតុនេះ តុលាការនៃច្បាប់នៅក្នុងប្រព័ន្ធច្បាប់ទំនើបបំផុតនេះ សន្មតជាមុនថា ជនជាប់ចោទពុំមានទោសបទឧក្រិដ្ឋកម្មទេ ដរាបណាជនជាប់ចោទពុំត្រូវបានរកឃើញថាមានទោស ។

តាមទស្សនៈស្តីពីនីតិវិធី គោលការណ៍នៃការសន្មតភាពគ្មានទោសជាមុន គឺជាការដាក់បន្ទុកភ័ស្តុតាងទៅលើព្រះរាជអាជ្ញាជាជាងទៅលើមេធាវីការពារក្តី ។ យោងតាមគោលការណ៍ច្បាប់ខមមិនឡជាមូលដ្ឋាន ព្រះរាជអាជ្ញាត្រូវបង្ហាញសំណុំរឿងក្តី "ហួសផុតពីការសង្ស័យដ៏សមហេតុសមផល" ឬក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី ចំពោះការពេញចិត្តនឹង"ការកាត់សេចក្តីយ៉ាងស៊ីជម្រៅ"របស់ចៅក្រម ។ ដូចនេះ ព្រះរាជអាជ្ញាត្រូវមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញនូវពិរុទ្ធភាពរបស់ចុងចោទដែលត្រូវកាត់ទោស ។ ប្រសិនបើនៅពេលបញ្ចប់សំណុំរឿងក្តី ព្រះរាជអាជ្ញានៅតែមានភាពមន្ទិលសង្ស័យពិរុទ្ធភាពរបស់ចុងចោទដដែល ភាពមន្ទិលសង្ស័យនោះនឹងជួយទៅដល់ជនជាប់ចោទជាមិនខាន ។ នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រះរាជអាជ្ញាទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការធ្វើឲ្យតុលាការជឿ"ហួសពីការសង្ស័យដ៏សមហេតុសមផល" ថា ឧក្រិដ្ឋកម្មជាខ្សែសង្វាក់និងធ្ងន់ធ្ងរ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កើតពីអំពើពិរុទ្ធ ឬការខកខានមិនបានទប់ស្កាត់របស់ជនជាប់ចោទ ។

ជាចុងក្រោយ វិធាននីតិវិធីនិងវិធានភ័ស្តុតាងអះអាងបញ្ជាក់ថា ការកាត់ទោសណាមួយដែលធ្វើឡើងដោយការជំនុំជម្រះដោយយុត្តិធម៌នឹងត្រូវបានចាត់ទុកថា ជាការកាត់ទោសដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ ច្បាប់នេះត្រូវបានបង្កើតឡើងដើម្បីបញ្ចៀសនូវលទ្ធផលទាំងឡាយដូចជា ករណី "តុលាការកំប៉ាំងមុខ" ឆ្នាំ១៩៧៩ដែលបានទទួលរងនូវការរិះគន់យ៉ាងខ្លាំងអំពីការដាក់ទោស ប៉ុល ពត និង អៀង សារី ដោយ-សារតែនៅពេលនោះអ្នកទាំងពីរពុំមានវត្តមាននៅក្នុងសវនាការ ដែលមិនបានបង្ហាញភ័ស្តុតាងក្នុងការការពារខ្លួន ឬប្រឈមមុខជាមួយនឹងសាក្សី ។ ប្រការដែលអ្នកទាំងពីរមិនត្រូវបានផ្តល់សិទ្ធិតាមនីតិវិធីដោយរាប់បញ្ចូលទាំងឱកាសក្នុងការបកស្រាយរឿងរ៉ាវរបស់ខ្លួននៅក្នុងតុលាការ គឺជាហេតុផលមួយដែលសហគមន៍អន្តរជាតិបានថ្កោលទោសតុលាការនេះយ៉ាងខ្លាំងក្លាថាមិនមានភាពស្របច្បាប់ និងថែមទាំងបានបដិសេធពុំទទួលស្គាល់ការដាក់

ទោសនោះថែមទៀត ។ ដោយអនុវត្តតាមបទដ្ឋាននៃភាពត្រឹមត្រូវនៃនីតិវិធីដែលទទួលស្គាល់ជាអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចនឹងបញ្ចៀសផុតពីលទ្ធផលបែបនេះ និងអាចកាត់ទោសចុងក្រោយនិងតាមផ្លូវច្បាប់ក្នុងកម្រិតមួយល្អប្រសើរថែមទៀត ។

## ការរៀបចំបង្កើតវិធាននីតិវិធីនិងវិធានភស្តុតាង

វិធាននីតិវិធីដ៏សាមញ្ញបំផុត ដកស្រង់ចេញពីប្រព័ន្ធច្បាប់សំខាន់ៗចំនួនពីរនៅលើពិភពលោក គឺប្រព័ន្ធ “ច្បាប់រដ្ឋប្បវេណី” *(civil law)* និងប្រព័ន្ធច្បាប់ “ខមមិនឡ” *(common law)* ។ ប្រព័ន្ធច្បាប់ទាំងពីរដកស្រង់ចេញពីប្រពៃណីនៃច្បាប់អឺរ៉ុប និងច្បាប់អង់គ្លូសាក់សុង រៀងៗខ្លួន ។ ឥទ្ធិពលដ៏ធំជាអន្តរជាតិស្ដីអំពីសង្គមគំនិត និងរដ្ឋនៅអឺរ៉ុបក្នុងសម័យអាណានិគមនិយមនិងសម័យទំនើបបាននឹងកំពុងដឹកនាំប្រទេសជាច្រើននៅលើពិភពលោកអនុម័តច្បាប់និងវិធាននីតិវិធីដោយពឹងផ្អែកទៅលើប្រព័ន្ធច្បាប់មួយនៅក្នុងប្រព័ន្ធច្បាប់ទាំងពីរនេះ ។ នៅក្នុងប្រទេសកម្ពុជានិងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនទៀត ច្បាប់ដែលមានតាំងពីសម័យអាណានិគមនិយម ត្រូវបានធ្វើឲ្យទាន់សម័យផ្លាស់ប្ដូរ និងកែតម្រូវយ៉ាងល្អប្រសើរនូវបទដ្ឋានវប្បធម៌និងសាសនាក្នុងតំបន់និងទិដ្ឋភាពនយោបាយក្រោយសម័យអាណានិគមនិយម ។

ភាពខុសគ្នាជាមូលដ្ឋានមួយរវាងក្របខ័ណ្ឌប្រព័ន្ធច្បាប់ទាំងពីរនេះ គឺប្រព័ន្ធច្បាប់ខមមិនឡ អនុញ្ញាតឲ្យមានច្បាប់ “ដែលបង្កើតឡើងដោយចៅក្រម” ។ នៅក្នុងប្រព័ន្ធនេះ សេចក្ដីសម្រេចចិត្តរបស់ចៅក្រមមួយឬច្រើន គឺជាការវិនិច្ឆ័យរួមដែលនៅជាធរមាន និងជាប្រភពច្បាប់សម្រាប់សំណុំរឿងក្ដីថ្ងៃអនាគត ។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់រដ្ឋប្បវេណី គឺជាប្រព័ន្ធច្បាប់ដែលពឹងផ្អែកទៅលើច្បាប់ជាបឋម ហើយការវិនិច្ឆ័យរបស់ចៅក្រមគឺជាការវិនិច្ឆ័យដ៏សំខាន់ដែលអាចជឿទុកចិត្តបាន ដែលមិនមែនជាការវិនិច្ឆ័យរួមតែមួយ ដូចគ្នានឹងប្រព័ន្ធច្បាប់ខមមិនឡនោះទេ ។ ភាពខុសគ្នាសំខាន់មួយទៀតរវាងប្រព័ន្ធច្បាប់រដ្ឋប្បវេណីនិងប្រព័ន្ធច្បាប់ខមមិនឡ គឺនៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី ចៅក្រមជាអ្នកសម្រេចពិរុទ្ធភាព ឬភាពគ្មានទោសរបស់ចុងចោទដែលទាក់ទិននឹងអំពើឧក្រិដ្ឋ ។ ដោយឡែក នៅក្នុងប្រព័ន្ធច្បាប់ខមមិនឡវិញ ក្រុមប្រឹក្សាតុលាការជាអ្នកចេញសាលក្រមសម្រេច ។ ក្នុងករណីនេះ ចៅក្រមប្រព័ន្ធច្បាប់រដ្ឋប្បវេណី មានសិទ្ធិសេរីភាពក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដោះស្រាយបញ្ហានីតិវិធីនិងភស្តុតាងច្រើនជាងចៅក្រមប្រព័ន្ធច្បាប់ខមមិនឡដែលត្រូវបញ្ចៀសនូវការរើសអើងចំពោះក្រុមប្រឹក្សាតុលាការ ។ វិធាននីតិវិធីនិងវិធានភស្តុតាង មិនតឹងរ៉ឹងទេនៅក្នុងបទដ្ឋានច្បាប់រដ្ឋប្បវេណី ពីព្រោះចៅក្រមប្រព័ន្ធច្បាប់រដ្ឋប្បវេណីត្រូវបានសន្មតថា ជាមនុស្សដែលមានបទពិសោធន៍ និងដែលមិនងាយទទួលនូវការរើសអើង ឬការវិនិច្ឆ័យមិនត្រឹមត្រូវនូវតម្លៃនៃភស្តុតាងរបស់ជនសង្ស័យឡើយ ។

ប្រព័ន្ធច្បាប់រដ្ឋប្បវេណីបារាំង ជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ច្បាប់និងនីតិព្រហ្មទណ្ឌកម្ពុជា ។ ដូចនេះ វិធានភស្តុតាងកម្ពុជា ពឹងផ្អែកទៅលើការយល់ដឹងគោលការណ៍ច្បាប់បារាំង “*La Liberté des preuves*” ។ តាមគោលការណ៍នេះ ចៅក្រមមានឆន្ទានុសិទ្ធិពិនិត្យភស្តុតាងជាច្រើន ។ ចៅក្រមត្រូវពិចារណាយ៉ាងហ្មត់ចត់នូវភស្តុតាងទាំងនោះ មុនការសម្រេចដាក់ទោសដោយផ្អែកទៅលើការចោទប្រកាន់របស់ខ្លួនដែលបង្ហាញពីការប្រចបាច់បញ្ចូលគ្នារវាងការវិនិច្ឆ័យតាមផ្លូវច្បាប់និងស្មារតីសីលធម៌ ដែលភាសាបារាំងហៅថា “*intime conviction*” ។ ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាអនុម័តគោលការណ៍ទាំងនេះនៅក្នុងក្របខ័ណ្ឌមូលដ្ឋានស្ដីពីនីតិវិធីព្រហ្មទណ្ឌ ទោះបីជាមានបទបញ្ញត្តិជាច្រើនចែងនៅក្នុងច្បាប់ផ្សេងៗជាច្រើនទៀតក៏ដោយ ។

ដោយខុសពីប្រព័ន្ធតុលាការកម្ពុជា ពុំមានវិធាននីតិវិធីមិនចំពោះមុខណាមួយនៅក្នុងច្បាប់អន្តរជាតិឡើយ ។ ក៏ប៉ុន្តែ នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ដកស្រង់ចេញពីប្រព័ន្ធច្បាប់រដ្ឋប្បវេណីនិងប្រព័ន្ធច្បាប់ខមមិនឡដែលបានបង្កើតនីតិវិធីព្រហ្មទណ្ឌអន្តរជាតិនេះអស់រយៈពេលជាង៦០ឆ្នាំកន្លងមកហើយ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ជាតុលាការព្រហ្មទណ្ឌអន្តរជាតិដ៏ល្បីល្បាញនិងមានឥទ្ធិពលបំផុតចាប់តាំងពីការកាត់ទោសនៅទីក្រុងនូរីមប៊ឺកនូវមេដឹកនាំផ្ដាច់ការណាហ្ស៊ីនៃប្រទេសអាល្លឺម៉ង់នោះមក បានបង្កើតវិធានពិសេសផ្ទាល់ខ្លួនសម្រាប់ដំណើរការកាត់ក្ដី ។ តុលាការកូនកាត់ក្នុងការ

ចាត់នីតិវិធីផ្សេងៗខុសពីតុលាការពិសេសនៅប្រទេស សៀរ៉ាឡេអូន ដែលពឹងផ្អែកទៅលើវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងខុសពីតុលាការនៅទីម័រខាងកើតដែលបង្កើតវិធានផ្ទាល់ខ្លួនក្នុងកម្រិតមួយល្អប្រសើរ ។

បើទោះបីជាមានភាពខុសប្លែកគ្នារវាងច្បាប់ទាំងនេះយ៉ាងណាក៏ដោយ គោលការណ៍មួយចំនួនកើតចេញពីតុលាការអន្តរ-ជាតិទាំងនេះផងដែរ ។ គួរកត់សម្គាល់បំផុតនោះ តុលាការអន្តរជាតិដែលត្រូវបានបង្កើតឡើងចាប់តាំងពីការបញ្ចប់សង្គ្រាមត្រជាក់គាំទ្រវិធាននីតិវិធីនិងវិធានភស្តុតាងដែលត្រូវបានចងក្រងជាច្បាប់ ។ ច្បាប់បង្កើតតុលាការអន្តរជាតិទាំងនេះ អនុញ្ញាតឲ្យចៅក្រមអនុម័តនិងវិសោធនកម្មវិធាននីតិវិធីនិងវិធានភស្តុតាង ក្នុងករណីដែលចាំបាច់ ។ ក្នុងការធ្វើសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធី និងភស្តុតាងដាច់ដោយឡែកពីគ្នា ចៅក្រមត្រូវប្រើប្រាស់គោល-ការណ៍ដែលនៅជាធរមាននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងគោលការណ៍នៅក្នុងប្រព័ន្ធច្បាប់ជាតិផងដែរ ។ នៅពេលតុលាការកែតម្រូវច្បាប់របស់ខ្លួន តុលាការមានតួនាទីសំខាន់ក្នុងការប្រមូលចងក្រងច្បាប់ទាំងនេះជាច្បាប់តែមួយ ។ អង្គច្បាប់នេះ បានរួមចំណែកយ៉ាងខ្លាំងទៅដល់ការបង្កើតនូវវិធាននីតិវិធីនិងវិធានភស្តុតាងសម្រាប់តុលាការព្រហ្មទណ្ឌអន្តរ-ជាតិ ដែលបច្ចុប្បន្នជាការបង្ហាញដ៏ទូលំទូលាយនិងមានឥទ្ធិពលបំផុតនូវបទដ្ឋាននីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ។ ប្រការដែលសំខាន់នោះ ច្បាប់ទាំងនេះ ជះឥទ្ធិពលទៅដល់នីតិវិធីដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវអនុម័តនិងអនុវត្ត ។

## វិធាននីតិវិធីសម្រាប់សាលាក្តីខ្មែរក្រហម

ដោយខុសពីតុលាការអន្តរជាតិដទៃទៀត ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះ មិនបានផ្តល់ឲ្យចៅក្រមនូវសិទ្ធិអំណាចក្នុងការធ្វើសេចក្តីព្រាងច្បាប់ស្តីអំពីវិធាននីតិវិធីនិងវិធានភស្តុតាងដោយឡែកទេ ។ ដោយសារតែសាលាក្តីខ្មែរក្រហមជាតុលាការកូនកាត់ដែលមានលក្ខណៈជាតិនិងអន្តរជាតិ សាលាក្តីនេះ នឹងអនុវត្តជាបឋមនូវច្បាប់កម្ពុជាស្តីពីនីតិវិធីព្រហ្មទណ្ឌជាមុន ក៏ប៉ុន្តែត្រូវផ្តោតជាសំខាន់ទៅលើច្បាប់អន្តរជាតិក្នុងករណីចាំបាច់ ។ មាត្រា១២នៃកិច្ចព្រមព្រៀងឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានចែងនូវគោលការណ៍ណែនាំដែលតុលាការនេះត្រូវអនុវត្តក្នុងការដោះស្រាយបញ្ហានីតិវិធី ÷

នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា ។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាដោយឡែកណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ



ចៅក្រមខ្មែរនិងចៅក្រមអន្តរជាតិក្នុងពិធីធ្វើសច្ចាប្រណិធាន

ឬការអនុវត្តន៍បទបញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នា រវាងបទបញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

ដូចគ្នានេះដែរ ច្បាប់គ្រប់គ្រងអង្គជំនុំជម្រះវិសាមញ្ញ (ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ក៏បានអនុញ្ញាតឲ្យចៅក្រមពិភាក្សាច្បាប់អន្តរជាតិក្នុងករណីដែលចាំបាច់ដើម្បីបំពេញបន្ថែមលើចន្លោះខ្វះខាតរវាងច្បាប់កម្ពុជានិងបទដ្ឋានអន្តរជាតិ ។ ដោយសារតែនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានភាពមិនច្បាស់លាស់និងមានភាពខុសគ្នាច្រើន ច្បាប់អន្តរជាតិ

ទំនងជាដើរតួនាទីសំខាន់លើវិធាននីតិវិធីនៅក្នុងតុលាការនេះ ។ ច្បាប់បង្កើតសាលាក្តីខ្មែរក្រហម មានភាពទន់ភ្លន់ច្រើនសម្រាប់ ចៅក្រម ដរាបណាច្បាប់នេះផ្សារភ្ជាប់ជាមួយនឹងបទដ្ឋានអន្តរជាតិ ស្តីអំពីយុត្តិធម៌ ភាពត្រឹមត្រូវនិងនីតិវិធីដោយសមហេតុសមផល ។ ឧបសគ្គចម្បងរបស់ចៅក្រម គឺការទទួលស្គាល់ចន្លោះខ្វះខាត រវាងច្បាប់កម្ពុជានិងបទដ្ឋានអន្តរជាតិ ។ ឧបសគ្គនេះ ស្តែងចេញឲ្យឃើញយ៉ាងប្រាកដថា ចៅក្រមខ្មែរច្រើនមានទម្លាប់អនុវត្ត វិធាននីតិវិធីនិងវិធានភស្តុតាងជាតិជាជាងច្បាប់អន្តរជាតិ ។

មានប្រភពច្បាប់ផ្សេងៗស្តីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយទំនាក់ទំនងរវាងច្បាប់ទាំងនេះមានលក្ខណៈមិនច្បាស់លាស់ សូម្បីតែទំនាក់ទំនងរវាងមេធាវីនិងចៅក្រមខ្មែរ ។ នៅក្នុងប្រទេសកម្ពុជា មានប្រភពច្បាប់ចំនួនពីរស្តីពីនីតិវិធីព្រហ្មទណ្ឌថ្មី គឺច្បាប់ព្រហ្មទណ្ឌអន្តរកាល អ៊ុនតាក់ ឆ្នាំ១៩៩២ និងច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ។ ដោយប្រៀបធៀបច្បាប់ទាំងពីរបញ្ចូលគ្នា ច្បាប់ទាំងនេះ បានការពារនូវសិទ្ធិរបស់ជនជាប់ចោទ ដូចជាសិទ្ធិទទួលបាននូវការផ្តល់ប្រឹក្សា ការហាមប្រាមការដាក់ទណ្ឌកម្មធ្ងន់ធ្ងរនិងខុសប្រក្រតី ការសន្មតជាមុនថាគ្មានទោស និងសិទ្ធិប្តឹងឧទ្ធរណ៍ ។ លើសពីនេះទៀត ច្បាប់ទាំងនេះ ក៏បានកំណត់យ៉ាងច្បាស់នូវនីតិវិធីដែលទាក់ទងទៅនឹងការស្រាវជ្រាវ ការចាប់ខ្លួននិងការឃុំខ្លួន ការធានាអះអាងបញ្ជាក់នូវតុលាការអព្យាក្រឹត និងអាជ្ញាយុកាលលើបទឧក្រិដ្ឋ ។ ទោះយ៉ាងណាក៏ដោយកម្ពុជាពុំមានច្បាប់នីតិវិធីព្រហ្មទណ្ឌទូលំទូលាយមួយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញធ្វើការពិភាក្សានោះទេ ។ ម្យ៉ាងវិញទៀត នៅមានចន្លោះខ្វះខាតជាច្រើនរវាងច្បាប់ជាតិ និងបទដ្ឋានអន្តរជាតិ ជាពិសេសពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ និងការការពារជនរងគ្រោះនិងសាក្សី ។

ក្រុមអ្នកសង្កេតការណ៍អន្តរជាតិ មានការព្រួយបារម្ភអំពីប្រសិទ្ធភាពដែលចៅក្រម ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចពិភាក្សាច្បាប់ទាំងនេះដើម្បីស្វែងរកនូវចម្លើយនៃចម្ងល់ស្តីអំពីនីតិវិធី ដូចដែលអ្នកសង្កេតការណ៍បានលើកឡើងនោះ ។ ប្រសិនបើវិធាននីតិវិធីត្រូវបានអនុវត្តដោយពឹងផ្អែកទៅលើមូលដ្ឋានច្បាប់ពិសេសណាមួយ អ្នកដែលមានតួនាទីនៅក្នុងតុលាការអាចបកស្រាយវិធាននេះផ្សេងៗគ្នារាល់ពេលអនុវត្ត ។ ជាពិសេស មេធាវីចៅក្រមខ្មែរអាចបកស្រាយវិធាននេះខុសពីមេធាវី និងចៅក្រមអន្តរជាតិ ប្ុភាគីទាំងពីរអាចនឹងមានការយល់ច្រឡំគ្នាទៅវិញទៅមកលើតម្រូវការចាំបាច់ក្នុងការអនុវត្តនូវគោលការណ៍រួមដែលមានភាពមិនច្បាស់លាស់ស្តីអំពីគោលការណ៍ណែនាំជាតិនិងអន្តរជាតិ ។ ប្រការនេះ អាចធ្វើឲ្យរាំងស្ទះដល់ទិសដៅសំខាន់នៃវិធាននីតិវិធី គឺការអនុវត្តន៍ដ៏សមហេតុសមផលនូវនីតិរដ្ឋ និងអាចគំរាមកំហែងដល់លទ្ធភាពរបស់តុលាការក្នុងការឆ្លើយតបទៅនឹងតម្លាភាព និងបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

វាជាការល្អប្រសើរដែលអនុម័តវិធាននីតិវិធីនិងវិធានភស្តុតាងដោយឡែកមុនពេលតុលាការកោះហៅ ។ អង្គច្បាប់ដែលត្រូវបានបង្កើតឡើងមួយនឹងជម្រុញឲ្យមានភាពសមស្របគ្នា និងកាត់បន្ថយនូវការព្រួយបារម្ភរបស់អ្នកអង្កេតការណ៍អន្តរជាតិ ដែលតែងតែទទូចសុំឲ្យមានការជំនុំជម្រះដោយយុត្តិធម៌ ។ ក៏ប៉ុន្តែ វាឆាប់រហ័សពេកក្នុងការព្យាករណ៍ថាតុលាការនឹងអនុវត្តវិធាននេះ នៅពេលដែលតុលាការលេចចេញជារូបរាង ។ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ធ្វើកំណែទម្រង់លើច្បាប់ “ក្រមព្រហ្មទណ្ឌនិងក្រមនីតិព្រហ្មទណ្ឌ” ដែលត្រូវបានព្រាងជាភាសាបារាំង ដែលបច្ចុប្បន្នកំពុងរង់ចាំការអនុម័តពីរដ្ឋសភាជាតិ ។ ទោះបីជាសេចក្តីព្រាងច្បាប់នេះចែងយ៉ាងច្បាស់នូវនីតិវិធីព្រហ្មទណ្ឌដ៏ស្មុគស្មាញក៏ដោយ សេចក្តីព្រាងច្បាប់នេះនឹងមិនអាចក្លាយទៅជាច្បាប់បានទេ មុនការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ មាត្រា១៣៥នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជាចែងថា “មុខងាររបស់តុលាការនឹងត្រូវកំណត់នៅក្នុងច្បាប់ដោយឡែកពីគ្នា” មានន័យថា រដ្ឋធម្មនុញ្ញតម្រូវជាចាំបាច់ឲ្យមានការអនុម័តរាល់វិធាននីតិវិធីទាំងអស់ ។

ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជអាណាចក្រកម្ពុជា បានបង្អាក់សាលាក្តីខ្មែរក្រហមក្នុងការអនុម័តនីតិវិធី ដរាបណារដ្ឋសភាជាតិមិនទាន់បានផ្តល់សិទ្ធិអំណាចបែបនេះទៅដល់ចៅក្រមយ៉ាងពិតប្រាកដនោះ ។ រដ្ឋសភាជាតិ អាចផ្តល់សិទ្ធិអំណាចទៅដល់ចៅក្រមបានតាមរយៈវិសោធនកម្មច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអនុញ្ញាតឲ្យចៅក្រមធ្វើ

សេចក្តីព្រាងច្បាប់ស្តីពីវិធាននីតិវិធីផ្ទាល់ខ្លួន ដូចដែលតុលាការផ្សេងៗទៀត ។ តាមសេចក្តីរាយការណ៍បានឲ្យដឹងថាក្រុមការងារជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីវិធាននីតិវិធី បើទោះបីជានៅមិនទាន់ដឹងច្បាស់នៅឡើយថាតើច្បាប់នេះនឹងត្រូវចូលជាធរមាននៅពេលណាក៏ដោយ ។ ទាក់ទិនទៅនឹងពេលវេលាគាត់តែងច្បាប់នេះ សេចក្តីព្រាងច្បាប់នេះ នៅពុំទាន់ត្រូវបានប្រកាសជាសាធារណៈនៅឡើយទេ ហើយសេចក្តីព្រាងច្បាប់នេះ នឹងអូសបន្លាយពេលបន្ថែមក្នុងការបង្កើតសាលាក្តីខ្មែរក្រហម ។ តាមហេតុផលដែលពិភាក្សាខាងលើ រហូតមកដល់ពេលនេះ វិធាននីតិវិធីនិងវិធានភស្តុតាងក្លាយជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ចម្រូងចម្រាស់បំផុតជុំវិញបញ្ហាបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ទោះបីជាច្បាប់អង្គជំនុំជម្រះវិសាមញ្ញនិងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ មិនបានចែងយ៉ាងច្បាស់នូវវិធាននីតិវិធីនិងវិធានភស្តុតាងយ៉ាងពេញលេញក៏ដោយ ក៏ច្បាប់និងកិច្ចព្រមព្រៀងនេះ ជាមូលដ្ឋានមួយសម្រាប់ដំណើរការជំនុំជម្រះក្តីនេះដែរ ។ ផ្នែកបន្ទាប់នេះ នឹងពិភាក្សាអំពីសិទ្ធិនិងកាតព្វកិច្ចរបស់ជនផ្សេងៗទៀតដែលមានភារកិច្ចនៅក្នុងសាលាក្តីនេះតាមដំណាក់កាលនីមួយៗនៃនីតិវិធីដែលត្រូវបានគ្រោងទុកដូចជាបុរេជំនុំជម្រះនិងការស៊ើបអង្កេត ការជំនុំជម្រះក្តី និងឧទ្ធរណ៍ ។ ការពិភាក្សានេះ ប្រព្រឹត្តជាសំខាន់ទៅតាមកាលប្បវត្តិដោយប្រើប្រាស់វិធាននីតិវិធីនិងវិធានភស្តុតាងដែលពាក់ព័ន្ធឲ្យបានទូលំទូលាយ និងដោយបង្ហាញថាវិធាននេះសមស្របនឹងនីតិវិធីព្រហ្មទណ្ឌប៉ុនណា ។ ផ្នែកចុងក្រោយ នឹងធ្វើការវាយតម្លៃទៅលើបញ្ហាមួយចំនួនដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវដោះស្រាយនោះ គឺភាពតានតឹងរវាងនីតិវិធីព្រហ្មទណ្ឌកម្ពុជានិងអន្តរជាតិ ដោយសារតែវិធាននីតិវិធីកម្ពុជាមួយចំនួន មិនអាចធានាបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ច្រើនជាងនីតិវិធីនៃបទដ្ឋានអន្តរជាតិដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងដែលត្រូវបានបញ្ចូលទៅក្នុងច្បាប់លក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ។

**ដំណាក់កាលបុរេជំនុំជម្រះនិងការស៊ើបអង្កេត ៖ ការកសាងសំណុំរឿងក្តីចោទប្រកាន់មេដឹកនាំខ្មែរក្រហម**

គ្រប់តុលាការព្រហ្មទណ្ឌទាំងអស់ មានកិច្ចការជាច្រើនដែលត្រូវធ្វើមុនការចាប់ផ្តើម ការជំនុំជម្រះក្តីនីមួយៗនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីអះអាងបញ្ជាក់ថា សំណុំរឿងក្តីទាំងឡាយត្រូវធ្វើឡើងដោយចោទប្រកាន់ចំពោះបុគ្គលដែលសមស្រប ។ នៅក្នុងដំណាក់កាលនេះ ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតត្រូវប្រមូលភស្តុតាងដែលទាក់ទិននឹងសំណុំរឿងបទឧក្រិដ្ឋ បើទោះបីជាចុងចោទជំទាស់ពុំទទួលស្គាល់ភស្តុតាងដាក់បន្ទុក និងអះអាងថា ការចោទប្រកាន់ដែលគួរតែត្រូវដកចេញនេះក៏ដោយ ។ ដំណាក់កាលនេះ ត្រូវបានហៅថាដំណាក់កាលបុរេជំនុំជម្រះនិងការស៊ើបអង្កេត ។ ស្ថិតក្រោមច្បាប់កម្ពុជា ដំណាក់កាលនេះមានពីរដំណាក់កាលក្នុងការកសាងសំណុំរឿងចោទប្រកាន់អំពើឧក្រិដ្ឋ គឺដំណាក់កាលស៊ើបអង្កេតបឋមរយៈពេលខ្លីដែលដឹកនាំដោយព្រះរាជអាជ្ញា និងដំណាក់កាលស៊ើបអង្កេតបន្តបន្ទាប់របស់តុលាការដែលដឹកនាំដោយចៅក្រមស៊ើបអង្កេត ។

នៅក្នុងដំណាក់កាលស៊ើបអង្កេត ព្រះរាជអាជ្ញាជាបឋមត្រូវប្រមូលភស្តុតាងដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ។ នៅពេលដែលមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា មានការប្រព្រឹត្តអំពើឧក្រិដ្ឋ ព្រះរាជអាជ្ញា ត្រូវលើកសំណើសុំតុលាការបើកការស៊ើបអង្កេតរបស់ខ្លួនតាម «ទម្រង់ស្នើសុំស៊ើបអង្កេត» ប្រគល់ឯកសារព្រមទាំងរបាយការណ៍ជូនចៅក្រមស៊ើបអង្កេតអំពីសារជាតិនៃបទឧក្រិដ្ឋនិងជនសង្ស័យ ។ ក្នុងដំណាក់ការស៊ើបអង្កេតនេះតុលាការត្រូវប្រមែប្រមូលភស្តុតាងឲ្យបានច្រើនសម្រាប់ប្រើប្រាស់ក្នុងការជំនុំជម្រះក្តី ។ បន្ទាប់ពីការស៊ើបអង្កេតនេះចប់សព្វគ្រប់ សំណុំរឿងក្តីត្រូវបញ្ជូនត្រឡប់ទៅព្រះរាជអាជ្ញាដើម្បីរៀបចំដីកាចោទប្រកាន់ដែលហៅថា «ដីកាសន្និដ្ឋានស្ថាពរ» ។ ព្រះរាជអាជ្ញាត្រូវប្រគល់ដីកាចោទប្រកាន់របស់ខ្លួនទៅចៅក្រមស៊ើបអង្កេត ហើយប្រសិនបើចៅក្រមស៊ើបអង្កេតរកឃើញថាអង្គហេតុនោះជាបទល្មើសឧក្រិដ្ឋនិងរកឃើញថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនជាប់ចោទ ព្រះរាជអាជ្ញាត្រូវ

ចេញដីកាសុំបញ្ជូនសំណុំរឿងឡើងសាលាដំបូង ។

បញ្ហាមួយដែលទំនងជានឹងកើតឡើងចំពោះមុខអង្គបុរេជំនុំជម្រះនៃសាលាក្តីខ្មែរក្រហមនោះ គឺថាតើអង្គជំនុំជម្រះវិសាមញ្ញទទួលបន្ទុកដោះស្រាយបញ្ហាការលើកលែងទោស អៀង សារី ដោយរាជរដ្ឋាភិបាលកម្ពុជាចំពោះការកាត់ទោសក្នុងឆ្នាំ១៩៧៩ ដែរឬទេ ប្រសិនបើតុលាការរកឃើញថា តុលាការមិនអាចដាក់ទោស អៀង សារី បាន ។ ដូចនេះ វិធានសម្រាប់ដំណាក់កាលបុរេជំនុំជម្រះ និងការស៊ើបអង្កេតគ្រប់គ្រងលើក្រមសីលធម៌របស់ព្រះរាជអាជ្ញា នគរបាល និងចៅក្រមស៊ើបអង្កេត ដែលការពារសិទ្ធិរបស់ជនសង្ស័យក្នុងអំឡុងពេលជាប់ឃុំឃាំងនិងសួរចម្លើយ ។

## ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបង្កើតការិយាល័យមួយដែលមានសហព្រះរាជអាជ្ញាពីររូប (ព្រះរាជអាជ្ញាខ្មែរមួយរូប និងអន្តរជាតិមួយរូប) ដែលនឹងធ្វើការរួមគ្នាដើម្បីកាត់សេចក្តីនៅចំពោះមុខតុលាការ ។ នេះជាវិធីមួយដែលដំណាក់កាលបុរេជំនុំជម្រះនិងការស៊ើបអង្កេតនៃដំណើរការអង្គជំនុំជម្រះវិសាមញ្ញនឹងបំពេញការងារខុសពីបុរេជំនុំជម្រះ និងការស៊ើបអង្កេតនៅក្នុងតុលាការអន្តរជាតិដទៃទៀត ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា មានការិយាល័យមួយដែលមានតែព្រះរាជអាជ្ញាមួយរូបប៉ុណ្ណោះ ហើយរហូតមកទល់នឹងពេលនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិអនុម័តយកគំរូបែបនោះ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ព្រះរាជអាជ្ញាមានអំណាចដែលត្រូវបានកំណត់យ៉ាងច្បាស់ក្នុងការគ្រប់គ្រងគ្រប់ដំណាក់កាលនិងទិដ្ឋភាពទាំងអស់នៃការស៊ើបអង្កេតដោយចាប់ពីការចេញដីកាចោទប្រកាន់រហូតដល់ការចោទសួរជនសង្ស័យនិងសាក្សី រហូតដល់ការប្រមូលភ័ស្តុតាង និងរហូតដល់ការស៊ើបអង្កេតដល់ទីកន្លែងផ្ទាល់ ។ តាមវិធីនេះ ព្រះរាជអាជ្ញាត្រូវបំពេញមុខនាទីជាព្រះរាជអាជ្ញាផង និងជាចៅក្រមស៊ើបអង្កេតផងនៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណី ។ ផ្ទុយទៅវិញ សាលាក្តីខ្មែរក្រហមនៅតែពេញចិត្តនឹងច្បាប់រដ្ឋប្បវេណីដែលតម្រូវឲ្យមានការិយាល័យពីរដោយឡែកពីគ្នា ដែលមានសហចៅក្រមស៊ើបអង្កេតពីររូបជាអ្នកទទួលខុសត្រូវលើការស៊ើបអង្កេត និងសហព្រះរាជអាជ្ញាពីររូបត្រឹមតែធ្វើការកាត់សេចក្តីតែប៉ុណ្ណោះ ។

បញ្ហាដ៏មានសក្តានុពលដែលទាក់ទិនទៅនឹងរចនាសម្ព័ន្ធនៃស្ថាប័ននេះ គឺទាំងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិមិនបានបែងចែកយ៉ាងច្បាស់រវាងតួនាទីសហចៅក្រមស៊ើបអង្កេតនិងសហព្រះរាជអាជ្ញាឡើយ ។ ការរៀបចំឲ្យមានការចែករំលែកអំណាចគ្នានេះ បានឆ្លុះបញ្ចាំងអំពីសារជាតិរបស់ចៅក្រមស៊ើបអង្កេតនៃប្រព័ន្ធច្បាប់រដ្ឋប្បវេណី ដែលមានន័យថាសហព្រះរាជអាជ្ញានិងសហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចប្រមែប្រមូលភ័ស្តុតាងដែលព្រះរាជអាជ្ញានិងមេធាវីចុងចោទពេញចិត្តនឹងទទួលយក ។ ក៏ប៉ុន្តែ ទំនាក់ទំនងរវាងព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតនៅក្នុងច្បាប់កម្ពុជា ពុំត្រូវបានកំណត់យ៉ាងច្បាស់លាស់នោះទេ ។ ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេតសហការគ្នាច្រើនជាងការងារនៅការិយាល័យដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកនៅក្នុងប្រព័ន្ធច្បាប់រដ្ឋប្បវេណីដទៃទៀត ។ រចនាសម្ព័ន្ធដ៏ធូររលុងនេះធ្វើឲ្យមានការព្រួយបារម្ភអំពីឯករាជ្យភាពរបស់ព្រះរាជអាជ្ញាអង្គជំនុំជម្រះវិសាមញ្ញ ។ កង្វះតួនាទីពីមុនរបស់ចៅក្រមស៊ើបអង្កេតនៅក្នុងតុលាការអន្តរជាតិ ដោយផ្គួបផ្សំជាមួយនឹងទំនាក់ទំនងមិនច្បាស់លាស់រវាងចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញានៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ធ្វើឲ្យដំណើរការកាត់សេចក្តីនៅក្នុងដំណាក់កាលបុរេអង្គជំនុំជម្រះនិងការស៊ើបអង្កេតមានភាពស្មុគស្មាញនិងអូសបន្លាយពេលវេលាមិនសមហេតុសមផលដូចដែលរចនាសម្ព័ន្ធនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ ។

## យន្តការដោះស្រាយជម្លោះ

សេចក្តីសម្រេចបង្កើតការិយាល័យមួយដែលមានសហព្រះរាជអាជ្ញាពីររូប កើតចេញពីការព្រមព្រៀងគ្នារវាងអ្នកធ្វើសេចក្តីព្រាងច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សេចក្តីសម្រេចចិត្តនេះជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ចម្រូងចម្រាសនៅក្នុងអំឡុងពេលនៃកិច្ចចរចាបង្កើតសាលាក្តីខ្មែរក្រហម ។ ក៏ប៉ុន្តែ អ្នកធ្វើសេចក្តីព្រាងច្បាប់បានគិតទុកជាមុនថា

នឹងមានជម្លោះកើតឡើងរវាងព្រះរាជអាជ្ញា ជាពិសេសទៅលើបញ្ហាចុងក្រោយដែលទាក់ទិននឹងប្រភេទជនសង្ស័យដែលត្រូវចោទប្រកាន់ ។ ដើម្បីដោះស្រាយនូវភាពជាប់គាំងបែបនេះ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បញ្ចូលយន្តការដោះស្រាយជម្លោះរវាងព្រះរាជអាជ្ញា ។ ក្នុងករណីមានជម្លោះ ព្រះរាជអាជ្ញាម្នាក់ក្នុងចំណោមព្រះរាជអាជ្ញាទាំងនោះ អាចស្នើសុំអង្គបុរេជំនុំជម្រះដោះស្រាយជម្លោះនេះ ក្នុងរយៈពេល៣០ថ្ងៃ ។ អង្គជំនុំជម្រះនេះ ត្រូវសម្រេចឲ្យបាននូវការព្រមព្រៀងគ្នាមួយ តាមរយៈការបោះឆ្នោតមតិភាគច្រើនលើសលប់ដែលតម្រូវឲ្យមានសំឡេងបួនយ៉ាងតិចពីចៅក្រមប្រាំរូប ដែលយ៉ាងហោច មានមតិចូលរួមពីចៅក្រមអន្តរជាតិមួយរូបនៅក្នុងសេចក្ដីសម្រេចចិត្តនេះ ។ ប្រសិនបើចៅក្រមទាំងនេះ មិនអាចសម្រេចយកតាមការបោះឆ្នោតមតិភាគច្រើនវិញនោះ ការស៊ើបអង្កេតនិងការកាត់សេចក្ដីនឹងប្រព្រឹត្តទៅដូចពីមុន ។ ជាងនេះទៀត មានយន្តការស្រដៀងគ្នានេះសម្រាប់សហចៅក្រមស៊ើបអង្កេតអាចបដិសេធចំពោះដំណើរការស៊ើបអង្កេតនេះ ។

ទិសដៅក្រៅពីបទបញ្ញត្តិស្ដីពីការបោះឆ្នោតមតិភាគច្រើននេះ គឺការពិនិត្យ ការសន្និដ្ឋានចោទប្រកាន់ដែលមានជម្លោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអង្គបុរេជំនុំជម្រះ ខកខានមិនបានសន្និដ្ឋានចោទប្រកាន់ដោយការបោះឆ្នោតមតិភាគច្រើន ព្រះរាជអាជ្ញាអាចបន្តការសន្និដ្ឋានចោទប្រកាន់របស់ខ្លួន ។ ឧទាហរណ៍ខាងក្រោមនេះ នឹងបង្ហាញអំពីមូលហេតុដែលបទបញ្ញត្តិនេះបង្កជាបញ្ហា ។ សហព្រះរាជអាជ្ញាខ្មែរចោទប្រកាន់ជនសង្ស័យពីបទឧក្រិដ្ឋកម្ម ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិមានជំនឿថា សហព្រះរាជអាជ្ញាខ្មែរនឹងគ្មានអង្គហេតុគ្រប់គ្រាន់ដាក់បន្ទុកចំពោះការចោទប្រកាន់នេះឡើយ ។ ដោយហេតុផលនេះ សហព្រះរាជអាជ្ញាអន្តរជាតិអាចប្ដឹងទៅអង្គបុរេជំនុំជម្រះដោយស្នើសុំក្រុមចៅក្រមខ្មែរធ្វើការពិនិត្យអង្គហេតុនេះឡើងវិញ ។ ចៅក្រមខ្មែរមិនបានសន្និដ្ឋានចោទប្រកាន់តាមរយៈការបោះឆ្នោតមតិភាគច្រើន ពីព្រោះចៅក្រមខ្មែរបីរូបរកឃើញថាមានអង្គហេតុដាក់បន្ទុកគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់នេះ ។ ព្រះរាជអាជ្ញាខ្មែរនឹងបន្តការចោទប្រកាន់របស់ខ្លួនតាមមាត្រា២០នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលចែងថា "ប្រសិនបើពុំមានមតិភាគច្រើនដូចតម្រូវឲ្យមានចំពោះការធ្វើសេចក្ដីសម្រេចទេ ការចោទប្រកាន់ ត្រូវធ្វើបន្តទៅទៀត" ។ ដូចនេះ ការសន្និដ្ឋានចោទប្រកាន់នឹងបន្តទៅទៀត ទោះបីជាចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិរកឃើញថាពុំមានភ័ស្តុតាងគ្រប់គ្រាន់យ៉ាងណាក៏ដោយ ។

## សិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ

បទដ្ឋានអន្តរជាតិ អាចនឹងត្រូវទទួលការគំរាមកំហែងបន្ថែមនៅក្នុងដំណាក់កាលនេះ ពីព្រោះច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បដិសេធចំពោះសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ ច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ អនុញ្ញាតឲ្យជនជាប់ចោទប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចមួយចំនួនដោយចៅក្រមស៊ើបអង្កេត ប៉ុន្តែចុងចោទមិនអាចបដិសេធសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមានការកិច្ចដោះស្រាយការខ្វែងគំនិតគ្នារវាងសហចៅក្រមស៊ើបអង្កេតទេ តាមលក្ខណៈបច្ចេកទេស ការរឹតត្បិតទៅលើសិទ្ធិប្ដឹងឧទ្ធរណ៍នៅក្នុងដំណាក់កាលបុរេជំនុំជម្រះ មិនបានរំលោភបំពានលើសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះការចោទប្រកាន់ ឬការដាក់ទោសជាអន្តរជាតិឡើយ (ដូចដែលមានចែងនៅក្នុងមាត្រា១៤នៃអនុសញ្ញាអន្តរ-ជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ) ក៏ប៉ុន្តែការរឹតត្បិតនេះរំលោភបំពានទៅលើគោលការណ៍នេះខាងផ្នែកស្មារតី ។

ជាងនេះទៅទៀត ការប្រានចោលរបស់សាលាក្ដីខ្មែរក្រហមចំពោះគ្រប់សិទ្ធិប្ដឹងឧទ្ធរណ៍ទាំងអស់ ចំពោះសេចក្ដីសម្រេចចិត្តរបស់អង្គបុរេជំនុំជម្រះ គឺផ្ទុយស្រឡះទៅនឹងនីតិវិធីដែលមាននៅក្នុងតុលាការកូនកាត់និងតុលាការអន្តរជាតិដទៃទៀត ។ អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មានតួនាទីធំធេងជាងអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ប៉ុន្តែ ច្បាប់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ អនុញ្ញាតឲ្យមានសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចមួយចំនួននៃអង្គបុរេជំនុំជម្រះឲ្យបានឆាប់រហ័ស ព្រមទាំងសិទ្ធិប្ដឹងឧទ្ធរណ៍ចំពោះសេចក្ដីសម្រេចដែលប៉ះពាល់ទៅដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឬដោយឆាប់រហ័ស ។ តុលាការពិសេសនៅសៀរ៉ាឡេអូន

អនុញ្ញាតឲ្យមានការប្រឆាំងជាបឋមចំពោះបញ្ហាដែនសមត្ថកិច្ចដែលត្រូវដាក់បញ្ចូលទៅក្នុងឯកសារសំណុំរឿងដោយសាលាឧទ្ធរណ៍ចំពោះសេចក្តីសម្រេចចិត្តភ្លាមៗ ។ ការកំណត់តួនាទីអង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កាត់បន្ថយទៅដល់កិត្យានុភាពនៃសិទ្ធិប្តឹងឧទ្ធរណ៍ ក៏ប៉ុន្តែការហាមប្រាមនៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញមិនឲ្យប្រើប្រាស់សិទ្ធិប្តឹងឧទ្ធរណ៍បែបនេះ មានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត ឯកភាពគ្នាដោះស្រាយបញ្ហានីតិវិធី ចុងចោទមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេត ផ្ទុយទៅវិញ ប្រសិនបើសហចៅក្រមស៊ើបអង្កេត បដិសេធមិនដោះស្រាយ ហើយបែរជាអង្គបុរេជំនុំជម្រះជាអ្នកសម្រេចដោះស្រាយបញ្ហាវិញ ចុងចោទពុំមានសិទ្ធិជំទាស់នឹងការសម្រេចចិត្តរបស់អង្គបុរេជំនុំជម្រះបាននោះទេ ។ ប្រការនេះជួយដោះស្រាយនូវបញ្ហាយុត្តិធម៌ដែលផ្តោតជាខ្លាំងទៅលើបញ្ហានីតិវិធីដែលសម្រេចនៅក្នុងដំណាក់កាលស៊ើបអង្កេតបឋម ។


គុកសម្រាប់ឃុំឃាំងអ្នកទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម

ការស៊ើបអង្កេតនិងកិច្ចការរៀបចំសំណុំរឿងនឹងត្រូវបញ្ចប់នៅពេលដែលចាប់ផ្តើមដំណើរការកាត់សេចក្តី ដែលវិនិច្ឆ័យពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ ។ ភាពសមហេតុសមផលនៃភាពត្រឹមត្រូវ និងសមត្ថភាព តែងតែមានភាពតានតឹងនៅក្នុងពេលកាត់សេចក្តីនេះ ពីព្រោះចៅក្រមជាអ្នកទទួលខុសត្រូវការពារទាំងសិទ្ធិរបស់ចុងចោទ និងសិទ្ធិរបស់សាក្សីនិងជនរងគ្រោះ ដើម្បីធានាឲ្យបាននូវការជំនុំជម្រះឆាប់រហ័ស ។ មាត្រា៣៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្លុះបញ្ចាំងពីភាពតានតឹង ÷

*អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវនិងឆាប់រហ័សទៅតាម នីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនដែលត្រូវចោទ និងមានការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះនិងសាក្សី ។ បើជាការចាំបាច់ ហើយនីតិវិធីដែលនៅជាធរមាននោះមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។*

នៅក្នុងពេលបើកសវនាការ ភាគីជម្លោះទាំងពីរត្រូវបង្ហាញសំណុំរឿងរបស់ខ្លួននៅចំពោះមុខសាលា ដំបូងដែលមានសមាសភាពចៅក្រមចំនួន៥រូប (គឺចៅក្រមខ្មែរចំនួនបីរូប និងចៅក្រមបរទេសចំនួនពីររូប) ។ ជនដែលត្រូវឡើងសវនាការដំបូងគឺជនជាប់ចោទ ហើយជនដែលត្រូវឡើងសវនាការបន្ទាប់ គឺសាក្សីនៃភាគីជម្លោះទាំងអស់ ខាងព្រះរាជអាជ្ញាខាងជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្ម និងខាងមេធាវីចុងចោទ ។ បន្ទាប់ពីភស្តុតាងទាំងអស់ត្រូវបានបញ្ជូនទៅតុលាការ ភាគីជម្លោះត្រូវរក្សាការសម្ងាត់នូវសម្តីរបស់ខ្លួន ។ បន្ទាប់មក ចៅក្រមជាអ្នកដែលត្រូវពិចារណា និងអ្នកវិនិច្ឆ័យសម្រេច ។ នៅក្នុងអង្គបុរេជំនុំជម្រះ សេចក្តីសម្រេចតម្រូវឲ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមយ៉ាងតិចបួនរូប ដែលជាសំឡេងភាគច្រើនលើសលប់ ។ ក្នុងករណីដែលចៅក្រមមិនអាចសម្រេចបានជាឯកច្ឆ័ន្ទលើសេចក្តីសម្រេចរបស់ខ្លួន ចៅក្រមត្រូវរាប់បញ្ចូលទាំងមតិភាគច្រើន និងមតិភាគតិចនៅក្នុងសេចក្តីសម្រេចចុងក្រោយ ។ ជាចុងក្រោយ ចៅក្រមត្រូវកាត់ទោសដោយស្មើភាពគ្នាទៅនឹងសេចក្តីសម្រេចចុងក្រោយនេះ ។ នៅក្នុងសាលាក្តីខ្មែរក្រហមការដាក់ទោសខ្ពស់បំផុតនោះ គឺបានត្រឹមតែទោសជាប់គុកអស់មួយជីវិតប៉ុណ្ណោះ ។ **(នៅមានត)**

**ខេតទ្រីណា អេនឌឺសុន**

# ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពក្នុងសម័យខ្មែរក្រហម

*«កាលណាយើងមានទឹក យើងមានស្រូវ ។ កាលណាយើងមានស្រូវ យើងមានអ្វីៗទាំងអស់»*

នៅលើពិភពលោក ពុំមានរបបទំនើបណាមួយឲ្យតម្លៃខ្ពស់លើការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពថាមានសារសំខាន់ទេ ។ មានតែរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប៉ុណ្ណោះដែលគិតថាការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពមានសារ-សំខាន់ ។ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ឲ្យចេញពីទីក្រុងនិងទីប្រជុំនានា និងបង្ខំឲ្យប្រជាជនទូទាំងប្រទេសស្ទូងស្រូវ ជីកប្រឡាយ និងលើកទំនប់ ។ ផ្ទុយទៅវិញ ប្រជាជនខ្មែរជាង ២០ភាគរយបានស្លាប់ដោយការធ្វើការហួសកម្លាំង ដោយការអត់អាហារ ដោយជំងឺ និងដោយការសម្លាប់ ហើយផលស្រូវសរុបសម្រេចបានទាបជាងផលស្រូវក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ទៅទៀត ។ អត្ថបទនេះ នឹងបកស្រាយអំពីផែនការអភិវឌ្ឍប្រព័ន្ធស្រោចស្រពដ៏ធំធេងនេះរបស់ខ្មែរក្រហម និងមូលហេតុដែលខ្មែរក្រហមបរាជ័យក្នុងគោលនយោបាយរបស់ខ្លួន ។

មេដឹកនាំខ្មែរក្រហមមានជំនឿថាខ្លួនកំពុងតែបង្កើតនូវបដិវត្តន៍សង្គមនិយមដ៏ស្អាតស្អំមួយដែលពិភពលោកពុំធ្លាប់ជួបប្រទះ ដោយពឹងផ្អែកទៅលើការផ្សព្វផ្សាយ «មាគ៌ាដ៏ត្រឹមត្រូវ» និងដំបម្លែកស្តីពីគំនិតសង្គមនិយមរបស់ខ្លួន ។ នៅពេលនោះ សង្គមខ្មែរទាំងមូលត្រូវបានរៀបចំរចនាសម្ព័ន្ធជាថ្មីឡើងវិញតាមរបៀបយោធាក្នុងវិស័យកសិកម្មដើម្បីកាត់ផ្តាច់ប្រជាជនចេញពីភាពជាម្ចាស់កម្មសិទ្ធិដីនិងគ្នាទៅវិញទៅមក ។ ទិសដៅផលិតស្រូវសម្រាប់ឆ្នាំដំបូងត្រូវតែសម្រេចឲ្យបានខ្ពស់ច្រើនជាងទិន្នផលស្រូវមធ្យមមុនសម័យសង្គ្រាមបីដងសម្រាប់ប្រទេសកម្ពុជាទាំងមូល ។ ទិន្នផលស្រូវនេះ ត្រូវសម្រេចឲ្យបានខ្ពស់ដោយពុំបាច់ប្រើប្រាស់ជីគីមី អ្នកជំនាញ ឬគ្រឿងម៉ាស៊ីនអ្វីនោះទេ ។ ខ្មែរក្រហមចង់បង្ហាញថា បច្ចេកវិជ្ជាមិនមែនជាតម្រូវការចាំបាច់នោះឡើយ ។ តម្រូវការចាំបាច់តែមួយគត់ដើម្បីសម្រេចបានជោគជ័យនោះគឺឆន្ទៈរួមរបស់ប្រជាជនបដិវត្តន៍ ។ ដូចនេះ ការសិក្សាស្រាវជ្រាវនេះ ជាប្រតិនិក្ខេបបទមួយសម្រាប់ការស្វែងយល់អំពីប្រព័ន្ធស្រោចស្រពបែបទំនើបបន្ថែមទៅលើការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពបច្ចុប្បន្ន ជាពិសេស ទាក់ទងនឹងសារសំខាន់និងការប្រើប្រាស់ដ៏សមស្របនូវបច្ចេកវិជ្ជានិងការគ្រប់គ្រងប្រព័ន្ធស្រោចស្រពនិងកសិកម្មដោយប្រជាកសិករ ។

## សេចក្តីផ្តើម

*«ដើម្បីអនុវត្តឲ្យបានខ្ជាប់ខ្ជួនក្នុងការរៀបចំផែនការ និងដោះស្រាយបញ្ហាឲ្យទាន់ពេលវេលាក្នុងទិសដៅសម្រេចឲ្យបានតាមផែនការ៣តោនក្នុង១ហិកតា...ត្រូវជ្រើសរើសស្រុកដែលផលិតស្រូវបាន៣តោនក្នុង១ហិកតាធ្វើជាគំរូដើម្បីបង្ហូតទង់ «មហាលោតផ្លោះ» ។ ទិសដៅសំខាន់ពិតប្រាកដ គឺផលស្រូវគិតជាតោន(ក្នុង១ហិកតា)» ។*

គេជឿជាក់ថា ប៉ុល ពត បាននិយាយពាក្យទាំងនេះ នៅពេលដែល ប៉ុល ពត កំពុងតែពន្យល់ប្រាប់កម្មាភិបាលខ្មែរក្រហម ភូមិភាគបស្ចិមថា ត្រូវសម្រេចឲ្យបានតាមផែនការនូវផលស្រូវខ្ពស់ជាងបីដងមុនសម័យសង្គ្រាមនៅក្នុងរដូវខាងមុខនេះ ។ ទោះបីជាតំបន់នេះ ជាតំបន់ក្រីក្រមួយក្នុងចំណោមតំបន់ក្រីក្របំផុតជាច្រើននៅក្នុងប្រទេសកម្ពុជា និងក្នុងរយៈពេលមួយឆ្នាំ តំបន់នេះមានសភាពខុសប្លែកពីសម័យសង្គ្រាមស៊ីវិលរយៈពេល៥ឆ្នាំ យ៉ាងណាក៏ដោយ ប៉ុល ពត បានដឹងមុនថាកិច្ចការនេះ ជាកិច្ចការដែលអាចសម្រេចបានជោគជ័យដោយងាយស្រួលបំផុត ។ ក៏ប៉ុន្តែ យោងតាមមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជាប្រជាធិប-តេយ្យ ÷ យើងត្រូវលោតផ្លោះរំលងសង្គមអាណានិគមបែបថ្មី សង្គមពាក់កណ្តាលសក្តិភូមិរបស់ពួកចក្រពត្តិអាមេរិក សង្គមពួកសក្តិភូមិនិងពួកមូលធន និងត្រូវសម្រេចឲ្យបាននូវសង្គមនិយមមួយឆ្ពោះទៅមុខជានិច្ច ។ ស្ថានភាពរបស់យើងខុសពីស្ថានភាពរបស់ប្រទេសដទៃទៀត ។ សម្រាប់យើងទាំងអស់គ្នា យើងមានលក្ខណៈសម្បត្តិខុសពីអ្នកទាំងនោះ ។ យើងដើរលឿនជាងអ្នកទាំងនោះ ។ មាគ៌ារបស់យើង គឺត្រឹមត្រូវទាំងផ្អែកយុទ្ធសាស្ត្រ និង

*យុទ្ធវិធី ។ លក្ខណៈសម្បត្តិរបស់យើងគឺខុសគេ...។ មាគ៌ាយើងគឺខុសគេ ។ ចលនាបដិវត្តន៍របស់យើង គឺជាបទពិសោធន៍ថ្មីសន្លាងមួយនិងជាបទពិសោធន៍ដ៏មានសារសំខាន់សម្រាប់ពិភពលោកទាំងមូល ពីព្រោះយើងមិនបានយកគំរូតាមអ្នកដទៃឡើយ ។*

មេដឹកនាំខ្មែរក្រហមបានបង្កើតឃ្លានិងឯកសារនយោបាយរបស់ខ្លួនទាំងនេះដើម្បីបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីគោលនយោបាយដ៏សមស្រប ច្បាស់លាស់ និងពិតប្រាកដក្នុងការអភិវឌ្ឍន៍គោលនយោបាយនិងសេដ្ឋកិច្ចឆាប់រហ័សនៃរដ្ឋសង្គមនិយមដ៏ស្អាតស្អំមួយ ក្រោមពាក្យស្លោកថា "មហាលោតផ្លោះ មហាអស្ចារ្យ" ។ ពាក្យថា មហាលោតផ្លោះ មានន័យថា ការកើនឡើងយ៉ាងធំធេងនូវផលិតផលកសិកម្មទូទាំងប្រទេស ។ ទិន្នផលកសិកម្មនេះ ជាទុនផ្តោះទៅរកការបង្កើតឧស្សាហកម្មធុនស្រាលនិងធុនធ្ងន់ ។ កត្តាដែលអាចធ្វើឲ្យបដិវត្តន៍សម្រេចបានជោគជ័យ គឺការគ្រប់គ្រងនិងការប្រើប្រាស់កម្លាំងមហាជន ហើយរៀបកម្លាំងទាំងនេះជាក្រុមក្នុងការធ្វើកសិកម្ម ។

*កត្តាដែលអាចធ្វើឲ្យបដិវត្តន៍សម្រេចបានជោគជ័យ គឺកត្តាគោលនយោបាយប្រជាជនបដិវត្តន៍ និងយុទ្ធវិធីបដិវត្តន៍ មិនមែនកើតចេញពីកត្តាបច្ចេកវិជ្ជានោះទេ ។*

ខ្មែរក្រហមគ្រប់គ្រងប្រទេសកម្ពុជាបានត្រឹមតែជាងបីឆ្នាំប៉ុណ្ណោះ ក៏ដួលរលំទៅដោយបានបន្សល់ទុកប្រជាជនជាច្រើនដើរស្វែងរកក្រុមគ្រួសារពេញទូទាំងប្រទេសកម្ពុជា ។ តាមការប៉ាន់ប្រមាណថាមានប្រជាជនប្រហែលជា១,៧លាននាក់ បានស្លាប់ដោយការធ្វើការហួសកម្លាំងជំងឺ ការអត់អាហារ និងដោយការសម្លាប់ក្នុងអំឡុងពេលដែលខ្មែរក្រហមកំពុងកាន់កាប់អំណាច ។ ក្នុងរយៈពេលជាងបីឆ្នាំនេះ ប្រជាជនខ្មែរជាច្រើននាក់បានស្លាប់ដោយសារតែស្ថានភាពរស់នៅរបស់ប្រជាជនមានសភាពលំបាកលំបិន ហើយការបោសសម្អាតរបស់មជ្ឈិមបក្សចេះតែរីកធំឡើងមិនអាចគ្រប់គ្រងបាន ។

## តើពាក្យស្លោក "មហាលោតផ្លោះ មហាអស្ចារ្យ" កើតឡើងដោយរបៀបណា?

*របៀបរបបសង្គមថ្មី*

កិច្ចការដំបូងបំផុតរបស់ខ្មែរក្រហម គឺការរៀបចំរចនាសម្ព័ន្ធសង្គមទាំងមូលឡើងវិញ ។ ការរៀបចំរចនាសម្ព័ន្ធថ្មីនេះ គឺជាការរៀបចំដ៏សំខាន់ដើម្បីឲ្យប្រជាជនផ្លាស់មកចូលរួមនឹងបដិវត្តន៍ និងដើម្បីគ្រប់គ្រងកម្លាំងប្រជាពលករស្របតាម"របៀបផលិតកម្ម" ដទៃទៀតក្នុងការធ្វើកសិកម្ម ។ ភ្លាមៗនោះដែរ ទីក្រុងជាច្រើនបានក្លាយទៅជាស្ងាត់ជ្រងំគ្មានមនុស្សរស់នៅបន្ទាប់ពីខ្មែរក្រហមបានទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយបានជម្លៀសប្រជាជនឲ្យទៅធ្វើស្រែចម្ការនៅតាមតំបន់ជនបទ ។ ប្រជាជនខ្មែរត្រូវខ្មែរក្រហមរៀបចំឡើងវិញតាមរបៀបយោធាជា "ក្រុមផលិត" ដែលមាន "សហករណ៍" និង "កងចល័ត" ។ ប្រជាជនត្រូវបានចាត់ជាក្រុម តាមអាយុ ភេទ កាយសម្បទា និងវណ្ណៈភាព ដោយមានការចល័តប្រជាជនពីតំបន់មួយទៅតំបន់មួយ និងក្នុងតំបន់ដទៃដែលនៅជិតឃុំ ។ ក្រោយមកទៀត ក្រុមផលិតត្រូវបានបង្ខំឲ្យផលិតស្រូវបានច្រើន ដោយការ "វាយសម្រុកធ្វើដី" ។

សត្វពាហនៈ ឧបករណ៍ និងដីទាំងអស់ ត្រូវបានប្រមែប្រមូលដាក់ជាសមូហភាព ហើយប្រជាជនត្រូវអង្គការចាត់ឲ្យទៅធ្វើកសិកម្មផ្សេងៗ ដោយរាប់បញ្ចូលទាំងកុមារនិងមនុស្សចាស់ជរាផង ។ ជាក់ស្តែង ប្រជាជនទាំងអស់ ត្រូវបានចល័តឲ្យទៅលើកទំនប់និងជីកប្រឡាយទូទាំងប្រទេស ។ សតិអារម្មណ៍វិទ្ធង្សនាមួយទៀតក្រៅពីការរៀបចំរចនាសម្ព័ន្ធសង្គមថ្មីឡើងវិញនេះ គឺការបំបែកក្រុមគ្រួសារ ដែលជាទូទៅកុមារត្រូវអង្គការអនុញ្ញាតឲ្យមកជួបឪពុកម្តាយរបស់ខ្លួនរាល់ពីរឬបីខែម្តង និងត្រូវដុសខាត់ខួរក្បាលឲ្យជឿជាក់តែលើ"អង្គការ"ខ្មែរក្រហមប៉ុណ្ណោះ ។ ក្នុងការរៀបចំប្រជាជនឡើងវិញ កម្មាភិបាលមូលដ្ឋាន ជាអ្នករៀបចំគ្រួសារឲ្យប្រជាជនដោយពុំបានពិភាក្សាឬពិគ្រោះយោបល់ពីប្រជាជនទាំងនោះឡើយ ។

គំនិតជាចម្បងបន្ថែមមួយទៀតរបស់ខ្មែរក្រហម គឺការប្រកាន់ខ្ជាប់នូវ"ការតស៊ូវណ្ណៈ"រហូតដើម្បីលុបបំបាត់ចោលនូវអ្វីដែលខ្មែរក្រហមចាត់ទុកថាជាសត្រូវផ្ទៃក្នុងនិងសត្រូវខាងក្រៅដែលប្រឆាំងនឹងបដិវត្តន៍ ។ ម្យ៉ាងទៀត គំនិតនេះ ក៏នឹងប្រើប្រាស់ដើម្បីធ្វើឲ្យបក្សមានភាពស្អាតស្អំ និងពង្រឹងការគ្រប់គ្រងជាមួយនឹងមជ្ឈិមបក្ស ។ កសិករក្រីក្រដែលមកពីតំបន់ដែលគាំទ្រខ្មែរ

ក្រហមក្នុងសម័យសង្គ្រាមត្រូវបានកំណត់ថាជាវណ្ណៈសមស្រប ។ ដោយឡែក កសិករវណ្ណៈមានទ្រព្យសម្បត្តិ វណ្ណៈគហបតី ទាហាន ដែលមិនមែនជាខ្មែរក្រហម អ្នកដែលមានចំណេះដឹង ឬអ្នកដែលមកពីតំបន់ដែលប្រឆាំងនឹងខ្មែរក្រហមក្នុងសម័យសង្គ្រាម គឺជាសត្រូវវណ្ណៈ ។ ដោយហេតុនេះ ប្រជាជនត្រូវបានបែងចែកជា "ប្រជាជនមូលដ្ឋានឬប្រជាជនចាស់" ដែលអង្គការជឿទុកចិត្ត និង"ប្រជាជនថ្មី" ដែលអង្គការមិនជឿទុកចិត្ត ។ ការបំពានបដិវត្តន៍សបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថាការបញ្ជានៅមូលដ្ឋាន និងគោលនយោបាយជាតិ ត្រូវអនុវត្តតាមដោយគ្មានសង្ស័យអ្វីឡើយ បើទោះជាដឹងថាការអនុវត្តនេះមិនត្រឹមត្រូវយ៉ាងណាក៏ដោយ ។

## ២) ប្រព័ន្ធស្រោចស្រពជួយអភិវឌ្ឍវិស័យកសិកម្មថ្មី

យុទ្ធសាស្ត្រសំខាន់សម្រាប់ការបង្កើនផលិតផលស្រូវ គឺការបង្កើនការដាំដំណាំស្រូវពីរឬបីដងក្នុងមួយឆ្នាំនៅតាមតំបន់ជាច្រើនតាមដែលអាចធ្វើបានតាមរយៈប្រព័ន្ធស្រោចស្រពនេះ ។ ផ្ទៃដីដាំស្រូវនៅមុនសម័យសង្គ្រាមមានប្រហែលជា២,៥លានហិកតា ក្នុងនោះមានផ្ទៃដីតែ១៧,០០០ហិកតាប៉ុណ្ណោះ ដែលត្រូវបានស្រោចស្រព។ នៅខែធ្នូ ឆ្នាំ១៩៧៥ ប៉ុល ពត បានមានប្រសាសន៍ក្នុងបទសម្ភាសន៍មួយថា ផែនការបក្ស គឺការស្រោចស្រពផ្ទៃដី១,៥លានហិកតា ។ លោក ភីជភឺស៍ បានរៀបរាប់យុទ្ធសាស្ត្រនេះថា ÷

ដើម្បីសម្រេចឲ្យបានទិសដៅកំណើនផលិតកម្មជាតិ ផែនការជាតិរៀបចំដីឡើងវិញធ្វើឡើងដោយពឹងផ្អែកទៅលើបច្ចេកទេសដ៏សាមញ្ញ ÷ ១)ក្នុងមួយហិកតានៃផ្ទៃដីទូទាំងប្រទេស បែងចែកជាដីបន្តុបង្កើនផលនិងដីវានព្រៃ ។ ២) ការគ្រប់គ្រងទឹក (ប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធបង្ហូរទឹក) ត្រូវការជាចាំបាច់សម្រាប់ប្រភេទស្រូវផ្សេងៗដែលផ្តល់ទិន្នផលខ្ពស់តាមរយៈប្រឡាយមេ និងកូនប្រឡាយដែលមានរាងជាចតុកោណកែង ។ (ប្រឡាយមេដែលមានទំហំ១គុណ១គីឡូម៉ែត្រផ្ទៃក្រឡាស្របតាមខ្សែស្របកូអរដោនេនៅលើផែនទីហ្វានលេខ១លើ៥០,០០០ ឬភ្ជាប់តាមផ្លូវជាតិ និងមានមុខកាត់ទទឹងធំជាងពី៣ទៅ៥ម៉ែត្រ ។ ក្នុងប្រឡាយមេដែលមានទំហំ១គុណ១គីឡូម៉ែត្រផ្ទៃក្រឡានីមួយៗ មានកូនប្រឡាយជាច្រើនដែលកូនប្រឡាយនីមួយៗមានប្រវែង


សកម្មភាពកសាងទំនប់ទឹកសម័យខ្មែរក្រហម

២០០ម៉ែត្របួនជ្រុង ។ រូបភាពដែលចាប់ដោយផ្កាយរណបនៅក្នុងខេត្តតាកែវ បានបង្ហាញពីប្រឡាយមេធំដែលមានទំហំ១០គុណ១០គីឡូម៉ែត្រផ្ទៃក្រឡា ។ ៣) ការកសាងអាងស្តុកទឹកដោយសាងសង់ទំនប់ទឹកវែងៗនៅតាមតំបន់ទំនាប ឬដោយលើកទំនប់ការពារតំបន់ទំនាបនិងច្រកទ្វារទឹកធម្មជាតិ ។ គេតែងតែលើកទំនប់នៅតាមបណ្តោយប្រឡាយមេក្នុងខ្សែស្រប១គុណ១គីឡូ-ម៉ែត្រផ្ទៃក្រឡា ។ ៤) ការសាងសងមាត់ច្រកទន្លេដើម្បីបង្វែរទឹកបញ្ចូលអាងស្តុកទឹក ឬប្រព័ន្ធប្រឡាយទឹក ។ ៥) ការសាងសងទំនប់ទឹកដោយមានការណែនាំរួមដ៏សមហេតុសមផល ។ និង ៦) ការសាងសង់ស្ថានីយ៍បូមទឹកផ្គត់ផ្គង់ទឹកបន្ថែមដល់ប្រព័ន្ធប្រឡាយទឹក ។

មធ្យោបាយនេះ តម្រូវឲ្យផែនការជាតិនេះរៀបចំជាសម្ព័ន្ធមានខ្នាតគំរូដ៏សមហេតុសមផលសម្រាប់ការសាងសង់មុខទ្វារប្រឡាយមេ កូនប្រឡាយ និងទំនប់ទឹក ផ្គត់ផ្គង់សម្ភារ និងរៀបចំកម្លាំងពលកម្ម ។ គណៈភូមិនីមួយៗ ត្រូវបំពេញភារកិច្ចទៅតាមកម្មវិធីច្បាស់លាស់នៃការងារក្នុងតំបន់របស់ខ្លួន ។ ភារកិច្ចជាអាទិភាពដំបូងសម្រាប់ថ្នាក់ភូមិ គឺការបន្តការដាំដុះដំណាំស្រូវ ។ ការកាប់គាស់ដីសម្រាប់ «សកម្មភាពរៀបចំដីឡើងវិញ» គឺជាការងារដ៏មានសារសំខាន់បំផុតមួយ ។ គ្រប់ការងារទាំងអស់ត្រូវធ្វើដោយដៃដោយមានឧបករណ៍ប្រើដោយដៃពីរឬបីប៉ុណ្ណោះ ។ ដោយសារតែសម្ភារផ្គត់ផ្គង់មិនគ្រប់គ្រាន់ ដុះត្រូវរុះរើដើម្បីយកឥដ្ឋនិងរបាដែក ។ ពុំមានការត្រួតពិនិត្យគុណភាព ឬបច្ចេកទេសការងារទាំងនេះឡើយ ។ ភារកិច្ចសំខាន់គឺ ការសម្រេចឲ្យបានតាមចំនួនផែនការដែលដាក់ជូនលើការងារកាប់គាស់ដីនិងចំនួនប្រវែងប្រឡាយដែលជីកបាន ។

មរតកនៃស្នាដៃក្នុងរបប ប៉ុល ពត នេះ គឺបរិមាណដ៏ច្រើននៃប្រឡាយទឹក ទំនប់ទឹក និងសំណង់ទាំងអស់ដែលត្រូវបានសាងសង់នៅលើប្រទេសកម្ពុជា លើកលែងតំបន់ភ្នំដែលមិនអាចសាងសង់ប្រឡាយបាន... ។

នៅក្នុងតំបន់ដែលមានប្រព័ន្ធស្រោចស្រពបែបបុរាណ ឬទំនប់ទឹកដែលត្រូវបានសាងសង់នៅក្នុងសម័យបារាំង ខ្មែរក្រហមបានពង្រីកទំនប់ទឹកធំឡើងរហូតការពង្រីកអាងស្តុកទឹក និងបានសាងសង់ទំនប់ទឹកថ្មីៗជាច្រើន ។ ការរៀបចំដីស្រែជាក្រឡាចត្រង្គឡើងវិញដែលបានរៀបខាងលើនេះប្រព្រឹត្តទៅនៅក្នុងតំបន់ថ្មី និងដីតំបន់ទំនាបនិងដីបង្កបង្កើនផល ។ ការលុបបំបាត់ដីស្រែបុរាណក៏បានជួយក្នុងការកាត់ផ្តាច់ប្រជាជនចេញពីដីដែលប្រជាជនធ្លាប់កាន់កាប់ពីមុនមកដែរ ដែលជាយុទ្ធសាស្ត្រមួយទៀតក្នុងការលើកកម្ពស់នូវការធ្វើសមូហភាវូបនីយកម្ម ។

វិសាលភាពនៃការបង្កើតស្នាដៃទាំងនេះ គឺមានលក្ខណៈចម្លែកខ្លាំងដែលធ្វើឲ្យលោក ដាបែល យូដេវេនលៀ ដែលជាអ្នកជំនាញដ៏ល្បីល្បាញម្នាក់ខាងកសិកម្មនិងប្រព័ន្ធស្រោចស្រពនៅកម្ពុជានៃលេខាធិការដ្ឋានទន្លេមេគង្គ បានសិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពដោយប្រើប្រាស់នូវរូបភាពដែលចាប់តាមផ្កាយរណប ។ ក្នុងបញ្ជីរាយឈ្មោះប្រព័ន្ធស្រោចស្រពនៅកម្ពុជារវាងឆ្នាំ១៩៩៣និងឆ្នាំ១៩៩៤ ៧៩ភាគរយនៃផែនការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពនេះ ត្រូវបានសម្រេចជោគជ័យក្នុងរយៈកាលដ៏ខ្លីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាក់ស្តែង ផែនការទាំងអស់ដែលមានមុនរបបកម្ពុជាប្រជាធិបតេយ្យត្រូវខ្មែរក្រហមធ្វើការផ្លាស់ប្តូរ ។

ទាក់ទិននឹងវិស័យកសិកម្ម មានការផ្លាស់ប្តូរស្ទើរតែគ្រប់ផ្នែកទាំងអស់ ។ ពូជស្រូវចាស់ៗ ត្រូវបានជំនួសដោយពូជស្រូវផ្សេងៗដែលផ្តល់ទិន្នផលខ្ពស់ជាង ហើយត្រូវបាននាំចូលពីប្រទេសចិននៅឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ ។ សូម្បីតែរបាយការណ៍លម្អិតមួយចំនួនតូច ដូចជាគម្លាតគ្នារវាងសំណាបដែលស្ទូងបាននិងចំនួនសំណាបក្នុងមួយកណ្តាប់ ក៏ត្រូវបានផ្លាស់ប្តូរជាគោលនយោបាយទូទាំងប្រទេសដែរ ។ ដោយខ្វះខាតវត្ថុធាតុដើមនាំចូលដូចជា ជីនិងថ្នាំសម្លាប់សត្វល្អិត ប្រជាកសិករត្រូវខិតខំប្រឹងប្រែងប្រើប្រាស់វត្ថុធាតុដើមដែលអាចប្រើការបានដូចជាជីអាចម៍គោ ជីធម្មជាតិ និងផលិតផលថ្នាំសម្លាប់សត្វល្អិត ធម្មជាតិអស់ពីលទ្ធ-ភាព ។ ដីលាមកមនុស្សត្រូវប្រើប្រាស់ឲ្យបានច្រើនបំផុត ទោះជាជីប្រភេទនេះ មានក្លិនស្អុយខ្លាំងប៉ុនណាក៏ដោយ ។ ថ្នាំសម្លាប់ល្អិតមួយចំនួនត្រូវបាននាំចូលពីប្រទេសចិនដោយដោះដូរនឹងអង្ករ ប៉ុន្តែ ចំនួនកំណត់នេះ ត្រូវបានប្រើប្រាស់តែទៅលើដីដែលមានសក្តានុពលផ្តល់ផលិតផលខ្ពស់តែប៉ុណ្ណោះ ។

## សមិទ្ធិនៃការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពថ្មី

### ក) ការងារស្រោចស្រព

ការត្រួតពិនិត្យលើការងារស្រោចស្រពក្រោយរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ប្រព័ន្ធស្រោចស្រពថ្មីនេះបានបង្កឲ្យមានបញ្ហាជាច្រើន ។ ការសិក្សាប្រព័ន្ធស្រោចស្រពទាំងមូលត្រូវបានបោះបង់ ។ ប្រឡាយមេដែលមានប្រវែងរាប់សិបគីឡូម៉ែត្រ ត្រូវបានជីកភ្ជាប់នឹងទីជម្រាលដែលនៅបៀតជិតគ្នាតែម្តង ។ ម្យ៉ាងទៀត កម្មាភិបាលមូលដ្ឋានជាអ្នកគ្រប់គ្រងការបញ្ចូលទឹកចូលស្រែពីប្រឡាយមេ និងពីទន្លេបឹងបួតាមតម្រូវការចាំបាច់របស់ខ្លួន ។ ដូចនេះ ពុំមានមធ្យោបាយណាមួយដែលអាចដឹងឬអាចសន្និដ្ឋានជាមុនអំពីអានុភាពនៃប្រឡាយឬបឹងបួដែលនៅជិតនឹងប្រព័ន្ធស្រោចស្រពថ្មីនេះទេ ឬទំនាក់ទំនងណាមួយរវាងផ្នែកផ្សេងៗនៃប្រព័ន្ធថ្មីនេះដែលកំពុងតែដំណើរការឡើយ ។ ប្រព័ន្ធបង្ហូរទឹកបែបធម្មជាតិត្រូវបានរាំងស្ទះ និងផ្លូវថ្នល់ដែលទើបតែកសាងថ្មីៗបានបង្កឲ្យមានទឹកជំនន់ជន់លិចមកលើប្រជាជនដែលប្រកបរបរចិញ្ចឹមជីវិតនៅក្នុងតំបន់នោះដោយមិនបានដឹងខ្លួនជាមុន ។

ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ត្រូវបានធ្វើឡើងនៅគ្រប់ទីកន្លែងដែលអាចធ្វើទៅបាន ដោយពុំបានគិតអំពីសេចក្តីត្រូវការទឹកជាចាំបាច់ឬកម្លាំងចរន្តទឹកឡើយ ។ ដូចនេះ មានហេដ្ឋារចនា-សម្ព័ន្ធច្រើនប្រសើរជាងការប្រើប្រាស់នូវទឹកទន្លេឬបឹងបួ និងប្រសើរជាងគ្មានការគ្រប់គ្រងឬគ្មានការចែករំលែកដ៏សមហេតុសមផលនូវធនធានទៅដល់តំបន់ដែលអាចផ្តល់ទិន្នផលខ្ពស់ឬស្មើគ្នា ។ ដោយហេតុនេះ ប្រឡាយមេជាច្រើនដែលស្ថិតនៅលើតំបន់ទឹកជំនន់ បានទប់ទឹកភ្លៀង និងថែមទាំងប្រឡាយមេទាំងនេះមានប្រព័ន្ធបង្ហូរទឹកកាត់ខ្វែងគ្នាតិចតួចបំផុត ដែលជាហេតុបង្កមានទឹកជំនន់ នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំងម្តងៗ ។

ទំនប់ទឹក ដែលត្រូវបានសាងសង់ឡើងនៅលើដីរាបស្មើតែងតែជន់លិចដូចដែលទំនប់ទាំងនេះ ត្រូវបានបញ្ចូលទឹកដែរ ។ កម្លាំងពលកម្មមនុស្សដែលត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់ទំនប់ទឹក បានធ្វើឲ្យដីមានសភាពពុំសូវហាប់ល្អ ដែលធ្វើឲ្យទំនប់ងាយនឹងធ្លាយនិងហូរទឹកចេញទៅតាមកន្លែងធ្លាយ ។ បញ្ហានេះ មានសភាពធ្ងន់ធ្ងរដោយសារតែការប្រើប្រាស់ដីក្នុងតំបន់នោះដើម្បីសាងសង់ទំនប់ទឹក ដោយមិនបានគិតអំពីប្រសិទ្ធភាពដីនិងកម្ពស់ដីដែលកម្មករម្នាក់ៗជីកឡើយ ។

កង្វះអ្នកជំនាញបច្ចេកទេសលើគម្រោងប្លង់ និងសម្ភារមានន័យថាទំនប់បង្ហូរទឹកមានមុខហូរចេញតូចពេក និងមានកម្ពស់ខ្ពស់ជ្រុលដែលធ្វើឲ្យទឹកច្រាលហៀរឡើងមកលើមាត់ទំនប់ ឬធ្វើឲ្យមាត់ទំនប់មិនអាចទប់កម្លាំងទឹកបានដែលបង្កឲ្យមានប្រហោងយ៉ាងធំនៅក្នុងទំនប់ ។ ទំនប់ដែលធ្លាយនេះ បាននាំទឹកដែលហូរចេញយ៉ាងលឿនកាត់តាមព្រែកធម្មជាតិនិងកូនប្រឡាយខ្វាត់ខ្វែងគ្នាធ្លាយចូលទៅក្នុងប្រព័ន្ធទន្លេមេគង្គ ។ ស្នាដៃនេះ គឺផ្ទុយពីស្នាដៃនៃទំនប់ទឹកតូចៗដែលកសិករខ្មែរបានសាងសង់ពីបរមបុរាណ ដែលហូរនាំទឹកចេញពីទីជម្រាលទំនប់ទៅជាយទំនប់ចាក់ចូលក្នុងស្រែឬអាងស្តុកទឹកតូចៗ ។ ដោយហេតុថា ខ្មែរក្រហមបានប្រើប្រាស់ទំនប់បង្វៀរទឹកនេះសម្រាប់ការស្រោចស្រពដីស្រែ ក៏ដូចជាសម្រាប់ការបង្ហូរទឹកបញ្ចូលស្រែនោះ ប្រឡាយមេមានមុខងារជាប្រឡាយសំខាន់ដំបូងបង្អស់ នៅពេលដែលទំនប់បង្វៀរទឹកពុំត្រូវបានប្រើប្រាស់តាមតម្រូវការចាំបាច់នោះ ។ ដូចនេះ ដោយសារតែប្រឡាយនេះធំនិងមានជម្រៅជ្រៅពេក ធ្វើឲ្យប្រឡាយមិនអាចបញ្ជូនទឹកបញ្ចូលស្រែបានច្រើនឡើយ និងថែមទាំងរេចរឹលដោយចៀសពុំរួចដោយសារទឹកភ្លៀងដែលហូរច្រោះជារៀងរាល់ឆ្នាំ ។

ដោយសារតែកម្មាភិបាលមូលដ្ឋានពុំមានជំនាញ ឬអ្នកបច្ចេកទេសខាងគ្រោងប្លង់និងសំណង់ប្រឡាយត្រឹមត្រូវនោះ អាងស្តុកទឹកទាំងអស់មាន«កូនទំនប់តូចៗ» នៅពីក្រោមទំនប់មេដែលប្រើប្រាស់សម្រាប់បង្ហូរទឹកចេញពីទំនប់មេចូលទៅក្នុងប្រឡាយ ។ ប្រការនេះ បានធ្វើឲ្យបរិមាណទឹកដែលជ្រាបនិងហួតមានការកើនឡើង ព្រមទាំងបានធ្វើឲ្យតំបន់ដែលត្រូវបានបញ្ចូលទឹកនេះមិនអាចផ្តល់ផលិតផលគ្រប់គ្រាន់ថែមទៀត ។ នៅពេលដែលទឹកហៀរជន់លិច អាងស្តុកទាំងនោះបានហូរកាត់តាមកូនទំនប់តូចៗ ដែលបានបំផ្លិចបំផ្លាញទាំងអាងស្តុកទឹកនិងកូនទំនប់ព្រមទាំងប៉ះពាល់ទៅដល់ការថែទាំទៀតផង ។

ការរៀបចំបញ្ចូលដីស្រែតូចជាដីស្រែមួយហិកតា បានបំផ្លិចបំផ្លាញទៅដល់ប្រព័ន្ធភ្លឺស្រែដ៏សាំញាំដែលត្រូវបានកសាងឡើងយ៉ាងចិត្តទុកដាក់អស់ពេលជាច្រើនសតវត្សរ៍ដើម្បីស្តុកនិង

ចែកចាយទឹកភ្លៀងនិងដើម្បីអនុគ្រោះទៅដល់លក្ខខណ្ឌដាក់លាក់មួយចំនួននៃដីស្រែនិងប្រភេទពូជស្រូវបុរាណផ្សេងៗ ។

ប្រឡាយទឹកតូចធំដែលហ៊ុមព័ទ្ធជុំវិញស្រែ ដែលមានសណ្ឋានដូចនឹងព្រែករាបស្មើ ធំ និងរាក់ដែលមានភ្លឺស្រែទាបៗនោះមិនស័ក្តិសមប្រើប្រាស់ជាប្រព័ន្ធស្រោចស្រពនិងប្រព័ន្ធបង្ហូរទឹកឡើយ ។ កង្វះការស្ទាបស្ទង់តាមឋានលេខ និងបទដ្ឋានសាងសង់ប្រឡាយមិនត្រឹមត្រូវល្អ មានន័យថា ប្រព័ន្ធប្រឡាយទឹកជាច្រើនខ្សែហូរនាំទឹកពីដីស្រែខ្ពស់ដែលធ្វើដីស្រែទាំងនោះស្ងួតបែកក្រហែង ។ រីឯនៅក្នុងតំបន់ទាបឯណោះវិញ ទឹកដែលហូរចេញ


សកម្មភាពកសាងទំនប់ទឹកសម័យខ្មែរក្រហម

នេះ ត្រូវបានទំនប់ទឹកនិងប្រឡាយមេធំជាច្រើនទប់ ដែលជាហេតុបង្កឲ្យមានទឹកជំនន់កើតឡើង ។ ប្រឡាយទឹកជាធម្មតា ត្រូវបានប្រើប្រាស់ដើម្បីបញ្ជូនទឹកឡើងទៅតំបន់ភ្នំ ឬត្រូវបានជីកទៅក្នុងដីក្បែរដីស្រែដែលជាហេតុធ្វើឲ្យប្រឡាយទឹកទាំងនោះមិនអាចនាំទឹកចូលទៅស្រែដទៃទៀតបាន ។ ប្រព័ន្ធប្រឡាយទឹកក្រឡាចត្រង្គដែលត្រូវបានកសាងនៅលើដីស្រែបង្កបង្កើនផលទាំងនេះ មានមុខទ្វារទឹកជាច្រើនកន្លែង ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានសម្ភារ ឬអ្នកជំនាញសាងសង់ប្រព័ន្ធប្រឡាយទឹកអចិន្ត្រៃយ៍ក្នុងការចែកចាយនិងទប់ទឹកនោះឡើយ ។ ដោយហេតុនេះហើយ លទ្ធភាពក្នុងការចែកចាយនិងគ្រប់គ្រងការហូរទឹកចេញនៅក្នុងប្រព័ន្ធប្រឡាយជួបការលំបាកយ៉ាងខ្លាំង ហើយប្រព័ន្ធប្រឡាយទឹកទាំងនេះតម្រូវឲ្យមានការប្រុងប្រយ័ត្នជាប់ក្នុងការប្រើប្រាស់និងការថែទាំ ។

## ១) របៀបរបបសង្គមនិងកសិកម្ម

កម្ពុជា ជាប្រទេសដែលពឹងផ្អែកទៅលើវិស័យកសិកម្មជាច្រើនសតវត្សរ៍មកហើយ ។ កម្ពុជាបានផលិតនូវពូជស្រូវក្នុងស្រុកជាច្រើនប្រភេទដែលពូជស្រូវនីមួយៗត្រូវបានដាំទៅតាមប្រភេទដី ទឹក និងលក្ខខណ្ឌផ្សេងៗជាច្រើនទៀត ។ ប្រភេទពូជស្រូវមួយចំនួនមិនងាយស្រួលក្នុងការដាំដុះទេ ដូចជាប្រភេទស្រូវលិចទឹក ឬ “ស្រូវប្រដេញទឹក” ដែលខ្មែរក្រហមចាត់ទុកជាពូជស្រូវពុំផ្តល់ផលកម្រៃ ។ ដោយសារតែស្រូវប្រដេញទឹកជាប្រភេទស្រូវតែមួយគត់ដែលអាចដាំបានតែនៅក្នុងតំបន់មានទឹកជ្រៅ ហេតុដូច្នេះ បានជាដីដែលមានសារប្រយោជន៍នេះ ត្រូវបានទុកទំនេរចោល ។ លក្ខខណ្ឌដែលល្អប្រសើរសម្រាប់ប្រភេទស្រូវ

ដែលផ្តល់ទិន្នផលខ្ពស់ដែលខ្មែរក្រហមពេញចិត្តដាំនោះ ឃើញមានដាំនៅក្នុងតំបន់តែមួយចំនួនប៉ុណ្ណោះ ពោលគឺពុំសូវមានដាំនៅក្នុងតំបន់ជាច្រើនឡើយ ។ ដូចនេះ ផលកម្រៃដ៏មានសក្តានុពលដែលបានពីការជំនួសប្រភេទស្រូវថ្មីៗ ត្រូវបានខាតបង់ដោយសារតែការអនុវត្តលឿនជ្រុលក្នុងទម្រង់តែមួយ ។

ការរៀបចំបញ្ចូលដីស្រែមួយហិកតា ថ្វីដ្បិតតែបានធ្វើឲ្យការងារធ្វើស្រែទទួលបាននូវទិន្នផលច្រើនក៏ពិតមែន ក៏ប៉ុន្តែ ស្រែទាំងនេះ មិនអាចផ្តល់នូវទិន្នផលស្មើដូចគ្នាបានទេ ។ ដោយហេតុនេះ ទើបផ្នែកខ្លះនៃដីស្រែនេះ ទទួលរងនូវសម្ពាធទឹកខ្លាំងនិងជាជម្រកសត្វចង្រៃ ហើយផ្នែកខ្លះទៀតលិចកប់ទៅក្នុងទឹកជ្រៅ ។ ប្រសិនបើស្រូវប្រភេទតែមួយដែលត្រូវបានដាំនៅក្នុងស្រែ មានភាពខុសប្លែកគ្នានោះលក្ខខណ្ឌទាំងឡាយក្នុងដីស្រែដដែលនេះក៏ផ្លាស់ប្តូរទៅតាមនោះដែរ ដែលធ្វើឲ្យទិន្នផលមានការធ្លាក់ចុះ ។

ការអនុវត្តដែលមានលក្ខណៈខ្វះខាតតាមរយៈការប្រើប្រាស់នូវសម្ភារក្នុងស្រុកនេះ បានធ្វើឲ្យខាតបង់យ៉ាងច្រើនដល់ការខិតខំប្រឹងប្រែងក្នុងការផលិតស្រូវខ្ពស់បំផុត ដូចដែលលោកម៉ាធីន បានបកស្រាយដូចខាងក្រោមថា ÷

មេដឹកនាំរបបថ្មីនេះមានទស្សនៈផ្សេងពីមេដឹកនាំដទៃៗទៀត គឺត្រូវផលិតឲ្យបានច្រើន និងប្រើប្រាស់យុទ្ធវិធីតែមួយនៅគ្រប់ទីកន្លែងទាំងអស់ ។ អ្នកក្សេត្រសាស្ត្រដែលបានសិក្សាស្រាវជ្រាវអំពីការដាំដំណាំស្រូវបាននិយាយថា ដីលាមកមនុស្សនៅក្នុងកន្លែងមួយចំនួនមិនត្រូវបានប្រើប្រាស់ឲ្យត្រឹមត្រូវនោះទេ ពីព្រោះដីទាំងនេះ ត្រូវបានបាចបញ្ចូលស្រែ មុនពេលភ្ជួរនៅក្នុងរដូវប្រាំងដែលងាយនឹងធ្វើឲ្យដីហួតទៅតាមខ្យល់និងដោយកាំរស្មីព្រះអាទិត្យ ហើយទឹកភ្លៀងបានហូរច្រោះនាំដីទាំងនេះទៅតាមទឹកចេញពីស្រែ ជាពិសេសសារធាតុអាហ្សូត ។ ដូចគ្នានេះដែរ ជីធម្មជាតិត្រូវស្ងួតរឹង ដោយសារតែកម្តៅព្រះអាទិត្យមុនពេលយកទៅបាចបញ្ចូលស្រែ ។ [សម្រាប់ផែនការស្ទូងស្រូវថ្មីនេះ] ខ្មែរក្រហម បានជ្រើសយកយុទ្ធវិធីមួយដែលមានមុនឆ្នាំ១៩៧០ ក្នុងលក្ខណៈដ៏ចម្លែកមួយដែលកសិករនិងអ្នកក្សេត្រសាស្ត្រមិនស្គាល់ពិតប្រាកដ ។ កសិករ អ្នកឯកទេស វិស្វករ និងអ្នកក្សេត្រសាស្ត្រ ដែលបានចូលរួមនៅក្នុងការងារស្ទូងស្រូវបានសង្កត់ធ្ងន់ទៅលើផលប៉ះពាល់នៃការផ្លាស់ប្តូរផែនការថ្មីនេះថា គុម្ពស្រូវពុំសូវបែកគុម្ពដោយសារតែដើមស្រូវពុំសូវលូតលាស់ល្អ ផ្លែស្រូវឡើងកណ្តាប់ ផ្លែស្រូវពុំសូវទុំ និងក្នុងករណីខ្លះស្រូវស្អក ។ ប្រហែលជាមកពីកត្តារួមផ្សំទាំងនេះ ទើបធ្វើឲ្យទិន្នផលស្រូវមធ្យមចុះខ្សោយចាប់តាំងពីការចាប់ផ្តើមដំបូងនោះ ។

ផែនការផ្សេងៗទៀតដែលមាននៅក្នុងឯកសារបក្សកុម្មុយនីស្តកម្ពុជា បង្ហាញឲ្យឃើញអំពីកង្វះការស្វែងយល់ក្នុងការដឹកនាំអភិវឌ្ឍន៍វិស័យកសិកម្មឬឧស្សាហកម្ម ។ ផែនការនេះ មានភាពមិនស្របគ្នានិងមានតារាងបរិមាណផលិតផលដែលច្រើនជ្រុល ។ សកម្មភាពមួយចំនួនបង្ហាញអំពីថាតើមេដឹកនាំខ្មែរក្រហមមានភាពស្មោះត្រង់ប៉ុនណា និងថាតើផែនការរបស់ពួកគេបរាជ័យដោយរបៀបណា ។

[ដើម្បីកែលម្អស្ថានភាពផ្សេងៗនៃដំណាំស្រូវ] យើងត្រូវបង្កើតស្ថានីយ៍ខគុនិយមមួយ ។ [លើផ្នែករ៉ែផូស្វាត] យើងចាប់គិតពិចារណាអំពីរ៉ែផូស្វាតផ្ទាល់របស់យើងចាប់ពីពេលនេះតទៅ ប្រសិនបើមាន យើងស្វែងរករ៉ែផូស្វាតនេះ ។ យើងត្រូវបង្កើតរោងចក្រចម្រាញ់ផូស្វាត ។ [ចំពោះបញ្ហាជីវិញ] ប្រសិទ្ធភាពនៃប្រើប្រាស់ទឹកមូត្រមនុស្សវិញ នៅមិនទាន់ប្រើប្រាស់អស់លទ្ធភាពនៅឡើយដែរ ពីព្រោះទឹកមូត្រទាំងនេះ ពុំទាន់ត្រូវបានប្រមូលអស់នៅឡើយ ។ យើងទើបតែប្រមូលបានតែ៣០ភាគរយប៉ុណ្ណោះ នៅសេសសល់៧០ភាគរយទៀត ។ ម្យ៉ាងទៀត យើងត្រូវប្រមូលទឹកនោមគោនិងក្របីផងដែរ ។ យើងត្រូវប្រមែប្រមូលគោក្របីទាំងនោះដាក់មួយកន្លែង ហើយនៅពេលយប់ គោក្របីទាំងនោះនឹងនោមដាក់ស្នូកបាយជ្រូក ហើយបន្ទាប់មកទើបយើងប្រមែប្រមូលទឹកនោមសត្វទាំងនោះមកទុក ។ ក្នុងមធ្យោបាយបែបនេះទើបយើងអាចសម្រេចតាមផែនការឆ្នាំ១៩៧៧ ។

ផែនការទាំងនេះ គូសបញ្ជាក់អំពីទិដ្ឋភាពការងារទាំងមូល ដោយរាប់បញ្ចូលទាំងបញ្ជីរាយឈ្មោះមុខទំនិញទាំងអស់ដែលជាផលិតផលសម្រាប់ប្រជាជនប្រើប្រាស់ប្រចាំថ្ងៃ និងបរិមាណទំនិញរាប់គោនដែលត្រូវផលិតសម្រាប់ឆ្នាំនីមួយៗ ។ ជាងនេះទៀត ទិដ្ឋភាពនេះ ក៏បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីជីវិតប្រចាំថ្ងៃរបស់ប្រជាជនម្នាក់ៗ រួមមានប្រភេទ បរិមាណ និង

របបអាហារបរិភោគប្រចាំសប្តាហ៍ ។

ដោយសារតែមានការផ្លាស់ប្តូរឆាប់រហ័ស ហើយនិងចំនួនប្រជាជនដែលខ្មែរក្រហមអាចជឿទុកចិត្តមានកំណត់ វាចាំបាច់ណាស់ថា ត្រូវតែមានការអនុវត្តនូវគោលនយោបាយវិមជ្ឈការក្នុងកម្រិតមួយខ្ពស់នៅក្នុងមូលដ្ឋាន ។ វាសបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ណាស់ថា ខ្មែរក្រហមមានបំណងគ្រប់គ្រងគ្រប់ទិដ្ឋភាពកសិកម្មនិងប្រព័ន្ធស្រោចស្រពទាំងអស់ពីលើទៅតែម្តង ។ ដូចដែលលោក ធ្វីនីង បានកត់សម្គាល់ដោយផ្អែកទៅលើបទសម្ភាសន៍របស់លោកជាមួយនឹងជនរងគ្រោះនៃរបបកម្ពុជាប្រជាធិប-តេយ្យថា ÷ ជាតួយ៉ាង ដោយយោងតាមជនរងគ្រោះមួយចំនួនប្រជាជនត្រូវតែដាំស្រូវនៅលើដី មិនថាដីនោះមានដីជាតិល្អ ឬគ្មានដីជាតិទេ ហើយគ្រប់អង្គភាពគ្រប់គ្រងនីមួយៗត្រូវសម្រេចការងារស្រោចស្រពតាមផែនការកំណត់ជាដាច់ខាត មិនថាសេចក្តីត្រូវការអ្វីនោះទេ ។ ពេលវេលាដាំ ពេលវេលាជម្រះស្មៅ និងពេលវេលាប្រមូលផល ផ្ទាក់លើជាអ្នកចេញបញ្ជា ។ តំបន់ទាំងមូលត្រូវចាប់ផ្តើមដាំពេញមួយថ្ងៃដូចៗគ្នា ទោះជាស្ថានភាពទឹកគ្របដណ្តប់លើផ្ទៃដីដ៏ធំធេងបែបនេះមិនដូចគ្នាយ៉ាងណាក៏ដោយ ។

ផលលំបាកនៃការបែងចែកប្រជាជនជាប្រជាជនថ្មី និងប្រជាជនចាស់ និងការប្រកាន់ខ្ជាប់ជានិច្ចនូវ«ការស្អប់ខ្ពើមវណ្ណៈ» គឺនៅក្នុងតំបន់ជាច្រើនប្រជាជនដែលមានចំណេះដឹងផ្នែកបច្ចេកទេស ដោយរាប់បញ្ចូលទាំងវិស្វករ និងអ្នកកសិកម្ម ព្រមទាំងកសិករដែលមានគំនិតច្នៃប្រឌិតជាច្រើននាក់ ត្រូវខ្មែរក្រហមលុបបំបាត់ ឬត្រូវបានធ្វើបាបយ៉ាងធ្ងន់ធ្ងរខុសពីប្រជាជនដែលក្រីក្រជាអ្នកមើលខុសត្រូវនិងដឹកនាំអ្នកទាំងនោះទៅវិញ ។ ប្រជាជនក្រីក្រទាំងនោះ ពុំមានជំនាញក្នុងការគ្រប់គ្រងការងារកសិកម្មនិងការងារស្រោចស្រព ហើយកង្វះសមត្ថភាពរបស់ពួកគេបានធ្វើឲ្យការងារជាច្រើនបរាជ័យ ។

ផែនការចុងក្រោយ ទិសដៅដ៏មហិច្ឆតាសម្រាប់ផលិតផលស្រូវបានញុំាងឲ្យកម្មាភិបាលនៅមូលដ្ឋានប្រមែប្រមូលស្រូវដែលផលិតបាននិងដឹកជញ្ជូនស្រូវទាំងនោះទៅកាន់មន្ទីរមជ្ឈិមដោយពុំបានបន្សល់ទុកស្រូវគ្រប់គ្រាន់សម្រាប់ប្រជាជនក្នុងសហករណ៍របស់ខ្លួនបរិភោគឡើយ ។ កង្វះអាហារ លក្ខខណ្ឌការងារដ៏យង់ឃ្នង់បន្ទុកការងារដ៏ធ្ងន់ កង្វះឱសថព្យាបាល និងកម្មាភិបាលគ្មានសមានចិត្ត បានបណ្តាលឲ្យប្រជាជនជាច្រើននាក់ស្លាប់ដោយការធ្វើការងារហួសកម្លាំង ជំងឺ ការអត់អាហារ និងការសម្លាប់ ។ កម្លាំងការងារធ្លាក់ចុះជាលំដាប់ ក្នុងខណៈពេលដែលបន្ទុកការងារកើនឡើង ។ ការធ្វើវិសុទ្ធកម្មផ្ទៃក្នុងលើការដឹកនាំក្នុងតំបន់និងមូលដ្ឋាន បានជំរុញឲ្យមានការផ្លាស់ប្តូរមេដឹកនាំនិងការចល័តប្រជាជនដែលធ្វើឲ្យផលិតផលកសិកម្មធ្លាក់ចុះ ។

## ប្រភពនៃបញ្ហាដែលជាឫសគល់

ខ្មែរក្រហមមានលក្ខណៈម្ចាស់ការជ្រុល និងប្តេជ្ញាបង្ហាញថាបដិវត្តន៍របស់ខ្លួនត្រូវសម្រេចឲ្យបានជោគជ័យដោយប្រើប្រាស់ចំណេះដឹងនិងជំនួយបច្ចេកទេសក្នុងកម្រិតមួយទាបបំផុត ។ បើទោះបីជាកន្លែងមួយចំនួនមានប្រើប្រាស់អ្នកដែលត្រូវបានបណ្តុះបណ្តាលផ្នែកបច្ចេកទេស ដូចជាអ្នកបច្ចេកទេសជនជាតិចិន និងកូរ៉េខាងជើងដែលបានមកជួយក្នុងការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពនិងដំណាំឧស្សាហកម្មយ៉ាងណាក៏ដោយ វាច្បាស់ណាស់ថាជំនួយបច្ចេកទេសគឺផ្ទុយនឹងការដឹកនាំរបស់ខ្មែរក្រហមរួចទៅហើយ ។ ការងារស្រោចស្រពភាគច្រើន ត្រូវបានធ្វើឡើងរបៀបពិសោធន៍ជាច្រើនលើក ដូចដែលលោក វីកឺរី បង្ហាញខាងក្រោមនេះថា ÷ ពិតប្រាកដណាស់ ខ្មែរក្រហមឈ្លក់វង្វេងនឹងភាពម្ចាស់ការ និងការកសាងសង្គមវណ្ណៈអធនដោយមិនប្រើប្រាស់ជំនាញបច្ចេកទេសពីសង្គមក្នុងសម័យលន់នល់ ជាងការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។ នៅដើមឆ្នាំ១៩៧៧ ខៀវ សំផន បាននិយាយថា «មិនមែនបញ្ហានោះទេដែលទំនប់ទឹកនិងប្រឡាយទឹកដែលយើងកសាងអាចប្រើប្រាស់បានរយៈពេល៥ឬ១០ឆ្នាំនោះ» ពីព្រោះប្រជាជននឹងស្វែងយល់អំពីការងារដោយធ្វើការងារផ្ទាល់ (ដោយពុំមានជំនួយពីវិស្វករខាងប្រព័ន្ធស្រោចស្រព ដូចជាលោក ពិន យ៉ាថៃ ជាដើម) ។

ក៏ប៉ុន្តែ កង្វះជំនាញបច្ចេកទេសវិស្វកម្ម បានធ្វើឲ្យការងារស្រោចស្រពមិនអាចផ្តល់ផលប្រយោជន៍ ឬមិនអាចសម្រេចបាននូវទិន្នផលច្រើនឡើយ ពីព្រោះការសាងសង់ប្រព័ន្ធស្រោចស្រព និងការជួសជុលប្រព័ន្ធស្រោចស្រពឡើងវិញដដែលនេះបានធ្វើឲ្យខាតបង់កម្លាំងអស់ជាច្រើន និងបានសម្លាប់មនុស្ស

ថែមទៀត ។ ការប្រើប្រាស់កម្លាំងពលកម្មច្រើនមិនអាចសម្រេច បាននូវសមិទ្ធផលបានទេ ដោយសារតែកង្វះការពង្រីកនិងការស្រាវជ្រាវលើវិស័យកសិកម្ម ។ ទោះបីជាយ៉ាងណាក៏ដោយ ខ្មែរក្រហមមិនបានអើពើបញ្ហានេះឡើយ ពីព្រោះបច្ចេកវិជ្ជាជាធាតុគំរាមកំហែងបដិវត្តន៍ ។ អ្នកដែលចេះបច្ចេកវិជ្ជា មានអំណាចដែលមិនមែនកើតចេញពីសតិអារម្មណ៍បដិវត្តន៍ ហើយអ្នកដែលចេះបច្ចេកវិជ្ជានេះបានទទួលចំណេះដឹងពីសង្គមពុករលួយដែលខ្មែរក្រហមត្រូវលុបបំបាត់ចោល ។

បើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតទាក់ទិននឹងវិស័យឧស្សាហកម្ម យើងនៅទន់ខ្សោយខ្លាំងនៅឡើយ ។ ម្យ៉ាងទៀត យើងមិនបានប្រើប្រាស់នូវកម្មករចាស់ ពីព្រោះប្រសិនបើយើងប្រើប្រាស់កម្មករចាស់ដោយគ្មានការជ្រើសរើសនិងដោយគ្មានការធ្វើវិសុទ្ធកម្មអ្នកទាំងនេះពីដំបូងទេ នឹងបង្កឲ្យមានភាពស្មុគស្មាញជាច្រើនខាងនយោបាយដែលនឹងធ្វើឲ្យយើងជួបការលំបាកច្រើន ។

ដូចនេះ នៅពេលដែលបដិវត្តន៍ចាប់ផ្តើម និស្សិតខ្មែរដែលសិក្សានៅក្រៅប្រទេស ត្រូវខ្មែរក្រហមកោះហៅឲ្យវិលត្រឡប់មកមាតុភូមិរបស់ពួកគេវិញដើម្បីកសាងប្រទេសជាតិឡើងវិញ ។ ក៏ប៉ុន្តែ នៅពេលដែលនិស្សិតទាំងនោះវិលត្រឡប់មកកាន់ប្រទេសកម្ពុជា និស្សិតទាំងនោះត្រូវខ្មែរក្រហមសម្លាប់ឬចាប់ដាក់គុកដោយចោទថាជាសំណល់ពីរបបមុនៗ ។ សូម្បីតែអ្នកផ្តាច់ខ្លួនចុះចូលនឹងខ្មែរក្រហមដំបូងដែលធ្វើការនៅលេខាធិការដ្ឋានទន្លេមេគង្គលើគម្រោងឈានមុខក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មក៏មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នូវចំណេះដឹងរបស់ខ្លួនដែរ ផ្ទុយទៅវិញ ត្រូវខ្មែរក្រហមចាប់ឃុំខ្លួននៅក្នុងជំរំបឹងត្របែកដើម្បីលាងខួរក្បាល ។

ការអនុវត្តឆាប់រហ័សនិងទំហំនៃការងារស្រោចស្រព ព្រមទាំងការផ្លាស់ប្តូរក្នុងវិស័យកសិកម្មមានលក្ខណៈធំជ្រុល ហើយថែមទាំងមិនបានពឹងផ្អែកទៅលើការស្វែងយល់អំពីបញ្ហាទាំងនេះដោយពេញលេញ ឬប្រកបដោយសមត្ថភាព ។ ខ្មែរក្រហមពុំមានផែនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន និងពុំមានការសាកល្បងអភិវឌ្ឍន៍ទិសដៅប្រកបដោយជោគជ័យ ឬការផ្លាស់ប្តូរក្នុងតំបន់ឡើយ ។ ដោយហេតុដូចនេះ ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពច្រើនហួសរបស់ខ្មែរក្រហមបានទទួលបរាជ័យទាំងស្រុង ដោយបានបន្សល់ទុកនូវកម្ទេចកម្ទីពាសពេញប្រទេស ។ បញ្ហាហេដ្ឋារចនាសម្ព័ន្ធដែលបរាជ័យនិងកង្វះធនធានមនុស្សនេះ នៅតែជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏លំបាកបំផុតជាច្រើនដែលប្រទេសកម្ពុជាត្រូវប្រឈមមុខដោះស្រាយសព្វថ្ងៃ ។

## ការដោះស្រាយបញ្ហាដែលជាឫសគល់

មជ្ឈិមបក្ស ដែលជាក្រុមស្នូលតូចមួយនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាដែលដឹកនាំបដិវត្តន៍នោះ ជាអ្នកទទួលបន្ទុកដោះស្រាយគ្រោះមហន្តរាយរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្រុមនេះទទួលខុសត្រូវការអភិវឌ្ឍន៍ “មាគ៌ានយោបាយដ៏ត្រឹមត្រូវ”របស់បក្ស ។ ពាក្យសម្តីរបស់ក្រុមនេះនៅក្នុងសុន្ទរកថានិងឯកសារទាំងឡាយដែលនៅសេសសល់បង្ហាញពីមោទកភាពដ៏ចម្លែកថាគោលនយោបាយរបស់ខ្លួនមិនអាចភ័ន្តច្រឡំបានឡើយ និងបង្ហាញនូវទស្សនៈក្នុងលក្ខណៈនយោបាយជាសំខាន់ ។

យើងមិនត្រូវបន្ទោសលក្ខខណ្ឌទិសដៅដែលដាក់ជូននោះទេ

ជាការពិតណាស់ ការសម្រេចបដិវត្តន៍ឲ្យបានជោគជ័យកើតចេញពីការរក្សាឲ្យបាននូវសតិអារម្មណ៍វណ្ណៈដ៏សមស្របនិងអនុវត្តតាមមាគ៌ានយោបាយដ៏ត្រឹមត្រូវមិនមែនដោយសារតែភ្លៀងធ្លាក់ទៀងទាត់ ឬ “លក្ខខណ្ឌទិសដៅដែលដាក់ជូន” ផ្សេងៗទៀតនោះទេ ។ ហេតុដូច្នេះ អ្នកដែលមិនសម្រេចតាមទិសដៅដែលថ្នាក់លើដាក់ជូននោះ ជាមនុស្សដែលពុំមានភាពស្អាតស្អំនៅមានធាតុពិតជាមូលដ្ឋានក្នុងសង្គមអយុត្តិធម៌នៅឡើយ ។ ប្រការនេះ បានបង្ហាញឲ្យឃើញពីមូលហេតុដែលវណ្ណៈអធនត្រូវខ្មែរក្រហមជឿទុកចិត្ត ខុសពីប្រជាជនថ្មីដែលខ្មែរក្រហមមិនមានការជឿទុកចិត្ត ។ លក្ខខណ្ឌសម្ភាររបស់បុគ្គលម្នាក់ បង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីសតិអារម្មណ៍វណ្ណៈរបស់បុគ្គលនោះ ។

ការមិនធ្វើឲ្យផែនការផលិតកម្មសម្រេចបានជោគជ័យ គឺជាការគំរាមកំហែងដល់មូលដ្ឋានគ្រឹះរបស់បដិវត្តន៍ ពីព្រោះទិន្នផលស្រូវដែលផលិតបានមិនគ្រប់គ្រាន់ក្នុងការជំរុញវិស័យឧស្សាហូបនីយកម្មបានឆាប់រហ័សក្នុងការផលិតអាវុធសម្រាប់បំពាក់ដល់កងទ័ពក្នុងការធ្វើសង្គ្រាមជាមួយនឹង“សត្រូវសួពូជ”គឺវៀតណាម ។ ដូចនេះ ការមិនសម្រេចតាមទិសដៅផលិតកម្មជាភ័ស្តុតាងយ៉ាងប្រត្យក្សថាមានពួកក្បត់ក្នុងជួរបក្សកុម្មុយនីស្ត

កម្ពុជានៅក្នុងតំបន់ដែលកំពុងធ្វើវិច្ឆេទកម្មបដិវត្តន៍ ។ មជ្ឈិមបក្សនឹងធ្វើវិសុទ្ធកម្មស្វែងរកអ្នកដែលធ្វើវិច្ឆេទកម្មបដិវត្តន៍ ។ កម្មាភិបាលដែលត្រូវខ្មែរក្រហមស្រាវជ្រាវរកឃើញថា បានធ្វើវិច្ឆេទកម្មត្រូវបញ្ជូនទៅកាន់គុកទួលស្លែង ហើយត្រូវបានធ្វើទារុណកម្មយ៉ាងឃោរឃៅរហូតដល់អ្នកទោសទាំងនោះឆ្លើយសារភាពថា ខ្លួនបានប្រឆាំងនឹងបដិវត្តន៍មែន ។ ការធ្វើបែបនេះជាភស្តុតាងដែលជួយដល់ការចោទប្រកាន់លើកដំបូងរបស់ខ្មែរក្រហម ពីព្រោះជនរងគ្រោះនឹងឆ្លើយប្រាប់ឈ្មោះមិត្តភក្តិនិងអ្នកដែលជិតនិតរបស់ពួកគេជាពុំខាន ដែលអ្នកទាំងនោះនឹងត្រូវនាំយកមកធ្វើទារុណកម្មរហូតដល់បែកឈាមស្លាប់យ៉ាងវេទនា ។

ទាក់ទងនឹងស្នាដៃបដិវត្តន៍កសិកម្ម លោក ម៉ាទីន បានសង្ខេបយ៉ាងក្បោះក្បាយថា ÷ បុគ្គលម្នាក់តែងតែសួរខ្លួនឯងថាតើវាចាំបាច់ណាស់ឬដែលត្រូវបោះបង់ចោលនូវគោលនយោបាយរបស់ប្រទេសខ្លួនលុបបំបាត់ចោលនូវរចនាសម្ព័ន្ធគ្រួសារ លុបបំបាត់វប្បធម៌និងអរិយធម៌ដែលមានជាច្រើនសតវត្សរ៍មកហើយ ចល័តប្រជាជនឲ្យទៅធ្វើស្រែ ខិតខំធ្វើការផលិតស្រូវឲ្យបានច្រើនដូចដែលធ្លាប់ផលិតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និងបង្អត់អាហារប្រជាជនដែលរស់នៅក្នុងប្រទេសមួយដែលពុំធ្លាប់ជួបប្រទះនូវកង្វះអាហារពីមុន ឬសូម្បីតែបរិមាណអាហារក៏មិនដែលខ្វះដែរនោះ ។ ប្រជាជនដែលរងគ្រោះដោយជំងឺ ការអត់អាហារ និងការគំរាមសម្លាប់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនេះ មន្ត្រីកម្ពុជាប្រជាធិបតេយ្យបាននិយាយថា «មានប្រជាជនចំនួនប្រហែលជិតមួយលាននាក់» ដែលនៅរស់នោះមិនអាចបំភ្លេចបានឡើយនូវរបបដ៏ព្រៃផ្សៃនេះ ។ ប្រជាជនដែលរងគ្រោះទាំងនោះ តែងតែពន្យល់រៀបរាប់ដោយខ្លួនឯងផ្ទាល់អំពីភាពគ្មានប្រជាប្រិយភាពនៃរបបមួយដែលឲ្យអាទិភាពទៅលើសមិទ្ធិកសិកម្ម និងដែលពួកគាត់រាប់បញ្ចូលទាំងកសិករ សព្វថ្ងៃព្យាយាមបំភ្លេចរបបនោះចោល ។

## មេរៀនដែលទទួលបានពីបទពិសោធន៍ក្នុងសម័យខ្មែរក្រហម

មេរៀនសំខាន់ៗដែលត្រូវបានសង្ខេបយ៉ាងខ្លីពីបទពិសោធន៍ដ៏សោកសៅនៃកម្ពុជាប្រជាធិបតេយ្យ ជាមេរៀនបន្ថែមសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រពសម័យទំនើបរួមមាន ÷ ១) សារសំខាន់នៃប្លង់និងការប្រើប្រាស់បច្ចេកទេសដ៏សមស្រប ។ ២) តម្រូវការចាំបាច់ក្នុងការស្វែងរកការដឹកនាំមួយថ្មី ដែលប្រកបដោយសមត្ថភាព និងដែលប្រជាជនក្នុងតំបន់ពេញនិយម រួចចាកផុតពីនយោបាយខាងក្រៅនានា ។ ៣) ភាពចាំបាច់ក្នុងការអភិវឌ្ឍន៍ក្នុងតំបន់ ក្នុងការរៀបចំផែនការដាក់ស្តែង និងវិធីដោះស្រាយដែលមានលក្ខណៈទន់ភ្លន់នូវប្រព័ន្ធស្រោចស្រពនិងកសិកម្ម ។ ៤) ការចាត់វិធានការសិក្សាស្វែងយល់ដោយយកចិត្តទុកដាក់ដែលស្របតាមសមត្ថភាពរបស់ប្រជាជននិងលទ្ធភាពនៃប្រព័ន្ធកសិកម្ម ។

**ជេហ្វ្រី ហ៊ីមមែល**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុFM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង ៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុFM១០៣.២៥MHz ខេត្តបាត់ដំបងរៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ស៊ិន សុធីតា និង ឆេង សុធារិន**

# ប្រវត្តិជីវិតកម្សត់របស់ខ្ញុំ

**អារម្ភកថាៈ**

ខ្ញុំចាប់ផ្តើមសរសេរជីវប្រវត្តិពិតនៃជីវិតខ្លួនខ្ញុំផ្ទាល់ គឺគ្រាន់តែចង់ឆ្លុះបញ្ចាំងអំពីជីវិតកម្សត់របស់ខ្ញុំដែលបានឆ្លងកាត់នៅក្នុងរបបវាលពិឃាត ក៏ដូចជាឆ្លុះបញ្ចាំងអំពីជីវិតមនុស្សជងទាំងឡាយដែលបានឆ្លងកាត់របបនោះដែរ ។ អ្នកដែលបានអានរឿងនេះ ប្រាកដជាអាចប្រៀបធៀបរឿងរ៉ាវរបស់ខ្លួនទៅនឹងសាច់រឿងក្នុងសៀវភៅនេះថាតើខុសគ្នាយ៉ាងណា?

ខ្ញុំសូមឧទ្ទិសកុសលជូនមាតាបិតា បងប្អូន ជីដូនជីតាញាតិមិត្ត និងគ្រូបាធ្យាយរបស់ខ្ញុំ ដែលបានបែកកាយរំលាយខន្ធទៅហើយ សូមឲ្យបានរួចនូវទុក្ខទោសទាំងពួងនិងសូមឲ្យបានទៅកើតនៅឋានបរមសុខ ហើយចំពោះញាតិមិត្តបងប្អូនដែលនៅរស់ សូមកុសលទាំងឡាយរបស់ខ្ញុំដឹកនាំឲ្យប្រព្រឹត្តតែអំពើជាកុសលនិងលះបង់នូវអំពើអកុសល ។ ចុងបញ្ចប់ខ្ញុំសូមសច្ចាទៅជាតិមុខ សូមឲ្យមានបញ្ញាទោះផ្លូវលោកក្តីផ្លូវធម៌ក្តី ។

**ប្រវត្តិកុមារភាព**

**(សម័យសង្គមរាស្ត្រនិយម)**

ខ្ញុំកើតនៅឆ្នាំ១៩៥២ ។ តាំងពីថ្ងៃកើតរហូតដល់អាយុជិតបានមួយឆ្នាំ ខ្ញុំចេះតែឈឺមិនឈប់ឈរ ។ មានថ្ងៃមួយ ខ្ញុំស្រាប់តែមានជំងឺធ្ងន់ ឪពុកខ្ញុំបានយកខ្ញុំទៅសម្រាកនៅមន្ទីរពេទ្យព្រះកេតុមាលាអស់រយៈពេលយ៉ាងយូរនៅតែមិនជាសះស្បើយ ។ ពោះរបស់ខ្ញុំចេះតែប៉ោងធំ ហើយមិនបត់ជើងតូច-ធំអ្វីទាំងអស់ ។ ឪពុកខ្ញុំជឿជាក់លើពេទ្យ គាត់ទុកខ្ញុំឲ្យពេទ្យព្យាបាលបន្តទៀត ។ ចំណែកជីដូនខ្ញុំ គាត់ទទូចយកខ្ញុំចេញពីមន្ទីរពេទ្យ ប៉ុន្តែឪពុកខ្ញុំមិនព្រម ។ ដោយមិនអាចអត់ធ្មត់តទៅទៀតបាន ជីដូនខ្ញុំបានបីខ្ញុំចេញពីមន្ទីរពេទ្យ ហើយឡើងជិះស៊ីក្លូសំដៅទៅផ្ទះនៅសង្កាត់លេខ១ ទីក្រុងភ្នំពេញ ។ ធ្វើដំណើរដល់រោងអ្នកតាចិនមួយ គាត់ក៏ដាក់ខ្ញុំឲ្យអ្នកតាព្យាបាល ហើយលោកតាចូលរូបគាត់យកថ្នាំដក់មកបំពោកលើពោះខ្ញុំ ស្រាប់តែមួយសន្ទុះ ខ្ញុំបត់ជើងតូចរួចទាំរញ៉ាំបបរ ។ ខ្ញុំក៏បានជាសះស្បើយតាំងពីនោះមក ឪពុកខ្ញុំក៏លែងមាត់-កអ្វីទាំងអស់ ហើយគាត់ក៏បានយកថ្ងៃដែលខ្ញុំជាសះស្បើយធ្វើជាថ្ងៃកំណើត ។

ខ្ញុំមានបងប្អូនបង្កើត៤នាក់(ស្រី២ប្រុស២) ក្នុងគ្រួសារមធ្យមមួយ ឪពុកខ្ញុំជាជាងកាត់ដេរខោអាវប្រុស ឯម្តាយខ្ញុំជាជាងកាត់ដេរខោអាវស្ត្រី ។ ម្តាយខ្ញុំចេះកាត់ដេរនេះមិនមែនចេះមកពីឪពុកខ្ញុំឡើយ គាត់លួចរៀនដោយខ្លួនឯង គាត់ចេះដេរខោអាវគ្រប់ប្រភេទទាំងអស់ ។ អ្នកភូមិនៅជុំវិញផ្ទះដែលរាប់អានម្តាយខ្ញុំនិងអ្នកលក់ដូរនៅផ្សារគីឡូម៉ែត្រលេខ៦ សុទ្ធតែមកកាត់សម្លៀកបំពាក់នៅផ្ទះម្តាយខ្ញុំ ។ ខ្ញុំនៅចាំច្បាស់ថា កាលពីខ្ញុំអាយុប្រហែល៥ឆ្នាំ រៀងរាល់ពេលរសៀល ម្តាយខ្ញុំតែងតែនាំខ្ញុំទៅផ្សារញ៉ាំនេះញ៉ាំនោះ មិនដែលខានឡើយ ។ ម្តាយខ្ញុំស្រឡាញ់កូនៗណាស់ ។ មានថ្ងៃមួយខ្ញុំឈឺធ្មេញ គាត់ក៏នាំខ្ញុំទៅដកធ្មេញ ។ ម្តាយខ្ញុំបានលួងលោមខ្ញុំថា “កូនកុំយំ ចាំដល់កូនជា ម៉ែ នាំកូនទៅអ៊ុតសក់” ។ ពេលនោះខ្ញុំមានអារម្មណ៍កក់ក្តៅណាស់ ពេលឮពាក្យលួងលោមរបស់ម្តាយខ្ញុំ ពីព្រោះសក់អ៊ុតកាលពីជំនាន់នោះពេញនិយមណាស់ ។

**មរណភាពម្តាយខ្ញុំ**

មានពេលមួយក្នុងឆ្នាំ១៩៥៩ ម្តាយខ្ញុំគាត់ចុកពោះ ហើយខ្ញុំឃើញចាស់ៗអុជធូបបន់ស្រន់ ។ ពីរថ្ងៃក្រោយមកឪពុកខ្ញុំបានយកគាត់ទៅមន្ទីរពេទ្យព្រះកេតុមាលាអស់រយៈពេលយ៉ាងយូរនៅតែព្យាបាលមិនជា ឪពុកខ្ញុំក៏យកគាត់ទៅសម្រាកនៅមន្ទីរពេទ្យកាល់ម៉ែត្រ រយៈពេលប្រហែលកន្លះខែ ម្តាយខ្ញុំក៏បានធូរស្រាលបន្តិច ហើយក៏ត្រឡប់មកសម្រាកនៅផ្ទះវិញ ។ ខ្ញុំឃើញគាត់អាចដើរបាន ពិសាបបរបាន និយាយស្តីធម្មតាហាក់ដូចជាមិនមានអ្វីកើតឡើងចំពោះគាត់ឡើយ ។


ម្តាយរបស់ លឹម ស្រីផល្លា ឆ្នាំ១៩៥៧

មានថ្ងៃមួយ មានមនុស្សឈូឆរ ចុះឡើងក្នុងផ្ទះខ្ញុំ ស្រាប់តែរថយន្តសង្គ្រោះបានបើកមកឈប់នៅមុខផ្ទះរបស់ខ្ញុំ ហើយដឹកម្តាយខ្ញុំទៅមន្ទីរពេទ្យវិញ ។ ម្តាយខ្ញុំនៅសម្រាកពេទ្យអស់រយៈពេលប្រហែល២សប្តាហ៍ ដែលក្នុងរយៈពេលនោះខ្ញុំឃើញជីដូនខ្ញុំយំ និងនិយាយបន់ស្រន់រហូត ។ មិនយូរប៉ុន្មាន រថយន្តសង្គ្រោះបានដឹកម្តាយខ្ញុំត្រឡប់មកផ្ទះវិញ ។ ជីដូនខ្ញុំយំរៀបរាប់សព្វគ្រប់ ប៉ាខ្ញុំក៏យំ ម្តាយមីងខ្ញុំក៏យំ ញាតិមិត្តទាំងអស់សុទ្ធតែយំ ចម្លែកតែបងប្អូនខ្ញុំបួននាក់ហាក់ដូចមិនដឹងអ្វីទាំងអស់ ។ បងប្រុស អាយុប្រាំបីឆ្នាំ ខ្ញុំអាយុប្រាំមួយឆ្នាំ ប្អូនស្រីអាយុប្រាំឆ្នាំ ប្អូនប្រុសពៅអាយុបីឆ្នាំ ។

នៅថ្ងៃធ្វើបុណ្យសព ខ្ញុំស្រាប់តែក្តៅខ្លួន ហើយចាស់ៗបានយកខ្ញុំទៅផ្ទះជីដូនរបស់ខ្ញុំដើម្បីកោសខ្យល់និងញ៉ាំថ្នាំ លុះដល់ល្ងាចទើបម្តាយមីងខ្ញុំនាំខ្ញុំមកផ្ទះវិញ ។ ពេលមកដល់ផ្ទះ ខ្ញុំឃើញ



លីម ស្រីផល្លា ជាមួយ ឪពុក, ប្អូនស្រី និង បងប្រុស ក្នុងឆ្នាំ១៩៥៧

បងប្រុសនិងប្អូនៗរបស់ខ្ញុំកោរសក់ទាំងអស់ ខ្ញុំចម្លែកចិត្តនៅពេលឃើញបងប្អូនខ្ញុំកោសក់យ៉ាងដូច្នោះ ក៏ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍អំពីហេតុផលដែលត្រូវកោរសក់នោះឡើយ ។

នៅថ្ងៃបន្ទាប់ ម្តាយមីងខ្ញុំពុំឲ្យទៅមើលមុខម្តាយខ្ញុំជាលើកចុងក្រោយមុនពេលគេលើកដាក់ក្នុងមឈូស ។ ខ្ញុំឃើញម្តាយខ្ញុំនៅស្ងៀមហាក់ដូចជាមនុស្សកំពុងដេកលក់ ឯម្តាយមីងខ្ញុំយំរៀប



លីម ស្រីផល្លា អាយុ១៦ឆ្នាំ ក្នុងឆ្នាំ១៩៦៨

រាប់ថា «ហេតុអ្វីបានជាបងទៅហើយបិទភ្នែកមិនជិតដូច្នេះ? បងនៅមិនអស់ចិត្តនឹងកូនឬ? បងកុំព្រួយ ពួកខ្ញុំនឹងជួយមើលថែកូនៗជូនបង» ។ ម្តាយមីងខ្ញុំនិយាយមកកាន់ពួកខ្ញុំថា «ពួកឯងលែងបានឃើញមុខម្តាយឯងទៀតហើយ» ។ ថ្ងៃស្អែកឡើង គេហែម្តាយខ្ញុំចេញទៅដោយទុកម្តាយមីងខ្ញុំឲ្យនៅមើលថែខ្ញុំ ។

ខ្ញុំនៅចាំបានថា កាលគាត់នៅរស់ មានញាតិមិត្តជាច្រើនចេញចូលផ្ទះខ្ញុំខ្ចីលុយកាក់គាត់និងបបួលគាត់លេងតុងទីន (តុងទីនពីដើមមានច្បាប់ត្រឹមត្រូវចេញលិខិតអនុញ្ញាតពីសាលាក្រុង) ។ ថ្ងៃមួយ យាយម្នាក់ត្រូវជាប្អូនថ្លៃជីដូនខ្ញុំបានយកលុយមួយកញ្ចប់មកអុជធូបប្រាប់ម្តាយខ្ញុំថា គាត់បានយកលុយមកសងហើយ កុំទៅតាមទារគាត់ទៀត ។ ពេលសែនប្រាប់រួច គាត់ក៏ប្រគល់លុយមួយកញ្ចប់នោះជូនឪពុកខ្ញុំ ហើយប្រាប់ជីដូនខ្ញុំថា ខ្មោចម្តាយខ្ញុំទៅតាមទារលុយពីគាត់ ។

រឿងរ៉ាវទាំងអស់នេះធ្វើឲ្យអារម្មណ៍របស់ខ្ញុំនៅជិតជាប់នឹងម្តាយ ។ ខ្ញុំតែងតែយល់សប្តិឃើញគាត់រៀងរាល់យប់ ។ ខ្ញុំ

មានអារម្មណ៍ថា រូបថតរបស់គាត់ដែលព្យួរនៅលើជញ្ជាំងកំពុងសម្លឹងមើលខ្ញុំគ្រប់សកម្មភាព ។

នៅថ្ងៃបុណ្យអុំទូក ឪពុកខ្ញុំបាននាំកូនៗទៅដើរលេងនៅពេលយប់ នៅខណៈនោះខ្ញុំបានឃើញម្តាយខ្ញុំដើរតាមពីក្រោយពួកខ្ញុំរហូត ។ ខ្ញុំបានប្រាប់ឪពុកខ្ញុំថា "ប៉ាៗ ខ្ញុំឃើញម៉ែឈរពីក្រោយខ្ញុំ" ។ ឪពុកខ្ញុំងាកមើលតាមដៃខ្ញុំចង្អុល ពេលនោះស្រាប់តែបាត់ម្តាយខ្ញុំភ្លាម ។ ក្រោយមកទៀតខ្ញុំបានឃើញម្តាយខ្ញុំដើរតាមទៀត ដូចជាព្រលឹងគាត់តាមខ្ញុំជាប់ ។

ប្រហែលជាខែវិច្ឆិកា បងប្អូន ឪពុកខ្ញុំបាននាំឪពុកខ្ញុំទៅដណ្តឹងប្រពន្ធ ។ រាល់ពេលដែលឪពុកខ្ញុំទៅមើលអនាគតប្រពន្ធគាត់តែងយកខ្ញុំទៅជាមួយ ធ្វើជាទៅវាស់គាត់ខោអាវជាដើម ។ ទីបំផុត គាត់ពេញចិត្តនារីម្នាក់នៅស្រុកស្អាង ខេត្តកណ្តាល ។ ពេលរៀបការ ឪពុកខ្ញុំបានយកបងប្រុសនិងបងជីដូនមួយខ្ញុំទៅចូលរួម ពេលមង្គលការចប់សព្វគ្រប់គាត់ក៏នាំប្រពន្ធមកផ្ទះ ។ ប៉ុន្តែមុនពេលមកដល់ផ្ទះ បងប្អូនឪពុកខ្ញុំបានយកក្រណាត់ក្រហមមករុំរូបថតម្តាយខ្ញុំ ខ្ញុំមិនដឹងថាមូលហេតុអ្វីទេ ប៉ុន្តែខ្ញុំពួចាស់ៗថា ទាល់តែធ្វើដូច្នេះទើបបានសុខ ព្រោះរូបថតអាចមើលឃើញនូវសកម្មភាព ។ ស្រាប់តែពេលនោះមានអ្វីចូលសណ្ឋិតជីដូនខ្ញុំមិនឲ្យប្រពន្ធក្រោយឪពុកខ្ញុំចូលក្នុងផ្ទះទេ ។ ក្រោយមកទៀត ម្តាយខ្ញុំបានមកពន្យល់សប្តិឪពុកខ្ញុំថា ៖ "ធុញទ្រាន់ណាស់ៗ" ព្រឹកឡើងឪពុកខ្ញុំបានទៅកាប់ផ្ការព្រៃវល្លិ៍នៅផ្នូរម្តាយខ្ញុំ (គាត់មិនបានគិតដល់ក្រណាត់ក្រហមរុំរូបថតម្តាយខ្ញុំឡើយ) ។ ចំណែកខ្ញុំតែងតែយល់សប្តិឃើញម្តាយខ្ញុំរាល់យប់មិនដែលខាន ។

ឆ្នាំដែលឪពុកខ្ញុំរៀបការប្រពន្ធ គឺជាឆ្នាំដែលខ្ញុំត្រូវចូលរៀននៅសាលាបឋមសិក្សាឧត្តមទីយ៉ារាម (សាលាប្ញស្សីកែវ) ដែលស្ថិតនៅក្នុងវត្តឧត្តមទីយ៉ារាម អគារផ្ទាល់ដីប្រក់ស័ង្កសី ។ នៅទល់ខ្លោងទ្វារវត្តមានរោងចក្រកៅស៊ូយីតបៅលី និងទៅខាងជើងទៀតមានរោងចក្រធ្វើកែវនៅខាងលិចផ្លូវ ខាងកើតផ្លូវមានរោងចក្រផលិតដែកគោលនិងមន្ទីរឃុំជាក ខាងត្បូងជាកន្លែងសត្តឃាត ។ ឯផ្ទះខ្ញុំនៅជាប់ផ្សារតីឡូម៉ែត្រលេខ៦ នៅពីក្រោយផ្សារមានវត្តលោកសង្ឃយួនមួយ ។

ខ្ញុំនៅចាំបានច្បាស់ថានៅឆ្នាំខ្ញុំរៀនថ្នាក់ទី១២ ជាវដូវរងា នៅពេលទៅសាលារៀនព្រឹកៗ ខ្ញុំឃើញមិត្តភក្តិពាក់អាវរងាគ្រប់គ្នាអត់តែខ្ញុំម្នាក់គត់ ។ ខ្ញុំចង់បានអាវរងាពាក់នឹងគេណាស់ ខ្ញុំដាច់ចិត្តសុំឪពុកខ្ញុំទិញ តែគាត់មិនបានទិញឲ្យទេ ព្រោះគាត់ជាប់រវល់ ណាមួយឪពុកខ្ញុំមិនសូវគិតគូរដល់កូនៗទេ គាត់ទុកភារកិច្ចនេះឲ្យម្តាយចុងខ្ញុំមើលការខុសត្រូវ ។ មានថ្ងៃមួយ ខ្ញុំមិនព្រមទៅរៀន ព្រោះខ្ញុំរងាពេក ។ ខ្ញុំយំយ៉ាងខ្លាំង ទើបពូខ្ញុំដែលតែងតែជូនខ្ញុំទៅសាលារៀនទៅទិញអាវរងាមួយឲ្យខ្ញុំ ។

ជីវិតក្នុងវ័យកុមារ រៀននៅសាលាបឋមសិក្សា ខ្ញុំបានឆ្លងកាត់ការលំបាកសព្វបែបយ៉ាង ពេលទៅរៀនមួយថ្ងៃបានរបបប្រាក់ពីររៀល ព្រឹកមួយរៀល ល្ងាចមួយរៀល និងផ្លែឈើដូចជាក្រូចឬចេកអំបូងដែលម្តាយក្រោយខ្ញុំខ្ចប់ឲ្យ ។ មានពេលខ្លះខ្ញុំលាងចានបែកចានមួយ គាត់កាត់លុយប្រចាំថ្ងៃលុះតែគ្រប់តម្លៃចានទើបគាត់ឲ្យលុយខ្ញុំចាយប្រចាំថ្ងៃវិញ ។ ខ្ញុំគ្មានលុយចាយនឹងគេទេ រាល់ពេលដែលខ្ញុំអត់លុយបងជីដូនមួយខ្ញុំដែលរៀននៅថ្នាក់ក្បែរគ្នាតែងតែឲ្យខ្ញុំហាសិបសេនរាល់ពេល ជួនកាលគាត់មានផ្លែឈើដូចជា ផ្លែគូលែន ផ្លែប៉ោម (បងស្រីគាត់លក់ទឹកកកនៅកំពង់ផែភ្នំពេញ) យកមកឲ្យខ្ញុំញ៉ាំទៀតផង ។ បងប្រុសជីដូនមួយខ្ញុំអាយុបងខ្ញុំបីឆ្នាំ នៅពេលប្រឡងជាប់បាក់ឌុប គាត់ប្រឡងចូលមហាវិទ្យាល័យវេជ្ជសាស្ត្រ គាត់បាត់ខ្លួនក្រោយពេលជម្លៀសចេញពីភ្នំពេញ ។

នៅក្នុងថ្នាក់រៀនអ្នកគ្រូឲ្យខ្ញុំសូត្រមេសូត្រ "កូនអើយអត់ម៉ែ" ខ្ញុំសូត្រមិនចេញឡើយ ហើយពេលវិទ្យុជាតិលេងល្ខោនរឿងកម្សត់ៗខ្ញុំនឹកគួចចិត្តនឹងជីវិតកំព្រារបស់ខ្លួនឯងណាស់ ។ ពិសេសពេលស្តាប់រឿងព្រះវេស្សន្តរ ខ្ញុំកម្សត់ខ្លួនយំរហូតដល់គេងមិនលក់ ។ ក្រោយមក ផ្ទះខ្ញុំត្រូវផ្លាស់មកនៅខាងជើងរោងចក្រធ្វើកែវ ។ នៅពេលរៀនចប់ថ្នាក់បឋមសិក្សា ខ្ញុំបានដាក់ពាក្យប្រឡងចូលរៀនអនុវិទ្យាល័យព្រះនរោត្តម ។ (ជំនាន់នោះសិស្សដែលចង់ចូលរៀននៅអនុវិទ្យាល័យព្រះនរោត្តម ត្រូវតែដាក់ពាក្យប្រឡងចូល ។ អនុវិទ្យាល័យនេះមានសុទ្ធតែសិស្សស្រី ហើយភាគច្រើនជាកូនអ្នកធំឬកូនអ្នកមាន) ។ ខ្ញុំប្រឡងមិនជាប់ទេដោយខ្វះពិន្ទុមួយភាគបួន ។ បងប្រុសខ្ញុំក៏បានទិញពាក្យបង់លុយចូលរៀននៅវិទ្យាល័យចៅពញាយ៉ាតវិញ (បច្ចុប្បន្នមន្ទីរ

ខក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង) ។

ថ្ងៃបើកបវេសនកាល លោក វណ្ណ មូលីវណ្ណ ជារដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិបានអញ្ជើញមកជាអធិបតី ។ ឪពុកខ្ញុំបានយកខ្ញុំទៅផ្ញើផ្ទះបងរបស់គាត់នៅជិតសាលារៀន(ខាងត្បូងផ្សារអូឡាំពិក) ។ ការរស់នៅរបស់ខ្ញុំជាមួយឪពុកមាមានការលំបាកយ៉ាងខ្លាំង ព្រោះខ្វាចចិត្តគាត់ ពេលទំនេរខ្ញុំត្រូវជួយលក់ដូរទៀតផង ដូច្នេះការរៀនសូត្ររបស់ខ្ញុំនិងកូនគាត់ខុសគ្នាស្រឡះ ព្រោះកូនគាត់មានឱកាសបានរៀនច្រើនជាងខ្ញុំ ។ ដោយទ្រាំមិនបាន ខ្ញុំក៏សុំឪពុកមាត្រឡប់មកនៅផ្ទះវិញ ។

## ក្នុងអំឡុងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥

ខ្ញុំរៀនបានចប់ថ្នាក់ទីមួយទំនើបជាតិ ប៉ុន្តែមិនបានប្រឡងមធ្យមសិក្សាប័ត្រភាគមួយទេ(ធ្លាក់អង់) ។ លុះដល់រដូវភ្ជុំក្នុងឆ្នាំ១៩៧២ ខ្មែរក្រហមបានវាយចូលមកភ្នំពេញតាមផ្លូវជាតិលេខ៦អា ដោយដាក់គ្រាប់បែកផ្តាច់ស្ពានជ្រោយចង្វារ ។ ខ្ញុំឃើញខ្មោចទាហានយៀកកុងនិងខ្មែរក្រហមស្លាប់ជាច្រើននាក់នៅគល់ស្ពាន ។ ឆ្នាំ១៩៧៣ ឪពុកខ្ញុំក៏សម្រេចចិត្តឲ្យខ្ញុំឈប់រៀន ដើម្បីជួយលក់ក្រណាត់គាត់នៅផ្សារកណ្តាល ។ ក្រោយមកទៀត គាត់បំបែកតូបមួយឲ្យខ្ញុំលក់នៅផ្សារគីឡូម៉ែត្រលេខ៦វិញ ។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ មានទាហានចេញចូលចុះឡើងជាច្រើន ខ្ញុំត្រូវរងនូវពាក្យពេចន៍លេបខាយជាច្រើនពីសំណាក់ទាហានទាំងនោះ ។ ចំណែកបងប្រុសខ្ញុំបានចូលធ្វើប៉ូលិស ហើយបាននៅឈរជើងនៅវាលយន្តហោះពោធិ៍ចិនតុង ។

ខ្ញុំរៀបការនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៣ ។ ស្វាមីខ្ញុំឈ្មោះ ផល ជានាយឃ្លាំងនៅទេពកោសល្យស៊ីវិលទួលគោក ។ ក្រោយពេលរៀបការខ្ញុំទាំងពីរបានរស់នៅបែកផ្ទះ ដោយរស់នៅក្នុងជីវភាពសាមញ្ញជាអ្នកលក់ក្រណាត់ ស្វាមីខ្ញុំជារដ្ឋការ ។

នៅក្នុងរបបសាធារណរដ្ឋខ្មែរ ទាហានលន់នល់ បានច្បាំងជាមួយខ្មែរក្រហមនិងយៀកកុង ហើយមានទាហានប៉េអឹមចេញចូលជាច្រើន មានទ័ពបាក់រត់ខ្ចាត់ខ្ចាយដើរយករបស់របរអ្នកផ្សារធ្វើឲ្យអ្នកផ្សារក្តៅក្រហាយជេរប្រទេចរាល់ថ្ងៃ ។ សភាពការណ៍ច្របូកច្របល់នេះធ្វើឲ្យប្រជាជនពិបាកក្នុងការរស់នៅណាស់ ប្រាក់បៀវត្សរ៍មិនអាចទប់ទល់នឹងទំនិញដែលចេះតែឡើងថ្លៃមិនឈប់ឈរ ។

ចាប់ពីឆ្នាំ១៩៧៣ គ្រាប់បែកផ្ទុះកាន់តែច្រើនឡើង ។ ជួនកាលផ្ទុះតាមរោងភាពយន្ត មានពេលខ្លះគ្រាប់ផ្លោងធ្លាក់ក្បែរៗផ្ទះខ្ញុំ ពេលខ្លះធ្លាក់ចំផ្សារ ធ្វើឲ្យអ្នកលក់ដូរខកខាន ជីវភាពក៏ធ្លាក់ដុនដាបទៅៗ ។ ខ្ញុំបន់ឲ្យការច្បាំងគ្នានេះឆាប់ចប់ ។

## ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥

នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមដែលបានចូលមកដល់ផ្លូវគីឡូម៉ែត្រលេខ៦ ។ បងប្រុសរបស់ខ្ញុំបានជិះម៉ូតូមកយកខ្ញុំនិងកូនតូចទៅផ្ទះគាត់នៅមុំរោងកុនភ្នំពេញ ។ ប្រហែលម៉ោង៥ល្ងាច ខ្ញុំមើលពីលើផ្ទះឃើញកងទ័ពរំដោះស្លៀកពាក់ខ្មៅស្បែកជើងកង់ឡាន បង់-កក្រមា ព្រមទាំងពាក់មួកកន្ទឹប កាន់កាំភ្លើងដើរព្រោងព្រាតពេញទីក្រុងភ្នំពេញ ។ ប្រជាជនទាំងអស់ត្រេកអរនៅពេលឃើញកងទ័ពខ្មែរក្រហមបោះជំហានចូលក្នុងក្រុងដោយគិតថា សង្គ្រាមរវាងខ្មែរនិងខ្មែរត្រូវបានបញ្ចប់ហើយ ។ មិនបានប៉ុន្មានម៉ោងផង ស្រាប់តែកងទ័ពរំដោះបាញ់កាំភ្លើងក្តុងក្តាំងប្រកាសឲ្យប្រជាពលរដ្ឋទាំងអស់ចេញពីលំនៅដ្ឋាន *«អង្គការឲ្យចេញទៅក្រៅក្រុងតែបីថ្ងៃទេ មិនបាច់យកអ្វីទៅទាំងអស់ ទុកពេលឲ្យអង្គការដេញចក្រពត្តិអាមេរិកចេញឲ្យអស់ពីទឹកដីយើង»* ព្រឹកថ្ងៃ១៧មេសា កងទ័ពខ្មែរក្រហមបានយកសម្តេចព្រះសង្ឃរាជហួត តាត និងលោក ឡុង បូរ៉េត ឲ្យនិយាយ និងមានពុទ្ធដីកាផ្សព្វផ្សាយតាមវិទ្យុថា ៖ *«ទ័ពរំដោះបានរំដោះទឹកដីទាំងស្រុងទទួលបានជ័យជម្នះលើចក្រពត្តិអាមេរិក សូមបងប្អូនកុំបារម្ភ»* ។ គ្រាន់តែនិយាយរួចកងទ័ពខ្មែរក្រហមសម្លាប់ចោលអ្នកទាំងពីរតែម្តង ។ នេះជាអំពើឃាតកម្មមួយយ៉ាងសាហាវបំផុតក្នុងដំណាក់កាលដំបូងដែលកងទ័ពខ្មែរក្រហមបានចាប់ផ្តើមអនុវត្ត ។

ខ្ញុំបីកូនតូចចាកចេញពីមុំរោងភាពយន្តភ្នំពេញជាមួយប្តីបងថ្លៃ ប្អូនស្រីថ្លៃ និងបងប្រុសខ្ញុំ ឆ្ពោះទៅគីឡូម៉ែត្រលេខ៦វិញ ហើយឃើញសាកសពស្លាប់ហូរហែតាមផ្លូវ ពេលនោះខ្ញុំហាក់ដូចជាអស់សង្ឃឹម ស្រាលខ្លួនស្ទើរបោះជំហានទៅមុខពុំរួច ។ ពួកយើងមានការលំបាកក្នុងការធ្វើដំណើរណាស់ ណាមួយខ្ញុំកូនតូចផង ណាបងថ្លៃមានផ្ទៃពោះផង ។ លុះដើរមកដល់រោងចក្រទឹកដោះគោ ខ្ញុំបានឃើញកន្លែងផ្ទុកប្រេងឆេះផ្សែងឡើងខ្មៅងងឹត ។

ពេលនោះពួកយើងបានជួបនឹងបងស្រី យក់ កែម គាត់បបួលយើងឲ្យដើរបន្តទៅទៀត ។ បន្ទាប់មកធ្វើដំណើរតាមកាណូតវិញរហូតដល់រោងចក្រផលិតស្រា (SKD) ហើយសម្រេចសំចតនៅទីនោះមួយយប់ ។ ស្អែកឡើងប្ដីខ្ញុំបានត្រឡប់ទៅផ្ទះយកបានរបស់របរខ្លះៗសម្រាប់កូនតូច មានបំពង់ទឹកក្ដៅនិងទឹកដោះគោ ។ ពេលនោះគាត់ក៏បានជួបឪពុកនិងប្អូនស្រីខ្ញុំនិងគ្រួសារខាងប្អូនថ្លៃទៀត យើងទាំងអស់គ្នាក៏បបួលគ្នាឡើយកាណូតបន្តដំណើរទៅមុខទៀត ។ ចំណែកអីវ៉ាន់ខ្ញុំត្រូវបានពូខាងម្ដាយខ្ញុំយកទៅទាំងអស់រួមទាំងជីដូនខ្ញុំផង ។ ខ្ញុំត្រូវបែកពីជីដូន និងបងប្រុស ក្រៅពីនោះពួកយើងជុំគ្នាធ្វើដំណើរចេញទៅតាមកាណូតរហូតដល់កំពង់ចម្លងព្រែកក្ដាម ហើយបានឆ្លងទៅត្រើយខាងកើត ។ អ្នកកាណូតក៏ប្រាប់ឲ្យពួកយើងឡើងទៅលើគោករួចធ្វើដំណើរដោយថ្មើរជើងបន្តទៀត ក្រោមការដេញរបស់ពួកកងទ័ពរំដោះ ។


លឹម ស្រីជល្លា អាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧០

កងទ័ពខ្មែរក្រហមចេះតែដេញឲ្យយើងបន្តដំណើរទៅមុខរហូតមិនឲ្យយើងស្នាក់នៅមួយកន្លែងឡើយ ពួកយើងបន្តដំណើរទៅមុខដល់ស្រុកមុខកំពូល ដែលមានទីស្នាក់ការកងទ័ពខ្មែររំដោះ ។ កងទ័ពខ្មែរក្រហមបានប្រមូលអ្នកធ្វើការឲ្យចុះឈ្មោះ ដោយសន្យាថានឹងយកអ្នកទាំងនោះត្រឡប់ទៅធ្វើការតាមជំនាញវិញ ប៉ុន្តែមុននឹងទៅធ្វើការត្រូវទៅរៀនសូត្រសិន ។ ពេលនោះស្វាមីខ្ញុំបានជួបអនុប្រធានរបស់គាត់ ហើយអនុប្រធានរបស់គាត់បានបបួលគាត់ឲ្យទៅចុះឈ្មោះ ។ ស្វាមីខ្ញុំបម្រុងនឹងទៅចុះឈ្មោះនឹងគេ ប៉ុន្តែឪពុកខ្ញុំឃើញទាន់ក៏យកកាតមកវិញ ហើយប្រាប់ថា «យើងកុំទាន់ទុកចិត្តពួកគេនោះពេក យើងមិនដឹងជាគេគិតយ៉ាងណាទេ យើងត្រូវលាក់សិន» ។

ពួកយើងក៏បន្តដំណើរទៅមុខទៀត ពេលនោះប្អូនស្រីខ្ញុំនិងគ្រួសារខាងប្ដីបានបែកចេញពីពួកយើង ហើយធ្វើដំណើរតាមផ្លូវរកាកោងទៅព្រែកតាគង់ ។ ចំណែកខ្ញុំនិងស្វាមីបន្តដំណើរទៅដល់ភូមិជាលា ។ ឆ្លៀតពេលនោះឪពុកខ្ញុំក៏ដើរស៊ើបរកស្រូវអង្ករដើម្បីទុកដាំបាយ អ្នកស្រុកបានប្រាប់គាត់ថា កុំទៅមុខទៀតអីគួរតែចូលតាមភូមិស្រុកសិនទៅ ។ ខ្ញុំនិងឪពុកបានពិភាក្សាគ្នាហើយសម្រេចចិត្តជួលរទេះគោអ្នកស្រុកមកដឹកអីវ៉ាន់និងមនុស្សចាស់ៗមានម្ដាយក្មេករបស់ឪពុកខ្ញុំ (ម្ដាយរបស់ប្រពន្ធក្រោយគាត់) ព្រមទាំងកូនខ្ញុំ ចូលភូមិបែកពាង ។

ពេលចេញដំណើរមេឃចាប់ផ្ដើមងងឹត បន្តិចក្រោយមក ក៏មានភ្លៀងធ្លាក់យ៉ាងខ្លាំង ។ កូនស្រីខ្ញុំជិះរទេះជាមួយម្ដាយក្មេកខ្ញុំទៅមុន ។ នៅពេលត្រូវទឹកភ្លៀងច្រើនពេក វារងារហូតសន្លប់លែងមាត់-ក ។ ចំណែកខ្ញុំនិងប្ដីរងារពេកក៏នាំគ្នាចូលជ្រកក្នុងពាងរបស់អ្នកស្រុកដែលបានរត់ចោលផ្ទះសម្បែង ។ ក្រោយពីភ្លៀងរាំងពួកខ្ញុំដើរបន្តទៅមុខទៀតក៏បានជួបឪពុក ហើយគាត់ប្រាប់ថា កូនរបស់ខ្ញុំប្រហែលស្លាប់ហើយ ព្រោះរងារពេក ។ គ្រាន់តែឮដូច្នេះ ខ្ញុំអស់ព្រលឹងពីខ្លួន ខ្ញុំបង្កាត់ភ្លើងកម្ដៅវាឲ្យក្ដៅ ។ ក្រោយមកកូនខ្ញុំដឹងខ្លួនឡើងវិញ ។

ពួកយើងធ្វើដំណើរផងរង់ចាំដំណឹងពីបងប្រុសខ្ញុំផង ។ នៅតាមផ្លូវខ្ញុំឃើញសោកនាដកម្មយ៉ាងខ្លោចផ្សាដែលយើងមិនធ្លាប់បានជួបប្រទះពីមុនមក ។ សាកសពមនុស្សជាច្រើនស្លាប់នៅតាមផ្លូវ និងមនុស្សឈឺដែលត្រូវបានបណ្ដេញចេញពីមន្ទីរពេទ្យ អ្នកខ្លះទើបវះកាត់រួច អ្នកខ្លះទើបឆ្លងទន្លេ អ្នកខ្លះឈឺពោះឆ្លងទន្លេនៅតាមផ្លូវ ហើយត្រូវពួកអាវខ្មៅបណ្ដេញឲ្យដើរទៅទៀតទាំងមិនទាន់រឹងដៃរឹងជើងនិងគ្មានថ្នាំសង្កូវអ្វីទាំងអស់ ។ ឃើញទិដ្ឋភាព

ទាំងអស់នេះ ខ្ញុំតក់ស្លុតយ៉ាងខ្លាំង ។

ពួកយើងចេះតែធ្វើដំណើរមួយថ្ងៃបន្តិចៗក៏ទៅដល់ផ្សារផ្អាវ ហើយសំណាក់នៅទីនោះអស់រយៈពេលជិតកន្លះខែ ។ ពួកខ្ញុំនៅតែមិនបានដំណឹងអ្វីបន្តិចពីបងប្រុស ។ ឪពុកខ្ញុំក៏ចូលទៅក្នុងភូមិមួយនៅខាងក្រោយផ្សារផ្អាវ ដើម្បីដូរអង្ករពីអ្នកភូមិ ។ អ្នកមូលដ្ឋានបានខ្សឹបប្រាប់ខ្ញុំថា “កុំទៅមុខទៀត អង្គការមិនឲ្យត្រឡប់ទៅភ្នំពេញវិញទេ ។ រដូវភ្លៀងមកដល់ហើយត្រូវប្រញាប់ចូលទៅតាមក្រុមសាមគ្គីនឹងគេទៅ ហើយចុះបង្កបង្កើនផលទើបបានរបបស្រូវអង្ករហូប” ។ ក្នុងចំណោមអ្នកភូមិនោះមានតាម្នាក់ជាអ្នកមូលដ្ឋាន បានខ្សឹបប្រាប់ស្វាមីខ្ញុំថា “អឺអាណិតឯង សូមឯងកុំប្រាប់គេថា ធ្វើការឲ្យសោះប្រយ័ត្នគេយកទៅរៀនសូត្រតែទៅហើយមិនបានត្រឡប់មកជួបមុខប្រពន្ធកូនទេ ត្រូវភរគេថាជាអ្នកលក់ដូរ” ។ ឪពុកខ្ញុំសម្រេចចិត្តចូលស្នាក់អាស្រ័យនៅក្នុងឃុំមេព្រីងនោះតែម្តង ។

ភូមិមេព្រីងស្ថិតនៅឆ្ងាយពីទីប្រជុំជនផ្អាវប្រហែលពាគីឡូ-ម៉ែត្រ ។ ខ្មែរក្រហមឲ្យពួកយើងទៅស្នាក់នៅវត្តសិនដើម្បីរង់ចាំអង្គការរៀបចំក្រុមសាមគ្គី ។ ឪពុកនិងម្តាយទីពីរខ្ញុំស្នាក់នៅក្នុងរោងមួយ ចំណែកខ្ញុំស្នាក់នៅក្រោមទូក-ងរបស់វត្ត ដែលតម្កល់ទុកនៅក្រោមដើមឈើធំៗនិងមានម្ចប់ត្រជាក់ ។ ពួកយើងស្នាក់នៅក្នុងវត្តអស់រយៈពេលយ៉ាងយូរទើបអង្គការចុះឈ្មោះពួកយើងបញ្ចូលក្នុងក្រុម ។ ឈ្មោះខ្ញុំនិងស្វាមីត្រូវបានចាត់តាំងឲ្យទៅរស់នៅភូមិវាល ឪពុកខ្ញុំត្រូវនៅក្រុមផ្សេងពីខ្ញុំ ប្អូនថ្លៃខ្ញុំនៅភូមិតាំងច្រើងផ្សេងពីពួកខ្ញុំដែរ ។

ពេលនោះកូនស្រីខ្ញុំចាប់ផ្តើមក្តៅខ្លួននិងរាកយ៉ាងខ្លាំង ខ្ញុំដាក់ថ្នាំអ្វីក៏មិនត្រូវដែរ ។ អ្នកមូលដ្ឋានបានប្រាប់ខ្ញុំឲ្យយកជន្ទេនដាក់ក្នុងផ្ទែននោង រួចដុតពូតយកទឹកឲ្យកូនញ៉ាំ ខ្ញុំធ្វើហើយក៏កូនខ្ញុំនៅតែមិនបានធូរស្រាលទៀត ។ ពេទ្យយោធាខ្មែរក្រហមបានឲ្យថ្នាំពេទ្យដឹក ក៏នៅតែមិនបាត់ ។ អ្នកភូមិផ្សេងទៀតប្រាប់ឲ្យខ្ញុំលីងអង្ករដាំទឹកឲ្យផឹក ។ ក៏ប៉ុន្តែនៅតែមិនធូរស្រាល កូនខ្ញុំរាករហូតដល់ភ្នែកឡើងរូង ខ្ញុំបានសុំសំបុត្រពីប្រធានក្រុមដើម្បីយកកូនទៅមន្ទីរពេទ្យនៅស្គន់ ។ ពេលទៅដល់ពេទ្យស្គន់ ខ្ញុំឃើញអ្នកជំងឺជាច្រើន ខ្លះដេកស្លាប់នៅទីនោះ ។ ខ្ញុំរឹតតែតក់ស្លុតមិនហ៊ានឲ្យកូននៅសម្រាកព្យាបាលទេ ខ្ញុំក៏សុំថ្នាំយកមកទុកឲ្យកូនហូប ហើយត្រឡប់មកមូលដ្ឋានវិញ ។ ពេទ្យបានប្រាប់ខ្ញុំថា កូនខ្ញុំឈឺខ្លាំងហើយមើលមិនជាទេ ។

ជីវភាពរស់នៅជាមួយអ្នកភូមិមូលដ្ឋានមានការលំបាកណាស់ ខ្ញុំ កូន និងប្តី ត្រូវរស់នៅក្រោមផ្ទះរបស់អ្នកភូមិ ជួនពេលខ្លះពួកខ្ញុំត្រូវកូនម្ចាស់ផ្ទះជុះអាចម៍ដាក់លើក្បាលក៏មាន ។ ពួកខ្ញុំត្រូវរស់នៅជាមួយសត្វគោដែលចិញ្ចឹមនៅក្រោមផ្ទះនោះដែរ ។ ស្វាមីខ្ញុំទៅធ្វើការជាមួយក្រុមសាមគ្គីរាល់ថ្ងៃ ។ ដំបូងអង្គការចាត់តាំងឲ្យគាត់ភ្ជួររាស់ដីស្រែ បររទេះ តែគាត់មិនសូវចំណាប់ខាងការងារនេះទេ ។ ឃើញដូច្នោះ ប្រធានគាត់អនុគ្រោះឲ្យគាត់មកជញ្ជូនកណ្តាប់ និងច្រឹបស្មៅភ្លឺស្រែវិញ ។

ទ្រឹស្តីរបស់ខ្មែរក្រហម “អ្នកណាធ្វើអ្នកនោះហូប” ។ អ្នកដែលគេចវេះពីការងារ ឬធ្វើពុតជាឈឺមិនបានហូបទេ ។ ពេលកំពុងបង្កបង្កើនផល អង្គការមិនទាន់ចែកស្រូវឲ្យទេ យើងត្រូវដោះស្រាយខ្លួនឯង ។ ក៏ដូចជាប្រជាជនថ្មីដទៃទៀតដែរ ខ្ញុំបានយកសារុងឬខោអាវដែលខ្ញុំបានយកមកពីភ្នំពេញទៅលួចដូរស្រូវដើម្បីទុកញ៉ាំទម្រាំដល់ពេលប្រូត ។

ប្អូនប្រុសខ្ញុំបានជិះកង់ចេញពីភូមិទៅរកប្អូនស្រីខ្ញុំនៅម្តុំភូមិព្រែកតាគង់(ព្រែកលាប) ហើយក៏បាត់ដំណឹងសូន្យ ។ ខ្ញុំតែងសើបសួរអំពីដំណឹងប្អូនប្រុសពីអ្នកមូលដ្ឋានជារៀងរាល់ថ្ងៃ ព្រោះប្អូនប្រុសខ្ញុំចាកចេញពីភូមិដោយមិនមានសំបុត្រអនុញ្ញាត ។ អ្នកមូលដ្ឋានបានប្រាប់ខ្ញុំថាការធ្វើដំណើរឆ្លងពីកន្លែងមួយទៅកន្លែងមួយដោយគ្មានការអនុញ្ញាតយ៉ាងនេះអាចត្រូវអង្គការចោទថាខ្មាំងនិងប្រាកដជាស្លាប់ហើយ ។ នៅពេលឮសម្តីនេះ ទុក្ខព្រួយរបស់ខ្ញុំហាក់ដូចជាត្រួតកាន់តែធ្ងន់ឡើងៗ ។

មួយរយៈក្រោយមក ការព្រួយបារម្ភពីសុវត្ថិភាពប្អូនប្រុសខ្ញុំត្រូវស្ងប់ស្ងាត់ទៅវិញ ។ ប្អូនថ្លៃខ្ញុំនិងម្តាយក្មេកខ្ញុំ បានចុះឈ្មោះជាមួយអង្គការដើម្បីវិលត្រឡប់ទៅភ្នំពេញវិញ ដោយសង្ឃឹមថានឹងបានទៅរស់នៅសុខស្រួល ហើយពួកគាត់ក៏រៀបចំខ្លួនចេញដំណើរនៅពេលនោះដែរ ។

***(នៅមានត)***

**លឹម ស្រីផល្លា**

## ដំណឹងស្វែងរកកូនប្រុសឈ្មោះ ស ហៃ

នាងខ្ញុំឈ្មោះ កោះ ចាន់ អាយុ៧១ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ សូមស្វែងរកកូនប្រុសឈ្មោះ ស ហៃ ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៨ ដោយសារអង្គការចាត់តាំងឲ្យទៅសមរភូមិ ។ ពេលនោះ ហៃ មានអាយុ១៥ឆ្នាំ ។ បើបងប្អូនប្រិយមិត្តបានស្គាល់ឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ។ សូមអរគុណ ។

## ដំណឹងស្វែងរកកូនប្រុសឈ្មោះ ហ៊ី អុល

នាងខ្ញុំឈ្មោះ ពេជ យ៉ាន់ អាយុ៦៦ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ខ្ញុំមានកូន៥នាក់ ។ ខ្ញុំសូមស្វែរកូនប្រុសឈ្មោះ ហ៊ី អុល ដែលបានបាត់ខ្លួនពេលចេញទៅ តាមទ័ពខ្មែរក្រហមមុនឆ្នាំ១៩៧៥ ។ កាលនោះ អុល មានអាយុ ១៦ឆ្នាំ ហើយបានទៅតាមទ័ពខ្មែរក្រហមនៅវត្តគុកក្នុងឃុំជ្រលងជាមួយមិត្ត ឡុន (បាត់ខ្លួន) ។ ក្រោយមកមិនដែលឮដំណឹងអ្វីទាំងអស់ ។ បើបងប្អូនប្រិយមិត្តបានស្គាល់ឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ។ សូមអរគុណ ។

## ដំណឹងស្វែងរកកូនប្រុសពីរនាក់

នាងខ្ញុំឈ្មោះ ស អ៊ុច អាយុ៧៣ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានកូន៩នាក់ សូមស្វែរក កូនប្រុសពីរនាក់ដែលបានបាត់ខ្លួននៅក្នុងបដិវត្តន៍ខ្មែរក្រហម ។

១) ជួន ចេន ភេទប្រុស ចូលបដិវត្តន៍មុនឆ្នាំ១៩៧៥ ។ ក្រោយថ្ងៃរំដោះ ចេន ធ្លាប់មកផ្ទះម្តង ហើយបានជួបម្តាយតែមួយភ្លែតក៏ប្រញាប់ចាកចេញទៅវិញ ។ តាំងពីពេលនោះមក ចេន មិនដែល ត្រឡប់មកផ្ទះវិញទេ ។ ២) ជួន សៀ ភេទប្រុស ចូលធ្វើបដិវត្តន៍ក្រោយ ចេន ប៉ុន្តែ សៀ មិនដែលបានមកលេងផ្ទះម្តងទេ ហើយក៏បាត់ខ្លួនរហូតតាំងពីពេលនោះមក ។ បើបងប្អូនប្រិយមិត្តបានស្គាល់ឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ។ សូមអរគុណ ។

## ដំណឹងស្វែងរកបងស្រី និងបងប្រុស

នាងខ្ញុំឈ្មោះ ឈុន រុំ អាយុ៥៣ឆ្នាំ រស់នៅភូមិមមាញ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានបងប្អូន៥នាក់ ។ ឪពុកឈ្មោះ ឈុន ផម និងម្តាយឈ្មោះ ឃុន រឿន ។ នាងខ្ញុំសូមស្វែរក ៖ ១) បងស្រី ឈុន រ៉ន និងប្តី (ជាប្អូនបង្កើតរបស់អ្នកចម្រៀងឈ្មោះ មាស សាម៉ន) ជាអតីតទាហានម៉ារីនមុនឆ្នាំ១៩៧៥ អ្នកទាំងពីររស់នៅទីក្រុងភ្នំពេញ ហើយបាត់ដំណឹងតាំងពីពេលអង្គការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ២) បងប្រុស ឈុន រៀន ដែលបានចេញទៅបម្រើកងទ័ពរំដោះនៅឆ្នាំ១៩៧២ ហើយក៏បាត់ដំណឹងរហូត ។ មុនឡើងរថយន្តចាកចេញពីភូមិជាមួយយុទ្ធជនដទៃទៀត រៀន បានផ្ញើសំបុត្រមួយច្បាប់ប្រាប់ក្រុមគ្រួសារថាខ្លួនចាកចេញពីភូមិហើយ ហើយឲ្យក្រុមគ្រួសារទៅយកកង់របស់ខ្លួនពីកន្លែងហ៊ឹកហាត់នៅជិតមន្ទីរឃុំ ។

ដូច្នេះបើបងប្រុសនិងបងស្រីបានឮឬបានអានសេចក្តីប្រកាសនេះសូមរកប្អូនតាមអាសយដ្ឋានខាងលើកុំខាន ។ សូមអរគុណ ។

## ដំណឹងស្វែងរកកូនប្រុសម្នាក់ និងក្មួយប្រុសពីរនាក់

ក្រូច កាន ភេទស្រី អាយុ៦៣ឆ្នាំ រស់នៅភូមិត្រពាំងឈូក ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ សូមស្វែរកកូនប្រុសឈ្មោះ នេត ចៀន និងក្មួយប្រុសឈ្មោះ សៃ អន និងឈ្មោះ ជា លន់ ។ អ្នកទាំងបីបានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៦ នៅពេលដែលប្រធានកងចល័តឃុំ ជ្រើសរើសឲ្យទៅសមរភូមិមុខ ។ បើបងប្អូនប្រិយមិត្តបានស្គាល់ឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ។ សូមអរគុណ ។



លឹម ស្រីផល្លា ជាមួយ ឪពុក ប្អូនស្រី និង បងប្រុស ក្នុងឆ្នាំ១៩៥៧

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 87, March 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.